# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងអប់រំ យុវជន និងកីឡា

# សៀវភៅសិក្សា

# ការអប់រំភាពជាពលរដ្ឋសកល

# GLOBAL CITIZENSHIP EDUCATION (GCED)

មជ្ឈមណ្ឌលសហប្រតិបត្តិការការអប់រំភាពជាពលរដ្ឋសកល

GCC-CAMBODIA 2023

# មាតិកា

**មេរៀនទី១៖ ប្រព័ន្ធ និងរចនាសម្ព័ន្ធនៅថ្នាក់មូលដ្ឋាន ជាតិ និងសកល**

LOCAL, NATIONAL AND GLOBAL SYSTEMS AND STRUCTURES
(MR. THAI HENG, DR. MAM CHANSEAN, MR. CHAN BUNTHAN, AND MR. LOCH CHANTHAN)

**មេរៀនទី២៖ បញ្ហាដែលប៉ះពាល់ទៅដល់អន្តរកម្ម និងទំនាក់ទំនងរបស់សហគមន៍នៅក្នុងកម្រិតមូលដ្ឋាន ជាតិ និងសកល**

ISSUES AFFECTING INTERACTION AND CONNECTEDNESS OF COMMUNITIES AT LOCAL, NATIONAL AND GLOBAL LEVELS
(MR. THAI HENG, DR. MAM CHANSEAN, MR. CHAN BUNTHAN, AND MR. LOCH CHANTHAN)

**មេរៀនទី៣៖ ប្រព័ន្ធអំណាចនៃការគ្រប់គ្រងរដ្ឋ**

UNDERLYING ASSUMPTIONS AND POWER DYNAMICS
(MR. THAI HENG, DR. MAM CHANSEAN, MR. CHAN BUNTHAN, AND MR. LOCH CHANTHAN)

**មេរៀនទី៤៖ កម្រិតផ្សេងៗគ្នានៃអត្តសញ្ញាណកម្មបុគ្គល**

DIFFERENT LEVELS OF IDENTITY
(MR. DY BONNA, MS. NOU CHANNY, MR. MAO SAROEUN, AND MR. MON MUNINT)

**មេរៀនទី៥៖ សហគមន៍មនុស្ស និងទំនាក់ទំនងរវាងសហគមន៍ទាំងនោះ**

DIFFERENT COMMUNITIES PEOPLE BELONG TO AND HOW THESE ARE CONNECTED
(MR. DY BONNA, MS. NOU CHANNY, MR. MAO SAROEUN, AND MR. MON MUNINT)

**មេរៀនទី៦៖ ការគោរពចំពោះភាពចម្រុះ និងភាពខុសគ្នា**

DIFFERENCE AND RESPECT FOR DIVERSITY
(DR. NEAU VIRA, MR. PO BUNTHAN, DR. UM CHAN CHAMNAN, AND MR. CHAN RADA)

**មេរៀនទី៧៖ សកម្មភាពដែលអាចធ្វើដោយបុគ្គល និងសមូហភាព**

ACTIONS THAT CAN BE TAKEN INDIVIDUALLY AND COLLECTIVELY
(DR. NEAU VIRA, MR. PO BUNTHAN, DR. UM CHAN CHAMNAN, AND MR. CHAN RADA)

**មេរៀនទី៨៖ ឥរិយាបថទទួលខុសត្រូវប្រកបដោយសីលធម៌**

ETHICAL RESPONSIBLE BEHAVIOUR
(Ms. Bun Sophanny, Mr. Prak Peau, and Dr. Moeun Linna)

**មេរៀនទី៩៖ ការចូលរួមសកម្មភាពនានារបស់សង្គម**

GETTING ENGAGED AND TAKING ACTION
(Ms. Bun Sophanny, Mr. Prak Peau, and Dr. Moeun Linna)

## គណៈកម្មការបច្ចេកទេស

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិតសភាចារ្យ | **ណាត ប៊ុនរឿន** | រដ្ឋលេខាធិការ |
| ២. ឯកឧត្តម | **ពុត សាមិត្ត** | អនុរដ្ឋលេខាធិការ |
| ៣. ឯកឧត្តមបណ្ឌិត | **សៀង សុវណ្ណា** | នាយកវិទ្យាស្ថានជាតិអប់រំ |
| ៤. ឯកឧត្តម | **លឹម សុធា** | អគ្គ.នៃអគ្គ.គោល. និងផែនការ |
| ៥. ឯកឧត្តមបណ្ឌិត | **ហួ ឈុនគ្រី** | អគ្គាធិការរងនៃអគ្គាធិការដ្ឋាន |
| ៦. លោក | **ឌី បុណ្ណា** | នាយករងវិទ្យាស្ថានជាតិអប់រំ |
| ៧. លោក | **ថៃ ហេង** | នាយករងវិទ្យាស្ថានជាតិអប់រំ |
| ៨. ឯកឧត្តមបណ្ឌិត | **ស៊ន សេងហុក** | ប្រធាននាយកដ្ឋាននីតិកម្ម |
| ៩. លោក | **ស៊ុន ប៊ុណ្ណា** | ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |

## គណៈកម្មការនិពន្ធ

| | | |
|---|---|---|
| ១. លោកបណ្ឌិត | **នួវ វីរ៉ា** | នាយករងវិទ្យាស្ថានជាតិអប់រំ |
| ២. លោក | **ឌី បុណ្ណា** | នាយករងវិទ្យាស្ថានជាតិអប់រំ |
| ៣. លោកស្រី | **ប៊ុន សុផានី** | នាយិការងវិទ្យាស្ថានជាតិអប់រំ |
| ៤. លោក | **ថៃ ហេង** | នាយករងវិទ្យាស្ថានជាតិអប់រំ |
| ៥. លោកបណ្ឌិត | **ម៉ម ចាន់សៀន** | អនុប្រធានដេប៉ាតឺម៉ង់នៃវជអ |
| ៦. លោក | **ចាន់ ប៊ុនថន** | ប្រធានលេខាធិការដ្ឋាននៃអគ.អរ |
| ៧. លោក | **ម៉ៅ សារឿន** | ប្រធានដេប៉ាតឺម៉ង់នៃវជអ |
| ៨. លោក | **ម៉ន មុនិន្ទ** | ប្រធានដេប៉ាតឺម៉ង់នៃវជអ |
| ៩. លោក | **ប៉ូ ប៊ុន្លន** | អនុប្រធានការិយាល័យនៃវជអ |
| ១០. លោកស្រី | **នូ ចន្នី** | គ្រូឧទ្ទេសនៃវជអ |
| ១១. លោក | **ឡុច ចាន់ថន** | គ្រូឧទ្ទេសនៃវជអ |
| ១២. លោក | **ប្រាក់ ពៅ** | គ្រូឧទ្ទេសនៃវជអ |
| ១៣. លោក | **ចាន់ វ៉ាដា** | មន្ត្រីការិយាល័យគណនេយ្យនៃវជអ |
| ១៤. លោកបណ្ឌិត | **អ៊ុំ ចាន់ចំណាន** | គ្រូឧទ្ទេសនៃវជអ |
| ១៥. លោកបណ្ឌិត | **មឿន លិនណា** | គ្រូឧទ្ទេសនៃវជអ |

# អារម្ភកថា

ពលរដ្ឋសកល គឺជាពលរដ្ឋដែលជាសមាជិកនៃសកលលោកទាំងមូលដោយមិនមានការរើសអើង និងជាពលរដ្ឋដែលប្រកាន់ខ្ជាប់នូវការចែករំលែកវប្បធម៌ ការទទួលស្គាល់ និងការឱ្យតម្លៃវប្បធម៌ចម្រុះនៃជាតិសាសន៍ដទៃ ព្រមទាំងមានការទទួលខុសត្រូវ ខ្វាយខ្វល់ទៅលើបញ្ហានយោបាយ បញ្ហាសេដ្ឋកិច្ច បញ្ហាបរិស្ថាន និងបញ្ហាសង្គម។

ការអប់រំអំពីភាពជាពលរដ្ឋសកល ជួយឱ្យអ្នកសិក្សាយល់ច្បាស់ពីការវែកញែកអំពីអំណាចដែលនៅពីក្រោយបញ្ហាទាំងក្នុង និងក្រៅប្រទេស ហើយលើកទឹកចិត្តឱ្យអ្នកសិក្សាចូលរួមស្វែងរកឫសគល់នៃបញ្ហាទាំងនោះ ដើម្បីឈានទៅរកការអភិវឌ្ឍជាវិជ្ជមាននៅក្នុងសង្គម។ ការអប់រំអំពីភាពជាពលរដ្ឋសកល មានគោលបំណងជំរុញអ្នកសិក្សាឱ្យក្លាយជាភ្នាក់ងារនៃការអភិវឌ្ឍសង្គម ដោយការលើកកម្ពស់ចំណេះដឹង ជំនាញ និងបទពិសោធ ព្រមទាំងការផ្លាស់ប្តូរជាវិជ្ជមាននូវអាកប្បកិរិយា ឬទម្លាប់មិនល្អ។

សៀវភៅនេះ នឹងផ្តល់ដល់អ្នកសិក្សានូវចំណេះដឹង និងការត្រិះរិះពិចារណាអំពីបញ្ហាសកល បញ្ហាតំបន់ បញ្ហាថ្នាក់ជាតិ និងមូលដ្ឋាន ព្រមទាំងទំនាក់ទំនង និងការពឹងពាក់គ្នាទៅវិញទៅមករវាងប្រទេសជាតិ និងប្រជាជន។ សៀវភៅនេះក៏នឹងជំរុញផងដែរនូវការចែករំលែកតម្លៃ ទំនួលខុសត្រូវ ការយល់ចិត្ត សាមគ្គីភាព និងការគោរពចំពោះភាពខុសគ្នា និងភាពចម្រុះ។ រីឯអាកប្បកិរិយាវិញ អ្នកសិក្សានឹងមានសកម្មភាពយ៉ាងសកម្ម មានទំនួលខុសត្រូវប្រកបដោយសីលធម៌ ទាំងនៅកម្រិតមូលដ្ឋាន កម្រិតថ្នាក់ជាតិ និងអន្តរជាតិ ដើម្បីឱ្យពិភពលោកកាន់តែមានសន្តិភាព និងនិរន្តរភាព។

គណៈកម្មការនិពន្ធសង្ឃឹមយ៉ាងមុតមាំថា សៀវភៅនេះនឹងក្លាយជាឯកសារមួយមានប្រយោជន៍សម្រាប់អ្នកសិក្សាក្នុងការលើកកម្ពស់ភាពជាពលរដ្ឋមានគុណភាព ដោយផ្តោតលើចំណេះដឹង ជំនាញ និងបំណិនជីវិត ក៏ដូចជាការគោរពច្បាប់ និងសណ្តាប់ធ្នាប់សហគមន៍ ការអភិវឌ្ឍប្រកបដោយចីរភាព និងការចូលរួមក្នុងសកម្មភាពនយោបាយ ព្រមទាំងការយល់ដឹងពីស្ថានភាពសកលលោក ការគោរពជាតិសាសន៍ និងតម្លៃមនុស្ស និងការធ្វើឱ្យពិភពលោកក្លាយជាកន្លែងល្អប្រសើរ និងមានការទទួលខុសត្រូវខ្ពស់។

**គណៈកម្មការនិពន្ធ**

# មេរៀនទី១៖
# ប្រព័ន្ធ និងរចនាសម្ព័ន្ធនៅថ្នាក់មូលដ្ឋាន ជាតិ និងសកល

**LOCAL, NATIONAL AND GLOBAL SYSTEMS AND STRUCTURES**

( Mr. Thai Heng, Dr. Mam Chansean, Mr. Chan Bunthan, and Mr. Loch Chanthan )

## ផ្នែកទី១៖ ស្ថាប័នតុលាការនៃព្រះរាជាណាចក្រកម្ពុជា

ផ្នែកទី១ រៀបរាប់ពីស្ថាប័នតុលាការនៃព្រះរាជាណាចក្រកម្ពុជា ដោយក្នុងនោះបានផ្តោតសំខាន់លើស្ថាប័នតុលាការ រចនាសម្ព័ន្ធសាលាជម្រះក្តី ការតែតាំងមន្ត្រីតុលាការ លក្ខណៈទូទៅនៃការប្តឹងផ្តល់ដែលតែងតែកើតមាននៅក្នុងប្រទេសកម្ពុជា។

**ក. ទស្សនៈនៃមេរៀន៖** ក្រោយពីបញ្ចប់ការសិក្សាមេរៀននេះ អ្នកសិក្សានឹង៖

| | |
|---|---|
| **វិជ្ជាសម្បទា/ពុទ្ធិ៖** | - យល់ដឹងអំពីរបៀបរៀបប្រើប្រាស់ ស្ថាប័នតុលាការ រចនាសម្ព័ន្ធសាលាជម្រះក្តី ការតែតាំងមន្ត្រីតុលាការ និងលក្ខណៈទូទៅនៃការប្តឹងផ្តល់ ដែលកើតមាន។ |
| **បំណិនសម្បទា/ចិត្ត-សង្គម៖** | - ប្រើប្រាស់ និងឱ្យតម្លៃលើ ស្ថាប័នតុលាការ សាលាជម្រះក្តី ការតែតាំងមន្ត្រីតុលាការ និងលក្ខណៈទូទៅនៃការប្តឹងផ្តល់ឱ្យបានច្បាស់លាស់ |
| **ចរិយាសម្បទា/ឥរិយាបថ៖** | - ចូលរួមអនុវត្ត និងគោរពច្បាប់រដ្ឋ ជាមួយស្ថាប័នតុលាការ សាលាជម្រះក្តី និងកាត់បន្ថយការប្តឹងផ្តល់ និងការប្តឹងផ្តល់ឡើងតុលាការ។ |

**ខ. វិធីសាស្ត្របង្រៀន៖** សិស្សមជ្ឈមណ្ឌល បែបពិភាក្សា និងការងារក្រុម

**គ. សម្ភារៈឧបទេ្ទស៖** មេរៀនស្តីពីស្ថាប័នតុលាការនៃព្រះរាជាណាចក្រកម្ពុជា ដែលរៀបចំដោយក្រុមការងារ GCED នៃវិទ្យាស្ថានជាតិអប់រំ និងឯកសារយោងដែលពាក់ព័ន្ធ..

❖ **ពន្យល់ពាក្យ៖** - វិសោធនកម្ម ឆន្ទានុសិទ្ធិ ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី បណ្តឹងរដ្ឋប្បវេណី និងបណ្តឹងព្រហ្មទណ្ឌ...

## I. សេចក្តីផ្តើម

❖ អគតិទាំង៤យ៉ាងដែលចៅក្រមត្រូវវៀរចាកៈ

- ធន្ទាគតិ = លំអៀងព្រោះស្រឡាញ់
- ទោសាគតិ = លំអៀងព្រោះស្អប់
- ភយាគតិ = លំអៀងព្រោះភ័យខ្លាច
- មោហាគតិ = លំអៀងព្រោះមិនដឹង ល្ងង់........

❖ សមាសភាពរបស់តុលាការមានៈ

- ចៅក្រម (ចៅក្រមជំរះក្តី និងចៅក្រមស៊ើបអង្កេត)
- ព្រះរាជអាជ្ញា (ធ្វើការចោទប្រកាន់)
- ក្រឡាបញ្ជី (ជំនួយការ ឬ លេខាកត់ត្រា)

## ១. តួនាទីនៃស្ថាប័នតុលាការ

ស្ថាប័នតុលាការគឺជាស្ថាប័នមួយមានអំណាចឯករាជ្យ មានតួនាទីការពារសេរីភាពរបស់ប្រជាពលរដ្ឋ។ តុលាការមានអំណាចគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផងដែរ។

- មានតែចៅក្រមទេដែលមានសិទ្ធិជម្រះក្តីដោយគោរពច្បាប់យ៉ាងម៉ឹងម៉ាត់ និងអោយអស់ពីដួងចិត្ត និងសម្បជញ្ញៈ របស់ខ្លួន។
- តុលាការមានអំណាចនៅក្នុងការធ្វើសេចក្តីសម្រេចលើរឿងក្តីផ្សេងៗ។
- ចៅក្រមមានអំណាចជំនុំជម្រះរឿងក្តីទាំងអស់ រួមទាំងរឿងក្តីទាំងឡាយដោយបុគ្គលដែលមានមាន បំណងប្តឹងពីកំហុសឆ្គងផ្នែករដ្ឋបាលរបស់រាជរដ្ឋាភិបាល។
- តុលាការមានអំណាចឯករាជ្យ ចៅក្រមអាចសម្រេចសេចក្តីដោយធន្ទានុសិទ្ធិរបស់ខ្លួន។

## ២. រចនាសម្ព័ន្ធសាលាជម្រះក្តី

**ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនិងក្រមនីតិវិធីរដ្ឋប្បវេណីបានបញ្ជាក់ច្បាស់អំពីសាលាជម្រះក្តីដូចខាងក្រោមៈ**

- សាលាជម្រះក្តីថ្នាក់ទាប ឬសាលាដំបូងគឺតុលាការរាជធានីខេត្តដែលក្នុងនោះមានៈ
  - ប្រធានតុលាការមួយរូប អនុប្រធាន និងចៅក្រមមួយរូប
  - អយ្យការអមតុលាការមាន ព្រះរាជអាជ្ញាមួយរូបជាប្រធាន និងព្រះរាជអាជ្ញារងមួយ ឬច្រើន

- តុលាការយោធាមានបុគ្គលិកទាំងអស់ជាយោធាដែលមានប្រធានម្នាក់ អនុប្រធាន និងចៅក្រម ។
- សាលាឧទ្ធរណ៍ត្រូវបានបែងចែកជាផ្នែករដ្ឋប្បវេណី ព្រហ្មទណ្ឌ រដ្ឋបាល និងផ្នែកពាណិជ្ជកម្ម។ក្នុងនោះមានៈ
  - ប្រធានតុលាការមួយរូប អនុប្រធាន និងចៅក្រមច្រើនរូប ។
  - អគ្គព្រះរាជអាជ្ញាមួយរូបជាប្រធាន អគ្គព្រះរាអាជ្ញារង និងមានព្រះរាជអាជ្ញាជាច្រើនរូប
- តុលាការកំពូលត្រូវបានដឹកនាំដោយប្រធានមួយរូប អនុប្រធាន និងចៅក្រមជាច្រើនរូប និងពីរផ្នែក គឺ ផ្នែករដ្ឋប្បវេណី និងផ្នែកព្រហ្មទណ្ឌ។ ស្ថាប័ននេះត្រូវចែកជា៣ផ្នែក និងមាននាទីផ្សេងៗគ្នាៈ
  - ផ្នែកស៊ើបអង្កេត មានភារកិច្ចធានានូវនីត្យានុកូលភាពនៃការស៊ើបអង្កេត ។
  - ផ្នែករដ្ឋប្បវេណី ទទួលខុសត្រូវចំពោះការប្រមូលពត៌មាន និងភស្តុតាង ដើម្បីធ្វើការសន្និដ្ឋាន។
  - ផ្នែកព្រហ្មទណ្ឌ ទទួលខុសត្រូវចំពោះអគ្គព្រះរាជអាជ្ញាដោយប្រើសិទ្ធិព្រះរាជអាជ្ញានៅក្នុងការពិនិត្យចោទប្រកាន់នានា ការធ្វើសេចក្តីសន្និដ្ឋាន ការសួរចម្លើយ ។
- អង្គការអយ្យការ នៅអមសាលាជម្រះក្តី សាលាជាន់ទាប ឬសាលាដំបូង។ នៅក្នុងរឿងព្រហ្មទណ្ឌ ក្រុមអយ្យការដើរតួនាទីជាម្ចាស់បណ្តឹងអាជ្ញា ដោយតាំងខ្លួនជាគូដើមក្តីជានិច្ច ។
- ក្រឡាបញ្ជី ក្រៅពីចៅក្រមនិងអយ្យការគ្របដណ្តប់សាលាជម្រះក្តី នៅមានផ្នែកមួយទៀតគឺក្រឡាបញ្ជី។ ក្រឡាបញ្ជីជាជំនួយការរបស់ចៅក្រម និងព្រះរាជអាជ្ញានៅគ្រប់ដំណាក់កាលនៃរឿងក្តី។

## ៣. ការតែងតាំងមន្ត្រីតុលាការ

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវបានបង្កើតឡើងដើម្បីជួយព្រះមហាក្សត្រ ក្នុងការធានាឯករាជ្យភាពនៃអំណាចតុលាការ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមានករណីយកិច្ចសម្រេច និងស្នើថ្វាយព្រះមហាក្សត្រអំពីការតែងតាំង ការផ្លាស់ប្តូរ ការដកហូតមុខងារ ការដំឡើងឋានន្តរសក្តិរបស់ចៅក្រម និងព្រះរាជអាជ្ញាទាំងអស់។

**ឧត្តមក្រុមប្រឹក្សាអង្គចៅក្រមមានអាណត្តិ ៥ឆ្នាំ មានសមាសភាពដូចខាងក្រោមៈ**

- ព្រះមហាក្សត្រ ជាព្រះប្រធាន
- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាសមាជិក
- ប្រធានតុលាការកំពូល ជាសមាជិក
- អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ជាសមាជិក
- ប្រធានតុលាការ សាលាឧទ្ធរណ៍ ជាសមាជិក
- អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ ជាសមាជិក

- ចៅក្រម ៣រូប ដែលបានបោះឆ្នោតដោយចៅក្រម ជាសមាជិក

## ៤. លក្ខណៈទូទៅនៃការប្ដឹងផ្ដល់

ដំណើរការប្ដឹងផ្ដល់ត្រូវបានប្រព្រឹត្តទៅតាមរបៀបផ្សេងៗទៅតាមនៃរឿងរដ្ឋប្បវេណី និងរឿងព្រហ្មទណ្ឌ។

## ក. បណ្ដឹងរដ្ឋប្បវេណី

**ភាគីដែលអាចធ្វើបណ្ដឹងរដ្ឋប្បវេណីមាន៖**

- ភាគីដែលមានប្រយោជន៍មានសិទ្ធិឬទ្រព្យសម្បត្តិរបស់ខ្លួនដែលត្រូវធ្វើអោយខូចឬខាតដោយភាគីម្ខាងទៀត។
- ម្ចាស់ទ្រព្យសម្បត្តិ អ្នកទទួលមរតក ឬម្ចាស់បំណុលជាដើម ។
- ចំពោះជនដែលមានសមត្ថភាព និងជនដែលគ្មានសមត្ថភាពត្រូវមានតំណាង ដោយមានលិខិតសិទ្ធិប្រទាន ដូចជា មេធាវីជាដើម។

**១. ដំណាក់កាលដំបូងនៃបណ្ដឹងរដ្ឋប្បវេណី**

**បណ្ដឹងនេះចែកជា៥ដំណាក់កាល រួមមាន៖**

- ដំណាក់កាលទី១៖
  ដាក់ពាក្យបណ្ដឹងត្រូវធ្វើឡើងនៅការិយាល័យទទួលពាក្យបណ្ដឹងនៃតុលាការរាជធានី-ខេត្ត ដែលក្រឡាបញ្ជីជាអ្នកពិនិត្យមើលពាក្យបណ្ដឹង។
- ដំណាក់កាលទី២៖
  ដំណាក់កាលផ្សះផ្សារនៅតុលាការ រឿងនេះច្រើនមានក្នុងរឿងអាពាហ៍ពិពាហ៍ និងគ្រួសារ។
- ដំណាក់កាលទី៣៖
  ការចុះបញ្ជីពាក្យបណ្ដឹង និងប្រាក់ប្រដាប់ក្ដី អោយទៅតុលាការ ចំពោះអ្នកក្រីក្រ ត្រូវមានការបញ្ជាក់ពីអាជ្ញាធរ ..........។
- ដំណាក់កាលទី៤៖
  ជាដំណាក់ការស៊ើបអង្កេត ក្នុងករណីភាគីទាំងពីរមិនអាចផ្សះផ្សាគ្នាបាន។
- ដំណាក់កាលទី៥៖
  គឺប្ដឹងជំទាស់ទៅនឹងសមាសភាពចៅក្រម ក្នុងពេលជំនុំជំម្រះ។

### ២. ដំណើរការជំនុំជម្រះ

ការជំនុំជម្រះត្រូវធ្វើឡើងជាសាធារណៈ លើកលែងតែក្នុងករណីខ្លះដែលទាក់ទង និងការសម្ងាត់ផ្នែកសន្តិសុខ ឬអ្វីដែលប៉ះពាល់ដល់សីលធម៌សង្គម។

### ៣. សកម្មភាពក្រោយពេលជំនុំជម្រះ

**មានវិធី២ យ៉ាងដែលសម្រាប់តវ៉ា និងសាលក្រមដែលសាលាជំនុំជម្រះក្តីបានសំរេចគឺៈ**

- ចំពោះភាគីមួយដែលមិនសុខចិត្តនឹងសាលក្រមអាចប្តឹងអោយមានការជំនុំជំរះជាថ្មីក្នុងរយៈពេល១៥ថ្ងៃ។
- ប្រសិនបើភាគីបណ្តឹងដែលមិនសុខចិត្តពីសេចក្តីសម្រេច ឬសាលក្រមរបស់តុលាការ រាជធានី-ខេត្ត អាចប្តឹងឧទ្ធរណ៍បានក្នុងរយៈពេល៥ថ្ងៃ ហើយសាលាឧទ្ធរណ៍ត្រូវឆ្លើយតបវិញរយៈពេល១៥ថ្ងៃ។

### ៤. ការអនុវត្តសាលក្រមរដ្ឋប្បវេណី

កាលបើសាលក្រមផុតរលត់ហើយដំណាក់កាលមកទៀតគឺការអនុវត្តសាលក្រម។ នេះមានន័យថាសាលក្រមកំបាំងមុខចូលជាស្ថាពរ ប្រសិនបើគ្មានបណ្តឹងជំទាស់ និងបណ្តឹងឧទ្ធរណ៍។ ការអនុវត្តសាលក្រមចំពោះបណ្តឹងរដ្ឋប្បវេណីមានដូចជា បញ្ជាអោយភាគីចាញ់ក្តី សងជំងឺចិត្ត ឬសងបំណុល រឹបអូសទ្រព្យសម្បត្តិ....។

## ខ. បណ្តឹងព្រហ្មទណ្ឌ

បណ្តឹងព្រហ្មទណ្ឌអាចធ្វើឡើងដោយៈ

- ស្ថាប័នដែលមានសមត្ថកិច្ច ជាពិសេសនគរបាលយុត្តិធម៌។
- ជនរងគ្រោះ ឬសាច់ញាតិអាចប្តឹងទៅនគរបាលយុត្តិធម៌។
- ក្នុងករណីជាក់ស្តែង ព្រះរាជអាជ្ញាអាចចាត់ការដំណើររឿងព្រហ្មទណ្ឌនោះ ដោយខ្លួនឯងតែម្តង។
- ចំពោះបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែក្រោយមកតុលាការរកឃើញថា ជាបទល្មើសព្រហ្មទណ្ឌនោះ តុលាការ ប្រគល់រឿងនេះទៅអោយអយ្យការចាត់ការជារឿងព្រហ្មទណ្ឌ។

## គ. ដំណើរការបណ្តឹងព្រហ្មទណ្ឌមានដូចជាៈ

- ការរៀបចំសំណុំរឿងដោយនគរបាលយុត្តិធម៌ ហើយនគរបាលយុត្តិធម៌អាចចាប់ជនល្មើសបាន។
- បណ្តឹងក្រោមការចាត់ចែងរបស់ព្រះរាជអាជ្ញា បន្ទាប់ពីទទួលបានពាក្យបណ្តឹងពី នគរបាលយុត្តិធម៌ ជនរងគ្រោះ ឬសាច់ញាតិ។

- សំណុំរឿងក្នុងកិច្ចចាត់ការរបស់ចៅក្រមស៊ើបអង្កេត។ ចៅក្រមស៊ើបអង្កេតមិនអាចជំនុំជម្រះចំពោះរឿងដែលខ្លួនស៊ើបអង្កេតបានឡើយ។
- ពិធីសវនាការជំនុំជម្រះមានលក្ខណៈដូចគ្នា ទាំងនីតិវិធីព្រហ្មទណ្ឌ និងនីតិវិធីរដ្ឋប្បវេណី។
- អានុភាពនៃសាលក្រម ជនជាប់ចោទដែលត្រូវបានគេឃុំខ្លួនជាប់បណ្តោះអាសន្ន ត្រូវបានសាលក្រមសម្រេចអោយរួចខ្លួន បើកការជំនុំជំម្រះគេរកពុំឃើញកំហុស និងបើគ្មានការធ្វើបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងជំទាស់ពីដើមបណ្តឹង។ តែភាគីចុងចោទ អាចធ្វើបណ្តឹងទាមទារសងការខូចខាត។

## II. <u>**សំណួរ**</u>

១. តើអំណាចតុលាការគឺជាអ្វី? តើឯករាជភាពនៃអំណាចតុលាការមានន័យដូចម្តេច?

២. ចូរពន្យល់ពីភាពខុសគ្នានៃតួនាទីសាលាជម្រះក្តីនីមួយៗ។

៣. ចូរពន្យល់ពីដំណើរការដំបូងនៃបណ្តឹងរដ្ឋប្បវេណី។

៤. តើដំណើរការបណ្តឹងព្រហ្មទណ្ឌមានលក្ខណៈដូចម្តេចខ្លះ?

៥. ហេតុអ្វីបានជាបណ្តឹងរដ្ឋប្បវេណីមានដំណាក់កាលផ្សេះផ្សា?

៦. តើហេតុអ្វីបានជាបណ្តឹងព្រហ្មទណ្ឌមិនមានដំណាក់ផ្សះផ្សា?

៧. ចូរពន្យល់ពីសារៈសំខាន់របស់ស្ថាប័នតុលាការ។

*(ប្រភព៖ មេរៀនសីលធម៌ពលរដ្ឋ ថ្នាក់ទី១២ ជំពូក៣៖ ការចូលរួមអភិវឌ្ឍន៍សហគមន៍,ឆ្នាំសិក្សា ២០១៤)*

## ផ្នែកទី២៖ ស្ថាប័ននីតិប្រតិបត្តិនៃព្រះរាជាណាចក្រកម្ពុជា

**ក. ចំណុចបំណងនៃមេរៀន៖** ក្រោយពីបញ្ចប់ការសិក្សាមេរៀននេះ អ្នកសិក្សានឹង៖

| | |
|---|---|
| **វិជ្ជាសម្បទា/ពុទ្ធិ៖** | - យល់ដឹងអំពី ស្ថាប័ននីតិប្រតិបត្តិនៃព្រះរាជាណាចក្រកម្ពុជា |
| **បំណិនសម្បទា/ចិត្ត-សង្គម៖** | - ប្រើប្រាស់ស្ថាប័ននីតិប្រតិបត្តិនៃព្រះរាជាណាចក្រកម្ពុជាឱ្យបានត្រឹមត្រូវស្របតាមគោលការណ៍ច្បាប់របស់រដ្ឋ |
| **ចរិយាសម្បទា/ឥរិយាបថ៖** | - ចូលរួមរៀបកែលម្អស្ថាប័ននីតិប្រតិបត្តិនៃព្រះរាជាណាចក្រកម្ពុជាឱ្យមានប្រសិទ្ធភាព |

**ខ. វិធីសាស្ត្របង្រៀន៖** សិស្សមជ្ឈមណ្ឌល បែបពិភាក្សា និងការងារក្រុម

**គ. សម្ភារៈឧបទ្ទេស៖** មេរៀនស្តីពីស្ថាប័ននីតិប្រតិបត្តិនៃព្រះរាជាណាចក្រកម្ពុជា ដែលរៀបចំដោយក្រុមការងារ GCED នៃវិទ្យាស្ថានជាតិអប់រំ និងឯកសារយោងដែលពាក់ព័ន្ធ..

**I. ពន្យល់ពាក្យ** -ព្រះរាជក្រឹត្យ -ព្រះរាជក្រម -អនុក្រឹត្យ -ប្រកាស -សារាចរ -សេចក្តីសម្រេច -ដីកា -អាសនានុក្រម -ក្រឹត្យ

### ១. ការបង្កើតស្ថាប័ននីតិប្រតិបត្តិ

សង្គមប្រជាធិបតេយ្យចែកជាបីរបបគឺ -របបប្រធានាធិបតីនិយម -របបសភានិយម -របបចម្រុះ(ពាក់កណ្តាលរបបប្រធានាធិបតីនិយម និងសភានិយម)

មាត្រា៥១ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាចែងថា ព្រះរាជាណាចក្រកម្ពុជា អនុវត្តរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស។ ប្រជាពលរដ្ឋខ្មែរ ជាម្ចាស់វាសនានៃប្រទេសជាតិខ្លួន។ ប្រជាពលរដ្ឋជាអ្នកជ្រើសរើស អ្នកដឹកនាំតាមរយៈការបោះឆ្នោត។ ក្រោយការបោះឆ្នោតជ្រើសរើសសភាតំណាងរាស្ត្រ យើងសង្កេតឃើញរដ្ឋាភិបាលមួយកើតឡើងតាមការទទួលសេចក្តីទុកចិត្តពីសភាតំណាងរាស្ត្រ។

មាត្រា១១៩ថ្មី នៃរដ្ឋធម្មនុញ្ញចែងថា "តាមសេចក្តីស្នើពីប្រធានដោយមានមតិឯកភាព ពីអនុប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវីរជនមួយរូបក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សដែលឈ្នះឆ្នោតអោយបង្កើតរាជរដ្ឋាភិបាល។ វីរជនដែលចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណបក្សតំណាងនៅក្នុង

រដ្ឋសភាដែលផ្តួចផ្តើមឱ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាលទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា" កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល "។

## ២. យន្តការវ៉ៃផ្នែកនីតិប្រតិបត្តិ

### ក. គណៈរដ្ឋមន្ត្រី

គណៈរដ្ឋមន្ត្រីដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ ជាសមាជិក (មាត្រា១១៨នៃរដ្ឋធម្មនុញ្ញ)។ ការប្រជុំពេញអង្គគឺជាការប្រជុំរបស់គណៈរដ្ឋមន្ត្រី ដើម្បីសម្រេចដោះស្រាយរាល់កិច្ចការទូទៅរបស់រដ្ឋាភិបាល (មាត្រាទី១០ ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី)។

### ខ. សមត្ថកិច្ចសមាជិករដ្ឋាភិបាល

### ១. នាយករដ្ឋមន្ត្រី

ជាសមាជិករដ្ឋសភាជាអ្នកដឹកនាំការងារគណៈរដ្ឋមន្ត្រី និងចាត់ចែងបញ្ជារាល់សកម្មភាពរបស់រដ្ឋាភិបាលលើគ្រប់វិស័យ។ នាយករដ្ឋមន្ត្រី មានភារកិច្ចដូចតទៅ៖

- ទទួលខុសត្រូវរួមជាមួយសមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលចំពោះមុខរដ្ឋសភាអំពីនយោបាយនិងសកម្មភាពរបស់រដ្ឋាភិបាល
- ដឹកនាំការចរចា និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្ម សហប្រតិបត្តិការ សេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេស និង ការពារប្រទេស។
- លើកសំណើដល់គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា ដើម្បីកោះប្រជុំសភា។
- លើកសំណើសេចក្តីព្រាងច្បាប់ និងសំណើតែងតាំងផ្លាស់ប្តូរ បញ្ចប់ភារកិច្ចរបស់សមាជិករដ្ឋាភិបាល ជូនសភាអនុម័ត។
- លើកសំណើថ្វាយព្រះមហាក្សត្រតែងតាំង ផ្លាស់ប្តូរបញ្ចប់ភារកិច្ចមន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធា ដោយព្រះរាជក្រឹត្យ។
- ត្រួតពិនិត្យការងារ សកម្មភាព អំពីការប្រព្រឹត្តិ និងទំនួលខុសត្រូវរបស់សមាជិករដ្ឋាភិបាល ហើយមានសិទ្ធិផ្លាស់ប្តូរសមាជិករដ្ឋាភិបាលតាមនិតិវិធី។

### ២. ឧបនាយករដ្ឋមន្ត្រី

ជាសមាជិករដ្ឋាភិបាលដែលមានអាសនានុក្រមលើសមាជិករដ្ឋាភិបាលដទៃទៀត។ ឧបនាយករដ្ឋមន្ត្រីជួយការងារ

នាយករដ្ឋមន្ត្រីតាមការប្រគល់សិទ្ធិចំពោះមុខពីនាយករដ្ឋមន្ត្រី។

### ៣. ទេសរដ្ឋមន្ត្រី

សំដៅលើរដ្ឋមន្ត្រីដែលមានអតីតភាពយូរ។ អ្នកដែលកាន់តំណែងជាទេសរដ្ឋមន្ត្រីមិនបានកាន់កាប់ ក្រសួងណាមួយទេ តែបើជាទេសរដ្ឋមន្ត្រីផង ជារដ្ឋមន្ត្រីផង ទើបមានតំណែងជាប្រធានស្ថាប័នពិតប្រាកដ។ ទេសរដ្ឋមន្ត្រី ដែលមិនដឹកនាំក្រសួង អាចទទួលភារកិច្ចតាមការកំណត់របស់នាយករដ្ឋមន្ត្រី។

### ៤. រដ្ឋមន្ត្រី

រដ្ឋមន្ត្រីជាប្រធានស្ថានប័នក្នុងករណីដែលមានរដ្ឋលេខាធិការ ជាអនុប្រធានស្ថាប័ន។ រដ្ឋមន្ត្រីមានភារកិច្ចដឹកនាំគ្រប់គ្រងស្ថាប័ន និង អង្គភាពចំណុះក្នុងក្របខ័ណ្ឌសមត្ថកិច្ចដែលកំណត់ក្នុងច្បាប់។

### ៥. រដ្ឋលេខាធិការ

ជាប្រធានស្ថាប័ននៃរដ្ឋលេខាធិការដ្ឋានស្វយ័ត (រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល និងរដ្ឋលេខាធិការ ដ្ឋានមុខងារសាធារណៈ) ប៉ុន្តែរដ្ឋលេខាធិការដ្ឋានទាំងពីរនេះ ចំណុះទីស្តីការគណៈរដ្ឋមន្ត្រី។

### ៦. អនុរដ្ឋលេខាធិការ

មិនមែនជាសមាជិករដ្ឋាភិបាលទេ ជាជំនួយការក្នុងករណីដែលក្រសួងមានរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការជាប្រធាន និងអនុប្រធានស្ថាប័ន។

## គ. ខុទ្ទកាល័យទីស្តីការគណៈរដ្ឋមន្ត្រី

ខុទ្ទកាល័យទីស្តីការគណៈរដ្ឋមន្ត្រីទទួលខុសត្រូវលើកិច្ចការសំខាន់ៗដូចតទៅ៖

- រៀបចំជូននាយករដ្ឋមន្ត្រីដើម្បីសំរេចលើសំណុំរឿងទាំងឡាយដែលក្រសួងផ្សេងៗស្នើមក ។
- ជូនយោបល់នាយករដ្ឋមន្ត្រីក្នុងការរៀបចំគោលដៅនៃសកម្មភាពរដ្ឋាភិបាល។
- រាយការណ៍អំពីការវិវត្ត និងការអនុវត្តកិច្ចការទាំងឡាយដែលក្រសួងនានា បានចាត់ចែង។
- ទទួលរៀបចំទំនាក់ទំនងជាមួយស្ថាប័នខាងក្រៅ ដូចជា អង្គការ សហជីព អង្គការអន្តរជាតិ......។
- ពិនិត្យ និង ពិគ្រោះលើសេចក្តីព្រាងច្បាប់ ក្រឹត្យ អនុក្រឹត្យ ដែលរៀបចំឡើង ដោយ ក្រសួងផ្សេងៗ មុននឹងដាក់ជូនសម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រីពិនិត្យ និងអនុម័ត ។

### ឃ. ក្រសួងផ្សេងៗ

ក្រសួងជាស្ថាប័នដែលដឹកនាំដោយរដ្ឋមន្ត្រី ហើយរដ្ឋលេខាធិការដ្ឋាន ដឹកនាំដោយ រដ្ឋលេខាធិការ។ ស្ថាប័ននេះ ទទួលបន្ទុកអនុវត្តកម្មវិធីនយោបាយរាជរដ្ឋាភិបាល តាមជំនាញ រៀងៗខ្លួន។ រាល់ការបង្កើតឬរំលាយក្រសួងឬរដ្ឋលេខាធិការ ដ្ឋានត្រូវកំណត់ដោយច្បាប់ (មាត្រាទី៣៣ ច្បាប់នីមួយៗស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី)។ សម្រាប់នីតិកាលទី៤(ឆ្នាំ២០០៨) មានក្រសួងចំនួន២៥ និងរដ្ឋលេខាធិការដ្ឋានចំនួន២ ហើយស្ថាប័នទាំងនេះ ត្រូវរៀបចំឡើងតាមវិស័យដូចតទៅៈ

**ក្រសួងបំរើអោយវិស័យរដ្ឋបាលមានៈ**

- ក្រសួង ការពារជាតិ
- ក្រសួង មហាផ្ទៃ
- ក្រសួង យុត្តិធម៌
- ក្រសួង ផែនការ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួង ការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- ក្រសួង ដែនដីនគរូបនីយកម្ម និង សំណង់
- ក្រសួង ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច
- ក្រសួង ព្រះបរមរាជវាំង

**ក្រសួងបំរើអោយវិស័យសេដ្ឋកិច្ចមានៈ**

- ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួង ឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួង ពាណិជ្ជកម្ម
- ក្រសួង សាធារណៈការ និង ដឹកជញ្ជូន
- ក្រសួង ធនធានទឹក និង ឧត្តុនិយម
- ក្រសួង អភិវឌ្ឍនជនបទ
- ក្រសួង ទេសចរណ៍
- ក្រសួង កសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ
- ក្រសួង បរិស្ថាន
- រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល

**ក្រសួងបំរើអោយវិស័យវប្បធម៌ សង្គមកិច្ចមានៈ**

- ក្រសួង អប់រំយុវជន និង កីឡា
- ក្រសួង ពត៌មាន
- ក្រសួង សុខាភិបាល
- ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- ក្រសួងធម្មការ និង កិច្ចការសាសនា
- ក្រសួង កិច្ចការនារី
- ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ង. ក្រុមប្រឹក្សា

**- មាត្រាទី១៤** នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានចែងថា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានក្រុមប្រឹក្សារបស់ខ្លួន ដែលត្រូវបានជើសរើសឡើងតាមរយៈការបោះឆ្នោតអសកល ស្របតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។

**- មាត្រាទី២៩** នៃច្បាប់នេះចែងថាក្រុមប្រឹក្សាមានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចនូវគោលបំណងក្នុងការបង្កើត ជំរុញ និង ការធ្វើអោយមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។

**- មាត្រាទី៣០** ក្រុមប្រឹក្សាមានអំណាចពីរគឺៈ សិទ្ធិអំណាចធ្វើសេចក្តីសំរេចខាងបញ្ញត្តិនិងខាងប្រតិបត្តិ។ ក្រុមប្រឹក្សាប្រើប្រាស់សិទ្ធិអំណាចបញ្ញត្តិរបស់ខ្លួនដោយធ្វើដីកា។ ដីការរបស់ក្រុមប្រឹក្សាមានវិសាលភាពដើម្បីកំណត់ ហាមឃាត់ ឬត្រួតពិនិត្យលើសកម្មភាព លើនីតិវិធី ឬកិច្ចការ ណាមួយ ដែលស្ថិតក្នុងវិសាលភាពនៃមុខងារ។ សិទ្ធិអំណាចខាងប្រតិបត្តិ គឺក្រុមប្រឹក្សាត្រូវបំពេញមុខងារនិងភារកិច្ចដោយ ធ្វើសេចក្តីសំរេចក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាថាសេចក្តីសម្រេចនោះត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ។

ច. គណៈអភិបាល

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នីមួយៗត្រូវគ្រប់គ្រងដោយគណៈអភិបាល និងអភិបាលរងច្រើនរូប។ អភិបាលរាជធានី ខេត្ត ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ អភិបាលរងក្រុង ស្រុក ខណ្ឌ ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**II. សំណួរត្រិះរិះ**

1. ចូររៀបរាប់ពីការបង្កើតរដ្ឋាភិបាលក្នុងលទ្ធិប្រជាធិបតេយ្យ?
2. តើរដ្ឋាភិបាលកម្ពុជាកើតឡើងដោយរបៀបណា?
3. ចូររៀបរាប់ពីតួនាទី និងភារកិច្ចរបស់នាយករដ្ឋមន្ត្រី?
4. ចូររៀបរាប់ពីសមាសភាពរដ្ឋាភិបាលកម្ពុជាព្រមទាំងពន្យល់ពីមុខតំណែងនីមួយៗផង?
5. តើខុទ្ទកាល័យទីស្តីការណគៈរដ្ឋមន្ត្រីមានភារកិច្ចដូចម្តេចខ្លះ?
6. តើក្រសួង និងរដ្ឋលេខាធិការដ្ឋានត្រូវរៀបចំតាមវិស័យដូចម្តេចខ្លះ? លើកឧទាហរណ៍បញ្ជាក់ផង។

## ផ្នែកទី៣៖ រដ្ឋបាលមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា

ផ្នែកទី៣ រៀបរាប់ពីរដ្ឋបាលមូលដ្ឋានក្នុងប្រទេសកម្ពុជា ដែលទាក់ទងជាមួយរចនាសម្ព័ន្ធរដ្ឋបាលមូលដ្ឋាន លក្ខណៈនៃមជ្ឈការ វិមជ្ឈការ លក្ខណៈនៃមជ្ឈការអំណាច លក្ខណៈនៃវិមជ្ឈការ និងវិសហមជ្ឈការ។

**ក. វត្ថុបំណងនៃមេរៀន៖** ក្រោយពីបញ្ចប់ការសិក្សាមេរៀននេះ អ្នកសិក្សានឹង៖

| | |
|---|---|
| **វិជ្ជាសម្បទា/ពុទ្ធិ៖** | - យល់ដឹងអំពីរចនាសម្ព័ន្ធរដ្ឋបាលមូលដ្ឋាន លក្ខណៈនៃមជ្ឈការ វិមជ្ឈការ និងវិសហមជ្ឈការ និងអាជ្ញាធររដ្ឋបាលឯករាជ្យ |
| **បំណិនសម្បទា/ចិត្ត-សង្គម៖** | - ប្រើប្រាស់រចនាសម្ព័ន្ធរដ្ឋបាលមូលដ្ឋាន លក្ខណៈនៃមជ្ឈការ វិមជ្ឈការ និងវិសហមជ្ឈការ និងអាជ្ញាធររដ្ឋបាលឯករាជ្យ តាមត្រឹមត្រូវ និងស្របនីតិវិធីច្បាប់សម្រាប់ប្រជាពលរដ្ឋកម្ពុជា |
| **ចរិយាសម្បទា/ឥរិយាបថ៖** | - ស្រលាញ់ចូលចិត្ត និងចូលរួមអនុវត្តអំពីរចនាសម្ព័ន្ធរដ្ឋបាលមូលដ្ឋាន លក្ខណៈនៃមជ្ឈការ វិមជ្ឈការ និងវិសហមជ្ឈការ និងអាជ្ញាធររដ្ឋបាលឯករាជ្យប្រកបដោយប្រសិទ្ធភាព |

**ខ.វិធីសាស្ត្របង្រៀន៖** សិស្សមជ្ឈមណ្ឌល បែបពិភាក្សា និងការងារក្រុម

**គ.សម្ភារៈឧបទេ្ទស៖** មេរៀនស្តីពីរដ្ឋបាលមូលដ្ឋាននៅក្នុងប្រទេសកម្ពុជាដែលរៀបចំដោយក្រុមការងារ GCED នៃវិទ្យាស្ថានជាតិអប់រំ និងឯកសារយោងដែលពាក់ព័ន្ធ..

❖ ប្រជាភិថុតិ៖ ការបញ្ជ្រាបឬការបញ្ចើចលើកជើងប្រជារាស្ត្រ-អព្យាក្រឹតភាព-តម្លាភាព-គណនេយ្យភាព។

## ១. រចនាសម្ព័ន្ធរដ្ឋបាលមូលដ្ឋាន

អំណាចរដ្ឋបាលមូលដ្ឋាន មានតួនាទីបំពេញមុខងារសណ្តាប់ធ្នាប់និងសុខសុវត្ថិភាពជូនរដ្ឋសាធារណៈនិងប្រជាពលរដ្ឋ។ ក្រុមប្រឹក្សានីមួយៗ ត្រូវទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ ឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងជំរុញមូលដ្ឋាន អោយមានការអភិវឌ្ឍប្រកបទៅដោយនិរន្តរភាព។ ក្រុមប្រឹក្សាឃុំ-សង្កាត់ ក្រុមប្រឹក្សាក្រុង-ខណ្ឌ-ស្រុក និងក្រុមប្រឹក្សារាជធានី-ខេត្ត មានតួនាទីដឹកនាំគ្រប់គ្រង រដ្ឋបាលរបស់ខ្លួន ដោយធ្វើការប្រជុំយ៉ាងតិចមួយដងក្នុងមួយខែ នៅក្នុងសាលប្រជុំរបស់ខ្លួន។

## ២. លក្ខណៈនៃមជ្ឈការ វិមជ្ឈការ និង វិសហមជ្ឈការ

រដ្ឋដែលមានអ្នកគ្រប់គ្រង និងដឹកនាំល្អធ្វើអោយប្រជាពលរដ្ឋទទួលបាននូវអត្ថប្រយោជន៍ច្រើន។ រដ្ឋបាលកណ្តាលត្រូវតែចែករំលែកអំណាចរបស់ខ្លួនទៅអោយរដ្ឋបាលមូលដ្ឋានដែលគេអោយឈ្មោះថា វិមជ្ឈការនិងវិសហមជ្ឈការ ដែលផ្ទុយពីអ្វីដែលជាការប្រមូលផ្តុំអំណាចអោយនៅតែក្នុងដៃរដ្ឋបាលកណ្តាល។ ការប្រមូលផ្តុំអំណាចបែបនេះហៅថា មជ្ឈការ។

### ក. លក្ខណៈនៃមជ្ឈការអំណាចៈ

មជ្ឈការ គឺជាការប្រមូលផ្តុំអំណាច ឬជាប្រព័ន្ធគ្រប់គ្រងដែលប្រមូលផ្តុំអំណាចនៅតែក្នុងដៃរបស់ រដ្ឋបាលកណ្តាលគឺមានន័យថា អំណាចទាំងអស់នៅក្នុងដៃបុគ្គល ឬក្រុមដែលមានអំណាចគ្រប់គ្រងប្រ ទេស។ ការប្រមូលផ្តុំអំណាចតែក្នុងដៃបុគ្គលម្នាក់ឬក្រុមដែលមានអំណាចគ្រប់គ្រងប្រទេសដែលជាទូទៅហៅថា "អំណាចកណ្តាល" នោះអាចបង្កអោយអ្នកកាន់អំណាចឈានទៅរកការអនុវត្តរបបផ្តាច់ការ បុគ្គលនិយមជួនកាល អាចប្រើនយោ បាយប្រជាភិថុតិបោកប្រាស់ប្រជាជនខ្លួនឯងដើម្បីអំណាច។

គុណសម្បត្តិនៃប្រព័ន្ធមជ្ឈការត្រង់ថារដ្ឋអំណាចថ្នាក់ក្រោមអនុវត្តតាមវិធីរបស់រដ្ឋតែមួយដែលជាការពង្រឹង បាននូវឯកភាពជាតិ និងផ្តល់ភាពងាយស្រួលដល់ថ្នាក់កណ្តាលក្នុងការត្រួតពិនិត្យ វាយតម្លៃ សកម្មភាព អនុវត្តរបស់ថ្នាក់ក្រោម សម្រួលថ្នាក់កណ្តាលក្នុងការគ្រោង និងត្រួតពិនិត្យ ចំណាយ ចំណូល ថវិកា។ គុណវិបត្តិនៃប្រព័ន្ធដឹកនាំតាមបែបមជ្ឈការគឺរដ្ឋបាលសាធារណៈមិនអាចស្ថិតនៅជិត និងប្រជាពលរដ្ឋមិនបានដឹងពីតម្រូវការប្រជាពលរដ្ឋក៏ដូចជាតម្រូវការរបស់មូលដ្ឋានអោយពិតប្រាកដ ជួនកាលគម្រោងកម្មវិធីដែលថ្នាក់កណ្តាលបានដាក់ចុះធ្វើអោយខូចប្រយោជន៍ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ រដ្ឋបាលបែបមជ្ឈការជារដ្ឋបាលដែលមានលក្ខណៈបិទជិត។ ប្រជាពលរដ្ឋមិនអាចចូលរួមក្នុងការសម្រេចចិត្តអ្វីមួយ ឬក្នុងការរៀបចំនិងក្នុងការអនុវត្តគម្រោងកម្មវិធីអភិវឌ្ឍន៍ជាតិបានឡើយ។

### ខ. លក្ខណៈនៃវិមជ្ឈការៈ

វិមជ្ឈការ មានន័យថា ជាការគ្រប់គ្រងបុគ្គលភាពគតិយុត្តិរបស់រដ្ឋអោយទៅជាសមូហភាព ផែនដីទាំងឡាយណាដែលស្ថិតនៅក្រៅសមូហភាពរដ្ឋ ដើម្បីអោយសមូហភាពផែនដីនោះមានស្វ័យភាពក្នុងការរៀបចំប្រជាជននៅក្នុងមូលដ្ឋានរបស់ខ្លួនអោយមានការរីកចំរើនទាំងផ្នែកស្មារតី និងសម្ភារៈ។ ន័យម៉្យាងទៀត វិមជ្ឈការគឺជាការប្រគល់ភាពជាម្ចាស់លើមុខងារ ឬជាការចែករំលែកអំណាចក្នុងប្រព័ន្ធ អភិបាលកិច្ចតាមរយៈការផ្ទេរអំណាចនៃរដ្ឋបាលកណ្តាល

រួមទាំងការទទួលខុសត្រូវ និងត្រូវធនធានអោយទៅរដ្ឋបាលមូលដ្ឋានឬរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជាក្រុមប្រឹក្សារាជធានី-ខេត្ត ក្រុមប្រឹក្សា ខណ្ឌ-ក្រុង ស្រុក និងក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីឆ្លើយតបទៅនឹងតម្រូវភាពមូលដ្ឋាន ដែលស្ថិត នៅក្រោម ការគ្រប់គ្រងរបស់ពួកគេ ។

## ៣. វិសហមជ្ឈការ

វិសហមជ្ឈការ មានន័យថារាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នធ្វើប្រតិភូកម្មលើមុខងារ សិទ្ធិអំណាច និងធនធាន ទៅអង្គភាពក្រោមបង្គាប់ ឬទៅក្រុមប្រឹក្សាណាមួយ ដើម្បីអនុវត្តន៍ការងារនោះក្នុងនាមរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននោះ។ ក្នុងន័យនេះ ភាពជាម្ចាស់មិនបានផ្តល់ជូនអង្គភាពក្រោមបង្គាប់ ឬក្រុមប្រឹក្សាឡើយ។ រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលបានរក្សាទុកនូវភាពជាម្ចាស់នោះ ដូចជា៖ ក្រសួងមហាផ្ទៃធ្វើប្រតិភូកម្មលើមុខងារធ្វើសេចក្តីចម្លងអត្រានុកូលដ្ឋានទៅអោយក្រុមប្រឹក្សាក្រុង-ខណ្ឌ-ស្រុក ហើយអភិបាលទាំងនោះត្រូវបានគេប្រគល់អោយអនុវត្តការងារនេះក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។ ក្នុងការធ្វើប្រតិភូកម្មមុខងារនេះ ក្រសួងមហាផ្ទៃនិងផ្តល់ធនធាន និងការបណ្តុះបណ្តាល។

**រចនាសម្ព័ន្ធរដ្ឋបាលឃុំ-សង្កាត់បែបវិមជ្ឈការ**



## ៤. អាជ្ញាធររដ្ឋបាលឯករាជ្យ

ដើម្បីសម្របសម្រួល និងគាំទ្រដល់ដំណើរការនៃការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការប្រកបដោយប្រសិទ្ធភាព រដ្ឋនីមួយៗត្រូវរៀបចំកម្មវិធីជាតិមួយក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ខ្លួន។ គោលនយោបាយកំណែទម្រង់របស់រដ្ឋាភិបាលកម្ពុជា ទទួលបានការគាំទ្រ និងចូលរួមដោយឥតសំចៃពីគ្រប់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល មន្ត្រីរាជការស៊ីវិល នគរបាលជាតិ កងយោធពលខេមរៈភូមិន្ទ គ្រប់លំដាប់ថ្នាក់ ពីគ្រប់គណបក្សនយោបាយនានា ពីសង្គមស៊ីវិល និងផ្នែកឯកជន រួមទាំងប្រជាពលរដ្ឋទាំងមូល ក៏ដូចជាដៃគូអភិវឌ្ឍ ប្រទេសផ្តល់ជំនួយ សំដៅនាំកម្ពុជាឆ្ពោះទៅរកការអភិវឌ្ឍលើគ្រប់វិស័យ។

**សំណួរ៖**

**ក. ចូរផ្គូផ្គងផ្នែក A និង B ឱ្យបានត្រឹមត្រូវ**

| A | B | ចម្លើយ |
|---|---|---|
| ១. វិមជ្ឈការ<br>២. មជ្ឈការ<br>៣. វិសហមជ្ឈការ | ក-ប្រព័ន្ធគ្រប់គ្រងអំណាចស្ថិតនៅលើរដ្ឋបាលថ្នាក់កណ្តាល<br>ខ-ប្រព័ន្ធគ្រប់គ្រងអំណាចស្ថិតនៅលើរដ្ឋបាលថ្នាក់ក្រោម<br>គ-ស្ថាប័ននានាធ្វើប្រតិភូកម្មលើមុខងារ សិទ្ធិអំណាចនិងធនធាន | ១-<br>២-<br>៣- |

**ខ. ចូរបំពេញឈ្លះខាងក្រោមឱ្យបានត្រឹមត្រូវ**

១. រដ្ឋបាលថ្នាក់កណ្តាលចូលរួមជួយពិនិត្យលើផ្លូវច្បាប់ជូនដល់រដ្ឋបាលថ្នាក់ក្រោមក្នុងនាមជា.....

២. ក្នុងលទ្ធិប្រជាធិបតេយ្យ ការធ្វើបញ្ជីអត្រានុកូលដ្ឋានជូនដល់ប្រជារាស្ត្រគឺជាភារកិច្ចរបស់......

៣. ការទទួលខុសត្រូវនិងការឆ្លើយតបនឹងតម្រូវការប្រជាពលរដ្ឋក្នុងការជួយជំរុញឱ្យមានការអភិវឌ្ឍឃុំ-សង្កាត់ គឺជាភារកិច្ចរបស់..................................................

**គ. សំណួរត្រិះរិះ៖**

១. តើពាក្យមជ្ឈការមានន័យដូចម្តេច? តើគុណសម្បត្តិនិងគុណវិបត្តិរបស់មជ្ឈការនាំមកនូវផលប្រយោជន៍ និងផលវិបាកអ្វីខ្លះក្នុងការគ្រប់គ្រងការងារសង្គមមូលដ្ឋាន?

២. តើវិមជ្ឈការមានន័យដូចម្តេចខ្លះ? តើមជ្ឈការនិងវិមជ្ឈការមានលក្ខណៈខុសគ្នាត្រង់ណាខ្លះ?

៣. តើពាក្យវិសហមជ្ឈការមានន័យដូចម្តេចខ្លះ?

៤. តើទំហំនៃកម្រិតវិមជ្ឈការរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់មានអ្វីខ្លះ? តើវិមជ្ឈការឃុំ-សង្កាត់ មានអំណាចលើវិស័យអ្វីខ្លះ?

៥. ដើម្បីសម្របសម្រួលនិងគាំទ្រដល់ដំណើរការនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឱ្យមានប្រសិទ្ធភាព តើរាជរដ្ឋាភិបាលត្រូវមានវិធានការដូចម្តេចខ្លះ?

# មេរៀនទី២៖
# បញ្ហាដែលប៉ះពាល់ទៅដល់អន្តរកម្ម និងទំនាក់ទំនងរបស់សហគមន៍នៅក្នុងកម្រិតមូលដ្ឋាន ជាតិ និងសកល

**ISSUES AFFECTING INTERACTION AND CONNECTEDNESS OFCOMMUNITIES AT LOCAL, NATIONAL AND GLOBAL LEVELS**

( Mr. Thai Heng, Dr. Mam Chansean, Mr. Chan Bunthan, and Mr. Loch Chanthan )

## ផ្នែកទី១៖ សិទ្ធិជនជាតិផ្សេងៗនៅកម្ពុជា

ផ្នែកទី១ លើកឡើងពីក្រុមជនជាតិ និងវប្បធម៌ផ្សេងៗដែលមាននៅក្នុងប្រទេសកម្ពុជា សិទ្ធិជនជាតិដើមភាគតិច ជីវភាពរស់នៅ តម្រូវការរបស់ជនជាតិភាគតិច និងការឆ្លើយតបរបស់រដ្ឋាភិបាលកម្ពុជា។

**ក. វត្ថុបំណងនៃមេរៀន៖** ក្រោយពីបញ្ចប់ការសិក្សាមេរៀននេះ អ្នកសិក្សានឹង៖

| | |
|---|---|
| **វិជ្ជាសម្បទា/ពុទ្ធិ៖** | - យល់ដឹងអំពី អត្តសញ្ញាណ ក្រុមជនជាតិផ្សេងៗនិងវប្បធម៌ សិទ្ធិជនជាតិ ជីវភាពរស់នៅ និងតម្រូវការរបស់ជនជាតិភាគតិច និងការឆ្លើយតបរបស់រដ្ឋាភិបាល |
| **បំណិនសម្បទា/ចិត្ត-សង្គម៖** | - ប្រើប្រាស់ អត្តសញ្ញាណក្រុមជនជាតិផ្សេងៗ និងវប្បធម៌ សិទ្ធិជនជាតិ ជីវភាពរស់នៅ និងតម្រូវការរបស់ជនជាតិភាគតិច និងការឆ្លើយតបរបស់រដ្ឋាភិបាលឱ្យស្របគោលការណ៍ច្បាប់ |
| **ចរិយាសម្បទា/ឥរិយាបថ៖** | - ចូលរួមគោរពសិទ្ធិជនជាតិដើមភាគតិច ជីវភាពរស់នៅ និងតម្រូវការរបស់ជនជាតិភាគតិច និងការឆ្លើយតបរបស់រដ្ឋាភិបាល |

**ខ. វិធីសាស្រ្តបង្រៀន៖** សិស្សមជ្ឈមណ្ឌល បែបពិភាក្សា និងការងារក្រុម

**គ. សម្ភារៈឧបទ្ទេស៖** មេរៀនស្តីពីសិទ្ធិជនជាតិផ្សេងៗនៅកម្ពុជាដែលរៀបចំដោយក្រុមការងារ GCED នៃវិទ្យាស្ថានជាតិអប់រំ និងឯកសារយោងដែលពាក់ព័ន្ធ..

❖ ជនជាតិដើមភាគតិច៖

## ១. ការកំណត់អត្តសញ្ញាណ

ជាតិពន្ធុ សំដៅដល់អត្តសញ្ញាណរបស់ក្រុមមនុស្សដែលមានទំនាក់ទំនងនឹងគ្នា ដោយការបូកបញ្ចូលគ្នានៃវប្បធម៌ សាសនា ភាសា ប្រវត្តិសាស្ត្រ និងទីតាំងភូមិសាស្ត្រដោយឡែកៗ ។

## ២. ក្រុមជនជាតិផ្សេងៗ និងវប្បធម៌

**ក. ជនជាតិចិន** រស់នៅស្រុកខ្មែរតាំងពីសម័យមុនអង្គរ។ ចាប់តាំងពីឆ្នាំ១៤៣៤មក ភ្នំពេញបានក្លាយជារាជធានី។ ជនជាតិចិនបានបង្កើតជាសហគមន៍ធំៗ ពួកគេជាអ្នកម្ចាស់ហាង ម្ចាស់សណ្ឋាគារ ម្ចាស់ភោជនីយដ្ឋាន ពាណិជ្ជករ .......។

**ខ. ជនជាតិវៀតណាម** រស់នៅកម្ពុជាច្រើនសតវត្សមកហើយ គេចែកជនជាតិវៀតណាមជាបីក្រុមៈ

- ជនជាតិវៀតណាមដើមកំណើតនៅកម្ពុជា។
- ជនជាតិវៀតណាមដែលភៀសខ្លួនមកឆ្នាំ ១៩៧៩-១៩៨៩។
- ជនជាតិវៀតណាមដែលទើបចូលមកនិយាយភាសាខ្មែរតិចតួច ពួកគេភាគច្រើនធ្វើកម្មករសំណង់ ជាងជួស ជុល នេសាទ.....

**គ. ជនជាតិចាម** បន្ទាប់ពីបាត់បង់ទឹកដីដើមកំណើត បានភៀសខ្លួនទៅរស់នៅពេញពិភព លោកក្នុងនោះប្រទេសកម្ពុជាផងដែរ។ ពួកគេមានមុខរបរជាអ្នកនេសាទ កាប់គោ ក្របី អ្នកធ្វើឧបករណ៍ នេសាទ .......

**ឃ.** ជនជាតិភាគតិចអំបូរមនខ្មែរ ជនជាតិភាគតិចអំបូរខ្មែរមន ច្រើនរស់នៅតាមបណ្ដាខេត្តមួយចំនួន ដូចជា ស្ទឹងត្រែង ព្រះវិហារ រតនគីរី មណ្ឌលគីរី ក្រចេះ កំពង់ធំ សៀមរាប ពោធិសាត់។

ក្រុមជនជាតិទាំងនោះមានប្រហែល ២០ក្រុមខុសៗគ្នា ហើយក្រុមជនជាតិធំៗមានព្នង ទំពួន កួយ គ្រឹង ព្រៅ ចារាយ ស្ទៀង ការវែត។ ពួកគេនិយាយភាសាផ្សេងៗគ្នាមានមុខរបរ ធ្វើកសិកម្ម បេះផ្លែឈើ បរបាញ់សត្វ និងរកអនុផលព្រៃឈើ។ ការគោរពចាស់ទុំជាទំនៀមទំលាប់តឹងតែងបំផុតរបស់ពួកគេ ហើយ ចាស់ស្រុក ជាមនុស្សប្រុសស្រីដែលមានអាយុ ច្រើនជាងគេ និងមាននាទីដូចជាៈ

- អ្នកសម្របសម្រួលជម្លោះរវាងគ្រួសារនានាព្រមទាំងក្រើនរំលឹកឱ្យគ្រួសារទាំងអស់បំពេញតួនាទីចំពោះដូនតា

- អ្នកថែរក្សាប្រវត្តិសាស្ត្រកេរដំណែលបន្ត ជាអ្នកគ្រប់គ្រងច្បាប់ទម្លាប់ប្រពៃណីរបស់ក្រុមគេ

## ៣. សិទ្ធិជនជាតិដើមភាគតិច

ជនជាតិភាគតិចមានសិទ្ធិដូចខាងក្រោម៖

- អនុវត្តន៍គោរពសាសនារបស់ខ្លួន និងប្រើប្រាស់ភាសាខ្លួន
- ចូលរួមយ៉ាងសកម្មក្នុងជីវភាពវប្បធម៌ សាសនា សេដ្ឋកិច្ច និងកិច្ចការសាធារណៈ
- ចូលរួមធ្វើសេចក្តីសំរេចថ្នាក់ជាតិ ថ្នាក់តំបន់ពីបញ្ហាទំនាក់ទំនងនឹងជនជាតិភាគតិច
- បង្កើតនិងថែរក្សាសហគមន៍ហើយមានទំនាក់ទំនងដោយសេរីដោយសន្តិវិធីជាមួយសមាជិកក្នុងក្រុមខ្លួន និងក្រុមដទៃ
- អាចប្រើប្រាស់ដោយពេញលេញ និងដោយមានប្រសិទ្ធិភាពនូវសិទ្ធិគ្មានការបែងចែកឋានៈ និងមានភាពស្មើគ្នាចំពោះមុខច្បាប់
- ទទួលចំណេះដឹងប្រវត្តិសាស្ត្រ ប្រពៃណី ភាសា និងវប្បធម៌ដែលមានក្នុងដែនដីរបស់គេ
- មានឱកាសគ្រប់គ្រាន់ក្នុងការរៀនសូត្រ

## ៤. ជីវភាពរស់នៅនិងវប្បធម៌ជនជាតិដើមភាគតិច

ជនជាតិភាគតិចអំបូរមនខ្មែរដែលរស់នៅលើទឹកដីកម្ពុជាច្រើនរស់នៅតាមតំបន់ភ្នំ។ ពួកគេជួបការលំបាកក្នុង ការធ្វើដំណើរដោយសារគ្មានផ្លូវគមនាគមន៍។ ពួកគេនិយមដាំស្រូវ ពោត សណ្តែកលើចង្កេះភ្នំ ក្រៅពីនេះពួកគេប្រកបរបររ ខ្លឹមចន្ទន៍ បេះក្រវាញ និងប្រមាញ់ផងដែរ។ ពួកគេរស់នៅដោយរក្សាជំនឿ តាំងពីដូនតាដោយជឿលើបារមីនៃអ្នកតា និងជំនឿលើវត្ថុសក្តិសិទ្ធិ។ គេរស់នៅ ប្រកាន់ខ្ជាប់នូវសីលធម៌ ស្មោះត្រង់ និងមិនសូវឈ្លោះទាស់ទែងគ្នាទេ។

## ៥. តម្រូវការរបស់ជនជាតិភាគតិចនិងការឆ្លើយតបរបស់រដ្ឋាភិបាល

ក្នុងការឆ្លើយតបនឹងតម្រូវការរបស់ជនជាតិភាគតិច រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានរៀបចំគោលនយោបាយដូចតទៅ៖

- លុបបំបាត់ភាពរើសអើងនិងបង្កើតការចូលរួមពីជនជាតិភាគតិចក្នុងការធ្វើផែនការថ្នាក់ជាតិ និងមូលដ្ឋាន
- ជំរុញអោយមានការចូលរួមពេញលេញនិងមានប្រសិទ្ធិភាពពីជនជាតិភាគតិចក្នុងការសម្រេចចិត្ត
- កំណត់គោលនយោបាយអភិវឌ្ឍស្របតាមវប្បធម៌ ប្រពៃណីជំនឿ និងភាសារបស់ពួកគេ

- លើកទឹកចិត្តអោយមានការបកប្រែភាសាជនជាតិភាគតិចពេលមានការជម្រះក្តីក្នុងតុលាការ
- ជំរុញការអប់រំ ថែទាំសុខភាពនិងអនាម័យ និងបង្កើនការយល់ដឹងពីគោលនយោបាយរដ្ឋាភិបាល
- ទទួលស្គាល់ការប្រើប្រាស់ដីជាលក្ខណៈសមូហភាព
- ជំរុញអោយមានសេវាទេសចរណ៍ក្នុងសហគមន៍ជនជាតិភាគតិច
- ខិតខំរកជំនួយដើម្បីអភិវឌ្ឍពិសេសស្ត្រី និងកុមារ និងលើកកម្ពស់កំរិតជីវភាពគ្រួសារ
- បង្កើនសេវាកម្មផ្នែកសុខាភិបាល និងពិនិត្យការប្រើប្រាស់ថ្នាំបុរាណរបស់ពួកគេ
- ជំរុញការអប់រំថែទាំងសុខភាព អនាម័យ ផ្គត់ផ្គង់ទឹកស្អាត ការអប់រំនិងការផ្លាស់ប្តូរទម្លាប់ផ្នែកកសិកម្ម និងផ្នែកផ្សេងៗទៀត

**សំណួរ៖**

១. តើជនជាតិភាគតិចនៅកម្ពុជាមានអ្វីខ្លះ? តើពួកគេរស់នៅ និងប្រកបរបរចិញ្ចឹមជីវិតដូចម្តេច?

២. តើជនជាតិភាគតិចមានសិទ្ធិដូចម្តេចខ្លះ?

៣. តើរដ្ឋាភិបាលធ្វើដូចម្តេចដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ជនជាតិ?

៤. តើអ្នកមានអារម្មណ៍យ៉ាងណានៅពេលឃើញជនជាតិផ្សេងៗរស់នៅលើទឹកដីរបស់អ្នក?

៥. តើវត្តមាននៃជនជាតិផ្សេងៗនៅលើទឹកដីនៃប្រទេសណាមួយផ្តល់នូវគុណសម្បត្តិនិងគុណវិបត្តិដូចម្តេចខ្លះ?

# ផ្នែកទី២៖ ការអប់រំសិទ្ធិមនុស្ស

ផ្នែកទី២ ផ្តោតសំខាន់លើការអប់រំសិទ្ធិ បរិបទ និងនិយមន័យនៃការអប់រំសិទ្ធិមនុស្ស កម្មវិធីពិភពលោកសម្រាប់ការអប់រំសិទ្ធិមនុស្ស ការអប់រំសិទ្ធិមនុស្សនៅសហរដ្ឋអាមេរិច ទស្សវត្សរ៍អង្គការសហប្រជាជាតិ សម្រាប់ការអប់រំសិទ្ធិមនុស្ស សិទ្ធិមនុស្សក្នុងបរិបទនៃប្រទេសកម្ពុជា។

**ក.វត្ថុបំណងមេរៀន៖** ក្រោយពីបញ្ចប់ការសិក្សាមេរៀននេះ អ្នកសិក្សានឹង៖

| | |
|---|---|
| **វិជ្ជាសម្បទា/ពុទ្ធិ៖** | - យល់ដឹងអំពីសិទ្ធិមនុស្សដែលមានចែងនៅក្នុង សន្ធិសញ្ញាជាតិ និងអន្តរជាតិនិងសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ |
| **បំណិនសម្បទា/ចិត្តសង្គម៖** | - ប្រើប្រាស់សិទ្ធិមនុស្សស្របតាមសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សនៅក្នុងបរិបទកម្ពុជាក៏ដូចជានៅក្នុងតំបន់ និងពិភពលោក |
| **ចរិយាសម្បទា/ឥរិយាបថ៖** | - ស្រលាញ់ ចូលចិត្ត គោរពសិទ្ធិមនុស្ស តម្លៃមនុស្ស តម្លៃសង្គម និងវប្បធម៌នានាក្នុងនាមជាមនុស្សជាតិរបស់ភពផែនដីតែមួយ |

**ខ.វិធីសាស្ត្របង្រៀន៖** សិស្សមជ្ឈមណ្ឌល បែបពិភាក្សា និងការងារក្រុម

**គ.សម្ភារៈឧបទ្ទេស៖** មេរៀនស្តីពីការអប់រំសិទ្ធិមនុស្សដែលរៀបចំដោយក្រុមការងារ GCED នៃវិទ្យាស្ថានជាតិអប់រំ និងឯកសារយោងដែលពាក់ព័ន្ធ..

## ១. សេចក្តីផ្តើម

សព្វថ្ងៃនេះ ពិភពលោករបស់យើងកំពុងប្រឈមមុខនឹងជម្លោះជាច្រើននៅក្នុងទ្វីបមួយចំនួន ជាពិសេសនៅទ្វីបអាហ្វ្រិក ដែលការប្រល័យពូជសាសន៍ និងសង្គ្រាមកុលសម្ព័ន្ធ និងជនជាតិភាគតិចតែងតែគំរាមកំហែងដល់សន្តិភាព និងស្ថិរភាពនៃប្រជាជាតិទាំងអស់។ ហេតុដល់ទីបញ្ចប់ វាហាក់ដូចជាចាំបាច់កាន់តែខ្លាំងឡើងក្នុងការបង្កើតយន្តការសម្រាប់ការលើកកម្ពស់សន្តិភាពនៅក្នុងតំបន់ ECOWAS[1]។ ដើម្បីសម្រេចបាននូវគោលបំណងនេះ វាជាកត្តាចាំបាច់ក្នុងការរៀបចំទំនាក់ទំនងឡើងវិញជាមួយរដ្ឋ និងក្នុងចំណោមប្រទេសដទៃទៀត ដើម្បីធានាបាននូវការការពារសិទ្ធិ

[1] សហគមន៍សេដ្ឋកិច្ចនៃរដ្ឋអាហ្វ្រិកខាងលិចគឺជាសហភាពនយោបាយ និងសេដ្ឋកិច្ចក្នុងតំបន់ដែលមានដប់ប្រាំប្រទេស និងមានទីតាំង នៅ អាហ្វ្រិកខាងលិច។ សរុបមក ប្រទេសទាំងនេះមានផ្ទៃដី 5,114,162 គីឡូម៉ែត្រការ៉េ ហើយនៅឆ្នាំ 2015 មានប្រជាជនប៉ាន់ស្មានជាង 349 លាននាក់ ( https://en.wikipedia.org/wiki/Economic_Community_of_West_African_States )។

មនុស្សកាន់តែខ្លាំងឡើង។

## ២. ខ្លឹមសារមេរៀន

**២.១. បរិបទ និងនិយមន័យនៃការអប់រំសិទ្ធិមនុស្ស៖** សហគមន៍អន្តរជាតិ បានសម្តែងការយល់ស្រប កាន់តែខ្លាំងឡើងលើការរួមចំណែកជាមូលដ្ឋាននៃការអប់រំសិទ្ធិមនុស្ស ដល់ការអនុវត្តសិទ្ធិមនុស្ស។ ការអប់រំសិទ្ធិមនុស្សមានគោលបំណងអភិវឌ្ឍការយល់ដឹងអំពីទំនួលខុសត្រូវរួមរបស់យើងក្នុងការធ្វើឱ្យសិទ្ធិមនុស្សក្លាយជាការពិតនៅក្នុងគ្រប់សហគមន៍ និងក្នុងសង្គមទាំងមូល។ ក្នុងន័យនេះ វារួមចំណែកដល់ការទប់ស្កាត់នៃការរំលោភសិទ្ធិមនុស្សយូរអង្វែង និងជម្លោះដោយហិង្សា ការលើកកម្ពស់សមភាព និងការអភិវឌ្ឍប្រកបដោយចីរភាព និងលើកកម្ពស់ការចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តក្នុងប្រព័ន្ធប្រជាធិបតេយ្យ (Irina Bokova, Navanethem Pillay, 2012)[1]។ លទ្ធផលសិក្សាសិទ្ធិមនុស្សមានគោលបំណងកសាងសមត្ថភាពអ្នកចូលរួមដូចតទៅ៖

- ស្វែងយល់អំពីសិទ្ធិមនុស្ស។
- យល់ដឹងថាមនុស្សគ្រប់រូបមានសិទ្ធិមនុស្ស។
- ដឹងថា តើសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សជាអ្វី និងសិទ្ធិអ្វីខ្លះដែលវាមាន។
- ស្វែងយល់ពីមូលហេតុដែលវាមានសារៈសំខាន់ក្នុងការដឹងអំពីសិទ្ធិរបស់ពួកគេ។
- យល់ថាសិទ្ធិមនុស្សមានទំនាក់ទំនងគ្នាហើយសិទ្ធិមនុស្សទាំងអស់ត្រូវតែគោរពជាចាំបាច់។
- យល់ថារដ្ឋាភិបាលមានកាតព្វកិច្ចគោរព និងការពារសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋ។
- ដឹងថាសិទ្ធិមនុស្សនិងកាតព្វកិច្ចរដ្ឋាភិបាលត្រូវបានទទួលស្គាល់ក្នុងច្បាប់អន្តរជាតិនិងច្បាប់កម្ពុជា

**២.១.១. កម្មវិធីពិភពលោកសម្រាប់ការអប់រំសិទ្ធិមនុស្ស៖** នៅថ្ងៃ១០ធ្នូ២០០៤មហាសន្និបាតអង្គការសហប្រជាជាតិបានប្រកាសកម្មវិធីពិភពលោក សម្រាប់ការអប់រំសិទ្ធិមនុស្ស (២០០៥-កំពុងបន្ត) ដើម្បីជំរុញការអនុវត្តកម្មវិធីអប់រំសិទ្ធិមនុស្សលើគ្រប់វិស័យ។ ការកសាងមូលដ្ឋានគ្រឹះដែលបានដាក់ចេញក្នុងអំឡុងទសវត្សរ៍ នៃអង្គការសហប្រជា ជាតិសម្រាប់ការអប់រំសិទ្ធិមនុស្ស(1995-2004)។ កម្មវិធីពិភពលោកបានខិតខំប្រឹងប្រែងដើម្បីកំណត់ស្តង់ដារដាក់លាក់ថ្មីមួយពោលគឺការអភិវឌ្ឍសេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិ ស្តីពីការអប់រំសិទ្ធិមនុស្សនិងការបណ្តុះបណ្តាល ដោយមានការឆ្លុះបញ្ចាំង និងការទទួលស្គាល់ពីសហគមន៍អន្តរជាតិកាន់តែខ្លាំងឡើងថា ការអប់រំសិទ្ធិមនុស្សអាចទទួលបានលទ្ធផលយ៉ាងទូលំទូលាយ។ តាមរយៈការលើកកម្ពស់ការគោរពសេចក្តីថ្លៃថ្នូររបស់មនុស្ស និងសមភាព និងការចូលរួមធ្វើការសម្រេចចិត្តតាមបែបប្រជាធិបតេយ្យ ការអប់រំសិទ្ធិមនុស្សរួមចំណែកទប់

ស្កាត់ការរំលោភបំពាន និងជម្លោះដោយហិង្សាយូរអង្វែង។ ដើម្បីធ្វើឱ្យសិទ្ធិមនុស្សក្លាយជាការពិតនៅក្នុងសហគមន៍នីមួយៗ។

កម្មវិធីពិភពលោកស្វែងរកការលើកកម្ពស់ការយល់ដឹងទូទៅអំពីគោលការណ៍ និងវិធីសាស្ត្រជា មូលដ្ឋាននៃការអប់រំសិទ្ធិមនុស្ស ផ្តល់ក្របខ័ណ្ឌសកម្មភាពជាក់ស្តែង និងពង្រឹងភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការពីកម្រិតអន្តរជាតិរហូតដល់មូលដ្ឋាន។ មិនដូចពេលវេលាកំណត់នៃទសវត្សរ៍អង្គការសហប្រជាជាតិសម្រាប់ការអប់រំសិទ្ធិមនុស្ស (1995-2004)។ កម្មវិធីពិភពលោកគឺបើកចំហរ ហើយរចនាសម្ព័ន្ធត្រូវ បានរៀបចំឡើងជាដំណាក់កាលបន្តបន្ទាប់ក្នុងនោះដំណាក់កាលដំបូងគ្របដណ្តប់រយៈពេលពី 2005-2009 និងផ្តោតលើប្រព័ន្ធបឋមសិក្សា និងមធ្យមសិក្សា។ ទោះបីជនគោលដៅបានផ្លាស់ប្តូរតាំងពីឆ្នាំ 2010 ក៏ដោយក៏ក្រុមប្រឹក្សាសិទ្ធិមនុស្សបានលើកទឹកចិត្តរដ្ឋឱ្យបន្តការអនុវត្តការអប់រំសិទ្ធិមនុស្សនៅក្នុងប្រព័ន្ធសាលាបឋមសិក្សា និងមធ្យមសិក្សា (Irina Bokova, Navanethem Pillay, 2012)[2] ។

- សិទ្ធិមនុស្សត្រូវបានកាន់កាប់ដោយមនុស្សគ្រប់រូប ដោយស្មើភាព សកល និងជារៀងរហូត
- សិទ្ធិមនុស្សមានលក្ខណៈជាសកលៈ មនុស្សគ្រប់រូបមានលក្ខណៈដូចគ្នានៅគ្រប់ទីកន្លែងក្នុងពិភពលោក។ អ្នកមិនមានសិទ្ធិមនុស្ស ព្រោះអ្នកជាពលរដ្ឋនៃប្រទេសណាមួយ ប៉ុន្តែព្រោះតែអ្នកជាសមាជិកនៃគ្រួសារមនុស្ស។ នេះមានន័យថា កុមារមានសិទ្ធិមនុស្សក៏ដូចជាមនុស្សពេញវ័យដែរ។
- សិទ្ធិមនុស្សមិនអាចកាត់ផ្តាច់បានទេៈអ្នកមិនអាចបាត់បង់សិទ្ធិទាំងនេះណាមួយឡើយ ហើយអ្នកមិនអាចឈប់ធ្វើជាមនុស្សបានទេ។
- សិទ្ធិមនុស្សគឺមិនអាចបំបែកបានៈគ្មាននរណាម្នាក់អាចដកហូតសិទ្ធិបានទេព្រោះវា'មិនសូវសំខាន់' ឬ 'មិនសំខាន់' ។
- សិទ្ធិមនុស្សគឺអាស្រ័យគ្នាទៅវិញទៅមកៈ សិទ្ធិមនុស្សរួមគ្នាបង្កើតក្របខ័ណ្ឌបំពេញបន្ថែម។ ជាឧទាហរណ៍អ្នកមានសមត្ថភាពក្នុងការចូលរួមធ្វើសេចក្តីសម្រេចចិត្តក្នុងមូលដ្ឋានដោយផ្ទាល់ មានសិទ្ធិបញ្ចេញមតិ មានសិទ្ធិធ្វើទំនាក់ទំនងជាមួយអ្នកដទៃដើម្បីទទួលបានការអប់រំ និងទទួលបានតម្រូវការចាំបាច់ក្នុងជីវិត។
- សិទ្ធិមនុស្សឆ្លុះបញ្ចាំងពីតម្រូវការជាមូលដ្ឋានរបស់មនុស្ស។ គេបង្កើតស្តង់ដារជាមូលដ្ឋាននេះដោយគ្មានមនុស្សណាម្នាក់អាចរស់នៅដោយគ្មានភាពថ្លៃថ្នូរបានទេ។ ការរំលោភសិទ្ធិមនុស្សរបស់នរណាម្នាក់គឺត្រូវចាត់ទុកបុគ្គលនោះហាក់ដូចជាគាត់មិនមែនជាមនុស្ស។ ការតស៊ូមតិស្តីពីសិទ្ធិមនុស្សគឺទាមទារឱ្យមានការគោរពសេចក្តីថ្លៃថ្នូររបស់មនុស្សទាំងអស់។

- ក្នុងការទាមទារសិទ្ធិមនុស្សៗគ្រប់រូបក៏ត្រូវមានការទំនួលខុសត្រូវនេះផងដែរ៖ គោរពសិទ្ធិអ្នកដទៃការពារ និងគាំទ្រមនុស្ស ដែលសិទ្ធិត្រូវបានរំលោភបំពាន ឬបដិសេធ។ ការបំពេញទំនួលខុសត្រូវទាំងនេះមានន័យថាទាមទារឱ្យមានសាមគ្គីភាពជាមួយមនុស្សទាំងអស់ផ្សេងទៀត [3] (Compasito)

## ២.១.២. សិទ្ធិមនុស្សជាអ្វី

សិទ្ធិមនុស្សគឺជាសិទ្ធិរបស់បុគ្គលគ្រប់រូប ទាំងបុរសឬស្ត្រី ក្មេងស្រីឬក្មេងប្រុស ទារកឬមនុស្សចាស់ ពីព្រោះនាងឬគាត់គឺជាមនុស្សជាតិ។ ពួកគេតំណាងឱ្យស្តង់ដារមូលដ្ឋាន ដោយគ្មានមនុស្សណាម្នាក់មិនអាចដឹងពីសេចក្តីថ្លៃថ្នូររបស់ពួកគេពីកំណើតបានឡើយ។

- **សិទ្ធិមនុស្សមានលក្ខណៈជាសកល៖** ពួកគេមានសិទ្ធិពីកំណើតក្នុងមាន ជាសមាជិកនៃគ្រួសារ មនុស្សគ្រប់គ្នា។ គ្មាននរណាម្នាក់ត្រូវបានគេកេងចំណេញ រកប្រាក់ចំណូល ឬពីភាពជាមនុស្សរបស់គាត់បានឡើយ។
- **សិទ្ធិមនុស្សគឺមិនអាចកាត់ផ្តាច់បាន៖** អ្នកមិនអាចបាត់បង់សិទ្ធិទាំងនេះលើសពីអ្នក អាចឈប់ធ្វើជាមនុស្សបានទេ។
- **សិទ្ធិមនុស្សគឺមិនអាចបំបែកបាន៖** អ្នកមិនអាចត្រូវបានបដិសេធសិទ្ធិ ដោយសារនរណាម្នាក់សម្រេចចិត្តថាវា "សំខាន់តិច" ឬ "មិនសំខាន់"ទេ។
- **សិទ្ធិមនុស្សគឺអាស្រ័យគ្នាទៅវិញទៅមក៖** សិទ្ធិមនុស្សទាំងអស់គឺជាផ្នែក មួយនៃក្របខ័ណ្ឌបំពេញបន្ថែម។ ដោយសារតែសិទ្ធិមនុស្សមិនត្រូវបានផ្តល់ឱ្យដោយអាជ្ញាធរណាមួយ ដូចជាព្រះមហាក្សត្រ រដ្ឋាភិបាល ឬគ្រហស្ថ ឬអាជ្ញាធរខាងសាសនា។ ពួកគេមានលក្ខណៈមិនដូចគ្នាទៅនឹងសិទ្ធិស៊ីវិល ដូចជានៅក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់របស់សហរដ្ឋអាមេរិកនោះទេ។ សិទ្ធិរដ្ឋធម្មនុញ្ញត្រូវបានផ្តល់ដល់បុគ្គល មានគុណធម៌ក្នុងភាពជាពលរដ្ឋ ឬអ្នកដែលមានលំនៅដ្ឋានក្នុងប្រទេសមួយជាក់លាក់ ចំណែកឯសិទ្ធិមនុស្សគឺមាននៅក្នុង និងចាត់ទុកជាលក្ខណៈនៃបុគ្គលិកលក្ខណៈរបស់មនុស្ស។ សិទ្ធិមនុស្សមានទាំងអរូបី និងប្រតិបត្តិជាក់ស្តែង។ លក្ខខណៈទាំងពីរនេះវារក្សាចក្ខុវិស័យសេរីភាពខាងគំនិត យុត្តិធម៌ និងសន្តិភាព ហើយវាកំណត់ស្តង់ដារអប្បបរមាសម្រាប់របៀបដែលបុគ្គល និងស្ថាប័នគួរប្រព្រឹត្តចំពោះមនុស្ស។ ពួកគេត្រូវផ្តល់សិទ្ធិអំណាចដល់មនុស្សក្នុងការធ្វើសកម្មភាពទៅតាមតម្រូវការ និងការពារសិទ្ធិរបស់គេនិងសិទ្ធិអ្នកដទៃ។ ទោះបីជាសិទ្ធិមនុស្សត្រូវបានកំណត់និងចងក្រងនៅក្នុងសតវត្សទី២០ក៏ដោយ ក៏តម្លៃ

សិទ្ធិ មនុស្សត្រូវបានចាក់ឫសនៅក្នុងស្មារតីអក្សរសិល្ប៍ តម្លៃប្រពៃណី និងការបង្រៀនសាសនា ស្ទើរតែគ្រប់វប្បធម៌។

- ឧទាហរណ៍៖ ព្រហ្មញ្ញសាសនា[2] ( Hindu Vedas ) ក្រមបាប៊ីឡូនហាំមូរ៉ាប៊ី[3] ( Babylonian Code of Hammurabi ) ព្រះគម្ពីរ[4] ( Bible ) គម្ពីគូរ៉ាន[5] ( Bible ( Koran ) និងសម្រង់សម្តីរបស់ខុងជឺ[6] ( Analects of Confucius ) បានឆ្លើយតមនឹងសំណួរអំពីកាតព្វកិច្ច សិទ្ធិ និងទំនួលខុសត្រូវរបស់មនុស្ស។ ប្រភពជនជាតិដើមអាមេរិក បានកសាង ក្រមសីលធម៌ និងយុត្តិធម៌ ដោយផ្អែលើក្រមច្បាប់របស់ពួក ( Inca[7] ) និង ( Aztec[8] ) និងរដ្ឋធម្មនុញ្ញរបស់ពួក Iroquois[9] ( Flowers Nancy, Bernbaum Marcia, Rudelius-Palmer Kristi, and Tolman Joel.2000 )[4]។

## ២.២. ការអប់រំសិទ្ធិមនុស្សជាអ្វី?

[2] Vedas គឺជាអត្ថបទសាសនាដ៏ធំមួយដែលមានដើមកំណើតនៅប្រទេសឥណ្ឌាបុរាណ។ សរសេរជាភាសាវេទសំស្ក្រឹត អត្ថបទទាំងនោះបង្កើត ជាស្រទាប់ចាស់បំផុតនៃអក្សរសិល្ប៍សំស្ក្រឹត និងគម្ពីរបុរាណបំផុតនៃសាសនាហិណ្ឌូ។ ព្រះវេស្សន្តរមាន ៤ គឺៈ រីគវេដា យុគវេឡ្ឍ សាមវេដា និងអតថាវេដា ( https://en.wikipedia.org/wiki/Vedas ) ។

[3] ក្រមច្បាប់ Hammurabi ដែលជាបណ្តុំនៃច្បាប់ចំនួន 282 បានបង្កើតស្តង់ដារសម្រាប់អន្តរកម្មពាណិជ្ជកម្ម និងកំណត់ការផាកពិន័យ និងការដាក់ទណ្ឌ កម្មដើម្បីបំពេញតាមតម្រូវការនៃយុត្តិធម៌។ ក្រមរបស់ Hammurabi ត្រូវបានឆ្លាក់លើថ្មខ្មៅដ៏ធំ រាងម្រាមដៃ ( សសរ ) ហើយត្រូវបានលួចដោយពួកឈ្លានពាន ហើយទីបំផុតត្រូវបានរកឃើញឡើងវិញនៅឆ្នាំ 1901( Wikipedia )។

[4] ព្រះគម្ពីរគឺជាបណ្តុំនៃអត្ថបទសាសនា ឬគម្ពីរដ៏ពិសិដ្ឋនៅក្នុងសាសនាគ្រីស្ត សាសនាយូដា សាសនាសាម៉ារី និងសាសនាជាច្រើនទៀត។ ព្រះគម្ពីរគឺជាការចងក្រងអត្ថបទនៃទម្រង់ផ្សេងៗគ្នាដែលត្រូវបានសរសេរពីដើមជាភាសាហេប្រឺ អារ៉ាមិក និងកូអ៊ីនក្រិច( Wikipedia )។

[5] គម្ពីគូរ៉ា ជាអត្ថបទសាសនាកណ្តាលនៃសាសនាឥស្លាម មានឯកសារយោងទៅកាន់មនុស្សជាងហាសិបនាក់ និងព្រឹត្តិការណ៍ដែលត្រូវបាន រកឃើញនៅក្នុងព្រះ គម្ពីរផងដែរ។ នៅពេលដែលរឿងរ៉ាវដែលបានប្រាប់នៅក្នុងសៀវភៅនីមួយៗជាទូទៅអាចប្រៀបធៀបបាន វាក៏មានភាពខុសគ្នាគួរឱ្យកត់សម្គាល់ មួយចំនួនផងដែរ។ ដោយដឹងថាកំណែដែលសរសេរនៅក្នុងព្រះគម្ពីរហេព្រើរ និងគម្ពីរសញ្ញាថ្មីរបស់គ្រិស្តបរិស័ទ កំណត់ទុកជាមុននូវគម្ពីគូរ៉ា គ្រីស្ទបរិស័ទបាន វែកញែកថា គម្ពីគូរ៉ាមានប្រភពមកដោយផ្ទាល់ ឬដោយប្រយោលពីឯកសារមុនៗ។ ប្រជាជនម៉ូស្លីមយល់ពីគម្ពីគូរ៉ាជាចំណេះដឹងពីព្រះដ៏មានអំណាច។ ដូច្នេះ ជាទូទៅប្រជាជនម៉ូស្លីមជឿថា កំណែមុនៗត្រូវបានបង្ខូចទ្រង់ទ្រាយតាមរយៈដំណើរការបញ្ជូន និងការបកស្រាយមិនត្រឹមត្រូវតាមពេលវេលា ហើយចាត់ទុកកំណែរបស់គម្ពីគូរ៉ាឱ្យមានភាពសុក្រឹតជាងមុន( https://en.wikipedia.org/wiki/Biblical_and_Quranic_narratives )។

[6] អធិប្បាយរបស់ខុងជឺ ពាក្យរបស់ខុងជឺ ឬ លន់ យូ គឺជាសៀវភៅបុរាណចិនមួយ ដែលផ្សំឡើងដោយបណ្តុំនៃពាក្យ និងគំនិតជាច្រើន ដែលសន្មតថាជាទស្សនវិទូចិន ខុងជឺ និងសហសម័យរបស់គាត់ ដែលតាមប្រពៃណីត្រូវបានចងក្រង និងសរសេរដោយអ្នកដើរតាម របស់ខុងជឺ ( https://en.wikipedia.org/wiki/Analects )។

[7] Incas មិនមានភាសាសរសេរទេ។ ផ្ទុយទៅវិញ គេបានវាប្រាស្រ័យទាក់ទងគ្នាដោយប្រើប្រព័ន្ធ knots នៅក្នុងខ្សែពណ៌ដែលហៅថា khipus។ រហូតមកដល់ពេលនេះ មនុស្សមានការយល់ដឹងតិចតួចអំពីអ្វីដែលហៅថា knot ទាំងនោះដែលគេកំពុងតែធ្វើទំនាក់ទំនងគ្នា។

[8] Aztec codices គឺជាសាត្រាស្លឹករឹត Mesoamerican ដែលធ្វើឡើងដោយ Pre-Columbian Aztec និងកូនចៅដែលនិយាយភាសា Nahuatl ក្នុងអំឡុងពេលអាណានិគមនៅម៉ិកស៊ិក។

[9] Iroquois ហៅជាផ្លូវការថា Haudenosaunee គឺជាសហព័ន្ធនិយាយភាសា Iroquoian នៃប្រជាជាតិដំបូងគេរស់ នៅភាគឦសាន អាមេរិកខាងជើង ឬកោះអណ្តើក។ ពួកគេត្រូវបានគេស្គាល់ក្នុងអំឡុងឆ្នាំអាណានិគម ហើយបារាំងថាជា សម្ព័ន្ធ Iroquois និងក្រោយ មកទៀតក្លាយជាក្រុម សហព័ន្ធ Iroquois។

ការអប់រំសិទ្ធិមនុស្សអាចត្រូវបានកំណត់ថាជាការអប់រំ ការបណ្តុះបណ្តាល និងព័ត៌មានដែលមានគោលបំណងកសាងវប្បធម៌សកលនៃសិទ្ធិមនុស្ស។ ការអប់រំសិទ្ធិមនុស្សប្រកបដោយប្រសិទ្ធភាពមិនត្រឹម តែផ្តល់ចំណេះដឹងអំពីសិទ្ធិមនុស្ស និងយន្តការការពារពួកគេប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអភិវឌ្ឍជំនាញ ដែលមនុស្សត្រូវការដើម្បីលើកកម្ពស់ការពារ និងអនុវត្តសិទ្ធិមនុស្សក្នុងជីវិតប្រចាំថ្ងៃ។ ការអប់រំសិទ្ធិមនុស្ស ក៏ជំរុញឥរិយាបថ និងអាកប្បកិរិយាដែលត្រូវការ ដើម្បីលើកកម្ពស់សិទ្ធិមនុស្ស សម្រាប់សមាជិកទាំងអស់របស់សង្គម។ សកម្មភាពអប់រំសិទ្ធិមនុស្សគួរតែបង្ហាញពីគោលការណ៍សិទ្ធិមនុស្សជាមូលដ្ឋាន ដូចជាសមភាព និងការមិនរើសអើង ដែលអាចបញ្ជាក់បានពីភាពអាស្រ័យគ្នាទៅវិញទៅមក ភាពមិនអាចកាត់ ផ្តាច់ពីគ្នាបាន និងសកលភាព។ ទន្ទឹមនឹងនេះ សកម្មភាពនានាគួរតែប្រតិបត្តិជាក់ស្តែង សិទ្ធិមនុស្សដែល ទាក់ទងទៅនឹងបទពិសោធន៍ជីវិតពិតរបស់អ្នកសិក្សា និងអាចធ្វើឱ្យពួកគេកសាងគោលការណ៍សិទ្ធិ មនុស្សដែលមាននៅក្នុងបរិបទវប្បធម៌របស់ពួកគេផ្ទាល់។ តាមរយៈសកម្មភាពបែបនេះ អ្នកសិក្សាត្រូវបានផ្តល់សិទ្ធិអំណាចក្នុងការកំណត់អត្តសញ្ញាណ និងកំណត់ពីតម្រូវការសិទ្ធិមនុស្សរបស់ពួកគេ និងស្វែងរកដំណោះស្រាយស្របតាមស្តង់ដារសិទ្ធិមនុស្ស។ ជាងនេះទៅទៀត សម្រាប់អ្នកដែលមានទំនួលខុសត្រូវក្នុងការគោរព ការពារ និងបំពេញសិទ្ធិអ្នកដទៃ ការអប់រំសិទ្ធិមនុស្ស ការអភិវឌ្ឍសមត្ថភាពរបស់ពួក គឺត្រូវធ្វើដូច្នេះ។ អ្វីទាំងអស់ដែលបានរៀន និងវិធីដែលបានរៀនគួរតែឆ្លុះបញ្ចាំងពីតម្លៃសិទ្ធិមនុស្ស លើកទឹកចិត្តឱ្យមានការចូលរួម និងជំរុញបរិយាកាសសិក្សាដោយសេរីពីអ្វីដែលចង់បាន និងការភ័យខ្លាច (Irina Bokova, Navanethem Pillay, 2012)[5] )។

ការអប់រំសិទ្ធិមនុស្សគឺជាការរៀនសូត្រដែលអភិវឌ្ឍចំណេះដឹង ជំនាញ និងតម្លៃនៃសិទ្ធិមនុស្ស។ មេរៀនប្រវត្តិសាស្ត្រស្តីពីចលនាបោះឆ្នោតរបស់ស្ត្រី ចលនាសិទ្ធិស៊ីវិល ឬអំពើសម្លាប់រង្គាលអាចជាមេរៀន សិទ្ធិមនុស្ស ប្រសិនបើគ្រូលើកទឹកចិត្តសិស្សឱ្យមើលឃើញគោលការណ៍ជាសកលនៃសេចក្តីថ្លៃថ្នូរ និងសមភាពនៅក្នុងព្រឹត្តិការណ៍ទាំងនេះ។ កិច្ចខិតខំប្រឹងប្រែងរបស់ក្រុមតស៊ូមតិដើម្បីដោះស្រាយបញ្ហានៃភាពអត់ឃ្លាននៅក្នុងសហគមន៍តាមរយៈការផ្សព្វផ្សាយ និងច្បាប់អាចក្លាយជាមេរៀនសិទ្ធិមនុស្ស។ ការផ្តល់ទី ជំរកដើម្បីការពារដល់ជនអនាថា ឬជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារក៏ត្រូវធ្វើការអប់រំទាំងអ្នកផ្តល់សេវា និងអ្នកដែលត្រូវការពួកគេផងដែរ។ ទីកន្លែងថែទាំប្រចាំថ្ងៃ ថ្នាក់រៀន ឬអង្គការមិនរកប្រាក់ចំណេញ ដែលលើកកម្ពស់ការគោរព យុត្តិធម៌ និងសេចក្តីថ្លៃថ្នូរ កំពុងតែបណ្តុះតម្លៃសិទ្ធិមនុស្ស បើទោះបីជាពួកគេ មិនត្រូវបានកំណត់អត្តសញ្ញាណបែបនេះក៏ដោយ(Flowers Nancy, Bernbaum Marcia, Rudelius-Palmer Kristi, and Tolman Joel.2000)[6]។

កិច្ចខិតខំប្រឹងប្រែងដើម្បីកំណត់លើការអប់រំសិទ្ធិមនុស្សក្នុងទសវត្សរ៍ឆ្នាំ1950 និង 60 បានសង្កត់ធ្ងន់លើការរៀន ការយល់ដឹងរបស់យុវជននៅក្នុងសាលាផ្លូវការ។ នៅទសវត្សរ៍ឆ្នាំ1970 អ្នកអប់រំភាគច្រើន បានពង្រីកគំនិតនេះ ដើម្បីរួមបញ្ចូលជំនាញការគិតប្រកបដោយការរិះគន់ និងការយកចិត្តទុកដាក់ ឬការយល់ចិត្តចំពោះអ្នកដែលធ្លាប់មានបទពិសោធន៍រំលោភសិទ្ធិរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ ការផ្តោតសំខាន់លើការអប់រំនៅតាមសាលារៀនសម្រាប់យុវជន មានការយកចិត្តទុកដាក់តិចតួច ឬមិនយកចិត្តទុកដាក់លើការទទួលខុសត្រូវ ឬសកម្មភាពផ្ទាល់ខ្លួនដើម្បីលើកកម្ពស់ និងការពារសិទ្ធិ ឬឥទ្ធិពលនៃការផ្លាស់ប្តូរសង្គម(Flowers Nancy, Bernbaum Marcia, Rudelius-Palmer Kristi, and Tolman Joel.2000)[7]

**២.២.១. សិទ្ធិយល់ដឹងអំពីសិទ្ធិរបស់អ្នក៖** អាណត្តិសម្រាប់ការអប់រំសិទ្ធិមនុស្សគឺមិនច្បាស់លាស់៖ អ្នកមានសិទ្ធិមនុស្សដើម្បីយល់ដឹងពីសិទ្ធិរបស់អ្នក។ បុព្វកថានៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (Universal Declaration of Human Rights) ហៅថា (UDHR) ដាស់តឿនថា "គ្រប់បុគ្គល និងគ្រប់សរីរាង្គនៃសង្គម" ត្រូវ "ខិតខំ ដោយការបង្រៀន និងការអប់រំដើម្បីលើកកម្ពស់ការគោរពសិទ្ធិ និងសេរីភាពទាំងនេះ"។ មាត្រា 30 នៃ UDHR ប្រកាសថា គោលដៅមួយនៃការអប់រំគួរតែជា "ការពង្រឹងការគោរពសិទ្ធិមនុស្ស និងសេរីភាព ជាមូលដ្ឋាន" ។ យោងតាមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) រដ្ឋាភិបាលមួយ "ប្រហែលជាមិនជ្រៀតជ្រែកទៅក្នុងវិធីនៃការរៀនសូត្ររបស់ប្រជាជនអំពី [សិទ្ធិរបស់ពួកគេ] នោះ ទេ"។

**២.២.២. ការអប់រំសិទ្ធិមនុស្សនៅសហរដ្ឋអាមេរិក៖** កាលពីមុន គេប្រើសិទ្ធិមនុស្សនៅតែក្នុងសាលារៀនតែប៉ុណ្ណោះ ដោយប្រទេសជាច្រើនបានបង្កើតសិទ្ធិមនុស្សជាធាតុផ្សំដ៏សំខាន់នៃកម្មវិធីសិក្សារបស់សាលារៀនកាលពីទសវត្សរ៍មុន ។ ជាលទ្ធផល ប្រជាជនបច្ចុប្បន្នមានការយល់ដឹងខ្ពស់អំពីសិទ្ធិមនុស្ស។ ទោះយ៉ាងណាក៏ដោយ នៅសហរដ្ឋអាមេរិក ការអប់រំសិទ្ធិមនុស្សនៅតែស្ថិតក្នុងដំណាក់កាលដំបូងនៅឡើយ។ ទោះបីជាស្ទើរតែគ្រប់វិទ្យាល័យទាំងអស់នៅក្នុងប្រទេសតម្រូវឱ្យមានវគ្គសិក្សាស្តីពីរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក និងច្បាប់ស្តីពីសិទ្ធិក៏ដោយ ក៏នៅតែមានមនុស្សតិចណាស់ដែលសិក្សាសិទ្ធិមនុស្សនៅក្នុងសាលារៀន ឬនៅសាកលវិទ្យាល័យ ឬកម្រិតថ្នាក់បញ្ចប់មហាវិទ្យាល័យក្តី។

ក្រុមប្រឹក្សាជាតិសម្រាប់ការសិក្សាសង្គម (National Council for the Social Studies) ហៅកាត់ ថា(NCSS) បាននាំយកការអប់រំសិទ្ធិមនុស្សសម្រាប់ថ្នាក់ជាតិលើកដំបូងនៅក្នុងខែកញ្ញា ឆ្នាំ1985 ជា មួយនឹងបញ្ហាជាមូលដ្ឋាននៃការ

អប់រំសង្គម ដើម្បីឧទ្ទិសដល់ប្រធានបទសិទ្ធិមនុស្ស។ អត្ថបទនានា បានសង្កត់ធ្ងន់ទៅលើប្រធានបទសិក្សាសង្គម ប្រពៃណីនៃវិមាត្រសិទ្ធិមនុស្សដូចជាចលនាសិទ្ធិស៊ីវិលការសម្លាប់រង្គាល និងចលនារំដោះជាតិ។ នៅក្នុងអត្ថបទដ៏មានឥទ្ធិពលមួយ "សិទ្ធិមនុស្ស៖ ជាផ្នែកសំខាន់មួយនៃកម្មវិធីសិក្សាសង្គម" ដោយលោកស្រី Carole L. Hahn ជាប្រធានក្រុមប្រឹក្សាជាតិ សម្រាប់ការសិក្សាសង្គមរបស់ NCSS បានជជែកវែកញែកអំពីទស្សនៈពិភពលោក និងអាកប្បកិរិយាប្រជាធិបតេយ្យ ដែល ជំរុញឱ្យមានការអប់រំសិទ្ធិមនុស្ស។

ក្នុងឆ្នាំដដែល អង្គការលើកលែងទោសអន្តរជាតិសហរដ្ឋអាមេរិច (Amnesty International USA) បានរៀបចំបណ្តាញអ្នកអប់រំសិទ្ធិមនុស្សរបស់ខ្លួន ហើយនៅឆ្នាំ1989 បានចាប់ផ្តើមបង្កើតការអប់រំសិទ្ធិមនុស្ស៖ ការប្រជុំអំពីការអប់រំសិទ្ធិមនុស្សទាំង៤[10] បោះផ្សាយដោយទស្សនាវដ្តីអាមេរិក។ នៅឆ្នាំ1991 បណ្តាញអ្នកអប់រំសិទ្ធិមនុស្សនៃអង្គការលើកលែងទោសអន្តរជាតិសហរដ្ឋអាមេរិក បានបោះពុម្ពផ្សាយ និយមន័យសម្រាប់ការអប់រំសិទ្ធិមនុស្សដោយឆ្លុះបញ្ចាំងពីការពង្រីកនិយមន័យនៃវិស័យនេះ។ ការអប់រំ សិទ្ធិមនុស្សប្រកាសពីការប្តេជ្ញាចិត្តចំពោះសិទ្ធិមនុស្សទាំងនោះ ដោយមានចែងក្នុងសេចក្តីប្រកាសជាសក លស្តីពីសិទ្ធិមនុស្សឆ្នាំ១៩៤៨ កតិកាសញ្ញាអង្គការសហប្រជាជាតិ និងច្បាប់ស្តីពីសិទ្ធិរបស់សហរដ្ឋអាមេរិក។ នៅក្នុងប្រកាសទាំងនោះវាអះអាងនូវទំនួលខុសត្រូវ ក្នុងការគោរព ការពារ និងលើកកម្ពស់សិទ្ធិ របស់ប្រជាជនទាំងអស់។

- ការអប់រំសិទ្ធិមនុស្សលើកកម្ពស់គោលការណ៍ប្រជាធិបតេយ្យ។ វាពិនិត្យបញ្ហាសិទ្ធិមនុស្ស ដោយមិនឱ្យមានភាពលំអៀង និងដកចេញពីទស្សនវិស័យនានាតាមរយៈការប្រតិបត្តិការអប់រំផ្សេងៗ។
- ការអប់រំសិទ្ធិមនុស្សជួយអភិវឌ្ឍជំនាញទំនាក់ទំនង និងការត្រិះរិះពិចារណាប្រកបដោយ ការយល់ដឹងអំពីលទ្ធិប្រជាធិបតេយ្យជាសំខាន់។ វាផ្តល់នូវទស្សនវិស័យពហុវប្បធម៌ និងប្រវត្តិសាស្ត្រ ស្តីពីខិតខំជាសកលដើម្បីយុត្តិធម៌ និងសេចក្តីថ្លៃថ្នូរ។
- ការអប់រំសិទ្ធិមនុស្សចងភ្ជាប់វាង ចិត្ត និងបេះដូង។ វាក៏ជំរុញសិស្សឱ្យសួរថា តើសិទ្ធិមនុស្ស មានន័យយ៉ាងណាចំពោះពួកគេផ្ទាល់ ហើយលើកទឹកចិត្តពួកគេឱ្យបកប្រែការយកចិត្តទុកដាក់ទៅជាព័ត៌មាន និងទៅជាសកម្មភាពអហិង្សាដូចម្តេចឬរបៀបណា។
- ការអប់រំសិទ្ធិមនុស្សបញ្ជាក់ពីការពឹងពាក់គ្នាទៅវិញទៅមកក្នុងគ្រួសារមនុស្ស។ វាលើកកម្ពស់ការយល់ដឹងអំពីកងកម្លាំងរបស់ពិភពលោកដ៏ស្មុគស្មាញដែលបង្កើតឱ្យមានការរំលោភបំពាន ក៏ដូចជាលុបបំបាត់វិធីរំលោភបំពាននានា និងត្រូវជៀសវាងផងដែរ។

[10] សិទ្ធិមនុស្ស "4 R" ទាក់ទងជាមួយជនភៀសខ្លួនដូចជា ការធ្វើមាតុភូមិនិវត្តន៍(Repatriation) ការធ្វើសមាហរណកម្ម(Reintegration) ការស្តារនីតិសម្បទា(Rehabilitation) និងការកសាងឡើងវិញ(Reconstruction)

**២.២.៣. ទសវត្សរ៍អង្គការសហប្រជាជាតិសម្រាប់ការអប់រំសិទ្ធិមនុស្ស៖** ចាប់តាំងពីការអនុម័តសេចក្តីប្រកាសជាសកលមក មហាសន្និបាតអង្គការសហប្រជាជាតិ បានអំពាវនាវឱ្យរដ្ឋជាសមាជិក និងគ្រប់ផ្នែកនៃសង្គម ផ្សព្វផ្សាយ និងអប់រំអំពីឯកសារជាមូលដ្ឋាននេះ។ នៅឆ្នាំ1993 សន្និសីទពិភពលោកស្តីពីសិទ្ធិមនុស្សនៅទីក្រុងវីយែន បានអះអាងសារជាថ្មី អំពីសារៈសំខាន់នៃការអប់រំ ការបណ្តុះបណ្តាល និងព័ត៌មានសាធារណៈ អំពីសិទ្ធិមនុស្ស ដោយប្រកាសថាវា "មានសារៈ សំខាន់សម្រាប់ការលើកកម្ពស់ និងសមិទ្ធិផលនៃទំនាក់ទំនងស្ថិរភាព និងសុខដុមរមនាក្នុងចំណោមសហគមន៍ និងសម្រាប់ការលើកកម្ពស់ការយល់ដឹងពីគ្នាទៅវិញទៅមក ការអត់ឱន និងសន្តិភាព"។ ជាការឆ្លើយតបទៅនឹងការអំពាវនាវដោយសន្និសិទពិភពលោកនេះ មហាសន្និបាតបានប្រកាសរយៈពេលពីឆ្នាំ1995 ដល់ឆ្នាំ2004 ថាជាទសវត្សរ៍របស់អង្គការសហប្រជាជាតិសម្រាប់ការអប់រំសិទ្ធិមនុស្ស។

នៅក្នុងការប្រកាសអំពីទសវត្សរ៍អង្គការសហប្រជាជាតិសម្រាប់ការអប់រំសិទ្ធិមនុស្ស ក្នុងខែធ្នូ ឆ្នាំ1994 មហាសន្និបាតបានកំណត់ការអប់រំសិទ្ធិមនុស្សថា ជា"ដំណើរការពេញមួយជីវិតដែលមនុស្សគ្រប់កម្រិតត្រូវអភិវឌ្ឍ និងក្នុងគ្រប់ស្រទាប់នៃសង្គម ត្រូវរៀនគោរពសេចក្តីថ្លៃថ្នូររបស់អ្នកដទៃ ហើយមធ្យោបាយ និងវិធីសាស្ត្រនេះត្រូវធានាឱ្យបាននូវការគោរពនោះនៅក្នុងសង្គមទាំងអស់"។ សភាបានសង្កត់ធ្ងន់ថា ទំនួលខុសត្រូវសម្រាប់ការអប់រំសិទ្ធិមនុស្ស ស្ថិតនៅលើគ្រប់ផ្នែកនៃសង្គម ដូចជារដ្ឋាភិបាល អង្គការ មិនមែនរដ្ឋាភិបាល សមាគមវិជ្ជាជីវៈ និងគ្រប់វិស័យផ្សេងទៀតនៃសង្គមស៊ីវិល ព្រមទាំងបុគ្គល ផងដែរ។

ផែនការសកម្មភាពសម្រាប់ទសវត្សនេះ កំណត់បន្ថែមលើការអប់រំសិទ្ធិមនុស្សថា ជា "ការបណ្តុះបណ្តាល ការផ្សព្វផ្សាយ និងកិច្ចខិតខំប្រឹងប្រែងផ្នែកព័ត៌មាន សំដៅកសាងវប្បធម៌ជាសកលនៃសិទ្ធិមនុស្ស តាមរយៈការចែកចាយចំណេះដឹងនិងជំនាញ និងការបណ្តុះបណ្តាលអាកប្បកិរិយា ដោយផ្ទាល់ទៅលើ៖

1. ការពង្រឹងការគោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន។
2. ការអភិវឌ្ឍពេញលេញនៃបុគ្គលិកលក្ខណៈរបស់មនុស្ស និងស្មារតីនៃសេចក្តីថ្លៃថ្នូររបស់ខ្លួន
3. ការលើកកម្ពស់ការយល់ដឹង ការអត់ឱន សមភាពយេនឌ័រ និងមិត្តភាពក្នុងចំណោមប្រជាជាតិទាំងអស់ ជនជាតិដើមភាគតិច និងជាតិសាសន៍ ប្រជាជាតិ ជនជាតិ សាសនា និងភាសា
4. ការអនុញ្ញាតឱ្យមនុស្សទាំងអស់ចូលរួមក្នុងសង្គមដោយសេរីប្រកបដោយប្រសិទ្ធភាព។
5. ការបន្តសកម្មភាពរបស់អង្គការសហប្រជាជាតិសម្រាប់ការថែរក្សាសន្តិភាព"។

**២.២.៤. គោលដៅនៃការអប់រំសិទ្ធិមនុស្ស៖** ឯកសារសិទ្ធិមនុស្សអន្តរជាតិផ្តល់នូវគោលដៅក្នុងការបំផុសគំនិតសម្រាប់ការអប់រំសិទ្ធិមនុស្ស។ ជាឧទា ហរណ៍៖ ពាក្យដំបូងនៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) ប្រកាសថា "ការ ទទួលស្គាល់សេចក្តីថ្លៃថ្នូរពីកំ ណើត និងសិទ្ធិស្មើគ្នា និងមិនអាចកាត់ផ្តាច់បានរបស់សមាជិកទាំងអស់នៃ គ្រួសារមនុស្ស គឺជាមូលដ្ឋានគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពនៅក្នុងពិភពលោក"។ ទោះយ៉ាងណាក៏ដោយ ដើម្បីសម្រេចបាននូវសេរីភាព យុត្តិធម៌ និងសន្តិភាព មនុស្សក៏ត្រូវដោះស្រាយតម្រូវការសង្គម និងសេដ្ឋកិច្ចជាក់ស្តែងផងដែរ ដូចជាភាពក្រីក្រ និងការរើសអើង និងវិបត្តិនយោបាយ ដូចជាសង្គ្រាម និងការគាបសង្កត់នយោបាយជាដើម។ ដូច្នេះ ការអប់រំសិទ្ធិមនុស្សប្រកបដោយប្រសិទ្ធភាព មានគោលបំណង សំខាន់ពីរគឺ៖ រៀនអំពីសិទ្ធិមនុស្ស និងរៀនសម្រាប់សិទ្ធិមនុស្ស។

ការរៀនអំពីសិទ្ធិមនុស្សគឺជាការយល់ឃើញយ៉ាងទូលំទូលាយ រួមទាំងប្រវត្តិសាស្ត្រសិទ្ធិមនុស្ស ឯកសារ និងការអនុវត្តនៅយន្តការអ៊ីយ៉ុង។ ផ្នែកទាំងអស់នៃសង្គមត្រូវយល់អំពីបទប្បញ្ញត្តិរបស់ UDHR និង របៀបដែលស្តង់ដារអន្តរជាតិទាំងនេះប៉ះពាល់ដល់រដ្ឋាភិបាល និងបុគ្គល។ ពួកគេក៏ត្រូវយល់អំពី ភាពអា ស្រ័យគ្នាទៅវិញទៅមកនៃសិទ្ធិ ទាំងស៊ីវិល និងនយោបាយ និងសង្គម សេដ្ឋកិច្ច និងវប្បធម៌។ សិទ្ធិមនុស្ស គឺជា "4 R" ដែលទាក់ទងជាមួយជនភៀសខ្លួន ដូចជា ការធ្វើមាតុភូមិនិវត្តន៍ (Repatriation) ការធ្វើសមាហរណកម្ម (Reintegration) ការស្តារនីតិសម្បទា (Rehabilitation) និងការកសាងឡើងវិញ (Reconstruction) ដែលជាមូលដ្ឋានគ្រឹះនៃការអប់រំសំខាន់របស់មនុស្សគ្រប់រូប រួមទាំងការអាន ការសរសេរ និង"នព្វន្ទ" ជាដើម (Sajjad Malik, May 2003[11])។

## ២.៣. សិទ្ធិមនុស្សក្នុងបរិបទនៃប្រទេសកម្ពុជា

សិទ្ធិមនុស្សអនុញ្ញាតឱ្យមនុស្សរស់នៅប្រកបដោយសុភមង្គល សុខភាពល្អ និងមានសេរីភាព។ ក្នុងជីវិតប្រចាំថ្ងៃរបស់យើង យើងទាំងអស់គ្នាមានតម្រូវការជាមូលដ្ឋាន ដូចជាមានអាហារគ្រប់គ្រាន់សម្រាប់បរិភោគ ទឹកស្អាតសម្រាប់ផឹក និងទទួលបានការថែទាំសុខភាពនៅពេលយើងឈឺ។ យើងក៏ត្រូវការសេរីភាពជាមូលដ្ឋានមួយចំនួនផងដែរ ដូចជាសេរីភាពក្នុងការបញ្ចេញមតិ និងការអនុវត្តសាសនារបស់យើង។ ការទទួលបានរបស់ទាំងនេះ និងរីករាយនឹងសេរីភាពទាំងនេះ គឺជាសិទ្ធិជាមូលដ្ឋានរបស់យើងក្នុងនាមជាមនុស្ស។ មនុស្សគ្រប់រូបនៅគ្រប់ទីកន្លែង សុទ្ធតែមានសិទ្ធិមនុស្ស ទាំងបុរស ទាំងស្ត្រី ក្មេងទាំង ចាស់ អ្នកមាននិងអ្នកក្រ មិនថាពួកគេកើតនៅទីណា ឬពួកគេជឿអ្វី

[11] Framework for Durable Solutions for Refugees and Persons of Concern, Core Group on Durable Solutions UNHCR Geneva, May 2003

នោះទេ។ សិទ្ធិទាំងនេះមិនអាច ដក ចេញពីយើងបានទេ ហើយត្រូវតែគោរពគ្រប់ពេលវេលា (Natalie Bugalski, 2011)[8]។

**២.៣.១. តើសិទ្ធិមនុស្សចេញមកពីណា?**

សិទ្ធិមនុស្សកើតចេញពីតម្លៃរួមនៃវប្បធម៌ និងសហគមន៍ជុំវិញពិភពលោក។ តម្លៃទាំងនេះបាន អភិវឌ្ឍនៅក្នុងសង្គម និងប្រទេសផ្សេងៗគ្នា ដោយសារមនុស្សភាគច្រើននៅជុំវិញពិភពលោកជឿថាពួកគេ និងមនុស្សជុំវិញខ្លួនគួរតែត្រូវបានគេគោរព។

ជាអកុសល នៅទូទាំងប្រវត្តិសាស្ត្រ មនុស្សបានជួបប្រទះ ឬបានឃើញទុក្ខវេទនាដ៏គួរឱ្យភ័យខ្លាច ដែលជារឿយៗបណ្តាលមកពីការប្រព្រឹត្តអាក្រក់ ពីសំណាក់រដ្ឋាភិបាលឃោឃៅ និងមនុស្សផ្សេងទៀតយ៉ាងខ្លាំង។ មនុស្សជាច្រើនបានឆ្លងកាត់សង្គ្រាម និងអំពើហឹង្សា នៅក្រោមរដ្ឋាភិបាលដែលគាបសង្កត់ និងឃោរឃៅ ឬមិនមានអាហារគ្រប់គ្រាន់សម្រាប់បរិភោគ ឬការថែទាំសុខភាពនៅពេលពួកគេឈឺ។ **ឧទាហរណ៍៖ ប្រជាជនកម្ពុជាដែលបានឆ្លងកាត់សម័យកម្ពុជាប្រជាធិបតេយ្យចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ បានជួបប្រទះនូវរបបដ៏ឃោរឃៅបំផុតមួយក្នុងសតវត្សរ៍ចុងក្រោយនេះ។** នៅក្រោមរបបប៉ុល ពត មនុស្សជាង១,៥លាននាក់ ត្រូវបានសម្លាប់ ធ្វើទារុណកម្ម អត់ឃ្លាន និងធ្វើការរហូតដល់ស្លាប់។ ព្រឹត្តិការណ៍ និងបទពិសោធន៍ទាំងនេះបានធ្វើឱ្យមនុស្សកាន់តែជឿជាក់ថែមទៀតថា ច្បាប់ត្រូវតែមានដើម្បីទប់ស្កាត់ការប្រព្រឹត្តអាក្រក់របស់មនុស្សជាតិនេះ។

**២.៣.២. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស៖** អង្គការសហប្រជាជាតិ គឺជាអង្គការអន្តរជាតិមួយដែលបង្កើតឡើងដោយរដ្ឋភាគីជាច្រើននៃពិភពលោក។ គោលបំណងរបស់វាគឺដើម្បីសម្រេចបាននូវសន្តិភាពពិភពលោក តាមរយៈការទប់ស្កាត់ជម្លោះ ការលើកកម្ពស់សិទ្ធិមនុស្ស និងជួយដល់ការអភិវឌ្ឍសេដ្ឋកិច្ច(Natalie Bugalski, 2011)[6]។

នៅឆ្នាំ1948 អ្នកតំណាងមកពីរដ្ឋជាច្រើនបានមកជួបជុំគ្នានៅអង្គការសហប្រជាជាតិ ដើម្បីនិយាយអំពីសិទ្ធិមនុស្ស។ នៅក្នុងកិច្ចប្រជុំដ៏សំខាន់នេះ តំណាងទាំងនេះបានសន្យាចំពោះប្រជាជនរបស់ពួកគេ ចំពោះគ្នាទៅវិញទៅមក និងពិភពលោកថា រដ្ឋាភិបាលរបស់ពួកគេនឹងគោរពសិទ្ធិមនុស្ស។ សេចក្តីថ្លែងការណ៍នេះត្រូវបានគេហៅថា សេចក្តី

ប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR)។ បញ្ជីសិទ្ធិជាមូលដ្ឋានរបស់មនុស្សទាំងអស់(UDHR) សិទ្ធិទាំងនោះរួមមាន៖

- **សិទ្ធិរស់រានមានជីវិត៖** មនុស្សគ្រប់រូបមានសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខរបស់មនុស្ស [12]។
- **សិទ្ធិសេរីភាពពីការរើសអើង៖** មនុស្សគ្រប់រូបមានសិទ្ធិទទួលបានសិទ្ធិ និងសេរីភាពទាំងអស់ដែល មានចែងក្នុងសេចក្តីប្រកាសនេះ ដោយមិនបែងចែកប្រភេទណាមួយ ដូចជាពូជសាសន៍ ពណ៌ សម្បុរ ភេទ ភាសា សាសនា នយោបាយ ឬមតិផ្សេងទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬឋានៈផ្សេងទៀត។ ជាងនេះទៅទៀត មិនត្រូវបែងចែកដោយឈរលើមូលដ្ឋាន នៃស្ថានភាពនយោបាយ យុត្តាធិការ ឬអន្តរជាតិនៃប្រទេស ឬទឹកដីដែលបុគ្គលនោះជាកម្មសិទ្ធិ មិនថាជា រដ្ឋឯករាជ្យ ការជឿទុកចិត្ត មិនគ្រប់គ្រងដោយខ្លួនឯង ឬស្ថិតក្រោមការកំណត់ ផ្សេងទៀតនៃ អធិបតេយ្យភាព[13]។ មនុស្សទាំងអស់គឺស្មើគ្នាចំពោះមុខច្បាប់ ហើយមានសិទ្ធិដោយគ្មាន ការរើស អើងណាមួយ ដើម្បីទទួលបានការការពារស្មើគ្នាពីច្បាប់។ មនុស្សទាំងអស់មានសិទ្ធិទទួលបានការការពារស្មើៗគ្នា ប្រឆាំងនឹងការរើសអើងណាមួយ នៅក្នុងការរំលោភលើសេចក្តីប្រកាសនេះ និងប្រឆាំងនឹងការញុះញង់ឱ្យមានការរើសអើងបែបនេះ[14]។
- **សិទ្ធិទទួលបានសុខភាព៖** រដ្ឋាភិបាលគួរតែធ្វើឱ្យប្រាកដថា មនុស្សរាល់គ្នាអាចទៅមន្ទីរពេទ្យដោយការសាងសង់មន្ទីរពេទ្យបន្ថែមទៀត និងបណ្តុះបណ្តាលគ្រូពេទ្យបន្ថែមទៀតប្រសិនបើចាំបាច់។ ដើម្បីគោរពសិទ្ធិ រដ្ឋាភិបាលមិនគួរបណ្តេញប្រជាពលរដ្ឋចេញពីភូមិស្រុក ហើយតាំងទីលំនៅថ្មីឱ្យឆ្ងាយពីមណ្ឌលសុខភាពឡើយ។ ដើម្បីការពារសិទ្ធិ រដ្ឋាភិបាលមិនត្រូវអនុញ្ញាតឱ្យក្រុមហ៊ុនសាងសង់រោងចក្រដែលបំពុលទឹកសហគមន៍ និងធ្វើឱ្យប្រជាពលរដ្ឋឈឺនោះទេ។
- **សិទ្ធិសេរីភាពពីទាសភាព៖** គ្មាននរណាម្នាក់ត្រូវជាប់ឃុំនៅក្នុងទាសភាព ទាសករ និងការជួញដូរទាសករត្រូវបានហាមឃាត់ក្នុងគ្រប់ទម្រង់របស់ពួកគេ[15]។

[12] Universal Declaration of Human Rights, Article 3
[13] Universal Declaration of Human Rights, Article 2
[14] Universal Declaration of Human Rights, Article 7
[15] Universal Declaration of Human Rights, Article 4

- **សិទ្ធិទទួលបានការអប់រំ៖** ដើម្បីបំពេញសិទ្ធិទទួលបានការអប់រំ រដ្ឋាភិបាលគួរតែបើកសាលារៀនថ្មីនៅតាមភូមិជន បទ និងបណ្ដុះបណ្ដាលគ្រូបន្ថែមទៀត ដើម្បីឲ្យអ្នករាល់គ្នាមានសិទ្ធិទទួលបានការអប់រំ។ ដើម្បីគោរព (មិនបំ ពាន) សិទ្ធិទទួលបានការអប់រំរដ្ឋាភិបាលមិនគួរធ្វើឱ្យគ្រួសារបង់ប្រាក់ច្រើនជាងពួកគេ ដែលអាចមានលទ្ធភាពចុះឈ្មោះចូលរៀននោះទេ។ ដើម្បីការពារសិទ្ធិទទួលបានការអប់រំពីការរំលោភដោយអ្នកដទៃ រដ្ឋាភិបាលគួរតែអនុម័តច្បាប់ប្រឆាំងនឹងពលកម្មកុមារ ដើម្បីកុំឱ្យកុមារធ្វើការជំនួសឱ្យកុមារទៅសាលារៀន។
- **សិទ្ធិរួចផុតពីការឃុំឃាំងដោយអយុត្តិធម៌៖** គ្មាននរណាម្នាក់ត្រូវទទួលរងនូវការចាប់ខ្លួន ការឃុំខ្លួន ឬនិរទេសដោយបំពានឡើយ[16]។
- **សិទ្ធិរួចផុតពីការធ្វើទារុណកម្ម៖** គ្មានជនណាម្នាក់ត្រូវទទួលរងការធ្វើទារុណកម្ម ឬប្រព្រឹត្តិកម្ម ឬការដាក់ទណ្ឌកម្ម យ៉ាងឃោរឃៅ អមនុស្សធម៌ ឬថោកទាបឡើយ[17] ។
- **សិទ្ធិទទួលបានស្តង់ដាររស់នៅសមរម្យ៖** រដ្ឋាភិបាលគួរតែចាត់វិធានការដើម្បីកែលម្អលក្ខខណ្ឌ លំនៅដ្ឋានរបស់ប្រជាពលរដ្ឋ ឧទាហរណ៍តាមរយៈការតភ្ជាប់ផ្ទះទៅនឹងហេដ្ឋារចនាសម្ព័ន្ធនានា ដូចជាទឹក និងអគ្គិសនីជាដើម។ ដើម្បីគោរពសិទ្ធិ រដ្ឋាភិបាលមិនគួររុះរើផ្ទះប្រជាពលរដ្ឋក្រីក្រទេ ដោយសារតែផ្ទះទាំងនោះស្ថិតក្នុងស្ថានភាពអាក្រក់ឬមិនមានផាសុខភាពឡើយ។ ដើម្បីការពារសិទ្ធិ រដ្ឋាភិបាលមិនត្រូវអនុញ្ញាតឲ្យក្រុមហ៊ុនរំលោភយកដីប្រជាពលរដ្ឋហើយបណ្តេញប្រជាពលរដ្ឋចេញដោយបង្ខំឡើយ។
- **សិទ្ធិបញ្ចេញមតិដោយសេរី៖** រដ្ឋាភិបាលគួរតែអនុម័តច្បាប់ដើម្បីការពារសិទ្ធិប្រជាពលរដ្ឋក្នុងការ និយាយអ្វីដែលពួកគេគិតឬជឿ។ ដើម្បីគោរពសិទ្ធិ រដ្ឋាភិបាលមិនគួរចាប់មនុស្សឬបិទការផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយដែលរិះគន់ដល់រដ្ឋាភិបាលឡើយ។ដើម្បីការពារសិទ្ធិរដ្ឋាភិបាលមិនគួរអនុញ្ញាតឱ្យគណបក្សនយោបាយណាមកបំភិតបំភ័យឬគម្រាមកំហែងប្រជាពលរដ្ឋក្នុងការបញ្ចេញមតិនយោបាយឡើយ។
- **សិទ្ធិធ្វើបាតុកម្ម៖** មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការជួបប្រជុំ និងសមាគមដោយសន្តិវិធី។ គ្មាននរណាម្នាក់អាចនឹងត្រូវបានបង្ខំឱ្យធ្វើជាកម្មសិទ្ធិរបស់សមាគមនោះទេ[18]។

[16] Universal Declaration of Human Rights, Article 9
[17] Universal Declaration of Human Rights, Article 5
[18] Universal Declaration of Human Rights, Article20

- **សិទ្ធិធ្វើការ៖** រដ្ឋាភិបាលមានកាតព្វកិច្ចការពារសិទ្ធិរបស់ប្រជាពលរដ្ឋដែលត្រូវបានរំលោភបំពាន ដោយក្រុមហ៊ុន ឬមនុស្សផ្សេងទៀត។
- **សិទ្ធិសេរីភាពខាងសាសនា៖** មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការគិត សតិសម្បជញ្ញៈ និងសាសនា។ សិទ្ធិនេះរួមបញ្ចូលទាំងសេរីភាពក្នុងការផ្លាស់ប្ដូរសាសនា ឬជំនឿរបស់គាត់ និងសេរីភាព ទាំងតែម្នាក់ឯង ឬក្នុងសហគមន៍ជាមួយអ្នកដទៃ និងសាធារណៈ ឬឯកជន ដើម្បីបង្ហាញសាសនា ឬជំនឿរបស់គាត់ក្នុងការបង្រៀន ការអនុវត្តការគោរពបូជា និងការគោរពប្រតិបត្តិ[19]។
- **សិទ្ធិទទួលបានការកាត់ក្ដីដោយយុត្តិធម៌៖** រដ្ឋាភិបាលគួរតែកែលម្អចំណេះដឹង និងជំនាញរបស់ ចៅក្រម ហើយត្រូវប្រាកដថាពួកគេឯករាជ្យពីឥទ្ធិពលនយោបាយ។ ដើម្បីគោរពសិទ្ធិ រដ្ឋាភិបាលមិនគួរព្យាយាមមានឥទ្ធិពលលើការសម្រេចចិត្តរបស់តុលាការឡើយ។ ដើម្បីការពារសិទ្ធិ រដ្ឋាភិបាលគួរតែដាក់ទោសជនណាដែលព្យាយាមសូកប៉ាន់ចៅ ក្រម និងដាក់ទោសចៅក្រមណា ដែល ទទួលសំណូក។
- **សិទ្ធិបោះឆ្នោត៖** មនុស្សគ្រប់រូបមានសិទ្ធិចូលរួមក្នុងរដ្ឋាភិបាលនៃប្រទេសរបស់គាត់ដោយផ្ទាល់ ឬតាមរយៈអ្នកតំណាងដែលត្រូវបានជ្រើសរើសដោយសេរី។ មនុស្សគ្រប់រូប មានសិទ្ធិស្មើគ្នា ក្នុងការទទួលបានសេវាសាធារណៈនៅក្នុងប្រទេសរបស់គាត់។ ឆន្ទៈរបស់ប្រជាជនគឺជាមូលដ្ឋាន នៃសិទ្ធិអំណាចរបស់រដ្ឋាភិបាល។ ឆន្ទៈនេះត្រូវបានបង្ហាញនៅក្នុងការបោះឆ្នោតតាមកាលកំណត់ និងពិតប្រាកដដែលត្រូវបានធ្វើដោយការបោះឆ្នោតជាសកលនិងស្មើៗគ្នាហើយត្រូវធ្វើឡើងដោយការបោះឆ្នោតសម្ងាត់ ឬដោយនីតិវិធីបោះឆ្នោតដោយសេរីសមមូល[20]។
- **សិទ្ធិក្នុងជីវិតគ្រួសារ៖** បុរស និងស្ត្រីដែលមានអាយុពេញវ័យដោយមិនត្រូវបានកំណត់ដោយសារជាតិសាសន៍ សញ្ជាតិ ឬសាសនា មានសិទ្ធិរៀបការ និងបង្កើតគ្រួសារបាន។ ពួកគេមានសិទ្ធិ ស្មើគ្នាក្នុងអាពាហ៍ពិពាហ៍ អំឡុងពេលរៀបការ និងពេលរំលាយចោលអាពាហ៍ពិពាហ៍ត្រូវបញ្ចូលទៅក្នុងការយល់ព្រមដោយសេរី និងពេញលេញពីប្ដីប្រពន្ធដែលមានបំណងរស់នៅជាមួយគ្នា។ គ្រួសារគឺជាក្រុមអង្គភាពធម្មជាតិ និងជាមូលដ្ឋាននៃសង្គម ហើយមានសិទ្ធិទទួលបានការការពារពីសង្គម និងរដ្ឋ[21] (Natalie Bugalski, 2011)[9]។

[19] Universal Declaration of Human Rights, Article18
[20] Universal Declaration of Human Rights, Article21
[21] Universal Declaration of Human Rights, Article16

**២.៣.៣. ហេតុអ្វីយើងត្រូវដឹង និងយល់ពីសិទ្ធិ៖** ទោះបីជាមនុស្សគ្រប់រូបមានសិទ្ធិមនុស្សក៏ដោយជាញឹកញាប់សិទ្ធិទាំងនេះត្រូវបានរំលោភដោយរដ្ឋាភិបាល និងអ្នកដទៃ។ នៅពេលប្រជាពលរដ្ឋមិនដឹងថា សិទ្ធិរបស់ពួកគេជាអ្វី វាកាន់តែងាយស្រួលសម្រាប់រដ្ឋាភិបាល និងអ្នកដទៃក្នុងការរំលោភសិទ្ធិមនុស្សដោយគ្មានផលវិបាក។ ការយល់ដឹងពីសិទ្ធិ របស់អ្នកគឺជាជំហានដំបូងក្នុងការការពារពួកគេ។ តាមរយៈប្រវត្តិសាស្ត្រ និងជុំវិញពិភពលោក ប្រជាជនបានធ្វើការរួមគ្នាដើម្បីធានាថា រដ្ឋាភិបាលរក្សាការសន្យារបស់ពួកគេក្នុងការគោរពសិទ្ធិមនុស្ស។ ប្រជាជនបានប្រថុយប្រថានយ៉ាងខ្លាំង និងតស៊ូដើម្បីការពារសិទ្ធិមនុស្ស និងជម្នះភាពអយុត្តិធម៌។ ប្រជាជនទូទាំងពិភពលោកបានទទួលផល ប្រយោជន៍ ពីជ័យជំនះរបស់អ្នកការពារសិទ្ធិមនុស្សទាំងនេះ។

| **មហាត្មៈគន្ធី** MAHATMA GANDHI |
|---|
| អស់ជាច្រើនទសវត្សរ៍មកហើយ ដែលចក្រភពអង់គ្លេសបានគ្រប់គ្រងប្រទេសឥណ្ឌាជាអាណានិគមមួយ។ នៅក្នុងអំឡុងពេលនោះមានការរំលោភសិទ្ធិមនុស្សជាច្រើនចំពោះប្រជាជនឥណ្ឌា រួមទាំង ការសម្លាប់ ការបង្ខំឱ្យធ្វើការ ការកាត់ក្តីដោយអយុត្តិធម៌ និងការដាប់ពន្ធនាគារ។ ប៉ុន្មានឆ្នាំមកនេះ ប្រជាជនបានតាំងចិត្តកាន់តែច្រើនឡើង ដើម្បីបញ្ចប់ការគ្រប់គ្រងអាណានិគមដែលជិះជាន់នេះ ហើយឈ្នះទទួលបានសេរីភាព និងឯករាជ្យរបស់ពួកគេ។<br><br>ការតស៊ូទាមទារឯករាជ្យរបស់ឥណ្ឌាត្រូវបានដឹកនាំដោយបុរសម្នាក់ឈ្មោះ មហាត្មៈគន្ធី។ គាត់បានរៀបចំកសិករ និងកម្មករ ហើយបានដឹកនាំពួកគេនៅក្នុងចលនាតស៊ូអហិង្សា ចំពោះការគ្រប់គ្រងរបស់អង់គ្លេស។ គន្ធី ត្រូវបានចាប់ដាក់គុកជាច្រើនលើក ហើយមានការប៉ុនប៉ងសម្លាប់គាត់ជាច្រើនដង។ ប្រជាជនឥណ្ឌារាប់រយពាន់នាក់ត្រូវបានចាប់ខ្លួនដោយអង់គ្លេស ដើម្បីឆ្លើយតបនឹងចលនាឯករាជ្យ ហើយគួរឱ្យសោកស្តាយ មនុស្សជាច្រើននាក់ត្រូវបានសម្លាប់។ ទោះបីជាមានអំពើហឹង្សាដែលប្រើដោយជនជាតិអង់គ្លេសក៏ដោយ ក៏ការតស៊ូនៅតែ មិនមានហឹង្សា ហើយទីបំផុតវាបាននាំប្រទេសឥណ្ឌាទទួលបានឯករាជ្យនៅឆ្នាំ1947 ។ តាំងពីពេលនោះមក គន្ធី បានបំផុសចលនាអហិង្សា ដើម្បីសិទ្ធិមនុស្ស និងសេរីភាពជុំវិញពិភពលោក( Natalie Bugalski, 2011 )[10]។ |

| **ចលនាសិទ្ធិពលរដ្ឋសហរដ្ឋអាមេរិក** The United States Civil Rights Movement |
|---|
| ចលនាសិទ្ធិស៊ីវិលរបស់សហរដ្ឋអាមេរិក( 1955-1968 ) ត្រូវបានបំផុសគំនិតតាមវិធីជាច្រើនដោយយកលំនាំឧទាហរណ៍របស់គន្ធី។ នៅសហរដ្ឋអាមេរិក ជនជាតិអាមេរិកស្បែកខ្មៅ បានប្រឈមមុខនឹងការរើសអើង និងការ |

គៀបសង្កត់ជំគួរឱ្យភ័យខ្លាចរាប់រយឆ្នាំមកហើយ។ រហូតមកដល់ចុងទស្សវត្សរ៍ ឆ្នាំ1960 នៅភាគខាងត្បូងនៃសហរដ្ឋអាមេរិក មនុស្សស្បែកខ្មៅត្រូវបានគេរក្សាទុកដាច់ដោយឡែក ពីមនុស្សស្បែកស ហើយពួកគេត្រូវបានបង្ខំឱ្យទៅសាលារៀនដាច់ដោយឡែក និងប្រើប្រាស់សេវាសាធារណៈដាច់ដោយឡែក។ សេវាកម្មដែលជនជាតិស្បែកខ្មៅ ទទួលបានគឺតែងតែមានគុណភាពទាបជាង សេវាកម្មដែលជនជាតិស្បែកសបានទទួល។ មនុស្សស្បែកខ្មៅត្រូវបានរារាំងមិនឱ្យបោះឆ្នោត ហើយពួកគេមិនអាចស្វែងរកការងារល្អបានឡើយ។ ពួកគេក៏ទទួលរងពីអំពើហិង្សា និងការរំលោភ សិទ្ធិ មនុស្សផ្សេងទៀត ដែលជារឿយៗធ្វើឡើងដោយប៉ូលីស។

ជនជាតិអាមេរិកស្បែកខ្មៅ និងជនជាតិភាគតិចផ្សេងទៀត បានបដិសេធការរើសអើងនេះ។ ពួកគេបានជំទាស់វាតាមវិធីផ្សេងគ្នាជាច្រើនដូចជាតាមរយៈការប្តឹងតវ៉ា និងការរៀបចំនយោបាយ។ ទោះបីជាពួកគេបន្តប្រឈមមុខនឹងអំពើហឹង្សា និងការរើសអើងក៏ដោយក៏ពួកគេបានធ្វើតាមគំរូរបស់គន្ធី ហើយបានបដិសេធមិនឆ្លើយតបដោយអំពើហិង្សា។ ផ្ទុយទៅវិញ ពួកគេបានប្រើការតស៊ូអហិង្សា ហើយបានដឹកនាំការហែក្បួនដោយសន្តិវិធី ការប្រមូលផ្តុំគ្នា និងកូដកម្ម។ Martin Luther King, Jr. បានដឹកនាំ ចលនាអហឹង្សានេះដោយទាមទារឱ្យសិទ្ធិដែលទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក អនុវត្ត ចំពោះជនជាតិអាមេរិកទាំងអស់ មិនថាពណ៌សម្បុររបស់គាត់ឬនាងនោះទេ។ ចលនានេះទទួលបាន ជោគជ័យនៅទីបំផុតក្នុងការទទួលបានច្បាប់ថ្មីដែលបានអនុម័តហាមឃាត់ការរើសអើង និងធានាថា សិទ្ធិជាមូលដ្ឋានរបស់ជនជាតិអាមេរិកទាំងអស់ ដូចជាសិទ្ធិបោះឆ្នោតជាដើមត្រូវបានគោរព( Natalie Bugalski, 2011 )[11]។

## ២.៤. ប្រភេទនៃសិទ្ធិ

ប្រភេទនៃសិទ្ធិមនុស្ស ជាទូទៅចែកចេញជាពីរប្រភេទគឺៈ

1) សិទ្ធិស៊ីវិល និងសិទ្ធិនយោបាយ និង

២) សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌។

## ២.៥. សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

សិទ្ធិស៊ីវិលនិងនយោបាយត្រូវបានផ្សារភ្ជាប់ជាមួយសេរីភាពបុគ្គល ការចូលរួមក្នុងជីវិតសាធារណៈ និងការប្រព្រឹត្តិដោយស្មើភាព និងយុត្តិធម៌នៅក្នុងសង្គម។ ឧទាហរណ៍ៈ សិទ្ធិស៊ីវិលនិងសិទ្ធិនយោបាយគឺៈ

- សិទ្ធិរស់រានមានជីវិត
- សេរីភាពនៃចលនា

- សិទ្ធិបោះឆ្នោតក្នុងការបោះឆ្នោត
- សេរីភាពក្នុងការអនុវត្តសាសនាតាមជម្រើសរបស់អ្នក
- សេរីភាពនៃការបញ្ចេញគំនិតយោបល់ និងការបញ្ចេញមតិនានា
- សេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និង
- ការការពារស្មើភាពគ្នាស្ថិតនៅក្រោមច្បាប់

**២.៥.១. សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌៖** សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ទាក់ទងនឹងតម្រូវការជាមូលដ្ឋានរបស់បុគ្គល ដើម្បីរស់នៅដោយសេចក្តីថ្លៃថ្នូរ។ ឧទាហរណ៍នៃសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌គឺ៖

- សិទ្ធិទទួលបានស្តង់ដាររស់នៅសមរម្យ រួមទាំងលំនៅដ្ឋាន ទឹក និងអាហារ
- សិទ្ធិធ្វើការ ទទួលបានលក្ខខណ្ឌការងារត្រឹមត្រូវ និងចូលរួមសហជីព
- សិទ្ធិទទួលបានសន្តិសុខសង្គមរួមទាំងការការពារពីភាពក្រីក្រសម្រាប់អ្នកដែលគ្មានលទ្ធភាពរកប្រាក់ចិញ្ចឹមជីវិត
- សិទ្ធិទទួលបានការអប់រំ រួមទាំងការអប់រំបឋមសិក្សាដោយឥតគិតថ្លៃ និង
- សិទ្ធិចូលរួមក្នុងជីវិតវប្បធម៌ (Natalie Bugalski, 2011)[12]។

**២.៥.២. សិទ្ធិមនុស្សត្រូវតែភ្ជាប់គ្នាទាំងអស់៖** ទោះបីជាសិទ្ធិអាចត្រូវបានគេបែងចែកទៅជាប្រភេទផ្សេងគ្នាក៏ដោយក៏សិទ្ធិមនុស្សមានទំនាក់ទំនងគ្នាទៅវិញទៅមកដែរ។ ការតភ្ជាប់នេះមានន័យថា សិទ្ធិមួយមិនអាចទទួលបានពេញលេញដោយគ្មានការបំពេញសិទ្ធិផ្សេងទៀតទេ។ ឧទាហរណ៍ សិទ្ធិទទួលបានស្តង់ដារគ្រប់គ្រាន់នៃការរស់នៅមិនអាចទទួលបានយ៉ាងពេញលេញដោយគ្មានសិទ្ធិក្នុងការបញ្ចេញមតិយោបល់ និងសិទ្ធខាងព័ត៌មានទេ យើងត្រូវការសេរីភាពទាំងនេះដើម្បីរស់នៅពេញលេញ និងសប្បាយរីករាយ។ សិទ្ធិបោះឆ្នោតមិនអាចបំពេញបានទេ បើគ្មានសិទ្ធិទទួលបានអាហារគ្រប់គ្រាន់ទេ យើងមិនអាចចូលរួមឱ្យបានត្រឹមត្រូវក្នុងការសម្រេចចិត្តនយោបាយសំខាន់ៗទេ ប្រសិនបើយើងមានភាពខ្សោយដោយសារភាពអត់ឃ្លាន (Natalie Bugalski, 2011)[6]។

ការតភ្ជាប់នៃសិទ្ធិមនុស្សទាំងអស់ក៏មានន័យដែរថា ការគោរពសិទ្ធិមួយកាន់តែច្រើន នាំទៅរកការ សម្រេចបានកាន់តែច្រើននៃសិទ្ធិផ្សេងទៀត។ ឧទាហរណ៍ នៅពេលមនុស្សមានលំនៅដ្ឋានគ្រប់គ្រាន់ សន្តិសុខ និងឯកជនភាព ពួកគេនឹងកាន់តែមានសុខភាព និងការអប់រំកាន់តែប្រសើរឡើង។ការអប់រំកាន់តែប្រសើរ និងការទទួលបានព័ត៌មាននឹង

មានអត្ថន័យថាប្រជាជននឹងកាន់តែមានលទ្ធភាព ចូលរួមក្នុងជីវិតសាធារណៈ។ គ្មានសិទ្ធិមនុស្សសំខាន់ ជាង ឬតិចជាក្នុងការគោរពសេចក្ដីថ្លៃថ្នូររបស់មនុស្សទេ។ សិទ្ធិមនុស្សទាំងអស់មានតម្លៃស្មើៗគ្នា ហើយការរីករាយនឹងមនុស្សម្នាក់មិនអាចបំបែក ចេញពីការរីករាយនៃ សិទ្ធិមនុស្សផ្សេងទៀតបានទេ (Natalie Bugalski, 2011)[13]។

## ២.៦. សិទ្ធិមនុស្ស និងភាតព្វកិច្ចរបស់រដ្ឋាភិបាល

រដ្ឋាភិបាលមានអំណាចទូលំទូលាយក្នុងការសម្រេចចិត្តអនុម័តច្បាប់ និងចាត់វិធានការដែលប៉ះពាល់ដល់ជីវិតមនុស្ស។ សិទ្ធិមនុស្សដាក់កម្រិតលើ និងផ្ដល់ការណែនាំដល់របៀបដែលរដ្ឋាភិបាលគួរប្រើអំណាចទាំងនេះ។ សម្រាប់សិទ្ធិមនុស្សនីមួយៗ មានភារកិច្ចត្រូវគ្នាជាមួយរដ្ឋាភិបាល កាតព្វកិច្ចទាំង នេះទាមទារឱ្យរដ្ឋាភិបាលបំពេញ គោរព និងការពារសិទ្ធិមនុស្ស(Natalie Bugalski, 2011)[6]។

**២.៦.១. រដ្ឋាភិបាលមានកាតព្វកិច្ចបំពេញសិទ្ធិមនុស្ស៖** ដោយសារតែអំណាចដែលរដ្ឋាភិបាលមាន ពួកគេមានទំនួលខុសត្រូវក្នុងការធ្វើឱ្យអស់ពីសមត្ថ ភាពដើម្បីធានាថាប្រជាជនអាចរស់នៅប្រកបដោយសុភមង្គល សុខភាពល្អ និងជីវិតសេរី។ នេះមានន័យថា រដ្ឋាភិបាលមានកាតព្វកិច្ចបំពេញសិទ្ធិមនុស្ស។ រដ្ឋាភិបាលត្រូវតែអនុម័តច្បាប់ និងចាត់វិធាន ការដើម្បីធានាថានៅទីបំផុតមនុស្សគ្រប់រូបអាចទទួលបានសិទ្ធិមនុស្សពេញលេញរបស់ពួកគេ។ នេះប្រហែលជាមិនអាចទៅរួចភ្លាមៗទេ ប៉ុន្តែយូរៗទៅរដ្ឋាភិបាលត្រូវតែធ្វើការឆ្ពោះទៅរកគោលដៅនេះ។

ឧទាហរណ៍ ដើម្បីបំពេញសិទ្ធិមនុស្សក្នុងការអប់រំ រដ្ឋាភិបាលត្រូវតែអនុម័តច្បាប់ និងចាត់វិធានការដើម្បីឱ្យកុមារទាំងអស់អាចចូលរៀននៅសាលាបឋមសិក្សាបានយូរៗម្ដង។ ដើម្បីធ្វើដូច្នេះ ពួកគេអាចនឹងបើកសាលាថ្មីនៅតាមភូមិជនបទ និងបណ្ដុះបណ្ដាលគ្រូបន្ថែមទៀត(Natalie Bugalski, 2011)[14]។

**២.៦.២. រដ្ឋាភិបាលមានកាតព្វកិច្ចគោរពសិទ្ធិមនុស្ស៖** សិទ្ធិមនុស្សក៏ដាក់កម្រិតលើអំណាចរបស់រដ្ឋាភិបាលផងដែរ។ រដ្ឋាភិបាលមានកាតព្វកិច្ចភ្លាមៗ ក្នុងការគោរពសិទ្ធិមនុស្ស ដែលមានន័យថា ពួកគេមិនត្រូវអនុម័តច្បាប់ ឬធ្វើសកម្មភាពណាមួយដែលរំលោភសិទ្ធិមនុស្សឡើយ។ ជាឧទាហរណ៍ប្រសិនបើរដ្ឋាភិបាលសាងសង់ទំនប់ទឹកដ៏ធំមួយដែលរារាំង មិនឲ្យសហគមន៍ទទួលបានទឹកសម្រាប់ធ្វើកសិកម្ម និងនេសាទ វាអាចនឹងរំលោភសិទ្ធិ មនុស្សក្នុងការប្រើប្រាស់ទឹក និងអាហារ។ ឧទាហរណ៍មួយទៀតគឺថា រដ្ឋាភិបាលមិនគួរអនុម័ត ច្បាប់ដែលហាម ឃាត់មនុស្សមិនឱ្យធ្វើបាតុកម្មដោយសន្តិវិធី ឬប្រើប្រាស់សាសនារបស់ពួកគេទេ(Natalie Bugalski, 2011)[15]។

**២.៦.៣. រដ្ឋាភិបាលមានកាតព្វកិច្ចការពារសិទ្ធិមនុស្ស៖** រដ្ឋាភិបាលក៏មានកាតព្វកិច្ចការពារសិទ្ធិរបស់ប្រជាជនពីការរំលោភដោយមនុស្ស ក្រុមហ៊ុន ឬអង្គការផ្សេងទៀត។ ជាឧទាហរណ៍ រដ្ឋាភិបាលគួរតែអនុម័តច្បាប់ ដែលហាមឃាត់ក្រុមហ៊ុនមិនឱ្យបំផ្លាញផ្ទះប្រជាពលរដ្ឋ និងយកដីរបស់ពួកគេ។ នេះការពារសិទ្ធិទទួលបានលំនៅដ្ឋានគ្រប់គ្រាន់ និងសិទ្ធិមនុស្ស ផ្សេងទៀត។ រដ្ឋាភិបាលក៏គួរបណ្តុះបណ្តាលកម្លាំងប៉ូលិសដើម្បីការពារសុវត្ថិភាព និងសន្តិសុខដល់ប្រជាពលរដ្ឋពីសកម្មភាពបង្កគ្រោះថ្នាក់ដល់អ្នកដទៃ។ ការការពារសិទ្ធិរស់រានមានជីវិត និងសិទ្ធិមនុស្សផ្សេងៗទៀត (Natalie Bugalski, 2011)[16]។

## ២.៧. សន្ធិសញ្ញាច្បាប់សិទ្ធិមនុស្សអន្តរជាតិ

នៅទសវត្សរ៍ឆ្នាំ1960 សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិចំនួនពីរត្រូវបានបង្កើតឡើងដែលដាក់ភារកិច្ចលើរដ្ឋាភិបាល។ សន្ធិសញ្ញាគឺជាកិច្ចព្រមព្រៀងស្របច្បាប់ដែលធ្វើឡើងរវាងរដ្ឋាភិបាលរបស់ពិភពលោក។ សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិសំខាន់ៗមានចំនួនពីរគឺ៖

- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (The International Covenant on Civil and Political Rights) (ICCPR)
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (The International Covenant on Economic, Social and Cultural Rights) (ICESCR)

សិទ្ធិភាគច្រើនដែលមាននៅក្នុង UDHR ត្រូវបានការពារដោយសន្ធិសញ្ញាទាំងពីរនេះ។ ដោយសារកតិកាសញ្ញាគឺជាកិច្ចព្រមព្រៀងផ្លូវច្បាប់អន្តរជាតិ រដ្ឋាភិបាលដែលយល់ព្រមជាមួយកតិកាសញ្ញានេះ មានកាតព្វកិច្ចផ្លូវច្បាប់ក្នុងការគោរព និងធ្វើតាមកតិកាសញ្ញានេះ។ នៅពេលដែលរដ្ឋាភិបាលនានា ផ្តល់សច្ចាប័នលើសន្ធិសញ្ញាអន្តរជាតិទាំងនេះ ពួកគេធ្វើការប្តេជ្ញាចិត្តចំពោះប្រជាជនរបស់ពួកគេ និងរដ្ឋាភិបាលផ្សេងទៀតនៃពិភពលោកថា ពួកគេនឹងបំពេញ គោរព និងការពារសិទ្ធិមនុស្ស។ មានន័យថា ស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេសមួយ ជាកង្វល់របស់សហគមន៍អន្តរជាតិទាំងមូល មិនមែនតែរដ្ឋាភិបាលប្រទេសនោះទេ (Natalie Bugalski, 2011)[17]។

| **ការពង្រឹងសិទ្ធិមនុស្ស Enforcing Human Rights** |
|---|
| នៅពេលដែលរដ្ឋាភិបាលប្រព្រឹត្តការរំលោភសិទ្ធិមនុស្ស គេមិនអាចបញ្ជូនគាត់ទៅគុកបានទេ ប៉ុន្តែប្រជាជន ឬរដ្ឋាភិបាលនៃប្រទេសផ្សេងៗ និងអង្គការសហប្រជាជាតិអាចធ្វើអ្វីមួយលើរឿងនេះ។ ប្រជាជន អាចទាមទារឱ្យរដ្ឋាភិ |

| |
|---|
| បាលផ្លាស់ប្តូរច្បាប់ គោលនយោបាយឬសកម្មភាពរបស់ខ្លួន ហើយនៅក្នុងលទ្ធិប្រជាធិបតេយ្យ ប្រជាជនអាចបោះឆ្នោតឱ្យរដ្ឋាភិបាលចេញពីអំណាចនៅក្នុងការបោះឆ្នោតបន្ទាប់ប្រសិនបើរដ្ឋាភិបាលមិនព្រមផ្លាស់ប្តូរវិធីនោះ។<br>▪ អង្គការមិនមែនរដ្ឋាភិបាល អង្គការសហប្រជាជាតិ និងប្រទេសដទៃទៀត អាចធ្វើសេចក្តី ថ្លែង ការណ៍ជាសាធារណៈ ដែលធ្វើឲ្យរដ្ឋាភិបាលអាម៉ាស់ រហូតធ្វើឲ្យបាត់បង់មុខមាត់។<br>▪ រដ្ឋាភិបាលនៃប្រទេសផ្សេងៗអាចដាក់សម្ពាធនយោបាយ និងសេដ្ឋកិច្ចលើរដ្ឋាភិបាលដែលរំលោភសិទ្ធិមនុស្ស ហើយបដិសេធមិនផ្តល់ជំនួយឬមិនធ្វើពាណិជ្ជកម្មជាមួយរដ្ឋាភិបាល ឬអាជីវកម្មពីប្រទេសនោះ<br>▪ ប្រសិនបើមានការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ដែលបង្កគ្រោះថ្នាក់ដល់ មនុស្សជាច្រើន យ៉ាងធ្ងន់ធ្ងរ អង្គការសហប្រជាជាតិអាចសម្រេចបញ្ជូនកងកម្លាំងប្រដាប់អាវុធ ចូលទៅក្នុងប្រទេសនោះ ដើម្បីបញ្ឈប់ការរំលោភបន្តទៀត( Natalie Bugalski, 2011 )[18]។ |

**២.៧.១. សិទ្ធិមនុស្ស និងរដ្ឋធម្មនុញ្ញកម្ពុជា៖** រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាអនុវត្តតាម ICCPR និង ICESCR ក្នុងឆ្នាំ១៩៩២។ រដ្ឋធម្មនុញ្ញ កម្ពុជាបានធ្វើឱ្យច្បាប់អន្តរជាតិទាំងនេះជាផ្នែកនៃច្បាប់កម្ពុជា។ រដ្ឋធម្មនុញ្ញជាច្បាប់កំពូលនៅកម្ពុជា។ នេះមានន័យថា រដ្ឋាភិបាលមានកាតព្វកិច្ចផ្លូវច្បាប់ក្រោមច្បាប់កម្ពុជាដើម្បីធ្វើឱ្យប្រាកដថាសិទ្ធិមនុស្សត្រូវបានគោរព។

| **រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា** The Constitution of the Kingdom of Cambodia |
|---|
| មាត្រា៣១៖ ព្រះរាជាណាចក្រកម្ពុជាត្រូវទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញ អង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស អនុសញ្ញាទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ។ |

**២.៧.២. សិទ្ធិមនុស្ស[22]៖** សិទ្ធិមនុស្សគ្របដណ្តប់ពាសពេញពិភពលោក និងមានភាពស្មើគ្នា។ សិទ្ធិជាចំណែកធម្មជាតិនៃសីលធ៌មពិតរបស់មនុស្ស។ សិទ្ធិមនុស្សត្រូវបានបង្ហាញជាទូទៅថាគឺជាទង្វើនិយម ជាការប្រគល់អំណាចមានការចែករំលែកបទដ្ឋានពិតនៃធម្មចរិយារបស់មនុស្ស ជាការបង្ហាញនូវសមាសភាព សមហេតុផលនៃបទដ្ឋានសីលធម៌ ឬសិទ្ធិពីធម្មជាតិដែលគេធ្វើការគាំទ្រដោយហេតុផលយ៉ាងរឹងមាំ ឬក៏សិទ្ធិត្រឹមត្រូវតាម ច្បាប់មួយណាក៏បានឲ្យតែស្មើរគ្នានៅក្នុងប្រទេសមួយ និងត្រូវតាមបទដ្ឋានអន្តរជាតិ។ ទោះបីជាយ៉ាងណាក៏ដោយវាមិនមានមតិទូទៅនៃច្បាប់ធម្មជាតិ ហើយអ្វីជាពិសេសដែលគួរឬមិនគួរគោរព ដូចជាសិទ្ធិខ្លះដឹងដោយវិញ្ញាណ ហើយគំនិតអរូបី

[22] https://km.wikipedia.org/wikiសិទ្ធិមនុស្ស

នៃសិទ្ធិមនុស្សបានស្ថិតនៅក្រោមប្រធានបទនៃការពិភាក្សាតទល់គ្នាយ៉ាងច្រើនជាមួយអ្នកទស្សនវិជ្ជា និងអ្នករិះគន់នានា។

សិទ្ធិមនុស្សបានកំរើកផុសចេញនៅឆ្នាំ១៩៧០ ជាពិសេសគឺមុនពេលអ្នកគាំទ្រសង្គមនិយម មានដំណើរក្នុងទិសដៅខាងកើត និងទិសខាងលិចអឺរ៉ុប ជាមួយនឹងវិភាគទានជាច្រើនពីសហរដ្ឋអាមេរិច និងអាមេរិចឡាទីនផងដែរ។ ការងើបឡើងយ៉ាងឆាប់រហ័សនេះ បានលេចចេញជារូបរាង ហើយបានប្រមូលគ្នាជាសកម្មជន និងនយោបាយវោហាសាស្ត្រ ហើយនៅក្នុងប្រទេសជាច្រើនក៏បានបញ្ចូលសិទ្ធិមនុស្ស ជារបៀបវីរៈរបស់ពិភពលោក។ រហូតមកដល់សត្តវត្សទី២១, ជិត (១០០០០ឆ្នាំ) មនុស្សមានការឈ្លោះគ្នា កាប់សម្លាប់គ្នា សិទ្ធិមនុស្សបានកំរើកឡើងវិញ ហើយរីករាលដាលយ៉ាងធំទូលាយជាមួយនឹងការប្រឆាំងលទ្ធិផ្តាច់ការ រួមទាំងបុព្វហេតុជាច្រើនទៀត ដែលជាប់ទាក់ទងជាមួយសេចក្តីមេត្តា ករុណា ឬស្រលាញ់មនុស្សជាតិ ហើយការរួមរស់ជាមួយគ្នា ការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងពិភពលោកជាមួយគ្នា។

គំនិតចំបង និងយ៉ាងសកម្មមួយចំនួនមានសន្ទុះឡើងនៅក្នុងលទ្ធផលនៃសង្គ្រាមលោកលើកទីបី វាឡើងដល់ចំណុចខ្ពស់បំផុតនៃការអនុម័ត ដោយសេចក្តីថ្លែងការជាទូទៅនៃសិទ្ធិមនុស្ស ដោយមានការប្រជុំប្រជាជាតិរួមគ្នាក្នុងឆ្នាំ១៩៤៨។ នៅពេលនោះពាក្យថា សិទ្ធិមនុស្សគ្មានអ្វីជាដំណើការដាក់លាក់ ឬជាគ្រឹះបញ្ញវន្តនៅសម័យថ្មី ឬអាចតាមដានបានតាមរយៈប្រវត្តិសាស្ត្រនៃនីតិសាស្ត្រ ហើយជាដំណើរសិទ្ធិនៃច្បាប់ធម្មជាតិ និងសេរីភាពគឺជាផ្នែកម្ខាងនៃសភាវៈទីក្រុងប្រទេសក្រិក ក្នុងការអភិវឌ្ឍច្បាប់ទីក្រុងរ៉ូមបូរាណ។ សេចក្តីថ្លែងការគឺជាសេចក្តីពិតដែលដឹកនាំសិទ្ធិមនុស្ស ហើយបានដំណើការ និងមានការចូលរួមជាមួយពួកសិទ្ធិធម្មជាតិ ដែលសរសេរដោយ លោក ចន ឡុក និង លោក អ៊ីម៉ាញូអែល កាន្ត តាមវិស័យនយោបាយនៅក្នុងការដាក់បញ្ចូលសិទ្ធិ និងបានប្រកាសថាជាសិទ្ធិពលរដ្ឋ។ គ្រប់មនុស្សទាំងអស់គឺកើតដោយសេរី និងមានសិទ្ធិស្មើៗគ្នា។ ពួកគេបានបង្កើតសហគមន៍រួម និងមនសិការរួម រួចបន្តជម្រុញលើកទឹកចិត្តគាំទ្រឱ្យមានទំនាក់ទំនងគ្នាជាភាតរភាព។

**២.៧.៣. សន្ធិសញ្ញា** (Treaties)[23]៖ ក្នុងឆ្នាំ១៩៩៦កិច្ចព្រមព្រៀងអន្តរជាតិស្តីអំពីសិទ្ធិប្រជាជន និងសិទ្ធិនយោបាយ (ICCPR) និងកិច្ចព្រមព្រៀងស្តីអំពីសិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម និងសិទ្ធិវប្បធម៌ (ICESCR) ត្រូវបានអនុវត្តន៍

[23] https://km.wikipedia.org/wiki

ដោយសហប្រជាជាតិ រវាងកិច្ចព្រមព្រៀងនីមួយៗក្នុងការបង្កើតសិទ្ធិដែលមាននៅក្នុង UDHR ដើម្បីចងភ្ជាប់ទៅនឹងរដ្ឋទាំងអស់ដែលបានចុះហត្ថលេខាក្នុងសិន្ធិសញ្ញានេះគឺការបង្កើតច្បាប់នៃសិទ្ធិមនុស្ស។

ចាប់តាំងពីពេលនោះមកមានសិន្ធិសញ្ញាជាច្រើនផ្សេងៗគ្នា (បណ្ដុំនៃនីតិបញ្ញាតិ) ត្រូវបានចាត់ចូលជាថ្នាក់អន្តរជាតិ។សិន្ធិសញ្ញាទាំងនេះត្រូវបានគេស្គាល់ថាជាមូលដ្ឋានគ្រឹះនៃសិទ្ធិមនុស្ស។ សេចក្ដីសំខាន់ៗក្នុងចំណោមសេចក្ដីសំខាន់ទាំងអស់ជាមួយ (ICCPR **និង** ICESCR) គឺយោងទៅលើ**សន្ធិសញ្ញាសំខាន់ចំនួន៧** ដូចជា៖

- កិច្ចព្រមព្រៀងស្ដីអំពី ការលុបបំបាត់ការប្រកាន់ពូជសាសន៍
- កិច្ចព្រមព្រៀងស្ដីអំពី ការលុបបំបាត់ទំរង់នៃការរើសអើងស្ត្រី
- កិច្ចព្រមព្រៀងរបស់សហប្រជាជាតិស្ដីអំពី ការប្រយុទ្ធប្រឆាំងការធ្វើទារុណកម្ម

**២.៧.៤. សេចក្ដីប្រកាសជាសកលស្ដីអំពីសិទ្ធិមនុស្ស៖** ដោយយល់ឃើញថា ការទទួលស្គាល់សេចក្ដីថ្លៃថ្នូរជាប់ពីកំណើត និងសិទ្ធិស្មើភាព និងសិទ្ធិមិនអាចលក់ដូរ ផ្ទេរ ឬដកហូតបាន របស់សមាជិកទាំងអស់នៃគ្រួសារមនុស្សគឺជាគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាព ក្នុងពិភពលោក។

ដោយយល់ឃើញថាការមិនទទួលស្គាល់ និងការប្រមាថមើលងាយសិទ្ធិមនុស្សនាំឲ្យមានអំពើព្រៃផ្សៃ សាហាវយង់ឃ្នងធ្វើឱ្យក្ដៅក្រហាយដល់សតិសម្បជញ្ញៈមនុស្សជាតិនិងថាការឈានដល់ពិភពលោកមួយដែលមនុស្សទាំងឡាយមានសេរីភាពត្រូវបានប្រកាសថាជាសេចក្ដីប្រាថ្នាដ៏ខ្ពង់ខ្ពស់បំផុតរបស់មនុស្ស ត្រូវតែទទួលបានការការពារដោយនីតិរដ្ឋ ដើម្បីជៀសវាងកុំឱ្យមនុស្សបង្ខំចិត្តជាចុងក្រោយបង្អស់ បះបោរប្រឆាំងទល់នឹងអំណាចផ្ដាច់ការ និងការគាបសង្កត់។

ដោយយល់ឃើញថា ជាការចាំបាច់ដែលត្រូវលើកស្ទួយការពង្រីកទំនាក់ទំនងជាមិត្តភាពរវាងប្រជាជាតិនានា និងដោយ យល់ឃើញថាប្រជាជាតិទាំងឡាយនៃសហប្រជាជាតិបានប្រកាសបញ្ជាក់សារជាថ្មីក្នុងធម្មនុញ្ញសហប្រជាជាតិ នូវជំនឿរបស់ខ្លួនទៅលើមូលដ្ឋាននៃមនុស្ស លើសេចក្ដីថ្លៃថ្នូរ លើតម្លៃរបស់មនុស្ស និងលើសមភាពនៃសិទ្ធិរវាងបុរស និងស្ត្រី ហើយប្ដេជ្ញាលើកស្ទួយវឌ្ឍនភាពសង្គម និងកម្រិតជីវភាពរស់នៅឱ្យកាន់តែប្រសើរឡើង ក្នុងសេរីភាពកាន់តែទូលំទូលាយ។

ដោយយល់ឃើញថា ដោយសហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិ រដ្ឋជាសមាជិកទាំងអស់សន្យាធ្វើឱ្យមានការគោរពជាសកល និងការប្រតិបត្តិនូវសិទ្ធិ សិរីភាពមូលដ្ឋាន និងដោយយល់ឃើញថា ការយល់ដូចគ្នាអំពីសិទ្ធិ និងសេរីភាពទាំងនេះមានសារសំខាន់បំផុត ដើម្បីបំពេញនូវការសន្យាខាងលើ។ អាស្រ័យហេតុនេះមហាសន្និបាតប្រកាសថា៖

សេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស ជាឧត្តមគតិរួមដែលប្រជាពលរដ្ឋគ្រប់ៗប្រទេស និង ប្រជាជាតិទាំងអស់ត្រូវធ្វើឱ្យបានសម្រេច ដើម្បីឱ្យបុគ្គលគ្រប់ៗរូប និងអង្គការសង្គមទាំងអស់ ត្រូវរក្សាខ្ជាប់ខ្លួនជានិច្ចក្នុងស្មារតីរបស់ខ្លួននូវសេចក្តីប្រកាសនេះ ខិតខំប្រឹប្រែងបណ្តុះបណ្តាលការគោរពសិទ្ធិ និងសេរីភាពទាំងនេះតាមរយៈការបង្រៀននិងការអប់រំ ហើយនឹងខំប្រឹងប្រែងជានាឱ្យមានការទទួលស្គាល់ និងការអនុវត្តជាសកល និងដោយស័ក្តិសិទ្ធិនូវសិទ្ធិនិងសេរីភាពដោយវិធានការជាតិ និងអន្តរជាតិ ដែលមានលក្ខណៈរីកចម្រើនជាលំដាប់ ទាំងក្នុងចំណោមប្រជាពលរដ្ឋនៃរដ្ឋសមាជិកទាំងក្នុងចំណោមប្រជាពលរដ្ឋ ដែនដីដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចនៃរដ្ឋទាំងនោះ។

**មាត្រា១៖** មនុស្សទាំងអស់កើតមកមានសេរីភាពនិងសមភាព ក្នុងផ្នែកសេចក្តីថ្លៃថ្នូរនិងសិទ្ធិ។ មនុស្សមានវិចារណញ្ញាណ និងសតិសម្បជញ្ញៈជាប់ពីកំណើត ហើយគប្បីប្រព្រឹត្តចំពោះគ្នាទៅវិញទៅមកក្នុងស្មារតីភាតរភាពជាបងប្អូន

**មាត្រា២៖** មនុស្សម្នាក់ៗអាចប្រើប្រាស់សិទ្ធិ និងសេរីភាពទាំងអស់ដែលមានចែង ក្នុងសេចក្តីប្រកាសនេះ ដោយគ្មានការប្រកាន់ បែងចែកបែបណាមួយ មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើត ជាតិ ឬទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃផ្សេងៗទៀតឡើយ។ លើសពីនេះ មិនត្រូវធ្វើការប្រកាន់ បែងចែកណាមួយ ដោយសំអាងទៅលើឋានៈខាងនយោបាយ ខាងដែនសមត្ថកិច្ច ឬខាងអន្តរជាតិរបស់ប្រទេស ឬដែនដី ដែលបុគ្គលណាម្នាក់រស់នៅ ទោះបីជាប្រទេស ឬដែនដីនោះឯករាជ្យក្តី ស្ថិតក្រោមអាណាព្យាបាលក្តី ឬគ្មានស្វយ័គ្រប់គ្រងក្តី ឬស្ថិតក្រោម ការដាក់កម្រិតផ្សេងទៀតណាមួយដល់អធិបតេយ្យភាពក្តី។

**មាត្រា៣៖** បុគ្គលម្នាក់ៗមានសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិភាពផ្ទាល់ខ្លួន។

**មាត្រា៤៖** គ្មានជនណាម្នាក់ត្រូវស្ថិតនៅក្នុងទាសភាព ឬស្ថិតក្នុងភាពជាអ្នកបម្រើដាច់ថ្លៃឡើយ។ ទាសភាព និងទាសពានិជ្ជកម្មតាមគ្រប់ទម្រង់ទាំងអស់ត្រូវហាមឃាត់។

**មាត្រា៥៖** គ្មានជនណាម្នាក់ត្រូវទទួលទារុណកម្ម ឬការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបបានឡើយ។

មាត្រា៦៖ ជនគ្រប់រូប មានសិទ្ធិឲ្យគេទទួលស្គាល់បុគ្គលិកលក្ខណៈគតិយុត្តរបស់ខ្លួននៅគ្រប់ទីកន្លែង។

មាត្រា៧៖ ជនគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិទទួលការការពារពីច្បាប់ស្មើៗគ្នា ដោយគ្មានការរើសអើង។ មនុស្សគ្រប់រូបមានសិទ្ធិទទួលការការពារស្មើៗគ្នា ប្រឆាំងនឹងការរើសអើងណាដែលរំលោភលើសេចក្តីប្រកាសនេះ ព្រមទាំងប្រឆាំង និងការញុះញង់ឲ្យមានការរើសអើង។

មាត្រា៨៖ មនុស្សគ្រប់រូបមានសិទ្ធិរកដំណោះស្រាយស័ក្តិសិទ្ធមួយ នៅចំពោះមុខសាលាជំរះក្តីជាតិ ដែលមានសមត្ថកិច្ច ចំពោះអំពើទាំងឡាយណាដែលរំលោភសិទ្ធិមូលដ្ឋានរបស់ខ្លួន ដែលត្រូវបានទទួលស្គាល់ ដោយរដ្ឋធម្មនុញ្ញ ឬដោយច្បាប់។

មាត្រា៩៖ គ្មានជនណាម្នាក់ត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬនិរទេសខ្លួនតាមអំពើចិត្តឡើយ។

មាត្រា១០៖ មនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នាពេញលេញ សុំឲ្យតុលាការឯករាជ្យ និងមិនលំអៀង ពិនិត្យរឿងក្តីរបស់ខ្លួនជាសាធារណៈ និងដោយសមធម៌ ដើម្បីសម្រេចលើសិទ្ធិនិងកាតព្វកិច្ច និងលើភាព សមហេតុផលនៃការចោទប្រកាន់ទាំងឡាយខាងបទព្រហ្មទណ្ឌមកលើខ្លួន។

មាត្រា១១៖ ១. ជនណាដែលជាប់ចោទ ពីបទល្មើសព្រហ្មទណ្ឌ ត្រូវសន្មតជាជនគ្មានទោសរហូត ដល់ពិរុទ្ធភាពត្រូវបានរកឃើញនៅក្នុងសវនាការជាសាធារណៈ ដែលមានការធានាចំបាច់ ដើម្បីឱ្យជននោះការពារខ្លួន។ ២. គ្មានជនណាម្នាក់ត្រូវបានផ្តន្ទាទោសពីបទល្មើសព្រហ្មទណ្ឌនៅពេលធ្វើអំពើ ឬមានការខកខាននេះ ដូចគ្នានេះដែរមិនត្រូវមានការផ្តន្ទាទោសឲ្យធ្ងន់ធ្ងរជាងទោសដែលបានកំណត់ឲ្យអនុវត្តក្នុងអំឡុងពេលដែលបទល្មើសបានកើតឡើងនោះឡើយ។

មាត្រា១២៖ គ្មានមនុស្សណាម្នាក់ត្រូវរងការរំលោភ ជ្រៀតជ្រែកតាមអំពើចិត្តក្នុងជីវិតឯកជន គ្រួសារ ទីលំនៅ ឬការឆ្លើយឆ្លង ឬការធ្វើឲ្យប៉ះពាល់ដល់កិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ខ្លួនបានឡើយ។ ជន គ្រប់រូបមានសិទ្ធិទទួលការការពារពីច្បាប់ ប្រឆាំងនឹងការជ្រៀតជ្រែក ឬការប៉ះពាល់បែបនេះ។

មាត្រា១៣៖ ១. មនុស្សគ្រប់រូបមានសិទ្ធិធ្វើដំណើរដោយសេរី និងមានសិទ្ធិជ្រើសរើស និវេសនដ្ឋានក្នុងរដ្ឋមួយ។ ២. មនុស្សគ្រប់រូប មានសិទ្ធិចាកចេញពីប្រទេសណាមួយ រួមទាំងប្រទេសរបស់ខ្លួនផង និងមានសិទ្ធិវិលត្រឡប់មកប្រទេសរបស់ខ្លួនវិញ។

មាត្រា១៤៖ ១. មនុស្សគ្រប់រូប មានសិទ្ធិស្វែងរក និងទទួលកន្លែងជ្រកកោនក្នុងប្រទេសដទៃទៀត ក្នុងករណីមានការធ្វើទុកបុកម្នេញមកលើខ្លួន។ ២.សិទ្ធិសុំជ្រកកោននេះមិនអាចលើកមកសំអាងបានទេ ក្នុងករណីមានការចោទប្រកាន់ដែលពិតជាកើតឡើងពីបទល្មើសមិនមែននយោបាយរបស់សហប្រជាជាតិ

**មាត្រា១៥៖** ១.មនុស្សគ្រប់រូបមានសិទ្ធិទទួលបានសញ្ជាតិមួយ។ ២.គ្មានជនណាម្នាក់ អាចត្រូវ ដកហូតសញ្ជាតិ ឬរារាំងសិទ្ធិប្តូរសញ្ជាតិរបស់ខ្លួនបានឡើយ។

**មាត្រា១៦៖** ១.មនុស្សប្រុសស្រីដល់អាយុគ្រប់ការ មានសិទ្ធិរៀបអាពាហ៍ពិពាហ៍ និងកសាងគ្រួសារ ដោយមិនប្រកាន់ពូជសាសន៍ សញ្ជាតិ ឬសាសនាឡើយ។ មនុស្សប្រុសស្រីមានសិទ្ធិស្មើគ្នា ក្នុងការរៀបអាពាហ៍ ពិពាហ៍ ក្នុងចំណងអាពាហ៍ពិពាហ៍ និងក្នុងពេលរំលាយចំណងអាពាហ៍ពិពាហ៍។ ២.អាពាហ៍ពិពាហ៍អាចនឹងប្រព្រឹត្តទៅបាន លុះត្រាតែមានការព្រមព្រៀងដោយសេរី និងពេញលេញពីអនាគតប្តី ប្រពន្ធ។ ៣. គ្រួសារជាអង្គភាពធម្មជាតិ និងជាអង្គភាពមូលដ្ឋាននៃសង្គម ហើយគ្រួសារមានសិទ្ធិទទួល ការការពារពីសង្គម និងរដ្ឋ។

**មាត្រា១៧៖** ១. មនុស្សគ្រប់រូបទោះតែម្នាក់ឯងក្តី ឬដោយរួមជាមួយអ្នកដ៏ទៃក្តី មានសិទ្ធិជាម្ចាស់ កម្មសិទ្ធិ។ ២. គ្មានជនណាម្នាក់ត្រូវបានដកហូតកម្មសិទ្ធិតាមអំពើចិត្តឡើយ។

**មាត្រា១៨៖** ជនគ្រប់រូប មានសិទ្ធិសេរីភាពខាងការគិត សតិសម្បជញ្ញៈ និងសាសនា សិទ្ធិនេះរាប់ បញ្ចូលទាំងសេរីភាពផ្លាស់ប្តូរសាសនា ឬជំនឿព្រមទាំងសេរីភាព សម្តែងសាសនា ឬជំនឿរបស់ខ្លួនតែម្នាក់ឯង ឬដោយរួមជាមួយអ្នកដ៏ទៃជាសាធារណៈ ឬជាឯកជន តាមការបង្ហាត់បង្រៀន ការអនុវត្ត ការគោរពបូជា និងការប្រតិបត្តិតាម។

**មាត្រា១៩៖** មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការមានមតិ និងការសម្តែងមតិ។ សិទ្ធិនេះរាប់ បញ្ចូលទាំងសេរីភាពក្នុងការប្រកាន់មតិ ដោយគ្មានការរជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែងរកការទទួល និងការផ្សព្វផ្សាយព័ត៌មាន និងគំនិតនានាដោយគ្មានព្រំដែនទឹកដី ទោះតាមរយៈមធ្យោបាយសម្តែង មតិ ណាមួយដ៏ដោយ។

**មាត្រា២០៖** ១.មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការប្រជុំ ឬការរួមគ្នាជាសមាគម ដោយសន្តិវិធី។ ២. គ្មានជនណាម្នាក់ ត្រូវបានបង្ខិតបង្ខំឱ្យចូលរួមក្នុងសមាគមណាមួយឡើយ។

**មាត្រា២១៖** ១. មនុស្សគ្រប់រូប មានសិទ្ធិចូលរួមក្នុងការដឹកនាំកិច្ចការសាធារណៈនៃ ប្រទេសរបស់ ខ្លួនដោយផ្ទាល់ ឬតាមរយៈតំណាងដែលបានជ្រើសរើសដោយសេរី។ ២. មនុស្សគ្រប់រូបមានសិទ្ធិ ចូលបម្រើមុខងារសារធារណៈនៃប្រទេសរបស់ខ្លួនក្នុងលក្ខខណ្ឌសមភាព។ ៣.ឆន្ទៈរបស់ប្រជាពលរដ្ឋជាមូលដ្ឋានអំណាចនៃការដឹកនាំកិច្ចការសាធារណៈ។ ឆន្ទៈនេះត្រូវសម្តែងចេញតាមរយៈការបោះឆ្នោតទៀងទាត់ តាមពេលកំណត់ និងពិតប្រាកដដែលមានលក្ខណៈសកល ស្មើភាព និងសម្ងាត់ ឬតាមនីតិវិធីសមមូល ដែលធានាសេរីភាពនៃការបោះឆ្នោត។

មាត្រា២២៖ ក្នុងឋានៈជាសមាជិកនៃសង្គមមនុស្សគ្រប់រូប មានសិទ្ធិទទួលបានសន្តិសុខសង្គម និងមានបុព្វសិទ្ធិសម្រេចបានសិទ្ធិខាងសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលចាំបាច់សម្រាប់សេចក្តីថ្លៃថ្នូរ និងការរីកចំរើនដោយសេរីនៃបុគ្គលិកលក្ខណៈរបស់ខ្លួនតាមរយៈការខិតខំរបស់ជាតិ និងសហប្រតិបត្តិ ការអន្តរជាតិ និងដោយយោងទៅតាមការរៀបចំ និងធនធានរបស់ប្រទេសនីមួយៗ។

មាត្រា២៣៖ ១. មនុស្សគ្រប់រូបមានសិទ្ធិ មានការងារធ្វើ ជ្រើសរើសការងារដោយសេរី ទទួលលក្ខ ណ្ឌការងារត្រឹមត្រូវ និងពេញចត្ត និងមានការការពារប្រឆាំង នឹងភាពអត់ការងារធ្វើ។ ២. មនុស្សគ្រប់រូបមានសិទ្ធិទទួលប្រាក់បៀវត្សស្មើគ្នាចំពោះការងារដូចគ្នាដោយគ្មានការរើសអើង ៣.អ្នកធ្វើការងារ មានសិទ្ធិទទួលបានលាភការដោយសមធម៌ និងពេញចិត្ត ដើម្បីធានាអត្ថិភាពរស់នៅរបស់ខ្លួន និងគ្រួសារឲ្យសមស្រប នឹងសេចក្តីថ្លៃថ្នូរនៃមនុស្ស និងត្រូវបានបំពេញបន្ថែមទៀត ដោយមធ្យោបាយផ្សេងៗនៃការការពារផ្នែកសង្គមប្រសិនបើចាំបាច់។ ៤. មនុស្សគ្រប់រូបមានសិទ្ធិ បង្កើតសហជីព និងចូលរួមក្នុងសហជីព ដើម្បីការពារផលប្រយោជន៍របស់ខ្លួន។

មាត្រា២៤៖ មនុស្សគ្រប់រូប មានសិទ្ធិឈប់សម្រាក និងលំហែកាយ កំសាន្ត រួមបញ្ចូលទាំងកម្រិតម៉ោងការងារសមហេតុផល និងការឈប់សម្រាកដោយបានប្រាក់បៀវត្សតាមពេលកំណត់ទៀងទាត់។

មាត្រា២៥៖ ១.មនុស្សគ្រប់រូប មានសិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់ ដើម្បីធានាសុខភាព និងសុខមាលភាពរបស់ខ្លួន និងគ្រួសារ រួមមានចំណីអាហារ សម្លៀកបំពាក់ លំនៅដ្ឋាន ការថែទាំសុខភាព និងសង្គមកិច្ចចាំបាច់ផ្សេងៗទៀតផង។ មនុស្សគ្រប់រូប មានសិទ្ធិទទួលបានការគាំពារ នៅពេលគ្មានការងារធ្វើ មានជំងឺ ពិការ មេម៉ាយ ឬពោះម៉ាយ ចាស់ជរា ឬនៅពេលបាត់បង់មធ្យោបាយធានាជីវភាព ដែល បណ្តាលមកពីកាលៈទេសៈផុតពីឆន្ទៈរបស់ខ្លួន។ ២. មាតុភាព និងកុមារភាព មានសិទ្ធិទទួលជំនួយ និង ការថែទាំពិសេស។ កុមារគ្រប់រូប ទោះកើតពីឪពុកម្តាយមានខាន់ស្លា ឬឥតខាន់ស្លាក្តីត្រូវបានទទួលការ ការពារខាងសង្គមកិច្ចដូចគ្នា។

មាត្រា២៦៖ ១. មនុស្សគ្រប់រូប មានសិទ្ធិទទួលបានការអប់រំ។ ការអប់រំត្រូវឥតបង់ថ្លៃ យ៉ាងហោច ណាស់សម្រាប់ការអប់រំបឋមសិក្សា និងអប់រំមូលដ្ឋាន។ ការអប់រំបឋមសិក្សាគឺជាកាតព្វកិច្ច។ ការអប់រំខាងបច្ចេកទេស និងវិជ្ជាជីវៈត្រូវរៀបចំឱ្យមានជាទូទៅ។ ការអប់រំឧត្តមសិក្សាត្រូវបើកឱ្យចូលរៀនស្មើភាពគ្នា ដោយឈរលើមូលដ្ឋានសមត្ថភាព។ ២. ការអប់រំ ត្រូវសំដៅទៅរកការរីកលូតលាស់ពេញលេញនៃបុគ្គលិកលក្ខណៈរបស់មនុស្ស និងការពង្រឹងការគោរពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ការអប់រំនេះ ត្រូវលើកកម្ពស់ការយល់ដឹង ការអត់ឱនអធ្យាស្រ័យគ្នា និងមិត្តភាពរវាងប្រជាជាតិ និងក្រុមពូជសាសន៍ ឬក្រុមសាសនាទាំងអស់ ព្រមទាំងការអភិវឌ្ឍ សកម្មភាពរបស់

សហប្រជាជាតិ ក្នុងការថែរក្សាសន្តិភាព។ ៣. មាតាបិតា មានសិទ្ធិជាអាទិភាពក្នុងការជ្រើសរើសប្រភេទនៃការអប់រំសម្រាប់បុត្រធីតារបស់ខ្លួន។

**មាត្រា២៧៖** ១. មនុស្សគ្រប់រូប មានសិទ្ធិចូលរួម ដោយសេរី ក្នុងជីវភាពវប្បធម៌ របស់សហគមន៍ អាស្រ័យផលសិល្បៈ និងចូលរួមចំណែកក្នុងវឌ្ឍនភាពវិទ្យាសាស្ត្រ និងក្នុងផលប្រយោជន៍ ដែលបានមកពីវឌ្ឍនភាពនេះ។ ២. មនុស្សគ្រប់រូប មានសិទ្ធិទទួលការការពារផលប្រយោជន៍ខាងសីលធម៌ និងសម្ភារៈ ដែលបានមកពីផលិតកម្មខាងវិទ្យាសាស្ត្រ និងអក្សរសាស្ត្រ ឬសិល្បៈដែលជាស្នាដៃរបស់ខ្លួន។

**មាត្រា២៨៖** មនុស្សគ្រប់រូបមានសិទ្ធិទទួលបាននូវសណ្តាប់ធ្នាប់សង្គម និងអន្តរជាតិដែលធ្វើឱ្យសិទ្ធិ និងសេរីភាព ចែងក្នុងសេចក្តីប្រកាសនេះអាចសំរេចបានដោយពេញលេញ។

**មាត្រា២៩៖** ១.មនុស្សគ្រប់រូបមានករណីកិច្ចចំពោះសហកមន៍ ដែលជាកន្លែងតែមួយគត់ដែល អាចបង្កើតបានការរីកចម្រើនដោយសេរី និងពេញបរិបូរណ៍ នូវបុគ្គលិកលក្ខណៈរបស់ខ្លួន។ ២.ក្នុងការប្រើប្រាស់សិទ្ធិ និងសេរីភាពរបស់ខ្លួន មនុស្សគ្រប់រូបត្រូវស្ថិតនៅត្រឹមតែកំរិតព្រំដែនដែលច្បាប់បានកំណត់ សំរាប់ការទទួលស្គាល់និងការគោរពសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ និងបំពេញសេចក្តីត្រូវការយ៉ាងត្រឹមត្រូវខាងសីលធម៌ សណ្តាប់ធ្នាប់សាធារណៈ និងសុខុមាលភាពទូទៅ នៅក្នុងសង្គមប្រជាធិបតេយ្យតែប៉ុណ្ណោះ ។ ៣.តែយ៉ាងណាក៏ដោយសិទ្ធិ និងសេរីភាពទាំងនេះ មិនអាចយកទៅប្រើផ្ទុយ និងគោលបំណងនិងគោលការណ៍ទាំងឡាយរបស់សហប្រជាជាតិឡើយ។

**មាត្រា៣០៖** គ្មានបទបញ្ញត្តិណាមួយនៃសេចក្តីប្រកាសនេះ អាចត្រូវបានបកស្រាយតម្រូវថា រដ្ឋណាមួយ ក្រុមណាមួយ ឬបុគ្គលណាម្នាក់ មានសិទ្ធិបែបណាមួយក្នុងការធ្វើសកម្មភាព ឬការប្រព្រឹត្តិអំពើអ្វីមួយដែលសំដៅទៅបំផ្លិចបំផ្លាញនូវសិទ្ធិ និងសេរីភាពទាំងឡាយ ដែលមានចែងនៅក្នុងសេចក្តីប្រកាសនេះឡើយ។

បើយោងតាមគេហទំព័រចំណេះដឹងទូទៅ https://www.khsearch.com/qna/12950 និងសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស ប្រជាពលរដ្ឋកម្ពុជាមានសិទ្ធសំខាន់ៗមួយចំនួនដូចជា៖

**ក. សិទ្ធិពលរដ្ឋ៖** ជាសិទ្ធិរបស់មនុស្សក្នុងការរស់នៅនិងការពារខ្លួនស្របច្បាប់ ស្របតាមវប្បធម៌ទំនៀមទម្លាប់របស់ជាតិ។

**ខ. សិទ្ធិនយោបាយ៖** គឺសំដៅលើការចូលរួមចំណែកក្នុងឆាកនយោបាយ ការចូលរួមចំណែកក្នុងកិច្ចការសង្គម

ផ្សេងៗ និងការចូលរួមកំណត់វាសនាប្រទេសជាតិរបស់ខ្លួន(សិទ្ធិចូលរួមបោះឆ្នោត សិទ្ធិក្នុងការបញ្ចេញមតិ...)។

**គ. សិទ្ធិសេដ្ឋកិច្ច៖** ជាសិទ្ធិដែលផ្តល់ និងអនុញ្ញាតិឱ្យប្រជាពលរដ្ឋមានការអភិវឌ្ឍផ្នែកជីវភាព ទ្រព្យសម្បត្តិ ក្នុងបំណងលើកតំកើងសុខមាលភាពប្រជាពលរដ្ឋ ។

**ឃ. សិទ្ធិសង្គមកិច្ច៖** ជាសិទ្ធិដែលផ្តល់ការគាំទ្រដល់ប្រជាពលរដ្ឋឱ្យទទួលបាននូវសន្តិសុខ សន្តិភាព និងសុខភាព។

**ង. សិទ្ធិវប្បធម៌៖** ជាសិទ្ធិដែលផ្តល់ដល់ប្រជាពលរដ្ឋដើម្បីចូលរួមថែរក្សាទំនៀមទម្លាប់ ប្រពៃណី អក្សរសាស្ត្រនិងច្បាប់ទម្លាប់ផ្សេងៗ(ចំណេះដឹងទូទៅ, 2018-12-24)[24] ។

**២.៧.៥. សន្ធិសញ្ញាសិទ្ធិមនុស្ស អ.ស.ប៖** កម្ពុជាបានក្លាយជាភាគីនៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ និងពិធីសារបន្ថែមលើសន្ធិសញ្ញា ដូចខាងក្រោម៖

- កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ICESCR)
- កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)
- អនុសញ្ញាអន្តរជាតិ ស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (ICERD)
- អនុសញ្ញាស្តីពីការបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី (CEDAW) និងពិធីសារបន្ថែមលើអនុសញ្ញា នេះ
- អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប (CAT) និងពិធីសារបន្ថែមលើអនុសញ្ញានេះ
- អនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC) ពិធីសារបន្ថែមលើអនុសញ្ញានេះស្តីពីការលក់កុមារ ពេស្យាកម្មកុមារ និងកាមសាស្ត្រកុមារ និងពិធីសារបន្ថែមលើអនុសញ្ញានេះ ស្តីពីការពាក់ព័ន្ធនៅក្នុងជំលោះប្រដាប់អាវុធ
- អនុសញ្ញាស្តីពីសិទ្ធិជនពិការ
- អនុសញ្ញាស្តីពីការការពារមនុស្សគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ។

តាមរយៈការទទួលយកសន្ធិសញ្ញាទាំងនេះ រដ្ឋាភិបាលបានសន្យាភ្ជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ក្នុងការអនុវត្តសិទ្ធិទាំងឡាយដែលមានចែងក្នុងសន្ធិសញ្ញា ដើម្បីជាប្រយោជន៍ដល់មនុស្សគ្រប់រូប នៅប្រទេសកម្ពុជា។

[24] https://www.khsearch.com/qna/12950

រដ្ឋភាគីទាំងឡាយនៃសន្ធិសញ្ញាសិទ្ធិមនុស្សត្រូវដាក់បញ្ជូនរបាយការណ៍ជាទៀងទាត់ ទៅអង្គការសហប្រជាជាតិ ស្ដីពីរបៀបអនុវត្តសិទ្ធិក្នុងសន្ធិសញ្ញានេះ។ របាយការណ៍ទាំងនេះត្រូវបានពិនិត្យឡើងវិញ ដោយគណៈកម្មាធិការជំនាញឯករាជ្យដែលជារឿយៗគេហៅថាជា"ស្ថាប័នសន្ធិសញ្ញា"។ គណៈកម្មាធិការនេះពិនិត្យរបាយការណ៍នីមួយៗ និងដោះស្រាយកង្វល់ដែលមានក្នុងរបាយការណ៍ ហើយដាក់ចេញជាអនុសាសន៍ផ្សេងៗជូនទៅរដ្ឋភាគីក្នុងរូបភាពជា"សេចក្ដីសន្និដ្ឋានចុងក្រោយ"។ គោលបំណងនៃដំណើរការនេះមិនមែនដើម្បីរិះគន់រដ្ឋាភិបាលនោះទេ ប៉ុន្តែដើម្បីផ្ដល់ប្រឹក្សាយោបល់ក្នុងន័យស្ថាបនា ពីមធ្យោបាយដែលប្រទេសនានាអាចធ្វើឱ្យមានវឌ្ឍនភាពកាន់តែប្រសើរឡើង ឆ្ពោះទៅរកការធានាថាមនុស្សគ្រប់រូបអាចប្រើប្រាស់សិទ្ធិទាំងឡាយដែលមានចែងក្នុងសន្ធិសញ្ញានេះ។

ស្ថាប័នសន្ធិសញ្ញានេះ មិនពឹងផ្អែកទាំងស្រុងលើព័ត៌មានដែលបានផ្ដល់នៅក្នុងរបាយការណ៍របស់រដ្ឋាភិបាល ដើម្បីធ្វើការវាយតម្លៃនោះទេ។ គណៈកម្មាធិការបើកចំហផងដែរ ចំពោះការដាក់ស្នើពីអង្គការក្រៅរដ្ឋាភិបាល ជាតិ និងអន្តរជាតិក៏ដូចជាទីភ្នាក់ងារអង្គការសហប្រជាជាតិ ដូចជាអង្គការសុខភាពពិភពលោក (WHO) ឬអង្គការពលកម្មអន្តរជាតិ(ILO)(អង្គការសហប្រជាជាតិ, សិទ្ធិមនុស្ស, ការិយាល័យឧត្តមស្នងការ,កម្ពុជា, Jun 2017)[25]។

[25] https://cambodia.ohchr.org/kh/treaty-based-bodies

# ឯកសារយោង

## ក. ភាសាខ្មែរ


១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
២. រដ្ឋសភា, បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
៣. បណ្ឌិត ហែម ឡាច,មន្រ្តីស្រាវជ្រាវវិទ្យាស្ថានមនុស្ស និងវិទ្យាសង្គមនៃរាជបណ្ឌិតសភាកម្ពុជា ស្ថាប័ននីតិប្បញ្ញត្តិ(១៩៩៣-២០១៨)
៤. អង្គការតម្លាភាពកម្ពុជា,ការវាយតម្លៃប្រព័ន្ធសុចរិតភាពថ្នាក់ជាតិ ២០១៤, អំពើពុករលួយ និងប្រព័ន្ធអភិបាលកិច្ចប្រទេសកម្ពុជា
៥. https://www.tourismcambodia.com/about-cambodia/government.htm
៦. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, Exported from Wikisource on October 10, 2022,
៧. មេរៀនសីលធម៌ពលរដ្ឋថ្នាក់ទី១១ ឆ្នាំ២០១១
៨. មេរៀនសីលធម៌ពលរដ្ឋថ្នាក់ទី១២ ឆ្នាំ ២០១៤


## ខ. ភាសាបរទេស


[1] (Irina Bokova, Navanethem Pillay, 2012). wORLD PROGRAMME FOR HUMAN RIGHTS EDUCATION, Second Phase, Plan of Action
[2] Irina Bokova, Navanethem Pillay, 2012). WORLD PROGRAMME FOR HUMAN RIGHTS EDUCATION, Second Phase, Plan of Action
[3] (Compasito). Preamble, Universal Declaration of Human Rights
[4] (Flowers Nancy, Bernbaum Marcia, Rudelius-Palmer Kristi, and Tolman Joel.2000). he Human Rights Education Handbook: Effective Practices for Learning, Action, and Change
[5] (Flowers Nancy, Bernbaum Marcia, Rudelius-Palmer Kristi, and Tolman Joel.2000). he Human Rights Education Handbook: Effective Practices for Learning, Action, and Change
[6] (Natalie Bugalski, 2011). Civics: An Introduction to Law, Rights and Democracy for Cambodian Citizens,
[7] (Natalie Bugalski, 2011) Civics: An Introduction to Law, Rights and Democracy for Cambodian Citizens
[8] (Natalie Bugalski, 2011) Civics: An Introduction to Law, Rights and Democracy for Cambodian Citizens
[9] (Natalie Bugalski, 2011) Civics: An Introduction to Law, Rights and Democracy for Cambodian Citizens
https://km.wikipedia.org/wikiសិទ្ធិមនុស្ស
https://km.wikipedia.org/wiki
https://www.khsearch.com/qna/12950
https://cambodia.ohchr.org/kh/treaty-based-bodies

# មេរៀនទី៣៖
# ប្រព័ន្ធអំណាចនៃការគ្រប់គ្រងរដ្ឋ

**UNDERLYING ASSUMPTIONS AND POWER DYNAMICS**

( Mr. Thai Heng, Dr. Mam Chansean, Mr. Chan Bunthan, and Mr. Loch Chanthan )

## ផ្នែកទី១៖ ស្ថាប័ននីតិប្បញ្ញត្តិ-ព្រឹទ្ធសភាកម្ពុជា

នៅក្នុងផ្នែកទី១នេះ បរិយាយអំពីព្រឹទ្ធសភាកម្ពុជា ការរៀបចំ និងការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភា លក្ខខណ្ឌ និងកិច្ចដំណើរការនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា លក្ខខណ្ឌ និងកិច្ចដំណើរការនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ភាពខុសគ្នារវាងរដ្ឋសភា និងព្រឹទ្ធសភា នីតិវិធីនៃការពិនិត្យនិងឱ្យយោបល់ ឋានៈ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិសមាជិកព្រឹទ្ធសភា។

**ក. វត្ថុបំណងមេរៀន៖** ក្រោយពីបញ្ចប់ការសិក្សាមេរៀនស្តីពីព្រឹទ្ធសភាកម្ពុជា អ្នកសិក្សាអាចនឹង៖

| | |
|---|---|
| **វិជ្ជាសម្បទា/ពុទ្ធិ៖** | យល់ដឹងអំពីរបៀបរៀបចំច្បាប់ ការគ្រប់គ្រង ដឹកនាំរបស់ព្រឹទ្ធសភានៃប្រទេសកម្ពុជា។ |
| **បំណិនសម្បទា/ចិត្ត-សង្គម៖** | ប្រើប្រាស់ តម្លៃ គំនិត ចំណេះដឹងអំពីព្រឹទ្ធសភានៃប្រទេសកម្ពុជាប្រកបដោយទំនួលខុសត្រូវខ្ពស់។ |
| **ចរិយាសម្បទា/ឥរិយាបថ៖** | ស្រលាញ់ចូលចិត្ត ចូលរួមគោរពឱ្យតម្លៃស្ថាប័នព្រឹទ្ធសភានៃប្រទេសកម្ពុជាប្រកបដោយទំនួលខុសត្រូវ។ |

**ខ. វិធីសាស្រ្តបង្រៀន៖** សិស្សមជ្ឈមណ្ឌល បែបពិភាក្សា និងការងារក្រុម

**គ. សម្ភារៈឧបទ្ទេស៖** មេរៀនស្តីពី**ព្រឹទ្ធសភាកម្ពុជា** ដែលរៀបចំដោយក្រុមការងារ GCED នៃវិទ្យាស្ថានជាតិអប់រំ និងឯកសារយោងដែលពាក់ព័ន្ធ..

## ១. ការរៀបចំ និងប្រព្រឹត្តទៅរបស់ព្រឹទ្ធសភា

ការរៀបចំ និងការប្រព្រឹត្តទៅនៃព្រឹទ្ធសភាត្រូវបានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា។ ព្រឹទ្ធសភាបើកសម័យប្រជុំដំបូងនៃនីតិកាលនីមួយៗ៦០ថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។ ព្រះមហាក្សត្រ ឬព្រះរាជតំណាងទ្រង់ប្រទាន ឬផ្តល់កិត្តិយស ចំពោះការបើកសម័យប្រជុំដំបូង នៃនីតិកាលនីមួយៗ។

ក្រោយពីព្រះមហាក្សត្រ ឬព្រះរាជតំណាងទ្រង់បានឬបានបើកនីតិកាលព្រឹទ្ធសភារួចហើយ បើព្រឹទ្ធសភាមានសមាជិកវត្តមានលើសពីពាក់កណ្តាលនៃចំនួនសមាជិកទាំងមូល ព្រឹទ្ធសភាអាចដំណើរការបន្តក្រោមអធិបតីភាពនៃប្រធានបណ្តោះអាសន្ន១រូប ជាសមាជិកព្រឹទ្ធសភាជាប់ឆ្នោតឬចាត់តាំងអាយុច្រើនជាងគេដែលវត្តមាន ហើយឥតមានបណ្តឹងតវ៉ា ព្រមទាំងសមាជិកព្រឹទ្ធសភាជាប់ឆ្នោត ឬចាត់តាំងចំនួន៥រូប អាយុតិចជាងគេ ដែលវត្តមានជាលេខាធិការ ដើម្បីជួយប្រធានក្នុងការងារ។ ក្រោមការដឹកនាំរបស់ប្រធានបណ្តោះអាសន្ននេះព្រឹទ្ធសភា ត្រូវចាប់ផ្តើមការងារដូចតទៅ៖

ក. ប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ។

ខ. បោះឆ្នោតជ្រើសរើសប្រធាន និងអនុប្រធានទាំងពីររបស់ព្រឹទ្ធសភា។

មិនអាចជជែកពិភាក្សាអ្វីឡើយ នៅក្រោមអធិបតីភាពរបស់ប្រធានបណ្តោះអាសន្ន។ សមាជិកព្រឹទ្ធសភាទាំងអស់ត្រូវធ្វើសច្ចាប្រណិធានមុនពេលចូលកាន់តំណែង។ មុនចាប់ផ្តើមការងារ ក្រោមអធិបតីភាពនៃប្រធានរបស់ខ្លួន ព្រឹទ្ធសភាដំណើរការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មការនានាដាច់ដោយឡែកពីគ្នា តាមវិធីបោះឆ្នោតសម្ងាត់ និងអនុម័តបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃព្រឹទ្ធសភា ដោយសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។ គណៈកម្មការនីមួយៗ មានសមាជិកយ៉ាងតិចចំនួន០៥រូប។

ក្រោយពីបានទទួលការគាំទ្រពីអង្គព្រឹទ្ធសភារួចហើយ មុនចាប់ផ្តើមការងាររបស់ខ្លួនគណៈកម្មការនីមួយៗត្រូវប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីបោះឆ្នោតសម្ងាត់ជ្រើសតាំង ប្រធាន អនុប្រធាន និងលេខាធិការរបស់គណៈកម្មការនីមួយៗ។ គណៈកម្មការនីមួយៗ ត្រូវកំណត់តួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនឱ្យស្របនឹងរដ្ឋធម្មនុញ្ញ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងច្បាប់ជាធរមាន រួចដាក់ជូនគណៈកម្មាធិការ អចិន្ត្រៃយ៍ពិនិត្យ និងសម្រេច។

## ២. លក្ខខណ្ឌ និងកិច្ចដំណើរការនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

ការរៀបចំបែបបទ និងការប្រព្រឹត្តទៅនៃការចាត់តាំង និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ព្រមទាំងការកំណត់អំពី អ្នកបោះឆ្នោត អង្គបោះឆ្នោត និងមណ្ឌលបោះឆ្នោត កំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាត្រូវធ្វើឡើង០៦(ប្រាំមួយ)ឆ្នាំម្តងនៅថ្ងៃអាទិត្យសប្តាហ៍ទី៨ មុនដំណាច់ឆ្នាំទី៦នៃនីតិកាលព្រឹទ្ធសភា លើកលែងតែក្នុងករណីដែលមានចែងក្នុងបទប្បញ្ញត្តិ មាត្រា១០២ថ្មី នៃរដ្ឋធម្មនុញ្ញ។

កាលបរិច្ឆេទនៃការបោះឆ្នោតត្រូវកំណត់ និងប្រកាសដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ នីតិកាលព្រឹទ្ធសភាត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង។ ព្រឹទ្ធសភា មានចំនួនសមាជិកយ៉ាងច្រើន ស្មើនឹងពាក់កណ្តាលនៃចំនួន សមាជិករដ្ឋសភាទាំងមូល។ សមាជិកព្រឹទ្ធសភាចំនួន២ (ពីរ) រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ។ សមាជិកព្រឹទ្ធសភាចំនួន២ (ពីរ) រូប ត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើនដោយប្រៀបសមាជិកព្រឹទ្ធសភាឯទៀត ត្រូវជ្រើសតាំងដោយការបោះឆ្នោតអសកល មិនចំពោះតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់។

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាត្រូវអនុវត្តតាមប្រព័ន្ធសមាមាត្រ និងការបែងចែកអាសនៈ តាមមណ្ឌលត្រូវធ្វើតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ដូចមានកំណត់ក្នុងមាត្រា១៣៥ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ មណ្ឌលបោះឆ្នោតរបស់សមាជិកព្រឹទ្ធសភាមានចំនួន៨ភូមិភាគ។ សមាជិកព្រឹទ្ធសភាក្នុងព្រឹទ្ធ សភាគឺជាតំណាងរបស់ប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងឲ្យភូមិភាគរបស់ខ្លួននោះទេ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសមត្ថកិច្ចគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានា ការពារការ គោរពរដ្ឋធម្មនុញ្ញបកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ។ ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និងសម្រេចអំពីករណីវិវាទកម្មទាក់ទងនឹង ការបោះឆ្នោតជ្រើសតាំង តំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។ រាយការណ៍ជូនព្រឹទ្ធសភា ឬជូនគណៈ កម្មាធិការអចិន្ត្រៃយ៍ ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំព្រឹទ្ធសភាជាបន្ទាន់ដើម្បីសម្រេច។ ក្នុងករណីទាំងអស់ខាងលើនេះការឃុំខ្លួន ការចោទ ប្រកាន់សមាជិកព្រឹទ្ធសភាណាមួយត្រូវផ្អាក ប្រសិនបើព្រឹទ្ធសភាបញ្ចេញមតិ ឱ្យផ្អាកតាមមតិភាគច្រើនបីភាគបួន នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។ ក្នុងនីតិកាលរបស់ព្រឹទ្ធសភា អាសនៈរបស់សមាជិកព្រឹទ្ធសភាត្រូវប្រកាសថានៅទំនេរក្នុងករណីលាលែង បោះបង់ចោលការងារ មកពីវិសមិតភាព ប្រាសចាក សមាជិកភាព ឬទទួលអនិច្ចកម្ម។ អាសនៈរបស់ សមាជិកព្រឹទ្ធសភា ដែលនៅទំនេរយ៉ាងតិច៦ខែ មុនចប់នីតិកាលត្រូវបំពេញជំនួសដោយសមាជិកថ្មី ចេញពីប្រភពដើម ដែលមានអាសនៈ ទំនេរនោះដោយមិនចាំបាច់បោះឆ្នោតសារឡើងវិញ។

មុខងារជា សមាជិកព្រឹទ្ធសភា មានវិសមិតភាពជាមួយមុខងារ សមាជិករដ្ឋសភា សមាជិករាជរដ្ឋាភិបាល សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ និងវិសមិតភាពជាមួយនឹងការបំពេញមុខងារសាធារណៈជាសកម្ម រួមទាំងការប្រកបការងារក្នុង

វិជ្ជាជីវៈសេរីផងដែរ។

## ៣. លក្ខខណ្ឌ និងកិច្ចដំណើរការនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

ការរៀបចំបែបបទនិងការប្រព្រឹត្តទៅនៃការចាត់តាំង និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ព្រមទាំងការកំណត់អំពី អ្នកបោះឆ្នោត អង្គបោះឆ្នោត និងមណ្ឌលបោះឆ្នោត កំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាត្រូវធ្វើឡើង០៦(ប្រាំមួយ)ឆ្នាំម្តង នៅថ្ងៃអាទិត្យសប្តាហ៍ទី៨ មុនដំណាច់ឆ្នាំទី៦ នៃនីតិកាលព្រឹទ្ធសភា លើកលែងតែក្នុងករណីដែលមានចែងក្នុងបទប្បញ្ញត្តិ មាត្រា១០២ថ្មី នៃរដ្ឋធម្មនុញ្ញ។កាលបរិច្ឆេទនៃការបោះឆ្នោតត្រូវកំណត់ និងប្រកាសដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ នីតិកាលព្រឹទ្ធសភាត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង។ ព្រឹទ្ធសភាមានចំនួនសមាជិកយ៉ាងច្រើនស្មើនឹងពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ សមាជិកព្រឹទ្ធសភាចំនួន២ (ពីរ) រូប ត្រូវបានចាត់តាំង ដោយព្រះមហាក្សត្រ។ សមាជិកព្រឹទ្ធសភាចំនួន២ (ពីរ) រូប ត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើនដោយប្រៀបសមាជិកព្រឹទ្ធសភាឯទៀត ត្រូវជ្រើសតាំងដោយការបោះឆ្នោតអសកល មិនចំពោះតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់។ ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវអនុវត្តតាមប្រព័ន្ធសមាមាត្រនិងការបែងចែកអាសនៈតាមមណ្ឌល ត្រូវធ្វើតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ដូចមានកំណត់ក្នុងមាត្រា១៣៥ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ មណ្ឌលបោះឆ្នោតរបស់សមាជិកព្រឹទ្ធសភាមានចំនួន៨ភូមិភាគ។ សមាជិកព្រឹទ្ធសភាក្នុងព្រឹទ្ធសភាគឺជាតំណាងរបស់ប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងឲ្យភូមិភាគរបស់ខ្លួននោះទេ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសមត្ថកិច្ចគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ ក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ចជានា ការពារការ គោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ។

ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និងសម្រេច អំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្ដីសម្រេចបិទផ្លូវតវ៉ា។ រាយការណ៍ជូនព្រឹទ្ធសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍ ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំព្រឹទ្ធសភា ជាបន្ទាន់ដើម្បីសម្រេច។

ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទ ប្រកាន់សមាជិកព្រឹទ្ធសភាណាមួយត្រូវផ្អាក ប្រសិនបើព្រឹទ្ធសភាបញ្ចេញមតិឱ្យផ្អាកតាមមតិភាគច្រើន បីភាគបួននៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។ ក្នុងនីតិកាលរបស់ព្រឹទ្ធសភា អាសនៈរបស់សមាជិកព្រឹទ្ធសភាត្រូវប្រកាសថានៅទំនេរ ក្នុងករណីលាលែង បោះបង់ចោលការងារ មកពីវិសមិតភាព ប្រាសចាក សមាជិកភាព ឬទទួលអនិច្ចកម្ម។ អាសនៈរបស់ សមាជិកព្រឹទ្ធសភា ដែលនៅទំនេរយ៉ាងតិច៦ ខែមុនចប់នីតិកាល ត្រូវបំពេញជំនួសដោយសមាជិកថ្មីចេញពីប្រភពដើមដែលមានអាសនៈទំនេរនោះដោយមិនចាំបាច់បោះឆ្នោតសារឡើងវិញ។

មុខងារជាសមាជិកព្រឹទ្ធសភា មានវិសមិតភាពជាមួយមុខងារ សមាជិករដ្ឋសភា សមាជិករាជរដ្ឋាភិបាល សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ និងវិសមិតភាពជាមួយនឹងការបំពេញមុខងារសោធារណៈជាសកម្ម រួមទាំងការប្រកបការងារក្នុងវិជ្ជាជីវៈសេរីផងដែរ។

## ៤. ភាពខុសគ្នារវាងរដ្ឋសភា និងព្រឹទ្ធសភា

មុខងារនីតិកម្មមុខងារត្រួតពិនិត្យមុខងារតំណាង៖

| រដ្ឋសភា | ព្រឹទ្ធសភា |
|---|---|
| - ចំនួន៖ សមាជិកយ៉ាងតិច១២០រូប (មាត្រា៧៦ថ្មី នៃរដ្ឋធម្មនុញ្ញ)<br>- ការជ្រើសតាំង៖ បោះឆ្នោតជាសកល<br>- នីតិកាល៖ ៥ឆ្នាំ<br>- បេក្ខជន៖ អ្នកមានសិទ្ធិបោះ ឆ្នោតអាយុយ៉ាងតិច ២៥ឆ្នាំ មានសញ្ជាតិខ្មែរតាំងពីកំណើត<br>- អ្នកបោះឆ្នោត៖ អ្នកមានសិទ្ធិបោះឆ្នោតមានអាយុយ៉ាងតិច១៨ឆ្នាំ<br>- មណ្ឌលបោះឆ្នោត៖ រាជធានី ខេត្ត | - ចំនួន៖សមាជិកយ៉ាងច្រើនស្មើនឹងពាក់កណ្ដាល នៃចំនួនសមាជិករដ្ឋសភាទាំងមូល(មាត្រា៩៩ថ្មីនៃរដ្ឋធម្មនុញ្ញ)<br>- ការជ្រើសតាំង៖ បោះឆ្នោតជាអសកលផង ជ្រើសតាំងដោយរដ្ឋសភាផង និងចាត់តាំងផង<br>- នីតិកាល៖ ៦ឆ្នាំ<br>- បេក្ខជន៖ អ្នកមានសិទ្ធិបោះឆ្នោត អាយុយ៉ាងតិច ៤០ឆ្នាំ មានសញ្ជាតិខ្មែរតាំងពីកំណើត |

| | |
|---|---|
| - បោះឆ្នោតផ្តល់សេចក្តីទុកចិត្តដល់រាជរដ្ឋាភិបាលសួរដេញដោលដាក់ញត្តិបន្ទោសនិងអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាល<br>- អាចត្រូវបានរំលាយមុនផុតនីតិកាល បើសិនរាជរដ្ឋាភិបាលត្រូវបានទម្លាក់ពីរដងក្នុងរយៈពេល១២ខែ (មាត្រា៧៨ នៃរដ្ឋធម្មនុញ្ញ) ។ | - អ្នកបោះឆ្នោត៖ តំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងតំណែង<br>- មណ្ឌលបោះឆ្នោត៖ ភូមិភាគទាំង៨<br>- សម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល ដែលជាតួនាទីនយោបាយ<br>- មិនអាចរំលាយមុនផុតនីតិកាលបានឡើយ ។ |
| ▪ រដ្ឋសភាពិនិត្យ និងអនុម័តលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់<br>▪ រដ្ឋសភាពិភាក្សា និងអនុម័តលើខ្លឹមសារទាំងមូលលើ១មាត្រាម្តង ឬលើ១ ជំពូកម្តង និងលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ទាំងមូល<br>▪ សមាជិករដ្ឋសភាមួយភាគ បួននៃចំនួនសមាជិករដ្ឋសភា ទាំងមូល មានសិទ្ធិផ្តួចផ្តើមគំនិតសើរើ ឬផ្តួចផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ។ | ▪ ព្រឹទ្ធសភាពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងដែលរដ្ឋសភាបានអនុម័តបញ្ជូនមក<br>▪ ព្រឹទ្ធសភាពិនិត្យ និងឱ្យយោបល់លើរបាយការណ៍របស់គណៈកម្មការ ការឆ្លើយបំភ្លឺរបស់តំណាងរាជរដ្ឋាភិបាល ម្ចាស់សេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង<br>▪ ព្រឹទ្ធសភាពុំមានសិទ្ធិផ្តួចផ្តើមគំនិត សើរើ និងធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ។ |
| ▪ រដ្ឋសភាជ្រើសតាំងរាជរដ្ឋា ភិបាល។ រដ្ឋសភាបោះឆ្នោត ទុកចិត្តដល់រាជរដ្ឋាភិបាល និងអាចទម្លាក់សមាជិកគណៈ រដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែង<br>▪ រដ្ឋសភាមានអំណាចតាមច្បាប់ ក្នុងការចោទសួរដេញដោល និងអនុម័តញត្តិបន្ទោស ដកហូតតំណែង ឬរំលាយរដ្ឋាភិបាល។ | ▪ ព្រឹទ្ធសភា មានភារកិច្ចសម្រប សម្រួលការងារ រវាងរដ្ឋសភា និងរាជរដ្ឋាភិបាល<br>▪ ព្រឹទ្ធសភា អាចតាមដានត្រួត ពិនិត្យការងារ និងការអនុវត្តច្បាប់ និងគោលនយោបាយផ្សេងៗរបស់រាជរដ្ឋាភិបាល។ |
| ▪ តំណាងរាស្ត្រដែលត្រូវបានជ្រើសតាំង ដោយការបោះឆ្នោតជាសកល ក្រោយពីបានប្រកាសសុពលភាព និងស្បថចូលកាន់តំណែងរួចហើយ គឺជាតំណាងប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងរបស់ប្រជាពលរដ្ឋក្នុងមណ្ឌលរបស់នោះទេ | ▪ សមាជិកព្រឹទ្ធសភាក្នុងព្រឹទ្ធសភា គឺជាតំណាងរបស់ប្រជា ជាតិខ្មែរទាំងមូល ពុំមែនគ្រាន់ តែជាតំណាងឱ្យភូមិភាគរបស់ ខ្លួននោះទេ<br>▪ ប្រធានព្រឹទ្ធសភាត្រូវបំពេញ ភារកិច្ចជាប្រមុខរដ្ឋស្តីទី នៅពេលព្រះមហាក្សត្រអវត្តមាន |

| | |
|---|---|
| ▪ ប្រធានរដ្ឋសភាត្រូវបំពេញភារកិច្ច ជាប្រមុខរដ្ឋស្តីទី នៅពេលព្រះមហាក្សត្រ និងប្រធានព្រឹទ្ធសភាអវត្តមាន<br>▪ ប្រធានរដ្ឋសភាគឺជាអនុប្រធានទី១នៃក្រុមប្រឹក្សារាជសម្បត្តិ ។ | ▪ ប្រធានព្រឹទ្ធសភាគឺជាប្រធានក្រុមប្រឹក្សារាជសម្បត្តិ ។ |

## ៥. នីតិវិធីនៃការពិនិត្យ និងឱ្យយោបល់

តាមបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបានអនុម័តជាលើកដំបូងរួចហើយ ត្រូវបញ្ជូនមកព្រឹទ្ធសភាដើម្បីពិនិត្យ និងឱ្យយោបល់។ ព្រឹទ្ធសភាពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ញាទាំងពួង តាមនីតិវិធី ដូចខាងក្រោម៖

### ១) ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីពិនិត្យ និងសម្រេចលើសំណើរបស់រដ្ឋសភា

- ពិនិត្យលើទម្រង់ និងខ្លឹមសារនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបញ្ជូនមក និងសម្រេចបញ្ជូនទៅគណៈកម្មការណាមួយពិនិត្យសិក្សាទៅតាមវិស័យជាសមត្ថកិច្ច។
- ក្នុងករណីសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ញាទាំងពួងពាក់ព័ន្ធនឹងសមត្ថកិច្ច គណៈកម្មការច្រើន គណៈកម្មាធិការអចិន្ត្រៃយ៍សម្រេចចាត់តាំងគណៈកម្មការណាមួយឱ្យទទួលបន្ទុកធ្វើរបាយការណ៍

### ២) គណៈកម្មការទទួលបន្ទុកពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់

- ដំណើរការសុំយោបល់ពីគ្រប់សមាជិកព្រឹទ្ធសភា(យោបល់យល់ព្រមកែសម្រួល បដិសេធ ជាអសារបង់ ភ្ជាប់ដោយការកត់សម្គាល់ និង/ឬអនុសាសន៍) ជាលាយលក្ខណ៍អក្សរលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ញាទាំងពួងដែលសមាជិកព្រឹទ្ធសភាម្នាក់ៗបានទទួល
- ការផ្តល់យោបល់ពីសមាជិកព្រឹទ្ធសភា ត្រូវធ្វើក្នុងរយៈពេល៣ថ្ងៃយ៉ាងយូរ បើជាការប្រញាប់មកត្រឹមតែ១ថ្ងៃយ៉ាងយូរ មុនគណៈកម្មការប្រជុំ
- សមាជិកព្រឹទ្ធសភាគ្រប់រូប មានភារកិច្ចយកសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ញាទាំងពួងមកពិនិត្យសិក្សាលម្អិតដោយផ្តោតលើខ្លឹមសារទាំងមូលនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ញាទាំងពួង ដែលទាក់ទងនឹងវិមជ្ឈការ និងវិសហមជ្ឈការក្នុងក្របខណ្ឌភូមិភាគរបស់ខ្លួន

- ក្រុមសមាជិកព្រឹទ្ធសភានីមួយៗកោះប្រជុំដើម្បីកំណត់អំពីជំហររបស់ក្រុម និងចាត់តាំងតំណាងក្រុម ដើម្បីថ្លែងពីជំហររបស់ក្រុមក្នុងសម័យប្រជុំព្រឹទ្ធសភា
- គណៈកម្មការទទួលបន្ទុក ត្រូវប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល ម្ចាស់សេចក្ដីព្រាងច្បាប់ ឬតំណាងហត្ថលេខី ម្ចាស់សេចក្ដីស្នើច្បាប់ ដោយមានការអញ្ជើញតំណាងគណៈកម្មការនានា ឬតំណាងក្រុមសមាជិកព្រឹទ្ធសភា និងអ្នកជំនាញចូលរួម ដើម្បីពិគ្រោះយោបល់ និងរៀបចំរបាយការណ៍ស្ដីពីលទ្ធផលនៃការពិនិត្យសិក្សាលើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ឬបញ្ហាទាំងពួងរាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំព្រឹទ្ធសភា
- ប្រធានគណៈកម្មការទទួលបន្ទុក កាលបើពិនិត្យសិក្សាលើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ឬបញ្ហាទាំងពួង ឬសំណើសុំកែសម្រួលរួចហើយ ត្រូវធ្វើលិខិតស្នើសុំមកប្រធានគណៈ កម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីសុំដាក់បញ្ចូលទៅក្នុងរបៀបវារៈនៃអង្គប្រជុំព្រឹទ្ធសភានិងនាំយកយោបល់របស់គណៈកម្មការ មកជម្រាបជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំព្រឹទ្ធសភា។

**៣) ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការនានា សុំដាក់បញ្ចូលក្នុងរបៀបវារៈសម័យប្រជុំព្រឹទ្ធសភា**

- ប្រធានគណៈកម្មការទទួលបន្ទុក នាំយកយោបល់របស់គណៈកម្មការ មកជម្រាបជូនគណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីពិនិត្យ និងសម្រេច
- អង្គប្រជុំត្រូវសម្រេចថា យល់ព្រម ឬមិនយល់ព្រម ដើម្បីដាក់បញ្ចូលសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ឬបញ្ហាទាំងពួងនោះ ទៅក្នុងរបៀបវារៈនៃសម័យប្រជុំព្រឹទ្ធសភា ។

**៤) ប្រជុំព្រឹទ្ធសភា ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ឬបញ្ហាទាំងពួង**

- កូរ៉ុម ត្រូវតែមានគ្រប់ចំនួននៅពេលបើកការប្រជុំ និងនៅពេលអនុម័ត។ បើកូរ៉ុមមិនគ្រប់ ក្នុងរយៈពេល៣០ នាទី ក្រោយពេលកំណត់ចាប់ផ្ដើមការប្រជុំ ប្រធានអង្គប្រជុំត្រូវលើកពេលប្រជុំ
- តំណាងរាជរដ្ឋាភិបាល ម្ចាស់សេចក្ដីព្រាងច្បាប់ ឬតំណាងហត្ថលេខីម្ចាស់សេចក្ដីស្នើច្បាប់ ឬបញ្ហាទាំងពួង ដែលមកការពារត្រូវមានវត្តមាននៅក្នុងសាលប្រជុំតាមការអញ្ជើញរបស់ប្រធានព្រឹទ្ធសភា
- ដំណើរការប្រជុំ ត្រូវធ្វើតាមរបៀបវារៈ។ មុនចាប់ផ្ដើមសម័យប្រជុំ ព្រឹទ្ធសភាត្រូវអនុម័តរបៀបវារៈ និងសមាសភាពលេខាធិការសម័យប្រជុំនីមួយៗ

- ការពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង នៅក្នុងអង្គប្រជុំព្រឹទ្ធសភា ផ្តើមឡើងដោយការបង្ហាញរបាយការណ៍របស់គណៈកម្មការទទួលបន្ទុក
- អង្គប្រជុំព្រឹទ្ធសភាពិនិត្យពិភាក្សាលើសេចក្តីសន្និដ្ឋានរួមរបស់គណៈកម្មការទទួលបន្ទុក។ តំណាងក្រុមសមាជិកព្រឹទ្ធសភានីមួយៗដែលប្រធានអង្គប្រជុំបានអនុញ្ញាតឱ្យមានយោបល់ ត្រូវមានយោបល់តែអំពីរឿង ដែលកំពុងតែពិភាក្សាប៉ុណ្ណោះ
- តំណាងរាជរដ្ឋាភិបាល ម្ចាស់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ឬបញ្ហាទាំងពួងដែលមកការពារ ត្រូវឆ្លើយបំភ្លឺចំពោះយោបល់ របស់សមាជិកព្រឹទ្ធសភា ដែលបានលើកឡើង
- អង្គប្រជុំព្រឹទ្ធសភាពិនិត្យនិងឱ្យយោបល់(យល់ព្រមដោយឥតកែប្រែ ទទួលយកយោបល់សុំកែសម្រួល ឬទទួលយកយោបល់សុំបដិសេធជាអសារបង់)
- បន្ទាប់ពីព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់រួចហើយ សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងនេះ ត្រូវបញ្ជូនទៅរដ្ឋសភាវិញ ។

## ៦. អំពីការប្រជុំរបស់ព្រឹទ្ធសភា

ព្រឹទ្ធសភាប្រជុំជាសាមញ្ញពីរដងក្នុងមួយឆ្នាំ។សម័យប្រជុំនីមួយៗមានថិរវេលាយ៉ាងតិចបីខែ។បើមានសំណូមពរពីព្រះមហាក្សត្រ ឬសេចក្តីស្នើសុំពី នាយករដ្ឋមន្ត្រី ឬពីសមាជិក ព្រឹទ្ធសភាចំនួនមួយភាគបីយ៉ាងតិច ព្រឹទ្ធសភាអាចកោះប្រជុំជាវិសាមញ្ញ។ រាល់ការប្រជុំរបស់ព្រឹទ្ធសភា អាចប្រព្រឹត្តទៅបានលុះត្រាមានប្រធានដឹកនាំ ហើយត្រូវមានកូរ៉ុមគ្រប់ចំនួន ទាំងនៅពេលបើកការប្រជុំ និងនៅពេលអនុម័ត។

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាជាអ្នករៀបចំរបៀបវារៈក្នុងសម័យប្រជុំនីមួយៗ។ ការកំណត់ថ្ងៃប្រជុំត្រូវធ្វើជាលិខិតផ្ញើទៅជូនសមាជិកព្រឹទ្ធសភា។ បើមានការកំណត់ផ្ទាល់មាត់ក្នុងពេលប្រជុំ ការកំណត់នេះត្រូវធ្វើជាលិខិតផ្ញើទៅសមាជិកព្រឹទ្ធសភា ដែលមិនបានមកប្រជុំ។ តាមធម្មតាត្រូវកំណត់០២ថ្ងៃ មុនពេលប្រជុំ ដោយមានភ្ជាប់ទៅជាមួយនូវរបៀបវារៈប្រជុំ វៀរលែងតែក្នុងករណីប្រញាប់។

ការប្រជុំព្រឹទ្ធសភាត្រូវធ្វើជាសាធារណៈ និងត្រូវផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ជាតិ។ កំណត់ហេតុនៃការប្រជុំព្រឹទ្ធសភា មានកំណត់ហេតុសង្ខេប និងកំណត់ហេតុពិស្តារ។ កំណត់ហេតុទាំងអស់ត្រូវតម្កល់ទុកក្នុង បណ្ណសារដ្ឋានព្រឹទ្ធសភា។ ព្រឹទ្ធសភាអាចកោះប្រជុំជាសម្ងាត់បាន តាមសំណើសុំពីប្រធានព្រឹទ្ធសភាឬពីសមាជិកព្រឹទ្ធសភាចំនួន

មួយភាគ ដប់យ៉ាងតិច ឬពីព្រះមហាក្សត្រ ឬពីប្រធានរដ្ឋសភា ឬពីនាយករដ្ឋមន្ត្រី។ អាសនានុក្រម របស់សមាជិកព្រឹទ្ធសភា ត្រូវរៀបតាមក្រុមសមាជិកព្រឹទ្ធសភានីមួយៗ។ ក្រុមនីមួយៗត្រូវមានសមាជិក យ៉ាងតិច១០រូប។ សមា ជិកព្រឹទ្ធសភា១រូប អាចចូលជាសមាជិកក្រុមបានតែមួយប៉ុណ្ណោះ។ ក្រុមនីមួយៗត្រូវមាន ប្រធាន១រូប និង អនុប្រធាន១រូប។ សមាជិកព្រឹទ្ធសភា ចាត់តាំងដោយព្រះមហាក្សត្រ ជ្រើសតាំងដោយរដ្ឋសភា និងគណបក្សនយោបាយដែលមាន អាសនៈតិចជាងដប់អាចជ្រើសរើសចូលជាមួយ ក្រុមណាមួយ តាមការពេញចិត្តរបស់ខ្លួន។ បញ្ជីរាយនាមរបស់ក្រុមសមាជិកព្រឹទ្ធសភា ត្រូវផ្ញើជូនប្រធានព្រឹទ្ធសភា។

ក្រុមសមាជិកព្រឹទ្ធសភាបំពេញតួនាទី ដើម្បីប្រមូលផ្តុំបញ្ញាញាណ នយោបាយរបស់ព្រឹទ្ធសភា សំដៅបម្រើឱ្យការបញ្ចេញយោបល់របស់តំណាងក្រុមនៅក្នុងសម័យប្រជុំព្រឹទ្ធសភា។ ពហុនិយមខាងនយោបាយ ត្រូវអនុវត្តដោយថ្លៃថ្នូរ មានគុណធម៌ និងសុជីវធម៌ ក្នុងក្របខ័ណ្ឌនៃក្រមសីលធម៌ សមាជិកព្រឹទ្ធសភា គ្មានការរំលោភបំពាន និងគ្មានការរើសអើង សក្តិសមទៅនឹងលក្ខន្តិកៈទូទៅរបស់សមាជិកព្រឹទ្ធសភា ដែលជាតំណាងឱ្យភូមិភាគ និងប្រជាជាតិខ្មែរទាំងមូល។

**ក្រុមសមាជិកព្រឹទ្ធសភា មានភារកិច្ចដូចខាងក្រោម៖**

- រួមគ្នាពិភាក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដើម្បីរៀបចំតំណាងក្រុម យោបល់ក្នុងនាមក្រុមនៅក្នុងសម័យប្រជុំព្រឹទ្ធសភា និងប្រកាន់ជំហររួមរបស់ ក្រុមក្នុងការអនុម័ត
- រួមគ្នាផ្តួចផ្តើមគំនិត ស្នើច្បាប់ ឬស្នើវិសោធនកម្មច្បាប់
- រួមគ្នាប្រជុំដើម្បីចែករំលែកព័ត៌មានពិគ្រោះគ្នា កំណត់គោលជំហររបស់ក្រុមទៅលើបញ្ហាបច្ចុប្បន្នភាពណាមួយដែលក្រុមត្រូវយកចិត្តទុកដាក់ក្នុងការថ្លែងឬប្រកាសជំហរជាសាធារណៈ។

ជាគោលការណ៍រយៈពេលបញ្ចេញយោបល់សម្រាប់ក្រុមសមាជិកព្រឹទ្ធសភានីមួយៗ ត្រូវបានកំណត់។ សមាជិកព្រឹទ្ធសភាតំណាងក្រុមនីមួយៗដែលបានសុំចុះឈ្មោះ បញ្ចេញយោបល់អាចនិយាយបាន២០នាទីយ៉ាងយូរ។ សមាជិកព្រឹទ្ធសភា តំណាងក្រុមនីមួយៗដែលគ្រាន់តែសុំឆ្លើយតប និយាយបានត្រឹមតែ៥នាទីប៉ុណ្ណោះ។

បើប្រធានព្រឹទ្ធសភាយល់ថាជាការចាំបាច់ ឬជាការមានប្រយោជន៍ក្នុងការពិភាក្សា នោះប្រធានអាចអនុញ្ញាតបន្ថែមពេលឱ្យនិយាយបាន១០នាទីទៀត។ ការបន្ថែមនេះអាចឱ្យបន្តបានពីរដងក្នុងប្រធានបទតែមួយ។ សមាជិកក្នុងក្រុមជាមួយមានសិទ្ធិសុំបញ្ចេញមតិ បន្ថែមក្នុងប្រធានបទដដែល និងក្នុងរយៈពេលដែល នៅសល់ពីការកំណត់ខាងលើ។

សូមបញ្ជាក់ជូនថាបទប្បញ្ញត្តិអំពីការសុំចុះឈ្មោះបញ្ចេញយោបល់ និងការកំណត់រយៈពេលបញ្ចេញយោបល់ ខាងលើ ប្រើសម្រាប់តែសមាជិកព្រឹទ្ធសភាតែប៉ុណ្ណោះ មិនយកមកប្រើសម្រាប់តំណាងរាជរដ្ឋាភិបាល ឬសមាជិករដ្ឋសភា ឬម្ចាស់សេចក្តីស្នើច្បាប់ ឬអ្នកជំនាញការពារសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងនោះទេ។

## ៧. ឋានៈ និងអភ័យឯកសិទ្ធិសមាជិកព្រឹទ្ធសភា

ច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភាបានកំណត់នូវ អភ័យឯកសិទ្ធិសភា ឋានៈបុព្វសិទ្ធិ វិសមិតភាព និងលក្ខខណ្ឌចាំបាច់នានា ដើម្បីធានាជូនដល់សមាជិកព្រឹទ្ធសភា ក្នុងការបំពេញភារកិច្ចស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងបទដ្ឋានគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជា។ សមាជិកព្រឹទ្ធសភាមានអភ័យឯកសិទ្ធិសភា។ អភ័យឯកសិទ្ធិសភា ត្រូវបានចែកចេញជាពីរផ្នែកគឺ៖

**១) អភ័យឯកសិទ្ធិដាច់ខាត៖** ជាការធានាក្នុងការបញ្ចេញយោបល់ ឬការបញ្ចេញមតិក្នុងការអនុម័តទាំងឡាយរបស់សមាជិកព្រឹទ្ធសភានៅក្នុងក្របខ័ណ្ឌនៃការបំពេញតួនាទីជាសមាជិកព្រឹទ្ធសភា។

**២) អភ័យឯកសិទ្ធិដោយប្រៀប៖** ជាការធានាមិនឱ្យមានការចោទប្រកាន់ ការចាប់ខ្លួនឬការឃុំខ្លួនសមាជិកព្រឹទ្ធសភាណាមួយ។ សមាជិកព្រឹទ្ធ សភា មិនអាចឆ្លៀតប្រើអភ័យឯកសិទ្ធិនេះដោយរំលោភ នាំឲ្យប៉ះពាល់ដល់កិត្តិយសរបស់បុគ្គលដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ។ ប្រសិនបើបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌគឺអាចអនុញ្ញាតធ្វើការចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនតាមច្បាប់ និងនីតិវិធីបានលុះត្រាតែមានការលើកអភ័យឯកសិទ្ធិសភាជាមុនសិន។ ការស្នើសុំលើកអភ័យឯកសិទ្ធិសភារបស់សមាជិកព្រឹទ្ធសភារូបណាមួយ ត្រូវធ្វើឡើងដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ តាមរយៈរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដោយមានភ្ជាប់សេចក្តីថ្លែងហេតុមកជាមួយផងផ្ញើជូនប្រធានព្រឹទ្ធសភា។ ការលើកអភ័យឯកសិទ្ធិសភាក្នុងរយៈពេលសម័យប្រជុំព្រឹទ្ធសភា ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់តាមការស្នើសុំពីប្រធាន ឬពីសមាជិកព្រឹទ្ធសភាចំនួនមួយភាគដប់យ៉ាងតិចពីព្រះមហាក្សត្រពីនាយករដ្ឋមន្ត្រី ឬពីប្រធានរដ្ឋសភា
- កូរ៉ុមប្រជុំលើសពី ពីរភាគបី នៃសមាជិកព្រឹទ្ធសភាទាំងមូល។
- ការអនុម័តតាមមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

ការលើកអភ័យឯកសិទ្ធិសភាក្នុងចន្លោះសម័យប្រជុំព្រឹទ្ធសភា គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ត្រូវប្រជុំ និងអនុម័តស្របតាមបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា។ សេចក្ដីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ត្រូវដាក់ជូនសម័យប្រជុំព្រឹទ្ធសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

ក្នុងករណីសមាជិកព្រឹទ្ធសភាណា បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌជាក់ស្ដែង ក្រសួងមានសមត្ថកិច្ចអាចចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនបាន ហើយត្រូវធ្វើសេចក្ដីរាយការណ៍ជូនព្រឹទ្ធសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំព្រឹទ្ធសភាជាបន្ទាន់ដើម្បីសម្រេច។ ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់សមាជិកព្រឹទ្ធសភាណាមួយត្រូវផ្អាក ប្រសិនបើព្រឹទ្ធសភាបញ្ចេញមតិឱ្យផ្អាក តាមមតិភាគច្រើន៣ភាគបួន នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

ក្នុងនីតិកាលរបស់ព្រឹទ្ធសភា អាសនៈរបស់សមាជិកព្រឹទ្ធសភាត្រូវប្រកាសថានៅទំនេរ ក្នុងករណីលាលែង បោះបង់ចោលការងារមកពីវិសមិតភាព ប្រាសចាកសមាជិកភាព ឬទទួលអនិច្ចកម្ម។ អាសនៈរបស់សមាជិកព្រឹទ្ធសភា ដែលនៅទំនេរយ៉ាងតិច៦ខែ មុនចប់នីតិកាលត្រូវបំពេញជំនួសដោយសមាជិកថ្មី ចេញពីប្រភពដើម ដែលមានអាសនៈទំនេរនោះ ដោយមិនចាំបាច់បោះឆ្នោតសាឡើងវិញ។ មុខងារជាសមាជិកព្រឹទ្ធសភា មានវិសមិតភាពជាមួយមុខងារសមាជិករដ្ឋសភា សមាជិករាជរដ្ឋាភិបាល សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ និងវិសមិតភាពជាមួយនឹងការបំពេញមុខងារសាធារណៈជាសកម្ម រួមទាំងការប្រកបការងារក្នុងវិជ្ជាជីវៈសេរីផងដែរ។

## ចក្ខុវិស័យ និងយុទ្ធសាស្ត្រនៃការដឹកនាំព្រឹទ្ធសភានីតិកាលទី៤



## ផ្នែកទី២៖ ស្ថាប័ននីតិប្បញ្ញត្តិ-រដ្ឋសភាកម្ពុជា

នៅក្នុងផ្នែកទី២ ស្តីពីស្ថាប័ននីតិប្បញ្ញត្តិ ស្តីពីរដ្ឋសភាកម្ពុជានឹងធ្វើការរៀបរាប់អំពីរដ្ឋសភាកម្ពុជា ប្រវត្តិនៃការកកើតរដ្ឋសភា រដ្ឋសភាក្នុងពេលបច្ចុប្បន្ន សមត្ថកិច្ចរបស់រដ្ឋសភា នីតិវិធីពិនិត្យ និងការអនុម័តសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ និង**សម័យប្រជុំរដ្ឋសភា**នៅក្នុងប្រទេសកម្ពុជា។

**ក. វត្ថុបំណងមេរៀន៖** ក្រោយពីបញ្ចប់ការសិក្សាមេរៀនអំពីរដ្ឋសភាកម្ពុជា អ្នកសិក្សាអាចនឹង៖

| | |
|---|---|
| **វិជ្ជាសម្បទា/ពុទ្ធិ៖** | យល់ដឹងអំពីរបៀបរៀបចំច្បាប់ ការគ្រប់គ្រង ការដឹកនាំរបស់រដ្ឋសភាពនៃប្រទេស។ |
| **បំណិនសម្បទា/ចិត្តសង្គម៖** | ប្រើប្រាស់តម្លៃគំនិត ចំណេះដឹង អំពីរដ្ឋសភាពនៃប្រទេសកម្ពុជាប្រកបដោយទំនួលខុសត្រូវខ្ពស់។ |
| **ចរិយាសម្បទា/ឥរិយាបថ៖** | ចូលរួមគោរពនិងអនុវត្តច្បាប់រដ្ឋសភាពនៃប្រទេសកម្ពុជាប្រកបដោយទំនួលខុសត្រូវខ្ពស់ |

**ខ. វិធីសាស្ត្របង្រៀន៖** សិស្សមជ្ឈមណ្ឌល បែបពិភាក្សា និងការងារក្រុម

**គ. សម្ភារៈឧបទេ្ទស៖** មេរៀនស្តីពីរដ្ឋសភាកម្ពុជាដែលរៀបចំដោយក្រុមការងារ GCED នៃវិទ្យាស្ថានជាតិអប់រំ និងឯកសារយោងដែលពាក់ព័ន្ធ..

### ១. សេចក្តីផ្តើម

ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស ជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត អចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ មានទីតាំងស្ថិតនៅក្នុង ភូមិភាគអាស៊ី-អាគ្នេយ៍ មានផ្ទៃក្រឡា ១៨១.០៣៥ គីឡូម៉ែត្រការ៉េ មានភ្នំពេញជារាជធានី និងមានរាជធានី-ខេត្ត៖ ២៥ក្រុងចំនួន២៧ ស្រុកចំនួន១៦២ ខណ្ឌចំនួន១៤ ឃុំចំនួន១.៤០៥ សង្កាត់ចំនួន២៥១ និងភូមិចំនួន១៤.៤០៥ មានប្រជាពលរដ្ឋជាង១៥លាននាក់។

### ២. ប្រវត្តិរបស់រដ្ឋសភា

ព្រះរាជាណាចក្រកម្ពុជាត្រូវបានអាណានិគមនិយមបារាំងត្រួតត្រាពីឆ្នាំ១៨៦៣ ដល់ឆ្នាំ១៩៥៣។ ក្នុងរជ្ជកាលព្រះ

បាទស៊ីសុវត្ថិមានព្រះរាជប្បញ្ញត្តិមួយ ចុះថ្ងៃទី១៨ មីនា ១៩១៣ សម្រេចបង្កើតសភាពិគ្រោះយោបល់ដែលមានសមាជិក៣៩រូបតំណាង១០ខេត្ត-ក្រុង។ នេះជាសញ្ញាដំបូងនៃការកកើតសភា។

- ថ្ងៃ១០ មេសា ១៩៤០ សភាពិគ្រោះយោបល់បានកែប្រែទៅជាសភាតំណាងប្រជាជនកម្ពុជា ក្រោមរជ្ជកាលព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស
- ថ្ងៃ២៩ មីនា ១៩៤៥ ការបង្កើតសភាពិគ្រោះយោបល់ដែលមានសមាជិក៣៣រូប តំណាងឱ្យ១៤ខេត្ត-ក្រុង
- ខែវិច្ឆិកា ឆ្នាំ១៩៤៥ ការបង្កើតគណៈកម្មការបារាំង-ខ្មែរមួយដើម្បីរៀបរៀងសេចក្តីព្រាងរដ្ឋធម្មនុញ្ញដំបូង។
- ឆ្នាំ១៩៤៦មានព្រះរាជក្រម៤ សម្រេចផ្តល់សេរីភាពសារព័ត៌មានសេរីភាពបង្កើតសមាគម សេរីភាពបង្កើតគណបក្សនយោបាយនិងឱ្យប្រើច្បាប់បោះឆ្នោតសាកលជ្រើសតាំងរដ្ឋសភាបណ្តោះអាសន្ន (សភាធម្មនុញ)
- ថ្ងៃ០១ កញ្ញា ១៩៤៦ ការបោះឆ្នោតសាកលលើកដំបូងនៅកម្ពុជាជ្រើសតាំង សមាជិកសភាធម្មនុញ្ញ៦៧រូបមានបេសកកម្ម តាក់តែង និងអនុម័តរដ្ឋធម្មនុញ្ញទី១ នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៤៧

**ខាងក្រោមនេះគឺជាតារាងស្តីពីប្រវត្តិរបស់រដ្ឋសភាកម្ពុជាពីការកកើតមកដល់បច្ចុប្បន្ន៖**

| ល.រ | រដ្ឋសភា រយៈកាល | ចំនួនគណបក្ស | ចំនួនអាសនៈ | កាលបរិច្ឆេទបោះឆ្នោត |
|---|---|---|---|---|
| ១ | សភាធម្មនុញ្ញ ១៩៤៦-១៩៤៧ | ពហុបក្ស | ៦៧ | ០១-០៩-១៩៤៦ |
| ២ | រដ្ឋសភា ១៩៤៧-១៩៥១ | ពហុបក្ស | ៧៥ | ២១-១២-១៩៤៧ |
| ៣ | រដ្ឋសភា ១៩៥១-១៩៥៣ | ពហុបក្ស | ៧៨ | ០៩-០៩-១៩៥១ |
| ៤ | រដ្ឋសភា ១៩៥៥-១៩៥៨ | បក្សតែមួយ | ៩១ | ១១-០៩-១៩៥៥ |
| ៥ | រដ្ឋសភា ១៩៥៨-១៩៦២ (១) | បក្សតែមួយ | ៦១ | ២៣-០៩-១៩៥៨ |
| ៦ | រដ្ឋសភា ១៩៦២-១៩៦៦ | បក្សតែមួយ | ៧៧ | ១០-០៦- ១៩៦២ |
| ៧ | រដ្ឋសភា ១៩៦៦-១៩៧២ | បក្សតែមួយ | ៨២ | ១១-០៩-១៩៦៦ |
| ៨ | សភាជាតិសាធារណរដ្ឋខ្មែរ១៩៧២-១៩៧៥ | បក្សតែមួយ | ១២៦ | ០៣-០៩-១៩៧២ |
| ៩ | សភាតំណាងប្រជាជនកម្ពុជាប្រជាធិបតេយ្យ (២) | បក្សតែមួយ | ២៥០ | ២០-០៣-១៩៧៦ |
| ១០ | សភាសាធារណរដ្ឋប្រជាមានិតកម្ពុជា ១៩៨១-១៩៩៣ | បក្សតែមួយ | ១១៧ | ០១-០៥-១៩៨១ |
| ១១ | សភាធម្មនុញ្ញ ១៩៩៣ | ពហុបក្ស | ១២០ | ២៣ . ២៨-០៥-១៩៩៣ |
| ១២ | រដ្ឋសភានីតិកាលទី ១ ១៩៩៣-១៩៩៨ | ពហុបក្ស | ១២០ | ២៣ . ២៨-០៥-១៩៩៣ |

| | | | | |
|---|---|---|---|---|
| ១៣ | រដ្ឋសភានីតិកាលទី ២ ១៩៩៨-២០០៣ | ពហុបក្ស | ១២២ | ២៦-០៧-១៩៩៨ |
| ១៤ | រដ្ឋសភានីតិកាលទី ៣ ២០០៣-២០០៨ | ពហុបក្ស | ១២៣ | ២៧-០៧-២០០៣ |
| ១៥ | រដ្ឋសភានីតិកាលទី ៤ ២០០៨-២០១៣ | ពហុបក្ស | ១២៣ | ២៧-០៧-២០០៨ |
| ១៦ | រដ្ឋសភានីតិកាលទី ៥ ២០១៣ ដល់បច្ចុប្បន្ន | ពហុបក្ស | ១២៣ | ២៨-០៧-២០១៣ |
| ១៧ | រដ្ឋសភានីតិកាលទី ៦ ២០១៨ ដល់បច្ចុប្បន្ន | ពហុបក្ស | ១២៥ | ២៩-០៧-២០១៨ |

**កំណត់សំគាល់៖**

(១) ជាលើកដំបូងដែលស្ត្រីខ្មែរមានសិទ្ធិសេរីភាពទៅបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោត

(២) សម័យកម្ពុជាប្រជាធិបតេយ្យលទ្ធផលស្រាវជ្រាវរកឃើញត្រឹមសមាសភាពគណៈកម្មាធិការអចិន្ត្រៃយ៍ប៉ុណ្ណោះ

## ៣. រដ្ឋសភាបច្ចុប្បន្ន

រដ្ឋសភានីតិកាលទី៦កើតចេញពីការបោះឆ្នោតសកលកាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ តាមប្រព័ន្ធ សមាមាត្រ មាន២៥មណ្ឌល រាជធានី-ខេត្ត មានគណបក្សនយោបាយចំនួន២០ចូលរួម។ ប្រជាពលរដ្ឋបានចុះឈ្មោះបោះឆ្នោត ចំនួន៨.៣៨០.២១៧នាក់ ប្រជាជនបានទៅបោះឆ្នោតចំនួន៦.៩៥៦.៩០០នាក់ ស្មើនឹង៨៣,០២%។ អាសនៈ ដែលទទួលបានៈគណបក្សប្រជាជនកម្ពុជា ១២៥អាសនៈ ស្មើនឹង១០០%។ តំណាងរាស្ត្រសរុបចំនួន១២៥រូប ក្នុង នោះតំណាងរាស្ត្រស្ត្រី២៥រូប ស្មើនឹង២០%តំណាងរាស្ត្រ ជនជាតិភាគតិចចំនួន៧រូប ក្រុមសមាជិកសភាកម្ពុជានៃ អ្នកនយោបាយស្ត្រីត្រូវបានបង្កើត។

រដ្ឋសភានីតិកាលទី៦ បានបើកសម័យប្រជុំដំបូង ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ព្រះករុណា ព្រះបាទស ម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃពុធ ទី៥ ខែកញ្ញា ឆ្នាំ ២០១៨។ តំណាងរាស្ត្របានធ្វើសច្ចា ប្រណិធាន នៅព្រះបរមរាជវាំង មុនចូលកាន់តំណែងនៅរសៀលថ្ងៃដដែល។ រដ្ឋសភាបានប្រជុំក្រោមអធិបតីភាព **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ព្រឹទ្ធសមាជិករដ្ឋសភា ដើម្បីបោះឆ្នោត ជ្រើសតាំង ប្រធាន អនុប្រធានរដ្ឋសភា ប្រធាន អនុប្រធានគណៈកម្មការជំនាញ និងផ្តល់សេចក្តីទុកចិត្តរាជរដ្ឋាភិបា ល នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨។

## អង្គការលេខរបស់រដ្ឋសភា




### ៣.១. ប្រធានរដ្ឋសភាមានមុខការដូចតទៅៈ

- ជានាការប្រព្រឹត្តទៅនៃរដ្ឋសភាឱ្យបានត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ
- ដឹកនាំអង្គប្រជុំរបស់រដ្ឋសភា
- បើកនិងលើកពេលប្រជុំនៃរដ្ឋសភា
- ទទួលអាញ្ញត្តិច្បាប់និងសេចក្តីសម្រេចចិត្តទាំងឡាយដែលរដ្ឋសភាបានអនុម័ត
- ចាត់ចែងការពិភាក្សាហើយចុះហត្ថលេខាលើកំណត់ហេតុនៃការប្រជុំនៃរដ្ឋសភា
- ញាំងឱ្យប្រតិបត្តិតាមបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា
- រក្សាការពារសណ្តាប់ធ្នាប់ក្នុងរដ្ឋសភា
- តំណាងរដ្ឋសភាក្នុងការទាក់ទងជាមួយព្រះមហាក្សត្រនិងអាជ្ញាធរសាធារណៈ
- ចាត់ចែងការទាក់ទងអន្តរជាតិទាំងឡាយរបស់រដ្ឋសភា

អនុប្រធានទាំងពីរជួយធ្វើការប្រធានទៅតាមការបែងចែកភារកិច្ចពីប្រធាន។ កាលបើប្រធានអវត្តមាន ឬមកធ្វើការពុំបាន អនុប្រធានធ្វើការជួសប្រធាន ក្នុងឋានៈជាប្រធានស្តីទីតាមរយៈលិខិតផ្ទេរសិទ្ធិ។

## ៣.២. សមត្ថកិច្ចរបស់រដ្ឋសភា

### ៣.២.១. អំណាចនីតិប្បញ្ញត្តិ

១. **រដ្ឋសភា**ជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន (រ.ធ.មាត្រា៩០ថ្មី (ពីរ) ។

២. **រដ្ឋសភា**មានសមាជិកជាតំណាងរាស្ត្រយ៉ាងតិច ១២០ រូប (រ.ធ. មាត្រា ៧៦) ។

៣. នីតិកាលរបស់រដ្ឋសភាមានកំណត់៥ឆ្នាំ ហើយផុតកំណត់នៅពេលដែលរដ្ឋសភាថ្មីចូលកាន់តំណែង (រ.ធ. មាត្រា៧៨)។ រដ្ឋសភាបើកសម័យប្រជុំដំបូងហុកសិបថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោតតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ (រ.ធ មាត្រា៨២) ។

៤. រដ្ឋសភាមិនអាចត្រូវបានរំលាយមុនផុតអាណត្តិបានឡើយ វៀរលែងតែក្នុងករណីដែលរាជរដ្ឋាភិបាលត្រូវបានទម្លាក់ពីរដងក្នុងរយៈ ១២ខែ (រ.ធ. មាត្រា ៧៨)។

៥. តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា(រ.ធ.មាត្រា៨០និងច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ)។

៦. ការលើកអភ័យឯកសិទ្ធិសភារបស់តំណាងរាស្ត្រ ត្រូវអនុម័តដោយសម្លេង ២ភាគ៣ នៃចំនួនសមាជិករដ្ឋសភាទាំងមូល (រ.ធ .មាត្រា៨០ និងច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ)។

៧. ការសំរេចអោយតុលាការផ្អាកការចោទប្រកាន់ឬការឃាត់ខ្លួន ឬការឃុំខ្លួន រដ្ឋសភាត្រូវអនុម័តដោយសម្លេង ៣ ភាគ៤នៃចំនួនសមាជិករដ្ឋសភាទាំងមូល (រ.ធ. មាត្រា ៨០)។

៨. រដ្ឋសភាប្រជុំសាមញ្ញពីរដងក្នុងមួយឆ្នាំ សម័យប្រជុំនីមួយៗមានថេរៈវេលាយ៉ាងតិច៣ខែ (រ.ធ.មាត្រា៨៣)។

៩. រដ្ឋសភាអាចប្រជុំជាវិសាមញ្ញបើមានសំណូមពរពីព្រះមហាក្សត្រឬសំណើពីនាយករដ្ឋមន្ត្រីឬពីតំណាងរាស្ត្រមួយភាគបីយ៉ាងតិច( រ.ធ. មាត្រា ៨៣ )។

១០. រដ្ឋសភាអាចប្រជុំជាសម្ងាត់ (រ.ធ. មាត្រា ៨៨ ថ្មី (ពីរ )។

១១. សម្លេងភាគច្រើន២ភាគ៣ នៃចំនួនសមាជិករដ្ឋសភាទាំងមូលប្រើសំរាប់អនុម័តរដ្ឋធម្មនុញ្ញ ឬការលើកអភ័យឯកសិទ្ធិសភា ឬការបន្តនីតិកាលរដ្ឋសភាមួយឆ្នាំ ត្រូវមានកូរ៉ុមលើសពី២ភាគ៣(រ.ធ.មាត្រា៧៨-មាត្រា ៨០-មាត្រា១៥១ ថ្មី)។

១២. សម្លេងភាគច្រើនដាច់ខាត(ឬពាក់កណ្តាលបូកមួយ)នៃចំនួនសមាជិករដ្ឋសភាទាំងមូលប្រើសំរាប់អនុម័តច្បាប់ទាំងឡាយអនុម័តថវិកាជាតិ ផែនការរដ្ឋ ការសន្យាផ្នែកហិរញ្ញវត្ថុ ឬបោះឆ្នោតទុកចិត្ត ឬបោះឆ្នោតទម្លាក់រាជរដ្ឋាភិបាល ឬអនុម័តបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ឬបោះឆ្នោតជ្រើសតាំងប្រធាន អនុប្រធានសមាជិកគណៈកម្មការនានារបស់រដ្ឋសភា ។ រដ្ឋសភាអនុម័ត យល់ព្រម ឬលុបចោលសន្ធិសញ្ញាឬអនុសញ្ញាអន្តរជាតិ។ រដ្ឋសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម(រ.ធ.មាត្រា៨២ថ្មី មាត្រា៩០ថ្មី(ពីរ)។

១៣. តំណាងរាស្ត្រមានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាល វេទិកាសំណួរចម្លើយ ការជជែកដេញដោលរដ្ឋសភាកំណត់ទុកពេល១ថ្ងៃ ក្នុងមួយសប្តាហ៍សម្រាប់ការឆ្លើយសំណួរ(រ.ធ.មាត្រា៩៦)។

១៤. សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភាមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ (រ.ធ.មាត្រា៩១ ថ្មី)។

១៥. នាយករដ្ឋមន្ត្រីមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីព្រាងច្បាប់ (រ.ធ. មាត្រា៩១ថ្មី)។

១៦. ហាមឃាត់មិនឱ្យសើរើ ឬកែប្រែរដ្ឋធម្មនុញ្ញកាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស ឬប៉ះពាល់របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ។

## ៤. នីតិវិធីពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់

### ៤.១-សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់

### ក- សេចក្តីព្រាងច្បាប់

- ក្រសួងសាមីរៀបរៀងសេចក្តីព្រាងច្បាប់ម្នាក់ឯង ឬដោយសហការជាមួយក្រសួង ឬស្ថាប័នផ្សេងទៀតដែលត្រូវបានសិក្សាដោយក្រុមអ្នកច្បាប់ (ពិនិត្យធម្មនុញ្ញភាព និងច្បាប់ពាក់ព័ន្ធទាំងឡាយ ដែលនៅជរមាន)
- រួចបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី
- ការប្រជុំអាចធ្វើមួយលើកឬច្រើនលើកហើយត្រូវដាក់ជូនអង្គប្រជុំគណៈរដ្ឋមន្ត្រីពិនិត្យនិងសម្រេច
- នាយករដ្ឋមន្ត្រីត្រូវបំពេញទម្រង់បែបបទដើម្បីផ្ញើសេចក្តីព្រាងច្បាប់ជូនប្រធានរដ្ឋសភាមានជាអាទិ៍ អត្ថបទសេចក្តីព្រាងច្បាប់ និងលិខិតស្នើសុំឱ្យរដ្ឋសភាពិនិត្យ និងអនុម័ត សេចក្តីថ្លែងហេតុ ដែលចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី ។

### ខ- សេចក្តីស្នើច្បាប់របស់តំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភា

- តំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភា អាចផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់
- សេចក្តីស្នើច្បាប់ដើមត្រូវបានដាក់ឱ្យក្រុមអ្នកជំនាញច្បាប់ដែលពាក់ព័ន្ធប្រជុំពិនិត្យ ពិភាក្សា អំពីធម្មនុញ្ញភាព និងបញ្ហាទាក់ទងទៅនឹងច្បាប់នានាជាធរមានរហូតដល់សម្រេចបានជាសេចក្តីស្នើច្បាប់ចុងក្រោយ

- អ្នកតែងសេចក្តីស្នើច្បាប់ឬតំណាងក្រុមតំណាងរាស្ត្រ ឬក្រុមសមាជិកព្រឹទ្ធសភាហត្ថលេខី ត្រូវផ្ញើទម្រង់បែបបទផ្ញើជូនប្រធានរដ្ឋសភាមានជាអាទិ៍៖ អត្ថបទសេចក្តីស្នើច្បាប់ លិខិតស្នើសុំឱ្យរដ្ឋសភាពិនិត្យ និងអនុម័ត និងសេចក្តីថ្លែងហេតុ។

## ៤.២- នីតិវិធីពិនិត្យ និងការអនុម័តច្បាប់នៅរដ្ឋសភា

**ក- គណៈកម្មាធិការអចិន្ត្រៃយ៍៖** ប្រធានរដ្ឋសភាកោះប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ពិនិត្យ សម្រេច បញ្ជូនសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ឱ្យគណៈកម្មការជំនាញពិនិត្យ។

**ខ- គណៈកម្មការជំនាញ**

- ប្រជុំពិនិត្យផ្ទៃក្នុង។
- អាចរៀបចំវេទិកាសាធារណៈ(ស្តាប់ និងប្រមូលអនុសាសន៍ពីសាធារណៈមតិ)។
- ប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល ឬតំណាងក្រុមតំណាងរាស្ត្រ ឬក្រុមសមាជិកព្រឹទ្ធសភាហត្ថលេខីនៃសេចក្តីស្នើច្បាប់ (ប្រជុំមួយលើក ឬច្រើនលើក កែប្រែ ឬរក្សាទុកទាំងស្រុង) រួចអនុម័ត ព្រមឬមិនព្រមដាក់ចូលសម័យ ប្រជុំរដ្ឋសភា។
- កូរ៉ុមសម្រាប់ការប្រជុំគណៈកម្មការនានា ត្រូវឱ្យមានលើសពីពាក់កណ្តាលនៃចំនួនសមាជិកទាំងមូល។ឯការអនុម័តត្រូវយកតាមសម្លេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកគណៈកម្មការទាំងមូល
- គណៈកម្មការជំនាញធ្វើលិខិតជូនប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ធ្វើរបាយការណ៍អំពីលទ្ធផលនៃការ ពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់។

**គ- គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា**

- ប្រជុំពិនិត្យ និងអនុម័តបញ្ចូលក្នុងរបៀបវារៈសម័យប្រជុំរដ្ឋសភា។

**ឃ- សម័យប្រជុំរដ្ឋសភា**

**ឃ១-រដ្ឋសភាអនុម័តព្រមបញ្ចូលក្នុងរបៀបវារៈ**

**ឃ២-ប្រធានគណៈកម្មការជំនាញរាយការណ៍អំពីលទ្ធផលការងាររបស់ខ្លួនជូនរដ្ឋសភា**

**ឃ៣ -ការពិភាក្សា និងអនុម័តត្រូវធ្វើដូចតទៅ៖**

- ពិភាក្សា និងអនុម័តលើខ្លឹមសារទាំងមូល គឺបញ្ចេញមតិថា តើគួរទទួលពិចារណាឬទេ?
- ពិភាក្សា និងអនុម័តលើមាត្រាមួយម្តងៗឬលើជំពូកមួយម្តងៗ ដោយអានអត្ថបទសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ទាំងស្រុង ឬដោយធ្វើរបាយការណ៍សង្ខេបខ្លឹមសារជំពូក មិនអានអត្ថបទ ឬអង្គសភាអាចប្រើនីតិវិធីសង្ខេបដោយពិភាក្សាតែមាត្រាឬជំពូកណាដែលមានសំណើធ្វើវិសោធនកម្មជាលាយលក្ខណ៍អក្សរ

- តំណាងរាជរដ្ឋាភិបាលឬតំណាងក្រុមតំណាងរាស្ត្រឬក្រុមសមាជិកព្រឹទ្ធសភាហត្ថលេខីនិងប្រធានគណៈកម្មការជំនាញ សហការគ្នាការពារសេចក្ដីព្រាងច្បាប់ឬសេចក្ដីស្នើច្បាប់។

## ៤.៣- ការបញ្ជូនទៅព្រឹទ្ធសភាពិនិត្យ និងឱ្យយោបល់

- អត្ថបទសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ដែលរដ្ឋសភាបានអនុម័តលើកដំបូងរួចហើយ ត្រូវបញ្ជូនទៅព្រឹទ្ធសភាពិនិត្យ និងឱ្យយោបល់ ។
- ព្រឹទ្ធសភាពិនិត្យហើយឱ្យយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរលើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូងរួចហើយព្រមទាំងលើបញ្ហាទាំងពួង ដែលរដ្ឋសភាបានដាក់ឱ្យពិនិត្យ។ បើជាការប្រញាប់ រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ។
- បើព្រឹទ្ធសភាបានឱ្យយោបល់យល់ព្រម ឬពុំបានឱ្យយោបល់សោះ ក្នុងរយៈពេលដែលមានកំណត់ទុកហើយនោះទេ ច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះ នឹងត្រូវបានយកទៅប្រកាសឱ្យប្រើ។
- បើព្រឹទ្ធសភាសុំឱ្យកែសម្រួលសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់នោះ រដ្ឋសភាត្រូវយកមកពិចារណាភ្លាមជាលើកទី២។ រដ្ឋសភាត្រូវពិនិត្យ និងសម្រេចតែត្រង់បទប្បញ្ញត្តិឬចំណុចណាដែល ព្រឹទ្ធសភាសុំឱ្យកែសម្រួលដោយបដិសេធចោលទាំងមូល ឬទុកជាបានការខ្លះ។
- ការបង្វិលទៅបង្វិលមក រវាងព្រឹទ្ធសភា និងរដ្ឋសភាត្រូវធ្វើតែក្នុងរយៈពេលមួយខែ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមដប់ថ្ងៃ បើត្រូវពិនិត្យសម្រេចពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែពីរថ្ងៃ បើជាការប្រញាប់។
- បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់ ឬពន្យារពេលដែលកំណត់ទុកសម្រាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍ សម្រាប់រដ្ឋសភា និងព្រឹទ្ធសភាត្រូវបន្ថែមឱ្យស្មើគ្នាដែរ។
- បើព្រឹទ្ធសភាបដិសេធសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់នោះជាអសារបង់ រដ្ឋសភាមិនអាច នឹងយកមកពិចារណាជាលើកទី២បាន មុនរយៈពេលមួយខែទេ។ រយៈពេលនេះត្រូវបន្ថយមកត្រឹម១៥ថ្ងៃ បើពិនិត្យពីថវិកា ជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែបួនថ្ងៃ បើជាការប្រញាប់។
- ក្នុងការពិនិត្យសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ជាលើកទី២នេះ រដ្ឋសភាត្រូវអនុម័តដោយ វិធីបោះឆ្នោតចំហ និងយកតាមមតិភាគច្រើនដាច់ខាត។
- សេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ណា ដែលបានសម្រេចដូចខាងលើនេះហើយនោះ នឹងត្រូវបានយកទៅប្រកាសឱ្យប្រើ។

## ៤.៤- នីតិវិធីប្រកាសឱ្យប្រើ

ប្រធានរដ្ឋសភាត្រូវធ្វើលិខិត និងឯកសារភ្ជាប់ជូននាយករដ្ឋមន្ត្រី ដើម្បីអោយចាត់ការតាមនីតិវិធី ស្នើសុំព្រះមហាក្សត្រ ទ្រង់ឡាយព្រះហស្តលេខាលើ ព្រះរាជក្រម ប្រកាសឱ្យប្រើ។ ចំពោះច្បាប់រៀបចំអង្គការ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាត្រូវធ្វើជូនប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីពិនិត្យអំពីធម្មនុញ្ញភាព ជាមុនសិន មុននឹងប្រកាសអោយប្រើ។

# គំនូសបំព្រួញនីតិវិធីពិនិត្យ និង អនុម័តច្បាប់




**កំណត់សំគាល់** : ដំណើរនៃសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ :

( ១ ) ដំណើរការងារក្នុងសភានីមួយៗ

( ២ ) ការបង្វិលទៅមករវាងសភាទាំងពីរ

# មេរៀនទី ៤៖
# កម្រិតផ្សេងៗគ្នានៃអត្តសញ្ញាណកម្មបុគ្គល

**DIFFERENT LEVELS OF IDENTITY**

( Mr. Dy Bonna, Ms. Nou Channy, Mr. Mao Saroeun, and Mr. Mon Munint )

**គោលបំណងនៃមេរៀន៖ ក្រោយពីបញ្ចប់ខ្លឹមមេរៀននេះអ្នកសិក្សាទាំងអស់នឹងអាច៖**

| | |
|---|---|
| 1 | រៀបចំរបៀបសម្របខ្លួនតាមសង្គម និងធ្វើអន្តរកម្មជាមួយពិភពលោកជុំវិញខ្លួនតាមរយៈការអភិវឌ្ឍជំនាញទំនាក់ទំនងបុគ្គល និងជំនាញអន្តរបុគ្គល |
| 2 | ពិនិត្យពីកម្រិតខុសគ្នានៃអត្តសញ្ញាណនិងភាពជាប់ពាក់ព័ន្ធលើទំនាក់ទំនងនៃការគ្រប់គ្រងជាមួយអ្នកដទៃ |
| 3 | បែងចែកពីភាពខុសគ្នារវាងអត្តសញ្ញាណកម្មបុគ្គលអត្តសញ្ញាណកម្មរួម ក្រុមមនុស្សផ្សេងៗគ្នា និងបណ្តុះសតិស្មារតីឱ្យយល់ពីតម្លៃទៅលើមនុស្សជាតិទូទៅ |
| 4 | ត្រួតពិនិត្យល្អិតល្អន់ស៊ីជម្រៅទៅលើមធ្យោបាយផ្សេងៗនៃកម្រិតខុសគ្នារបស់អត្តសញ្ញាណ ដែលអាចមានអន្តរកម្មគ្នាទៅវិញទៅមកក្នុងការរស់នៅប្រកបដោយសន្តិភាពជាមួយក្រុមមនុស្សផ្សេងៗគ្នា។ |

## ១. សេចក្តីផ្តើម

តាមន័យទូទៅ យើងអាចកំណត់អត្តសញ្ញាណកម្មថាជាសតិអារម្មណ៍ផ្ទាល់ខ្លួនរបស់មនុស្សម្នាក់ៗ ដែលបានបង្កើតឡើងដោយចរិកលក្ខណៈពិសេសភាពជាប់ទាក់ទងគ្នា និងតួនាទីក្នុងសង្គមរបស់ពួកគេ។ លើសពីនេះ អត្តសញ្ញាណកម្មមាននិរន្តរភាព ដោយមនុស្សម្នាក់មានសតិអារម្មណ៍ស្រដៀងគ្នាទៅនឹងមនុស្សម្នាក់ទៀតហើយបន្តបន្ទាប់នឹងក្លាយជាមនុស្សតែមួយ ទោះបីជាមានការផ្លាស់ប្តូរច្រើនក្នុងស្ថានភាព របស់ពួកគេយ៉ាងណាដោយ។ គ្រាប់ពូជនៃអត្តសញ្ញាណកម្មត្រូវបានបណ្តុះក្នុងវ័យកុមារ ដែលអ្នកមើលថែមានឥទ្ធិពលទៅលើពួកគេជាទីបំផុត។ ប៉ុន្តែការផ្លាស់ប្តូរបុគ្គលពីវ័យកុមាររហូតដល់វ័យជំទង់នាពេលនោះ ពួកគេចាប់ផ្តើមចេះសួរសំណួរថា៖ តើពួកគេជាអ្នកណា និងតើពួកគេសម្របសម្រួលខ្លួនទៅក្នុងសង្គមដោយរបៀបណាដែរ?។ ដូច្នេះ មនុស្សវ័យជំទង់ត្រូវចាកចេញដើម្បីរកឲ្យឃើញពីអារម្មណ៍ផ្ទាល់ខ្លួនពួកគេ ដោយមានការធ្វើពិសោធជាមួយនឹងតួនាទី និងអត្តចរិកខុសៗគ្នា (Erikson, 1956)។ ទោះបីជាមនុស្សពេញវ័យ បន្តវាយតម្លៃអត្តសញ្ញាណក្នុងជីវិតពួកគេយ៉ាងណាក៏ដោយភាពផ្លាស់ប្តូរនៃអត្តសញ្ញាណគឺនៅមានតិចតួចនៅឡើយ។ ដូចនេះ យោងទៅតាមអ្នកចិត្តសាស្ត្រដ៏ល្បីល្បាញ គឺលោក អ៊ីរិក អ៊ីរិកសុន ការអភិវឌ្ឍ

ន៍អត្តសញ្ញាណកម្មនៅកំឡុងពេលពេញវ័យ គឺមានសារៈសំខាន់ដើម្បីឲ្យមនុស្សម្នាក់ៗអាចបង្កើតគោលគំនិតផ្ទាល់ខ្លួនមួយដ៏រឹងមាំ ហើយអាចអភិវឌ្ឍទិសដៅក្នុងជីវិតបាន (Erikson, 1956) ។ **ការបង្កើតអត្តសញ្ញាណកម្ម** ឬ អាចហៅថា **ការអភិវឌ្ឍអត្តសញ្ញាណកម្ម** ឬ **ការកសាងអត្តសញ្ញាណកម្ម** គឺជាដំណើរការស្មុគស្មាញមួយដែលមនុស្សទូទៅអាចអភិវឌ្ឍទិដ្ឋភាព និងអត្តសញ្ញាណពួកគេដោយ ច្បាស់លាស់ និងមានលក្ខណៈពិសេស។

គោលគំនិតផ្ទាល់ខ្លួន ការអភិវឌ្ឍន៍បុគ្គលិកលក្ខណៈនិងតម្លៃ គឺមានទំនាក់ទំនងជិតស្និតជាមួយនឹងការបង្កើតអត្តសញ្ញាណកម្ម។ ភាពជាបុគ្គលគឺជាផ្នែកមួយដ៏សំខាន់នៃការបង្កើតអត្តសញ្ញាណកម្ម។ និរន្តរភាពនិងការរួបង្រួម បង្រួមអារម្មណ៍ខាងក្នុងគឺជាការបង្កើតអត្តសញ្ញាណកម្មដ៏ល្អ ខណៈមានការមិនយល់ស្របមួយក្នុងការបង្កើតអត្តសញ្ញាណកម្មនេះអាចជាទិដ្ឋភាព និងសញ្ញាដែលចាត់ទុកថាជាការអភិវឌ្ឍដែលមិនប្រក្រតីតួយ៉ាងបង្ហាញពីស្ថានភាពជាក់ស្តែង ដូចជាស្លាកស្នាមរបួសពីកុមារភាពអាចរួមចំណែកក្នុងការអភិវឌ្ឍន៍មិនប្រក្រតីនេះ។ កត្តាសត្យានុម័តនានាក៏ដើរតួនាទីសំខាន់ក្នុងការបង្កើតអត្តសញ្ញាណកម្មដែរដូចជា៖ ពូជសាសន៍ ពណ៌សម្បុរ និងសាសនា ជាដើម។ គោលគំនិតនៃនិរន្តរភាពបុគ្គលឬអត្តសញ្ញាណបុគ្គល សំដៅទៅលើបុគ្គលទាំងឡាយណាដែលចោទសំណួរសួរខ្លួនឯង ដោយប្រឆាំងជំទាស់នឹងការយល់ឃើញ ដូចជា "តើខ្ញុំជាអ្នកណា? "ដំណើរការនេះ បានកំណត់លក្ខណៈបុគ្គលសម្រាប់ខ្លួនផ្ទាល់ និងសម្រាប់អ្នកដទៃ។ កត្តាជាច្រើនបានបង្កើតឱ្យមាននូវអត្តសញ្ញាណកម្មបុគ្គលដោយផ្សារភ្ជាប់ជាក់ស្តែងទៅនឹងបុគ្គលម្នាក់ ដែលមានការទាក់ទងគ្នាជាលក្ខណៈពិសេសនៃអារម្មណ៍រួមជាមួយអ្នកដទៃហើយ




អារម្មណ៍នៃទំនាក់ទំនងទាំងនេះផ្អែកលើតួនាទីរបស់ពួកគេនៅក្នុងក្រុមផ្សេងៗ ដូចជា គ្រួសារ ជនជាតិ និងមុខរបរ។ អត្តសញ្ញាណក្រុមទាំងនេះបង្ហាញ ពីតម្រូវការរបស់មនុស្សក្នុងការទំនាក់ទំនង ឬសម្រាប់បុគ្គលណាដែលចង់កំណត់ខ្លួនឯងនៅក្នុងភ្នែករបស់អ្នកដទៃ និងភ្នែកខ្លួនឯង។

អត្តសញ្ញាណកម្មត្រូវបានបង្កើតឡើងនៅក្នុងកម្រិតជាច្រើន។ កម្រិតមីក្រូ (តូច) គឺជាការកំណត់ ផ្ទាល់ខ្លួន ការទំនាក់ទំនងជាមួយមនុស្ស និងបញ្ហាដែលបានឃើញពីទស្សនៈផ្ទាល់ខ្លួន ឬបុគ្គល។ កម្រិត មេសូ (មធ្យម ឬកណ្តាល) ទាក់ទងទៅនឹងរបៀបដែលអត្តសញ្ញាណកម្មត្រូវបានមើល បង្កើត និងសាក សួរដោយសហគមន៍ និង/ឬក្រុមគ្រួសារដែលជិតដិត។ កម្រិតម៉ាក្រូ (ធំ) គឺជាទំនាក់ទំនងរវាងបុគ្គល និងបញ្ហាទាក់ទងនឹងទស្សនៈជាតិ។ កម្រិតសកល មានទំនាក់ទំនងទៅនឹងបុគ្គល បញ្ហា និងក្រុមនានា ក្នុងកម្រិតពិភពលោក។ ជារឿយៗ អត្តសញ្ញាណកម្មត្រូវ

បានពណ៌នាថាជាសញ្ញាណមួយដែលមានការកំណត់ និងមានភាពដោយឡែកខុសៗគ្នា ( ឧ. គ្រួសារ វប្បធម៌ បុគ្គលផ្ទាល់ខ្លួន វិជ្ជាជីវៈ )។

## ២. ទ្រឹស្តីនៃអត្តសញ្ញាណកម្ម

ការអភិវឌ្ឍន៍ទ្រឹស្តីជាច្រើន បានបញ្ចូលលក្ខណៈនៃការបង្កើតអត្តសញ្ញាណកម្មនៅក្នុងនោះទ្រឹស្តីពីរបានបង្ហាញដោយផ្ទាល់ពីដំណើរការនៃការបង្កើតអត្តសញ្ញាណកម្ម៖ ការអភិវឌ្ឍន៍ដំណាក់កាលនៃចិត្តសាស្ត្ររបស់លោកអ៊ីរិក អ៊ីរិកសុន (អត្តសញ្ញាណកម្មប្រៀបធៀបទៅនឹងដំណាក់កាលភ័ន្តច្រឡំតួនាទី) ទ្រឹស្តីអត្តសញ្ញាណកម្មរបស់លោកជេមស៍ មឺស្យា និងទ្រឹស្តីនៃការបង្កើតអត្តសញ្ញាណកម្មក្នុងភាពពេញវ័យរបស់លោកជេហ្វ៊ីរី អាននេត។

## ៣. ទ្រឹស្តីអត្តសញ្ញាណកម្មរបស់លោកអ៊ីរិកសុន ធៀបទៅនឹងការភ័ន្តច្រឡំតួនាទី

ទ្រឹស្តីរបស់លោកអ៊ីរិកសុន គឺបានបង្ហាញថាមនុស្សទទួលបទពិសោធន៍តាមរយៈវិបត្តិឬជម្លោះខុសៗគ្នាពេញមួយជីវិតរបស់ពួកគេដោយស្ថិតក្នុង៨ដំណាក់កាល។ ដំណាក់កាលនីមួយៗកើតឡើងនៅចំណុចមួយពិតជាក់ស្តែងក្នុងជីវិតនិងត្រូវបានដោះស្រាយដើម្បីអាចដំណើរការទៅតាមដំណាក់កាលបន្ទាប់។ ដំណាក់កាលពិសេសដែលទាក់ទងនឹងការបង្កើតអត្តសញ្ញាណកម្ម កើតមានឡើងក្នុងអំឡុងវ័យជំទង់៖ អត្តសញ្ញាណកម្មធៀបនឹងការភ័ន្តច្រឡំតួនាទី។ អត្តសញ្ញាណកម្មធៀបនឹងដំណាក់កាលភ័ន្តច្រឡំ តួនាទីពាក់ព័ន្ធទៅនឹងមនុស្សវ័យជំទង់ដែលព្យាយាមរកឲ្យឃើញថាពួកគេគឺជានរណាដើម្បីបង្កើតឲ្យបានអត្តសញ្ញាណគោលដែលពួកគេចង់បាននឹងត្រូវកសាងពេញមួយជីវិតរបស់ពួកគេ ជាពិសេសដំណើរនេះត្រូវទាក់ទងទៅនឹងអត្តសញ្ញាណសង្គម និងអត្តសញ្ញាណអាជីព។ ពួកគេសួរខ្លួនឯងនូវសំណួរមួយចំនួនថា៖ "តើខ្ញុំជាអ្នកណា?" និង "តើខ្ញុំអាចក្លាយជាអ្វី" ពួកគេប្រឈមមុខនឹងភាពស្មុគស្មាញក្នុងការកំណត់នូវអត្តសញ្ញាណផ្ទាល់ខ្លួនរបស់ពួកគេ។ លោកអ៊ីរិកសុនបានលើកឡើងថា វិបត្តិនេះត្រូវបានដោះស្រាយឡើងវិញជាមួយសមិទ្ធផលនៃការកំណត់អត្តសញ្ញាណមានន័យថាបុគ្គលបានពិចារណាយ៉ាងទូលំទូលាយពីគោលបំណង និងតម្លៃផ្សេងៗ ការទទួលយកកិច្ចការមួយចំនួន និងការបដិសេធអ្នកដទៃ ព្រមទាំងយល់ថាពួកគេគឺជាមនុស្សមានលក្ខណៈពិសេស។ នៅពេលដែលមនុស្សវ័យជំទង់ម្នាក់សម្រេចការកំណត់អត្តសញ្ញាណ ពួកគេនឹងត្រៀមខ្លួនរួចជាស្រេចដើម្បីឈានចូលដំណាក់កាលបន្ទាប់របស់ទ្រឹស្តីលោកអ៊ីរិកសុន ដែលដំណាក់កាលនោះនិយាយអំពីភាពស្និទ្ធស្នាលធៀបទៅនឹងការដាក់ខ្លួនឱ្យនៅឯកកោ វាជាស្ថានភាពមួយដែលពួកគេនឹងបង្កើតបានទំនាក់ទំនងមិត្តភាពរឹងមាំ និងអារម្មណ៍ភាពជាមិត្តជាមួយអ្នកដទៃ។

ប្រសិនបើវិបត្តិរវាងអត្តសញ្ញាណកម្មនិងការភ័ន្តច្រឡំតួនាទី មិនត្រូវបានដោះស្រាយដោយសមស្របនោះទេ មនុស្សពេញវ័យម្នាក់នឹងប្រឈមមុខទៅនឹងការភ័ន្តច្រឡំពីផែនការផ្សេងៗនាពេលអនាគត ជាពិសេសគឺតួនាទីរបស់ពួកគេក្នុងវ័យនេះ។ ការបរាជ័យក្នុងការបង្កើតអត្តសញ្ញាណផ្ទាល់ខ្លួន វាក៏ធ្វើឲ្យបរាជ័យក្នុងការចែករំលែកអត្តសញ្ញាណជាមួយអ្នកដទៃផងដែរ ដែលអាចនឹងនាំឲ្យអសមត្ថភាពត្រង់ចំណុចជាច្រើនក្នុងនាមជាបុគ្គលពេញវ័យមួយរូប។ ដំណាក់កាលបង្កើតអត្តសញ្ញាណកម្មនៃទ្រឹស្តីការអភិវឌ្ឍចិត្តសាស្ត្ររបស់លោកអ៊ីរិក អ៊ីរិកសុនគឺជាដំណាក់កាលមួយដ៏សំខាន់ក្នុងជីវិត។

## ៤. ទ្រឹស្តីអត្តសញ្ញាណកម្មរបស់លោក មីស្យា

មីស្យា បានបង្កើតការសម្ភាសន៍បែបគម្រោងមួយ ដែលធ្វើឡើងដើម្បីចាត់ក្រុមមនុស្សវ័យជំទង់ចូលទៅក្នុងគោលការណ៍មួយ ក្នុងចំណោម៤គោលការណ៍នៃអត្តសញ្ញាណកម្ម។ គោលការណ៍ទាំងនោះ ត្រូវបានប្រើដើម្បីពណ៌នា ឬបញ្ជាក់ពីដំណើរការនៃការបង្កើតអត្តសញ្ញាណកម្ម។ នៅក្នុងទ្រឹស្តីរបស់លោកមីស្យា អត្តសញ្ញាណកម្ម ត្រូវបានកំណត់ថាតើបុគ្គលម្នាក់បានរុករកនូវភាពខុសប្លែកពីគ្នា និងបានតាំងចិត្តក្នុងការប្រកបមុខរបរ ការគោរពសាសនា គ្រប់គ្រងទំនោរផ្លូវភេទ និងរៀបចំតម្លៃនយោបាយបានឬយ៉ាងណា?។

### គោលការណ៍អត្តសញ្ញាណកម្មទាំង៤ របស់ទ្រឹស្តីលោក ជែមស៍ មីស្យាមានដូចជា៖

1. **ការពង្រាយអត្តសញ្ញាណកម្ម-**Identity diffusion (អាចហៅថាការភ័ន្តច្រឡំតួនាទី)៖ ផ្ទុយទៅនឹងសមិទ្ធផលអត្តសញ្ញាណ បុគ្គលនោះមិនទាន់បានដោះស្រាយវិបត្តិអត្តសញ្ញាណរបស់ពួកគេនៅឡើយទេ ដោយមិនបានប្តេជ្ញាចិត្តចំពោះគោលដៅឬតម្លៃណាមួយ និងមិនបានបង្កើតទិសដៅជីវិតនាពេលអនាគត។ក្នុងវ័យជំទង់ ដំណាក់កាលនេះត្រូវបានកំណត់លក្ខណៈដោយការគិតមិនមានរបៀបរៀបរយ ការពន្យារពេល និងការជៀសវាងបញ្ហា និងសកម្មភាពផ្សេងៗ។
2. **ការផាត់ចេញនៃអត្តសញ្ញាណកម្ម** (Identity Foreclosure)៖ វាកើតឡើងនៅពេលក្មេងវ័យជំទង់។ ពួកគេមិនបានស្វែងរកផ្លូវដោះស្រាយវិបត្តិអត្តសញ្ញាណ របស់ពួកគេតាមរយៈភាពខុស ឆ្លងទៅជាការប្តេជ្ញាចិត្ត ទៅជាគោលដៅឬតម្លៃណាមួយ និងបង្កើតឱ្យបានទិសដៅជីវិត នាពេលអនាគត។ ឧ, ក្មេងជំទង់ប្រហែលជាមិនគោរពតម្លៃ និងតួនាទីរបស់ឪពុកម្តាយពួកគេឬទំនៀមទម្លាប់វប្បធម៌ឡើយ។ ពួកគេប្រហែលជាទំនោរទៅរកអត្តសញ្ញាណអវិជ្ជ មាន ឬ មានការប្រឆាំងផ្ទាល់លើតម្លៃឪពុកម្តាយរបស់ពួកគេ ឬទំនៀមទម្លាប់ប្រពៃណី។
3. **ការផ្អាកអត្តសញ្ញាណកម្ម** (Identity Moratorium)៖ គោលការណ៍នេះជាការពន្យាពេលក្នុង ការសម្រេចបានសមិទ្ធផលអត្តសញ្ញាណកម្មតាមរយៈការផ្តល់នូវជារនាំងបណ្តោះអាសន្នមួយ។ ក្នុងស្ថានភាពនេះជាការផ្តល់

ឱកាសដល់ការរុករកទាំងចម្ងាយ និងស៊ីជម្រៅ។ ជាឧទាហរ ណ៍ការផ្អាកនេះកើតឡើងនៅក្នុងសង្គមសហរដ្ឋអាមេរិក រួមបញ្ចូលទាំងមហាវិទ្យាល័យ ឬយោធា

4. **សមិទ្ធផលអត្តសញ្ញាណកម្ម៖** ស្ថានភាពនេះត្រូវបានសម្រេចនៅពេលដែលបុគ្គលនោះបានដោះស្រាយបញ្ហាអត្តសញ្ញាណដោយ ធ្វើការប្តេជ្ញាចិត្តចំពោះគោលដៅ ជំនឿ និងតម្លៃបន្ទាប់ពីការរុករក យ៉ាងទូលំទូលាយពីផ្នែកផ្សេង ៗ។

## ៥. ទ្រឹស្តីនៃការបង្កើតអត្តសញ្ញាណកម្មក្នុងភាពពេញវ័យរបស់លោកជេហ្វ៊ីរ អាននេត

ទ្រឹស្តីរបស់លោកជេហ្វ៊ីរ អាននេត បានលើកឡើងថាការបង្កើតអត្តសញ្ញាណកម្ម គឺជាចំណុចដែលលេចធ្លោបំផុតកើតឡើងនៅក្នុងភាពពេញវ័យ ដោយចាប់ពីអាយុ១៨ឆ្នាំ ដល់២៥ឆ្នាំ។ **អាននេត** បានកំណត់ថាការបង្កើតអត្តសញ្ញាណកម្មអាស្រ័យលើការទទួលយកឱកាស និងលទ្ធភាពផ្សេងៗក្នុងជីវិតដើម្បីធ្វើការសម្រេចចិត្តសំខាន់ៗរបស់ខ្លួន។ គាត់ជឿថានៅក្នុងដំណាក់កាលជីវិតនេះ ផ្តល់ឱកាសដ៏សម្បូរបែបក្នុងការបង្កើតអត្តសញ្ញាណកម្ម ជាពិសេសនៅក្នុងផ្នែកខុសៗគ្នាទាំង៣។ **ផ្នែកទាំង៣នៃការរុករកអត្តសញ្ញាណកម្មមានដូចតទៅ៖**

1. **សេចក្តីស្រឡាញ់៖** ក្នុងការឈានទៅដល់ភាពពេញវ័យ បុគ្គលគ្រប់រូប ត្រូវរុករកសេចក្តីស្រឡាញ់ដើម្បីស្វែងរកភាពស្និតស្នាលយ៉ាងជ្រាលជ្រៅ ខណៈដែលពួកគេកំពុងស្វែងរកសេចក្តីស្រឡាញ់បុគ្គលទាំងនោះ ជារឿយៗរុករកអត្តសញ្ញាណរបស់ពួកគេដោយផ្តោតទៅលើសំណួរមួយចំនួនដូចជា៖ "បើខ្ញុំជាមនុស្សបែបនេះ តើខ្ញុំប្រាថ្នាចង់បានមនុស្សប្រភេទណាជាដៃគូជីវិត?"
2. **ការងារ៖** ឱកាសការងារដែលមនុស្សកំពុងតែធ្វើ គឺត្រូវបានប្រមូលផ្តុំដោយគំនិតដែលពួកគេនឹងរៀបចំអាជីពណាដែលពួកគេអាចធ្វើនៅកំឡុងភាពពេញវ័យ។ បុគ្គលគ្រប់រូបរុករកអត្តសញ្ញាណពួកគេដោយសួរសំណួរមួយចំនួនទៅកាន់ខ្លួនឯងថា៖ "តើការងារប្រភេទបែបណាដែលខ្ញុំពូកែធ្វើ?" "តើការងារប្រភេទណាដែលខ្ញុំពេញចិត្តធ្វើក្នុងរយៈពេលយូរ?" ឬ "តើខ្ញុំមានឱកាសអ្វីខ្លះដើម្បីទទួលបានការងារដែលស្ថិតក្នុងផ្នែកដែលខ្ញុំសាកសមនឹងធ្វើបំផុត?"
3. **ទស្សនៈសាកលលោក៖** វាគឺជាកិច្ចការរួមសម្រាប់បុគ្គលណាដែលស្ថិតនៅក្នុងដំណាក់កាលឈានចូលភាពពេញវ័យ ក្នុងការចូលរៀននៅមហាវិទ្យាល័យ។ នៅទីនោះ ពួកគេប្រហែលជាបានដឹងឮពីនានាភាពនៃទិដ្ឋភាពសាកលលោកប្រៀបធៀបចំពោះអ្នកដែលបានរស់នៅទីនោះស្រាប់ ហើយបើកចិត្តដើម្បីធ្វើការផ្លាស់ប្តូរទស្សនៈសាកលលោកពីមុន ពួកគេប្រហែលជាត្រូវដាក់ខ្លួនចូលទៅក្នុងស្ថានភាពផ្សេងៗជាច្រើនក្នុងសាកលលោក។ បុគ្គលដែលមិនបានរៀនមហាវិទ្យាល័យ ក៏ជឿជាក់ផងដែរថាក្នុងនាមជាមនុស្សពេញវ័យគួរតែចេះសម្រេចចិត្តពីភាពជឿជាក់ និងតម្លៃរបស់ពួកគេ។

## ៦. អត្តសញ្ញាណបុគ្គល

គោលគំនិតបុគ្គលឬអត្តសញ្ញាណបុគ្គលគឺជាបណ្តុំនៃជំនឿនិងគំនិតដែលបុគ្គលមាននៅក្នុងខ្លួនគាត់ផ្ទាល់។ គោលគំនិតបុគ្គល គឺខុសគ្នាពីការស្គាល់ខ្លួនឯងដែលជាការដឹងពីខ្លួនឯង។ សមាសភាគនៃគោលគំនិតបុគ្គលរួមមានការចូលរួមខាងផ្នែករាងកាយវិទ្យា ចិត្តវិទ្យា និងសង្គមវិទ្យា ដែលអាចទទួលឥទ្ធិពលដោយឥរិយាបថ ទម្លាប់ ជំនឿ និងគំនិតទស្សនៈរបស់បុគ្គល ពួកគេមិនអាចបង្រួមចូលជាគោលគំនិតទូទៅសម្រាប់ក្តីស្រម័យនិងការឱ្យតម្លៃលើខ្លួនឯងឡើយ។ អត្តសញ្ញាណច្រើនប្រភេទស្ថិតនៅក្នុងបុគ្គលម្នាក់ៗរួមគ្នា ហើយអាចបែងចែកដូចខាងក្រោម៖អត្តសញ្ញាណវប្បធម៌ អត្តសញ្ញាណវិជ្ជាជីវៈ អត្តសញ្ញាណជនជាតិ និងជាតិ អត្តសញ្ញាណសាសនា អត្តសញ្ញាណយេនឌ័រ និងអត្តសញ្ញាណពិការភាព។

**ក. អត្តសញ្ញាណកម្ម ធៀបទៅនឹង បុគ្គលិកលក្ខណៈ ធៀបទៅនឹង ចរិកលក្ខណៈ៖** មនុស្សជាច្រើនប្រើពាក្យអត្តសញ្ញាណកម្មជំនួសគ្នានឹងពាក្យផ្សេងទៀតដូចជាចរិតលក្ខណៈ និងបុគ្គលិកលក្ខណៈ។ ទោះបីជាពាក្យគន្លឹះទាំងបីនេះស្តាប់ទៅស្រដៀងគ្នា ប៉ុន្តែពួកវាខុសពីគ្នាពីមួយទៅមួយវិញ ហើយនេះជារបៀបដែលអ្នកអាចមើលឃើញពួកវាមួយផ្នែក។ អត្តសញ្ញាណកម្ម រួមមានលក្ខណៈសម្បត្តិរបស់បុគ្គលដែលពួកគេអាចគ្រប់ គ្រងតិចតួច ឬគ្មានសិទ្ធិគ្រប់គ្រងទៅលើរឿងរាវគ្រួសារ ពណ៌សម្បុរ ឬកម្ពស់។ វាក៏រួមបញ្ចូលផងដែរនូវប្រព័ន្ធជំនឿ ជនជាតិ សីលធម៌ និងគុណតម្លៃរបស់ពួកគេ។ ផ្ទុយទៅវិញ បុគ្គលិកលក្ខណៈជាធម្មតារួមបញ្ចូលនូវគុណសម្បត្តិដូចជាការហួសចិត្តឧបនិស្ស័យ សុទិដ្ឋិនិយម និងមនសិការជាដើម។ម្យ៉ាងវិញទៀត អត្តសញ្ញាណរបស់អ្នកបង្ហាញថាអ្នកជានរណា និងអ្នកតំណាងឲ្យអ្វី ចំណែកឯបុគ្គលិកលក្ខណៈរបស់អ្នកដឹកនាំអាកប្បកិរិយារបស់អ្នក។ ចរិកលក្ខណៈ គឺស្រដៀងនឹងបុគ្គលិកលក្ខណៈ ដែលវាត្រូវបានប្រើដើម្បីពិពណ៌នាអំពីអាកប្បកិរិយារបស់មនុស្ស។ ចំណុចចម្បងដែលធ្វើឲ្យបុគ្គលិកលក្ខណៈខុសពីចរិកលក្ខណៈនោះគឺបុគ្គលិកលក្ខណៈរបស់បុគ្គល គឺស្តែងចេញជាសកម្មភាពរៀងរាល់ថ្ងៃរបស់ពួកគេ។ ផ្ទុយទៅវិញ ចរិកលក្ខណៈជាធម្មតាឆ្លុះបញ្ចាំងពីទំនោរអាកប្បកិរិយានៅក្នុងស្ថានភាពជាក់លាក់ ដូចជានៅពេលបង្ខំឱ្យធ្វើការសម្រេចចិត្តដែលមានហានិភ័យខ្ពស់។ ឧទាហរណ៍ បុគ្គលិកលក្ខណៈរបស់អ្នកកំណត់បានដោយអ្នកមានអន្តរកម្មជាមួយមិត្តរួមការងារនៅក្នុងទំនាក់ទំនងប្រចាំឆ្នាំ។ ផ្ទុយពីនេះ ចរិកលក្ខណៈរបស់អ្នកហាក់ដូចជាត្រូវបានបញ្ចេញមកក្រៅដោយរបៀបដែលអ្នកមានប្រតិកម្មចំពោះកាលៈទេសៈឬហេតុការណ៍ផ្សេងៗ ដូចជានៅពេលដែលអ្នកឃើញពីការរើសអើងនៅកន្លែងធ្វើការ ឬស្តាប់ឮមេរបស់អ្នកសន្ទនាតាមទូរស័ព្ទ ដែលគាត់រៀបរាប់លម្អិតអំពីគម្រោងគេចពន្ធរបស់គាត់។ ភាពខុសប្លែកគ្នាមួយទៀតរវាងបុគ្គលិកលក្ខណៈ និងចរិកលក្ខណៈគឺថាចរិករបស់មនុស្សគឺអាចបត់បែនបានជាងបុគ្គលិកលក្ខណៈរបស់ពួកគេ។ លើសពីនេះ ការផ្លាស់ប្តូរចរិកអាចឆ្លុះបញ្ចាំងពី

ការផ្លាស់ប្តូរអត្តសញ្ញាណ ដោយសារការផ្លាស់ប្តូរប្រព័ន្ធជំនឿ និងតម្លៃរបស់ពួកគេ។ ជាឧទាហរណ៍មនុស្សម្នាក់ប្រហែលជាមិនអាចផ្លាស់ប្តូរកម្រិតនៃការប្រែប្រួលរបស់ពួកគេបានច្រើនទេ។ យ៉ាងណាក៏ដោយ ពួកគេអាចគួរឲ្យតម្លៃទៅការពិតឲ្យកាន់តែច្រើននៅពេលដែលពួកគេកាន់តែមានវ័យចំណាស់ទៅៗ ហើយក្លាយជាមនុស្សកាន់តែស្មោះត្រង់ដោយអាស្រ័យទៅតាមពេលវេលាឬកាលៈទេសៈ។

**ខ. ប្រភេទនៃអត្តសញ្ញាណកម្ម៖** យើងបានពិភាក្សារួចហើយថា អត្តសញ្ញាណកម្មបានរួមបញ្ចូលជាមួយលក្ខណៈផ្សេងៗតាំងពីយើងកើតមក គំនិត ជំនឿ និងតម្លៃដែលយើងទទួលបានពីមជ្ឈដ្ឋានជុំវិញខ្លួន។ នេះគឺជាប្រភេទទូទៅមួយចំនួននៃអត្តសញ្ញាណកម្ម និងការពិពណ៌នាសង្ខេបរបស់ពួកវា។ ទោះបីជាអត្តសញ្ញាណកម្មទាំងនោះ គឺបានប្រើប្រាស់ទូទៅ ពួកវាមិនមែនជាអត្តសញ្ញាណទាំងអស់ដែលយើងជួបប្រទះនោះទេ។ អត្តសញ្ញាណកម្មមួយចំនួន មានទំនងទំនង ឬជាប់ពាក់ព័ន្ធនឹងប្រភេទនៃអត្តសញ្ញាណកម្មផ្សេងជាច្រើន ហើយខ្លះទៀតគឺត្រូវបានពិភាក្សាវែកញែកនៅក្នុងសង្គមបច្ចុប្បន្ន។ ខាងក្រោមនឹងបង្ហាញពីការពិភាក្សាអំពីប្រភេទនៃអត្តសញ្ញាណកម្ម។

1. **អត្តសញ្ញាណយេនឌ័រ៖** អត្តសញ្ញាណយេនឌ័រ ចង្អុលបង្ហាញពីក្រុមភេទមនុស្សដែលមានភេទជាប្រុស ភេទជាស្រី ឬក៏មិនមានភេទទាំងពីរ (ខ្ទើយ) ហើយរួមមានភាពទំនោរទៅកាន់ផ្លូវភេទណាមួយ ដែលវាប្រហែលជាអាចជាប្រភេទនៃអត្តសញ្ញាណដែលត្រូវបានគេពិភាក្សា វែកញែកជាច្រើននៅក្នុងសង្គមយើងបច្ចុប្បន្ន។ មនុស្សភាគច្រើនប្រៀបធៀបយេនឌ័រ និងភេទ ដោយសារតែមានការប្រឆាំងបានកើតឡើង នៅពេលដែលមនុស្សបានកំណត់យេនឌ័រពួកគេ ដែលមិនត្រូវជាមួយភេទដែលពួកគេមានពីកំណើត។ ដើម្បីយល់ពីការវែកញែកមួយនេះ សូមពិចារណាគោលគំនិតទាំងនេះ។ យេនឌ័រ គឺជាការបង្កើតកសាងឡើងដោយសង្គម ហើយវារួមបញ្ចូលអត្តចរិករបស់ក្រុមមនុស្សនិងការរំពឹងទុករបស់សង្គម។ ផ្ទុយទៅវិញ ភេទគឺជាគំនិតផ្នែកជីវសាស្ត្រ ដែលអាស្រ័យទៅលើក្រូម៉ូសូមរបស់បុគ្គលនីមួយៗ និងកត្តាសែនផ្សេងទៀត។ ប្រសិនបើអត្តសញ្ញាណយេនឌ័រត្រូវជាមួយភេទរបស់ពួកគេ (ឧទាហរណ៍៖ ភេទប្រុស និងភេទស្រី) វាត្រូវបានគេហៅថា Cisgender។ ប្រសិនបើអត្តសញ្ញាណយេនឌ័រនិងភេទមិនត្រូវគ្នា បុគ្គលទាំងនេះប្រហែលជាកំណត់ខ្លួនឯងថាជា ...........

   ជាទូទៅ បុគ្គលទាំងអស់ចាប់កំណើតដោយមានក្រូម៉ូសូមភេទពីរ ស្ត្រីមានក្រូម៉ូសូមXX ហើយបុរសមានក្រូម៉ូសូមXY។ ប៉ុន្តែការវិវត្តន៍នៃក្រូម៉ូសូមនៃភេទ គឺមិនត្រឹមត្រូវដូចដែលមនុស្សជាច្រើនបានគិតនោះទេ។ ជាឧទាហរណ៍៖ បុគ្គលណាដែលមានផ្ទុកអាការៈរោគរបស់លោកធ័ន៍ មនុស្សនោះមានក្រូម៉ូសូមXមួយ ហើយមិនមានក្រូម៉ូសូមភេទទី២ទេ (Heard & Turner, 2011)។ ទោះបីជាបុគ្គលទាំងនេះមានលក្ខណៈដូចស្ត្រីក៏ដោយ សរីរាង្គបន្តពូជរបស់ពួកគេមិនអាចអភិវឌ្ឍបានត្រឹមត្រូវដោយគ្មានការព្យាបាលដោយអរម៉ូនឡើយ ហើយជាធម្មតាពួកគេមិនអាចមានផ្ទៃពោះបានទេ។ ភេទតាមបែបជីវសាស្ត្រអាចមានការភ័ន្តច្រឡំ នៅពេលពិចារណាលើ

បុគ្គលដែលមានអាការៈរោគអរម៉ូនអង់ដ្រូសែនមិនច្បាស់លាស់។ បុគ្គលទាំងនេះមានផ្ទុកក្រូម៉ូសូម XY ដែលមានន័យថាបុរសពីកំណើត។ប៉ុន្តែបើមុយតាស្យុង (បំរែបំរួលមិនប្រក្រតីនៃហ្សែន) ទៅលើរេសិបទ័រ របស់ប្រូតេអ៊ីនដែលទទួលសញ្ញាអរម៉ូនប្រុសវិញ អាចធ្វើឲ្យបុគ្គលនោះ មានការឆ្លើយតបជាមួយអរម៉ូនប្រុសបានមិនពេញលេញ ឬមួយមិនឆ្លើយតបទាំងស្រុង (Mongan et al., 2015)។

បុគ្គលដែលមាន មុយតាស្យុង (បំរែបំរួលមិនប្រក្រតីនៃហ្សែន) បង្ករឲ្យមានភាពមិនឆ្លើយតបជាមួយអរម៉ូនប្រុស ជាហេតុធ្វើឲ្យបុគ្គលនោះមានរូបរាងលក្ខណៈជាមនុស្សស្រី តែមានហ្សែនជា XY (Mongan et al., 2015)។ បុគ្គលជាច្រើនរស់នៅជាមនុស្សស្រី ហើយមិនដឹងថាពួកគេមានហ្សែនជាមនុស្សប្រុស ក្នុងរយៈពេលជាច្រើនឆ្នាំ។ ផ្ទុយទៅវិញ បុគ្គលដែលឆ្លើយតបជាមួយអរម៉ូនប្រុសមិនពេញលេញ អាចនឹងជាមនុស្សស្រីពេលចាប់កំណើត ប៉ុន្តែវាប្រហែលជាអាចអភិវឌ្ឍទាំងបុគ្គលិកលក្ខណៈជាស្រីផង និងប្រុសផង នៅកំឡុងវ័យជំទង់ (Mongan et al., 2015) ។ ជាថ្មីម្តងទៀត ក្មេងទាំងនេះ និងឪពុកម្តាយពួកគេប្រហែលជាមិនបានដឹងពីស្ថានភាពលក្ខខណ្ឌនេះរហូតដល់ពួកគេស្ថិតក្នុងវ័យជំទង់។

ជាសង្ខេបខ្លី ភេទតាមបែបជីវសាស្ត្រមិនមែនជាភេទដែលយើងអាចដឹងច្បាស់តែម្តង ពេលចាប់កំណើតនោះទេ អត្តសញ្ញាណប្រភេទនេះអាចប្រែប្រួលគ្រប់ពេល។ លើសពីនេះទៅទៀត ពីព្រោះតែយេនឌ័រគឺជាការកសាងពីសង្គម អត្តសញ្ញាណយេនឌ័ររបស់បុគ្គលតែងតែមិនត្រូវនឹងភេទជីវសាស្ត្រ។ ប្រសិនបើអ្នកចង់ស្វែងយល់កាន់តែស៊ីជម្រៅនេះ គឺជាវីដេអូខ្លីមួយដែលពន្យល់ពីភាពខុសគ្នារវាងអត្តសញ្ញាណយេនឌ័រ និងភេទដែលមានពីកំណើត។ តាមន័យសង្គមវិទ្យា អត្តសញ្ញាណយេនឌ័រព័ណ៌នាថាជាយេនឌ័រដែលបុគ្គលម្នាក់កំណត់ (ឧទាហរណ៍ មនុស្សម្នាក់កំណត់ខ្លួនថាជាបុរស ជាស្ត្រី ឬមិនមែនជាភេទទាំងពីរ) ប៉ុន្តែវាក៏អាចសំដៅទៅលើយេនឌ័រដែលមានន័យថាមនុស្សដទៃចូលរួម ដែលមនុស្សផ្សេងទៀតសន្មតពីបុគ្គលដែលដឹងពីតួនាទីយេនឌ័រ (អាកប្បកិរិយាសង្គម សម្លៀកបំពាក់ ម៉ូតសក់។ល។)។ អត្តសញ្ញាណយេនឌ័រប្រហែលជាត្រូវបានជះឥទ្ធិពលដោយរចនាសម្ព័ន្ធសង្គមផ្សេងៗ រួមមានក្រុមជនជាតិ ឋានៈការងារ សាសនា ឬមិនសាសនា និងគ្រួសារ។ វាអាចបង្ហាញជាសញ្ញាណនៃភាពអាចបន្តពូជបានពេញលេញតាមបែបជីវសាស្ត្រផងដែរ។

2. **អត្តសញ្ញាណសេដ្ឋកិច្ចសង្គម៖** អត្តសញ្ញាណប្រភេទនេះរួមមានផ្នែកនៃការអប់រំ អាជីព និងអត្តសញ្ញាណតាមថ្នាក់ ដោយអាស្រ័យទៅលើចំណូល និងការងាររបស់បុគ្គល ហើយជាទូទៅចំណូល និងការងារបានឆ្លុះបញ្ចាំងកម្រិតនៃការអប់រំរបស់ពួកគេ។ ជាទូទៅ អត្តសញ្ញាសេដ្ឋកិច្ចសង្គមគឺជាសូចនាករនៃស្ថានភាពសង្គម សុខុមាលភាពសេដ្ឋកិច្ច និងកិត្យានុភាព។

មនុស្សជាច្រើនអាចនឹងនៅក្នុងថ្នាក់នៃសេដ្ឋកិច្ចសង្គមដដែលៗ នៅពេញមួយជីវិតរបស់ពួកគេ។ ទោះបីជាយ៉ាងណាក៏ដោយ អត្តសញ្ញាណសេដ្ឋកិច្ចសង្គមលូតលាស់ជាងអត្តសញ្ញាណផ្សេងទៀត ដូចជាពូជសាសន៍ជាដើម មនុស្សទាំងនោះអាចនឹងផ្លាស់ទីចេញពីអត្តសញ្ញាណសេដ្ឋកិច្ចសង្គមទៅអត្តសញ្ញាណមួយផ្សេងទៀត អាស្រ័យទៅតាមពេលវេលា។ ឧទាហរណ៍៖ ក្មេងម្នាក់កើតក្នុងគ្រួសាមានឪពុកម្តាយជាពលករ ដែលឪពុកម្តាយបានបោះបង់ការសិក្សានៅកម្រិតថ្នាក់មធ្យមសិក្សា វាអាចក្លាយជាមនុស្សដំបូងក្នុងគ្រួសារដែលនឹងបញ្ចប់មហាវិទ្យាល័យ ហើយក្រោយមកក្លាយជាមនុស្សដែលមានជីវភាពមធ្យមកម្រិតខ្ពស់។

3. **អត្តសញ្ញាណវប្បធម៌៖** វប្បធម៌ ត្រូវបានកំណត់ថាជាបណ្តុំនៃជំនឿ និងអត្តចរិកបែបប្រពៃណីដែលបានចែករំលែកដោយសមាជិកមនុស្សមួយក្រុម។ ឯអត្តសញ្ញាណរបស់ពួកយើងភាគច្រើនក៏មានជាប់ពាក់ព័ន្ធនឹងក្រុមមនុស្សដែលបានចែករំលែកវប្បធម៌តៗគ្នានេះដែរ។ ដូច្នេះអត្តសញ្ញាណវប្បធម៌របស់យើងរួមបញ្ចូលលក្ខណៈអត្តសញ្ញាណជាច្រើនដូចជា អត្តសញ្ញាណបែបជាតិសាសន៍ ពណ៌សម្បុរ សាសនា ជំនាន់ និងភូមិសាស្ត្រ។ ឧទាហរណ៍ សមាជិកក្រុមជនជាតិមួយអាចនឹងមានប្រពៃណីពិសេសរបស់ពួកគេ។ ដូចគ្នាផងដែរ ក្រុមសាសនាមួយអាចចែករំលែកការឲ្យតម្លៃទៅលើភាពស្មោះត្រង់របស់ពួកគេទៅកាន់អ្នកដទៃ។ លើសពីនេះ មនុស្សដែលរស់នៅក្នុងតំបន់ភូមិសាស្ត្រដូចគ្នាអាចមានការបញ្ចេញសំឡេងតាមតំបន់នោះ និងអាចចែករំលែកប្រវត្តិសាស្ត្រដែលមានឥទ្ធិពលលើវប្បធម៌របស់ពួកគេ ក៏ដូចជាអត្តសញ្ញាណរបស់គេផងដែរ។ កត្តាដែលសំខាន់សម្រាប់មនុស្សទូទៅគឺ មនុស្សគួរមានទំនាក់ទំនងជាមួយសង្គមខាងក្រៅ ហើយដែលស្ថិតនៅក្នុងក្រុមណាមួយ។ អត្តសញ្ញាណវប្បធម៌គឺជាចំណែកមួយក្នុងការសម្រេបខ្លួន ព្រមទាំងមានអារម្មណ៍ថាខ្លួនស្ថិតក្នុងក្រុមតែមួយ។ លើសពីនេះទៅទៀត វាជះឥទ្ធិពលទៅលើភាពខាងក្រៅរបស់យើង និងរបៀបយល់ឃើញរបស់យើងទៅកាន់ពិភពលោកជុំវិញ ដែលបរិបទនោះ អាចខុសពីវប្បធម៌ផ្សេងៗ។ ឧទាហរណ៍ អាកប្បកិរិយាល្អ ឬឬសរាយរាក់ទាក់នៅក្នុងវប្បធម៌មួយអាចត្រូវគេយល់ផ្សេង ថាមិនអាចទទួលយកបានឬមិនសមរម្យនៅក្នុងវប្បធម៌មួយផ្សេងទៀត។ ដោយសារវប្បធម៌នីមួយៗមានបទដ្ឋាននិងស្តង់ដារបស់វា ជម្លោះអាចកើតឡើងនៅពេលដែលមនុស្សមកពីវប្បធម៌ខុសៗគ្នាទទូចថាវិធីរបស់ពួកគេក្នុងការធ្វើអ្វីមួយគឺជាវិធីត្រឹមត្រូវ។ បច្ចុប្បន្ននេះ ចំណុចមួយទៀតដែលយើងសង្កេតឃើញថាវាមានបាតុ ភូតដូចទៅនឹងអត្តសញ្ញាណនយោបាយ ត្រូវបានចាត់ជាចំណុចដែលយើងនឹងបកស្រាយបន្ទាប់។

4. **អត្តសញ្ញាណនយោបាយ៖** នៅក្នុងន័យសាមញ្ញ នយោបាយត្រូវបានកំណត់ថា ជាការសម្រេចចិត្តរួមដោយផ្អែកលើការគ្រប់គ្រងរបស់មនុស្សមួយក្រុម។ នៅក្នុងប្រព័ន្ធនយោបាយប្រជាធិបតេយ្យ បុគ្គលគ្រប់រូបបោះឆ្នោតជ្រើសរើសយកបេក្ខជនណាដែលពួកគេគាំទ្រនៅក្នុងការបោះឆ្នោតដែលប្រព្រឹត្តទៅជាប្រចាំ។ ការបោះឆ្នោត ជា

ទូទៅត្រូវបានគេឃើញថាជាសិទ្ធិ ឯកសិទ្ធិ និងកាតព្វកិច្ចរបស់ពលរដ្ឋ។ ប៉ុន្តែរបៀបក្នុងការសម្រេចចិត្តបោះឆ្នោតបានបង្ហាញពីភាពខ្លួនយើងជាបុគ្គលច្រើន តម្លៃរបស់យើង ក៏ដូចជាអទិភាពរបស់យើង។ ម្យ៉ាងទៀត របៀបនៃការបោះឆ្នោតពាក់ព័ន្ធជាច្រើនទៅលើអត្តសញ្ញាណនយោបាយរបស់យើង។ អត្តសញ្ញាណនយោបាយនៃបុគ្គលមួយសំដៅទៅលើភាពលម្អៀង និងភាពចូលរួមក្នុងនយោបាយរបស់ពួកគេ។ បុគ្គលដែលជ្រើសរើសគណបក្សនយោបាយមួយរួចហើយ ប្រហែលជាបោះឆ្នោតឲ្យតែបេក្ខជនដែលនៅគណបក្សនោះប៉ុណ្ណោះ ដោយសារតែបុគ្គលិកលក្ខណៈ និងគុណវឌ្ឍិរបស់បេក្ខជននោះ។ លើសពីនេះ អត្តសញ្ញាណនយោបាយនៃបុគ្គលមានឥទ្ធិពលទៅលើអត្តចរិក ជំនឿ និងការសម្រេចចិត្តក្រៅពីកន្លែងបោះឆ្នោត (Collins, Mandel & Schywiola,2021)។ ឥទ្ធិពលនៃអត្តសញ្ញាណនយោបាយនេះត្រូវបានផ្សារភ្ជាប់ជាមួយនឹងការធ្វើនយោបាយនៃបញ្ហាអព្យាក្រឹតពីមុន ដូចជាកម្មវិធីសិក្សារបស់សាលា ឬការពាក់ម៉ាស់ និងការរក្សាគម្លាតពីសង្គមក្នុងអំឡុងពេលជំងឺរាតត្បាតផ្លូវដង្ហើម ក៏ដូចជាវ៉ាក់សាំងផងដែរ។

5. **អត្តសញ្ញាណវប្បធម៌៖** អត្តសញ្ញាណវប្បធម៌ គឺជាការបង្កើតគំនិតដែលបុគ្គលម្នាក់ៗយកតាមវប្បធម៌ដែលពួកគេមាន។ អត្តសញ្ញាណវប្បធម៌មានទំនាក់ទំនងគ្នាទៅវិញទៅមក តែវាមិនដូចគ្នាទីទៅនឹងអត្តសញ្ញាណនយោបាយឡើយ។ នៅទីនោះវាមានសំណួរជាច្រើនទាក់ទងនឹងវប្បធម៌ទំនើបដែលបានផ្លាស់ប្តូរទៅសំណួរបែបអត្តសញ្ញាណ។ វប្បធម៌ប្រវត្តិសាស្ត្រក៏មានឥទ្ធិពលលើអត្តសញ្ញាណបុគ្គល និងអត្តសញ្ញាណវប្បធម៌ទំនើបផងដែរ បុគ្គលអាចរកមើល និងជ្រើសរើសទិដ្ឋភាពផ្សេងៗ នៃអត្តសញ្ញាណវប្បធម៌ ខណៈពេលដែលបដិសេធនូវគំនិតពាក់ព័ន្ធផ្សេងទៀត។ លើសពីនេះ អត្តសញ្ញាណវប្បធម៌ត្រូវបានជាប់ពាក់ព័ន្ធដើម្បីមើលឃើញទិដ្ឋភាពខុសៗគ្នានៅក្នុងសង្គមដូចជា ជាតិសាសន៍ សាសនា អាយុ ភាសា ទំនោរនៃភេទ។ល។




6. **អត្តសញ្ញាណវិជ្ជាជីវៈ៖** អត្តសញ្ញាណវិជ្ជាជីវៈគឺជាអត្តសញ្ញាណសម្រាប់អាជីពមួយ ដែលព័ណ៌នាឲ្យស្របនឹងតួនាទី ទំនួលខុសត្រូវ តម្លៃ និងស្តង់ដារសីលធម៌ ដែលទទួលស្គាល់ដោយអាជីព។ នៅក្នុងវិស័យជំនួញ អត្តសញ្ញាណវិជ្ជាជីវៈគឺជាការកំណត់ផ្នែកវិជ្ជាជីវៈមួយដោយខ្លួនឯងលើគុណលក្ខណៈតម្លៃ និងបទពិសោធន៍។ អត្តសញ្ញាណវិជ្ជាជីវៈត្រូវបានអភិវឌ្ឍនៅពេលមានទស្សនៈមួយបានបង្ហាញនៅក្នុងវប្បធម៌រួបរួមជាច់ដោយឡែក-បុគ្គលិកលក្ខណៈរួបរួម។ អ្នកជំនាញផ្នែកធុរៈកិច្ច គឺជាបុគ្គលនៅក្នុងវិជ្ជាជីវៈដែលមានជំនាញមួយចំនួន ដែលជួនកាលត្រូវការការបណ្តុះបណ្តាល ឬការអប់រំជាផ្លូវការ។

ការអភិវឌ្ឍន៍វិជ្ជាជីវៈរួមបញ្ចូលការយល់ដឹងសរុបនៃចិត្តសាស្ត្រ សង្គមវិទ្យា ការអប់រំ រាងកាយ សេដ្ឋកិច្ច និងឱកាសដែលផ្លាស់ប្តូរការអនុវត្តការងាររបស់បុគ្គលម្នាក់ពេញមួយជីវិត។ ការអភិវឌ្ឍន៍អាជីព ក៏សំដៅទៅលើសកម្មភាពអនុវត្តនៅតាមអង្គភាព និងក្រុមហ៊ុនដែលធ្វើឲ្យរីកចម្រើននូវអាជីពរបស់បុគ្គល ឬការលើកទឹកចិត្តពួកគេឲ្យមានជម្រើសនៃអាជីព។ ការបណ្តុះបណ្តាលគឺជាទម្រង់នៃការកំណត់អត្តសញ្ញាណ ពីព្រោះវាមិនប៉ះពាល់ត្រឹមតែចំណេះដឹងប៉ុណ្ណោះទេ ប៉ុន្តែវាក៏ប៉ះពាល់គោលគំនិតរបស់សមាជិកក្រុមផងដែរ។ ម៉្យាងទៀត ចំណេះដឹងតាមតួនាទី បង្កើតឲ្យមានផ្លូវថ្មីដើម្បីឲ្យសិក្ខាកាមប្រឹងប្រែងតិចជាងមុន ដែលបន្តប្រសិទ្ធិភាពនៃការបណ្តុះបណ្តាលដោយលើកកម្ពស់ការបញ្ចេញគំនិតផ្ទាល់ខ្លួនឲ្យកាន់តែខ្លាំងក្លាជាងមុន។ ទម្រង់ផ្សេងទៀតនៃគោលការណ៍អត្តសញ្ញាណនៅក្នុងអង្គភាពមួយ រួមមាន កាតក្នុងវិស័យជំនួញ អត្ថប្រយោជន៍ជាក់លាក់ទៅតាមតួនាទីនិងការបញ្ជូនភារកិច្ចបន្ត។

7. **អត្តសញ្ញាណជនជាតិ និងសញ្ជាតិ៖** អត្តសញ្ញាណជនជាតិមួយ គឺជាអត្តសញ្ញាណមួយដែលជាជនជាតិមួយច្បាស់លាស់ ជាធម្មតាឈរនៅលើមូលដ្ឋាននៃពង្សាវតារទូទៅ ឬពូជពង្សដែលមានស្រាប់។ ការស្គាល់ជាតិសាសន៍អ្នកដទៃថាជាក្រុមជនជាតិមួយដ៏កម្រគឺជាកត្តារួមចំណែកមួយក្នុងការអភិវឌ្ឍន៍ឲ្យមានអត្តសញ្ញាណ។ ជារឿយៗ ក្រុមជនជាតិនានារួបរួមគ្នាដោយមានវប្បធម៌ អាកប្បកិរិយា ភាសា ការគោរពពិធី ឬសាសនា។

   ដំណើរការដែលនាំឱ្យមានការលេចឡើងនៃការកំណត់អត្តសញ្ញាណបែបនេះត្រូវបានសង្ខេបថាជាជាតិសាសន៍និយម។ ឯកសារវប្បធម៌ និងទ្រឹស្តីសង្គមជាច្រើន ពិនិត្យនិងស្វែងរកចម្ងល់ទាក់ទងនឹងអត្តសញ្ញាណវប្បធម៌ និងជនជាតិ។ អត្តសញ្ញាណវប្បធម៌ ប្រកាន់ខ្ជាប់នូវលក្ខខណ្ឌតំបន់ ភេទ ពូជសាសន៍ ប្រវត្តិសាស្ត្រ សញ្ជាតិ ទំនោរខាងភេទ ជំនឿសាសនា និងជនជាតិ។ អត្តសញ្ញាណសញ្ជាតិ គឺជាទ្រឹស្តីសីលធម៌ និងទស្សនវិជ្ជាដែលមនុស្សទាំងអស់ត្រូវបានបែងចែកទៅជាក្រុមដែលហៅថាជាតិសាសន៍។ ក្រុមមនុស្សនៃ"ជាតិសាសន៍" ចែករំលែកអត្តសញ្ញាណជាទូទៅ ហើយមកពីប្រភពដើមសាមញ្ញមួយ ពូជពង្ស ភាពតពីឪពុកម្តាយ និងតំណពូជ។

8. **អត្តសញ្ញាណសាសនា៖** អត្តសញ្ញាណសាសនាគឺជាបណ្តុំនៃជំនឿ និងការអនុវត្តជាទូទៅដែលបានប្រព្រឹត្តដោយបុគ្គលម្នាក់ ហើយវាពាក់ព័ន្ធនឹងការប្រកាន់ខ្ជាប់នូវជំនឿ និងពិធីសាសនា និងការសិក្សាអំពីប្រពៃណីដូនតា ឬវប្បធម៌ ការសរសេរ ប្រវត្តិសាស្ត្រ ទេវកថា ជំនឿ និងបទពិសោធន៍ដ៏អាថ៌កំបាំងនានា។ អត្តសញ្ញាណសាសនា សំដៅលើការប្រតិបត្តិផ្ទាល់ខ្លួនដែលទាក់ទងនឹងជំនឿសហគមន៍រួមជាមួយនឹងពិធីសាសនា និងការប្រាស្រ័យទាក់ទងដែលកើតចេញពីជំនឿបែបនេះ។ ការបង្កើតអត្តសញ្ញាណនេះចាប់ផ្តើមដោយមានការទំនាក់ទំនងជាមួយសាសនារបស់ឪពុកម្តាយ និងភាពជាបុគ្គលដោយវាទាមទារឲ្យបុគ្គលនោះជ្រើសរើសអត្តសញ្ញាណមួយដូចគ្នា ឬខុសគ្នាទៅនឹងអត្តសញ្ញាណឪពុកម្តាយរបស់ពួកគេ។

9. **អត្តសញ្ញាណពិការភាព៖** អត្តសញ្ញាណពិការភាពសំដៅទៅលើភាពពិការជាក់លាក់ដែលបុគ្គលមួយបានកំណត់។ នេះប្រហែលជាអ្វីមួយដែលមានពិតជាក់ស្តែងដូចជាមនុស្សពិការដែលកំណត់អត្តសញ្ញាណបែបនេះ ឬអ្វីមួយដែលមិនសូវលេចធ្លោ ដូចជាមនុស្សថ្លង់ដែលចាត់ទុកខ្លួនឯងថាជាផ្នែកមួយនៃសហគមន៍ក្នុងស្រុក ជាតិ ឬសង្គមនៃវប្បធម៌មនុស្សថ្លង់។ អត្តសញ្ញាណពិការភាព គឺស្ទើរតែត្រូវបានកំណត់ដោយបុគ្គលម្នាក់កើតមកពិការ ទោះបីជាបុគ្គលនោះអាចជាសះស្បើយនៅពេលក្រោយក្នុងជីវិត បុគ្គលម្នាក់ក្រោយមកក្លាយជាពិការវិញ ឬនៅពេលដែលបុគ្គលម្នាក់ក្រោយមករកឃើញថាពិការដែលមិនបានចាប់អារម្មណ៍ពីមុន (ជាពិសេសគឺចំពោះបញ្ហាផ្លូវចិត្ត)។ នៅក្នុងករណីកម្រខ្លះ ជនពិការអាចរងឥទ្ធិពលដោយការប៉ះពាល់ផ្លូវចិត្តមិនល្អ។
10. **អត្តសញ្ញាណនយោបាយ៖** អត្តសញ្ញាណនយោបាយ គឺត្រូវមានការទាមទារជាសាធារណៈ និងប្រមូលផ្តុំនូវសម្ភារៈ និងធនធានផ្សេងទៀតសម្រាប់បង្កើតឲ្យមានសកម្មភាពរួម។ ទ្រឹស្តីមួយបានរកឃើញពីរបៀបដែលអត្តសញ្ញាណនយោបាយកើតឡើងជាទ្រឹស្តីចលនាសង្គម។ យោងទៅតាមលោក ឆលស៍ ធីលលី ការបកស្រាយអំពីទំនាក់ទំនងរបស់យើងចំពោះ ("រឿងរ៉ាវ") អ្នកដទៃ គឺបង្កើតបានជាហេតុផល និងបង្កើតបានអត្តសញ្ញាណនយោបាយ។សមត្ថភាពក្នុងការធ្វើសកម្មភាពត្រូវទាមទារឲ្យមានធនធានសម្ភារៈ ហើយពេលខ្លះការយល់ឃើញផ្សេងៗអាចត្រូវបានរៀបចំដោយការប្រើយុទ្ធសាស្រ្តទំនាក់ទំនង ដោយប្រើយុទ្ធសាស្រ្តបំភាន់។
11. **អត្តសញ្ញាណរួម៖** អត្តសញ្ញាណរួម គឺជាផ្នត់គំនិតអារម្មណ៍ដែលស្ថិតនៅក្នុងក្រុមមួយ (រួម)។ ប្រសិនបើវាមានឥទ្ធិពល បុគ្គលម្នាក់ដែលចូលក្នុងក្រុមនឹងយកជីវិតនិងអត្តសញ្ញាណបុគ្គលរបស់គេចូលទៅក្នុងក្រុមនោះ ដោយពួកគេនឹងការពារទស្សនៈរបស់ក្រុម និងប្រថុយប្រថានដើម្បីក្រុមជាញឹកញាប់ដោយមិនមានការលើកទឹកចិត្តឬការបង្ខិតបង្ខំឡើយ។ អត្តសញ្ញាណរួម តែងតែបង្កើតបានតាមរយៈអារម្មណ៍នៃការចាប់អារម្មណ៍ ភាពពាក់ព័ន្ធ ឬភាពមិនអនុគ្រោះ។ ភាពស្អិតរមួតនៃអត្តសញ្ញាណរួមកើតឡើងខាងក្រៅសហគមន៍ទៀត ដោយសារក្រុមអាចជួបប្រទះទុក្ខសោកពីការបាត់បង់សមាជិកណាម្នាក់។

## ៩. ការអភិវឌ្ឍន៍អត្តសញ្ញាណអន្តរបុគ្គល

ការអភិវឌ្ឍន៍អត្តសញ្ញាណអន្តរបុគ្គល គឺកើតចេញមកពីទ្រឹស្តីអត្តសញ្ញាណកម្មរបស់លោកម៉ីស្សា ហើយវាសំដៅទៅលើមិត្តភាព ការណាត់ជួប តួនាទីយេនឌ័រ និងការកម្សាន្តដែលជាភាពសម្រាកនៃផ្លូវចិត្តអារម្មណ៍របស់បុគ្គល។ ទំនាក់ទំនងសង្គមអាចសំដៅទៅលើអន្តរកម្មសង្គមជាច្រើនដែលគ្រប់គ្រងដោយ ច្បាប់សង្គមរវាងមនុស្សពីរនាក់ ឬច្រើននាក់ ដោយម្នាក់ៗមានមុខតំណែងសង្គម និងតួនាទីសង្គម ដែលត្រូវបំពេញ។ នៅក្នុងឋានានុក្រមសង្គមវិទ្យា ទំនាក់ទំនងសង្គមមានភាពជឿនលឿនជាងអាកប្បកិរិយា សកម្មភាព អាកប្បកិរិយាសង្គម សកម្មភាពសង្គម

ប្រាស្រ័យទាក់ទងក្នុងសង្គម និងអន្តរកម្មសង្គម។ វាបង្កើតជាមូលដ្ឋាននៃគំនិត ដូចជាការរៀបចំសង្គម រចនាសម្ព័ន្ធសង្គម ចលនាសង្គម និងប្រព័ន្ធសង្គម។ **ការអភិវឌ្ឍន៍អត្តសញ្ញាណអន្តរបុគ្គលត្រូវបានបែងចែកជា៣សមាសភាពៈ**

- **ការដាក់ជាក្រុមៈ** ចាត់មនុស្សទៅតាមប្រភេទនៃក្រុម។
- **ការកំណត់អត្តសញ្ញាណៈ** ចាត់មនុស្សធ្វើការនៅក្នុងក្រុមជាក់លាក់។
- **ការប្រៀបធៀបៈ** ប្រៀបធៀបក្រុមទាំងអស់។

ការអភិវឌ្ឍន៍អត្តសញ្ញាណអន្តរបុគ្គល អនុញ្ញាតឲ្យបុគ្គលម្នាក់ចេះសាកសួរ និងពិនិត្យមើលបុគ្គលិកលក្ខណៈផ្សេងៗ ដូចជាផ្នាត់គំនិត ជំនឿ និងអាកប្បកិរិយា។ សកម្មភាព ឬ គំនិតរបស់អ្នកដទៃ បង្កើត ជាឥទ្ធិពលសង្គម ដែលអាចផ្លាស់ប្តូរបុគ្គលនោះបាន។ ឧទាហរណ៍នៃឥទ្ធិពលសង្គមប៉ះពាល់ ដល់អាកប្បកិរិយារបស់បុគ្គលម្នាក់ វាអាចត្រូវបានគេមើលឃើញនៅក្នុងសង្គមភាវូបនីយកម្ម សម្ពាធពីមិត្តភ័ក្តិ ការគិត អំពីខ្លួនឯង និងការទទួលយកឬការបដិសេធជាបន្តបន្ទាប់នៅពេល ដែលមនុស្សផ្សេងទៀត ព្យាយាម ជះ ឥទ្ធិពលលើខ្លួនបុគ្គលនោះ។

**១. អន្តរកម្មៈ** កំឡុងពេលអភិវឌ្ឍអត្តសញ្ញាណអន្តរបុគ្គល មានការកើតឡើងជាការផ្លាស់ប្តូរយោបល់ និងការទទួលយកយោបល់ ដូចនេះវាធ្វើឲ្យលេចចេញនូវលទ្ធផលជាពត៌មានបែបគុណវិស័យ។ គោលបំណងនៃការអភិវឌ្ឍន៍អត្តសញ្ញាណអន្តរបុគ្គលគឺដើម្បីដោះស្រាយទម្រង់ភាពដូចគ្នានៃបុគ្គលដែលត្រូវបានរកឃើញថាមិនអាចបែងចែកពីអ្នកដទៃបាន។ ការផ្តល់បែបនេះ អមជាមួយការអនុញ្ញាតផ្សេងទៀត បុគ្គលត្រូវបានដឹកនាំឲ្យចេះប្រឆាំងនឹងអ្នកដទៃព្រមទាំងបង្ខំឲ្យដកថយ និងទទួលស្គាល់ខ្លួនឯងថាជាការពិត។ ដើម្បីដោះស្រាយភាពមិនស៊ីសង្វាក់គ្នា បុគ្គលរូបនោះរួមបញ្ចូល ឬបដិសេធធាតុដែលបានជួបប្រទះ ជាហេតុនាំឱ្យទទួលបានអត្តសញ្ញាណថ្មី។ ក្នុងអំឡុងពេលនៃការផ្លាស់ប្តូរនីមួយៗ បុគ្គលត្រូវដោះស្រាយ ការផ្លាស់ ប្តូរនេះ មុនពេលប្រឈមមុខនឹងការផ្លាស់ប្តូរបន្ទាប់នាពេលអនាគត។ តាំងពីពិភពលោក មានការផ្លាស់ ប្តូរមក ការផ្លាស់ប្តូរ គឺគ្មានទីបញ្ចប់ នាពេលបច្ចុប្បន្នវាតែងតែបង្ហាញពីការផ្លាស់ប្តូររវាងបុគ្គលនិងបុគ្គល ដូច្នេះហើយការផ្លាស់ប្តូរនោះអនុញ្ញាតឱ្យបុគ្គលនោះកំណត់ខ្លួនឯងឡើងវិញជានិច្ច។

**២. ការគាំទ្រពីសង្គមៈ** បុគ្គលទាំងឡាយ ទទួលបានអត្តសញ្ញាណសង្គម និងអត្តសញ្ញាណក្រុមតាមរយៈការចូលរួមរបស់ ពួកគេនៅក្នុងក្រុមខុសៗគ្នាដែលរួមមាន គ្រួសារ ជនជាតិ ការអប់រំ ឋានន្តរសក្តិការងារ មិត្តភាព កាលៈ ទេសៈ និង ជំនឿសាសនា។

**៣. គ្រួសារ៖** ការចូលរួមដ៏សំខាន់ជាងគេមួយនោះ គឺការចូលរួមពីគ្រួសារ ទោះបីជាពួកគេស្ថិតក្នុងខ្សែ ស្រឡាយគ្រួសារតែមួយ ខ្សែស្រឡាយគ្រួសារច្រើនជុំគ្នា ឬ គ្រួសារចិញ្ចឹមយ៉ាងណាក៏ដោយ។ គ្រួសារនីមួយៗ មាន ឥទ្ធិពលរៀងៗខ្លួនលើអត្តសញ្ញាណ តាមរយៈអន្តរកម្មដែលកើតឡើងរវាងសមាជិកគ្រួសារ ជាមួយនឹងបុគ្គលនីមួយៗ។ អ្នកសិក្សាស្រាវជ្រាវ និងអ្នកទ្រឹស្តីនិយម បានកំណត់ថាអត្តសញ្ញាណរបស់បុគ្គលម្នាក់ (ផ្តោតទៅលើអត្តសញ្ញាណមនុស្សវ័យជំទង់) ត្រូវទទួលឥទ្ធិពលពីមនុស្សជុំវិញពួកគេ និងបរិស្ថាន ដែល គេរស់នៅ។ ប្រសិនបើគ្រួសារមួយមិនមានភាពរួបរួមគ្នាទេនោះ វានឹងបង្កឲ្យមានការផ្លាស់ប្តូរ អត្ត សញ្ញាណ ទាំងបុរស និងស្ត្រី (អត្តសញ្ញាណមួយក្នុងចំណោមអត្តសញ្ញាណទាំង៤របស់លោក ដែមស៍ មឹស្យា គឺ ជាអត្តសញ្ញាណដែលបុគ្គលម្នាក់មិនមានការតាំងចិត្ត និងមិនព្យាយាម បង្កើតការតាំងចិត្តនោះ ឡើយ)។

**៤. ទំនាក់ទំនងជាដៃគូ៖** ម៉ហ្គោន និងខូវ៉ូប៊ិយ បានធ្វើការសិក្សាស្រាវជ្រាវមួយដើម្បីវិភាគលើឥទ្ធិពលនៃមិត្តភាព ភេទដូចគ្នា នៅក្នុងការអភិវឌ្ឍន៍អត្តសញ្ញាណបុគ្គលមួយ។ ការស្រាវជ្រាវនេះសិក្សាទៅលើលក្ខណៈមិត្តភាព ភេទដូច គ្នា ចំនួន២៤ កំឡុងពេលមហាវិទ្យាល័យ រួមមានមិត្តភាពបុរស១២ និងមិត្តភាពស្ត្រី១២ ជាមួយអ្នកចូល រួមសរុប៧២នាក់។ ក្រុមនីមួយៗតម្រូវឲ្យស្គាល់គ្នាទៅវិញទៅមកយ៉ាងតិច៦ខែ។ វិធីសាស្ត្របែបគុណ វិស័យត្រូវបានជ្រើសរើសដើម្បីធ្វើការស្រាវជ្រាវនេះ ពីព្រោះវាជាវិធីសាស្ត្រដែលសាកសមនឹងសិក្សាពីការអភិវឌ្ឍន៍អត្តសញ្ញាណ។ ការសម្ភាសន៍បែបពាក់កណ្តាលគម្រោងត្រូវបានយកមកអនុវត្ត ដើម្បីសួរសិស្សឲ្យឆ្លុះបញ្ចាំងពីរឿងរ៉ាវ ឬបទពិសោធន៍ទាក់ទងនឹងបញ្ហាទំនាក់ទំនង។ លទ្ធផលបានបង្ហាញថាមានចំណុច៥ដែលបានលើកឡើងជាទូទៅ នៅពេលដែលជួបប្រទះបញ្ហាទំនាក់ទំនងនេះ មានដូចជាការលេង សើចអំពីបញ្ហាទំនាក់ទំនង ការផ្តល់ការគាំទ្រ ការផ្តល់ដំបូន្មាន ភាពជាប់ពាក់ព័ន្ធរវាងបទពិសោធន៍ អ្នក ដទៃជាមួយនឹងបទពិសោធន៍ផ្ទាល់ខ្លួន ព្រមទាំងការផ្តល់ការលើកទឹកចិត្ត។ លទ្ធផលបានសរុបសេចក្តីថា មនុស្សវ័យជំទង់កសាងអត្តសញ្ញាណពួកគេយ៉ាងសកម្មតាមរយៈការសន្ទនាលើរឿងរ៉ាវទូទៅរវាងមិត្តភាពភេទដូចគ្នានៅក្នុងករណីនេះ ដែលវាជាប់ពាក់ព័ន្ធនឹងបញ្ហាទំនាក់ទំនង។ កិច្ចសន្ទនា ដែលដៃគូមានភាព ជិតស្និត គឺបានជួយទាក់ទាញឲ្យមានការបង្កើតអត្តសញ្ញាណកម្មនៅក្នុងជីវិត។

## ១០. ឥទ្ធិពលលើអត្តសញ្ញាណកម្ម

**១. ឥទ្ធិពលនៃការគិតស៊ីជម្រៅ៖** ការអភិវឌ្ឍន៍ការគិតបែបស៊ីជម្រៅមានឥទ្ធិពលទៅលើការបង្កើតអត្តសញ្ញាណកម្ម។ នៅពេលដែលមនុស្សវ័យជំទង់អាចគិតបែបអរូបីបានដែលអាចផ្តល់ហេតុផលសមស្របបាន ពួកគេនឹងមានភាពពេលវេលាងាយស្រួលក្នុងការរុករកស្រាវជ្រាវ និងសញ្ជឹងគិតអត្តសញ្ញាណកម្មដែលអាចកើតមាន។ នៅពេលដែលមនុស្សវ័យជំទង់មានការអភិវឌ្ឍន៍ការគិតបែបស៊ីជម្រៅ និងមានភាពចាស់ទុំ ពួកគេនឹងមានទំនោរដោះស្រាយបញ្ហា

អត្តសញ្ញាណបានច្រើនជាងមិត្តភក្តិមានអាយុច្រើនដែលពួកគាត់មានការអភិវឌ្ឍន៍ការគិតមិនសូវស៊ីជម្រៅ។ នៅពេលដែលបញ្ហាអត្តសញ្ញាណកម្មត្រូវបានដោះស្រាយបានលឿននិងបានល្អ នុះត្រូវវាប្រើពេលវេលាច្រើន និងមានការខិតខំប្រឹងប្រែងឲ្យកាន់តែល្អ ដើម្បីអភិវឌ្ឍអត្តសញ្ញាណនេះ។

**២. ឥទ្ធិពលនៃការសិក្សា៖** មនុស្សវ័យជំទង់ដែលមានការសិក្សាត្រឹមកម្រិតវិទ្យាល័យ នឹងអាចមានគោលបំណងជាក់លាក់ច្រើន ហើយមានការតាំងចិត្តប្រកបអាជីពដោយស្ថិរភាព។ ការបន្តសិក្សានៅមហាវិទ្យាល័យឬសកលវិទ្យាល័យអាចធ្វើឲ្យការបង្កើតអត្តសញ្ញាណកាន់តែមានភាពរស់រវើក។ ផ្ទុយទៅវិញ វាក៏អាចពិតដែរ ដែលថាអត្តសញ្ញាណកម្មជះឥទ្ធិពលទៅលើការអប់រំនិងការសិក្សា។ ឥទ្ធិពលរបស់ការអប់រំទៅលើអត្តសញ្ញាណ អាចមានផលប្រយោជន៍សម្រាប់អត្តសញ្ញាណបុគ្គល ដែលបុគ្គលនីមួយៗក្លាយជាអ្នកមានចំណេះដឹងលើយុទ្ធវិធី និងផ្លូវផ្សេងៗគ្នា ដើម្បីបង្កើតឲ្យមានអត្តសញ្ញាណកម្ម។

**៣. ឥទ្ធិពលនៃសង្គមវប្បធម៌៖** ឥទ្ធិពលវប្បធម៌សង្គមគឺជាឥទ្ធិពលនៃបរិបទសង្គមនិងប្រវត្តិសាស្ត្រដ៏ទូលំទូលាយ។ ជាឧទាហរណ៍កាលពីដើមឡើយ ក្មេងជំទង់ទំនងជាទទួលយកការងារ ឬជំនឿសាសនាដែលគេបានរំពឹងទុក ឬដែលស្រដៀងនឹងឪពុកម្តាយរបស់ពួកគេ។ សព្វថ្ងៃនេះ ក្មេងជំទង់មានប្រភពធនធានកាន់តែច្រើនដើម្បីស្វែងរកជម្រើសនៃអត្តសញ្ញាណនោះក្នុងការប្តេជ្ញាចិត្ត។ ឥទ្ធិពលនេះកាន់តែមានសារៈសំខាន់តិចតួចដោយសារមានការកើនឡើងនៃជម្រើសអត្តសញ្ញា ណផ្សេងទៀត។ ជម្រើសអត្តសញ្ញាណជាច្រើនដែលមានពីមុនមក កំពុងក្លាយជាអត្តសញ្ញាណដែលគេមិនស្គាល់ និងមិនសូវពេញនិយមនាពេលបច្ចុប្បន្ននេះ។ ការផ្លាស់ប្តូរស្ថានភាពសង្គមវប្បធម៌កំពុងបង្ខំឱ្យបុគ្គលម្នាក់ៗបង្កើតអត្តសញ្ញាណតែមួយគត់ដោយផ្អែកលើសេចក្តីប្រាថ្នារបស់ពួកគេផ្ទាល់។ ឥទ្ធិពលវប្បធម៌សង្គមដើរតួនាទីខុសគ្នាក្នុងការបង្កើតបានអត្តសញ្ញាណនាពេលនោះ និងផ្ទុយពីអ្វីដែលពួកគេមានកាលពីអតីតកាល។

**៤. ឥទ្ធិពលរបស់ឪពុកម្តាយ៖** ប្រភេទនៃទំនាក់ទំនងដែលក្មេងជំទង់មានជាមួយឪពុកម្តាយរបស់ពួកគេមានតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតអត្តសញ្ញាណ។ ជាឧទាហរណ៍ នៅពេលដែលមានទំនាក់ទំនងដ៏រឹងមាំ និងវិជ្ជមានរវាងឪពុកម្តាយ និងក្មេងជំទង់ ពួកគេទំនងជាមានអារម្មណ៍ថាមានសេរីភាពក្នុងការស្វែងរកជម្រើសអត្តសញ្ញាណសម្រាប់ខ្លួនពួកគេ។ ការសិក្សាមួយបានរកឃើញថាសម្រាប់ក្មេងប្រុសនិងក្មេងស្រី ការបង្កើតអត្តសញ្ញាណត្រូវបានជះឥទ្ធិពលជាវិជ្ជមានដោយមានការចូលរួមពីឪពុកម្តាយ ជាពិសេសនៅក្នុងផ្នែកនៃការគាំទ្រ ការប្រឹក្សាពីសង្គម និងការប្រឹក្សាពីសាលារៀន។ ផ្ទុយទៅវិញ នៅពេលដែលទំនាក់ទំនងមិនមានភាពស្និទ្ធស្នាលនឹងគ្នា នុះនឹងមានការព្រួយបារម្ភចំពោះការបដិសេធ ឬការមិនសប្បាយចិត្តពីឪពុកម្តាយ ឬអាណាព្យាបាលផ្សេងទៀត ហើយពួកគេទំនងជាមានអារម្មណ៍មិនសូវជឿជាក់ក្នុងការបង្កើតអត្តសញ្ញាណដាច់ដោយឡែកពីឪពុកម្តាយរបស់ពួកគេឡើយ។

**៥. សង្គមតាមប្រព័ន្ធអនឡាញ និងអ៊ីនធឺណែត៖** អ៊ីនធឺណិតកំពុងពេញនិយមនិងក្លាយជាផ្នែកនៃការបញ្ចេញមតិរបស់ក្មេងជំទង់យ៉ាងទូលំទូលាយ។ នៅលើបណ្តាញអ៊ីនធឺណិត យុវជននិយាយអំពីជីវិត និងកង្វល់របស់ពួកគេ

ហើយបង្កើតខ្លឹមសារដែលធ្វើឱ្យអ្នកដទៃចូលរួម និងវាយតម្លៃប្រតិកម្មរបស់អ្នកដទៃក្នុងទម្រង់នៃការយល់ព្រមពីសង្គម ដែលសម្របសម្រួលតាមរយៈប្រព័ន្ធអេឡិចត្រូនិក។ នៅពេលភ្ជាប់ទំនាក់ទំនង យុវជននិយាយអំពីទម្លាប់ប្រចាំថ្ងៃ និងជីវិតរបស់ពួកគេ។ ជាមួយនឹងការបង្ហោះរូបភាព ឬវីដេអូនីមួយៗ ពួកគេអាចសួរខ្លួនឯងថាពួកគេជានរណា ហើយសាកល្បងធ្វើជាមនុស្សផ្សេងដែលខុសពីអ្វីដែលពួកគេបានអនុវត្តនៅក្នុងពិភព "ពិត"។

## ១១. អត្តសញ្ញាណធៀបនឹងការភ័ន្តច្រឡំតួនាទី

ការស្វែងយល់ក្នុងវ័យជំទង់គឺមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍអត្តសញ្ញាណរបស់យើង។ ទោះជាយ៉ាងណាក៏ដោយ ដំណើរការបង្កើតអត្តសញ្ញាណនេះមិនតែងតែសាមញ្ញដូចដែលបានដឹងនោះទេ។ ជាឧទាហរណ៍ អ្នកថែទាំក្មេងជំទង់ និងលក្ខខណ្ឌស្ថានភាពសង្គមមួយចំនួន អាចហួតចត់នឹងសមត្ថភាពរបស់ពួកគេដើម្បីដាក់ខ្លួនពិសោធន៍ជាមួយនឹងតួនាទី និងអត្តសញ្ញាណផ្សេងៗគ្នា។ ជាលទ្ធផល ក្មេងជំទង់ទាំងនេះមិនអាចរកឃើញពេញលេញនូវសតិអារម្មណ៍របស់ខ្លួន ឬក៏គោលបំណងក្នុងខ្សែជីវិតមួយឡើយនៅខណៈនេះ។ លោកអ៊ីរិក ហៅដំណាក់កាលនៃការរុករកដោយខ្លួនឯងនៅវ័យជំទង់ថាជា "ការប្រៀបធៀបអត្តសញ្ញាណជាមួយនឹងការភ័ន្តច្រឡំតួនាទី"។ យោងតាមការយល់ឃើញនេះ បុគ្គលបង្កើតអត្តសញ្ញាណរបស់ពួកគេបន្ទាប់ពីបានសាកល្បងតួនាទី អាកប្បកិរិយា និងយុទ្ធសាស្ត្រសង្គមផ្សេងៗ។ នៅពេលដែលពួកគេមិនអាចបញ្ចប់ដំណាក់កាលនេះប្រកបដោយប្រសិទ្ធភាព វានាំឱ្យមានការភ័ន្តច្រឡំតួនាទី (Erikson, 1956)។ និយាយឱ្យសាមញ្ញ ភាពច្របូកច្របល់តួនាទីអាចត្រូវបានចាត់ទុកថាជាការខ្វះអត្តសញ្ញាណរឹងមាំ។ បុគ្គលដែលមានភាពច្របូកច្របល់ក្នុងតួនាទីអាចមានអារម្មណ៍ថាមិនប្រាកដអំពីខ្លួនគេ និងរបៀបដែលពួកគេសាកសមនឹងនៅក្នុងសង្គម។ មិនដឹងថាពួកគេចង់ក្លាយជានរណា ឬអ្វីដែលពួកគេចង់បានក្នុងជីវិតពួកគេអាចនឹងតស៊ូដើម្បីឈានទៅរកផ្លូវអាជីពឬបង្កឲ្យមានទំនាក់ទំនងល្អ។ បទពិសោធន៍ ទាំងនេះអាចបន្ថយការគោរពខ្លួនឯង និងការបំពេញការងារក្នុងជីវិតរបស់ពួកគេ។

### ឧទាហរណ៍អត្តសញ្ញាណធៀបទៅនឹងការភ័ន្តច្រឡំតួនាទី

ចូរសន្មត់ថាមនុស្សម្នាក់កើតនៅក្នុងបរិយាកាសដែលពួកគេត្រូវបានគេបង្ខំឱ្យទទួលយកតួនាទីយេនឌ័របែបប្រពៃណី។ ពួកគេប្រហែលជាមិនត្រូវបានអនុញ្ញាតឱ្យសាកល្បងធ្វើជាអាកប្បកិរិយា ឬផ្លូវអាជីពដែលជាភេទផ្ទុយនោះទេ។ ជាលទ្ធផល មនុស្សនេះអាចមានភាពភ័ន្តច្រឡំទៅលើតួនាទី ប្រសិនបើពួកគេត្រូវបានគេបង្ខំឲ្យសម្របតាមច្បាប់ទម្លាប់ណាមួយដែលលើសពីអ្វីដែលពួកគេចង់បាន។

### តើវិបត្តិនៃអត្តសញ្ញាណកម្មគឺជាអ្វី?

អត្តសញ្ញាណរបស់បុគ្គលម្នាក់អាចផ្លាស់ប្តូរ និងផ្លាស់ប្តូរបន្តិចម្តងៗ ដោយសារតែភាពខុសប្លែកគ្នាអាស្រ័យទៅលើកាលៈទេសៈនិងមជ្ឈដ្ឋានដែលគេរស់នៅ។ ទោះយ៉ាងណាក៏ដោយ មានពេលខ្លះបុគ្គលម្នាក់អាចមានអារម្មណ៍ថាបាត់បង់ហាក់ដូចជាអ្វីៗទាំងអស់ដែលពួកគេជឿជាក់លើខ្លួនឯងបានបាត់បង់ភ្លាមៗ។ដូច្នេះ ទើបយើងហៅរយៈពេលនៃការវិភាគល្អិតល្អន់ និងការស្វែងយល់ពីអារម្មណ៍ក្នុងខ្លួនរបស់បុគ្គលនោះថាជាវិបត្តិអត្តសញ្ញាណ (Schmeck et al., 2013)។ ការស្វែងរកអត្តសញ្ញាណកំឡុងពេលវ័យជំទង់ និងក្រោយពេលនេះគឺជារឿងធម្មតា។ ការសិក្សាស្វែងយល់ពីខ្លួនឯង និងគោលបំណងរបស់ខ្លួនទាំងនេះផ្អែកលើការកែតម្រូវអត្តសញ្ញាណដែលមានស្រាប់របស់មនុស្ស។ ទោះជាយ៉ាងណាក៏ដោយវិបត្តិ អត្តសញ្ញាណកើតឡើងនៅពេលដែលបុគ្គលម្នាក់ជួបប្រទះស្ថានភាពដែលធ្វើឱ្យគំនិតរបស់គេមិននឹងនរ។ បទពិសោធន៍ទាំងនេះ ពេលខ្លះអាចក្លាយជាព្រឹត្តិការណ៍សោកសៅមួយ ដូចជាការបាត់បង់មនុស្សជាទីស្រឡាញ់ ការធ្វើរោគវិនិច្ឆ័យជំងឺ ឬការលែងលះដែលគួរឲ្យសោកស្តាយ។ ពួកវាក៏អាចជាព្រឹត្តិការណ៍ផ្សេងទៀតដែលផ្លាស់ប្តូរយើងតាមរបៀបផ្សេងទៀត ដូចជាការក្លាយជាឪពុកម្តាយគេ ភាពវ័យចំណាស់ ការ ផ្លាស់ប្តូរផ្លូវអាជីព ឬការផ្លាស់ប្តូរទៅកាន់តំបន់ដែលមិនធ្លាប់ស្គាល់។ ជាឧទាហរណ៍ លក្ខខណ្ឌដែលគេស្គាល់ថាជាវិបត្តិពាក់កណ្តាលជីវិត គឺជាទម្រង់មួយនៃវិបត្តិអត្តសញ្ញាណដែលបង្កឡើង ដោយអារម្មណ៍នៃភាពចាស់។ វិបត្តិអត្តសញ្ញាណគឺជាការខិតខំប្រឹងប្រែងដើម្បីកំណត់អារម្មណ៍នៃខ្លួនឯងឡើងវិញ។ ទោះបីជាមនុស្សមួយចំនួនអាចរុករកអារម្មណ៍ខ្លួនឯងដោយភាពងាយស្រួលយ៉ាងណាក៏ដោយ ប៉ុន្តែអ្នកផ្សេងទៀតក៏អាចតស៊ូក្នុងរយៈពេលយូរ។ វិបត្តិអត្តសញ្ញាណអាចក្លាយជាបញ្ហា ប្រសិនបើបុគ្គលនោះ មានអារម្មណ៍ថាទទេ គ្មានតម្លៃ ឬចាប់ផ្តើមមានអារម្មណ៍ស្អប់ខ្លួនឯង។ វាថែមទាំងអាចរំខានដល់ជីវិតប្រចាំថ្ងៃរបស់មនុស្សទាំងនោះផងដែរ។ប៉ុន្តែតើអ្នកអាចដោះស្រាយវិបត្តិអត្តសញ្ញាណដោយរបៀបណា?ជំហានដំបូង គឺការទទួលស្គាល់ថាហេតុអ្វីបានជាអ្នកមានអារម្មណ៍បែបនេះ។ ការទទួលស្គាល់បែបនេះ អាច អនុញ្ញាតឱ្យមានការរកឃើញនូវអត្ថន័យ និងគោលបំណងថ្មីៗនៅក្នុងជីវិតរបស់អ្នក។ ការចែករំលែកអារម្មណ៍របស់អ្នកជាមួយមនុស្សដែលអ្នកទុកចិត្តក៏អាចជួយអ្នកឱ្យមានការយល់ដឹងបន្ថែមផងដែរ។ ប្រសិន បើអ្នកមានគំនិតអវិជ្ជមានអំពីខ្លួនអ្នក អ្នកមានអារម្មណ៍បាក់ទឹកចិត្ត ឬមិនមានការគាំទ្រពីមនុស្សជុំវិញខ្លួន សូមព្យាយាមពិភាក្សាជាមួយគ្រូពេទ្យផ្លូវចិត្តដែលអ្នកមានទំនុកចិត្តលើគាត់។

## តើអ្វីជាការពង្រីកអត្តសញ្ញាណ?

លក្ខខណ្ឌមួយ ដែលជួនកាលច្រឡំជាមួយវិបត្តិអត្តសញ្ញាណគឺការពង្រីកអត្តសញ្ញាណ។ ទោះជា យ៉ាងណាក៏ដោយ វាមិនដូចវិបត្តិអត្តសញ្ញាណទេ លក្ខខណ្ឌនេះមានន័យថាបុគ្គលនោះមិនទាន់បានប្តេជ្ញា ចិត្តចំពោះអត្តសញ្ញាណនៅឡើយទេ ហើយក៏មិនអនុវត្តដើម្បីឆ្ពោះទៅរកការបង្កើតអត្តសញ្ញាណមួយផងដែរ។ យោងតាមលោកជេមស៍ មីស្យា ការពង្រីកអត្តសញ្ញាណគឺជាដំណាក់កាលមួយនៃការបង្កើតអត្តសញ្ញាណក្នុងអំឡុងពេលវ័យជំទង់(Marcia, 1980)

។ បុគ្គលដែលឆ្លងកាត់ការពង្រីកអត្តសញ្ញាណអាច មានការពិបាកក្នុងការពង្រឹងការយល់ដឹងអំពីអត្តសញ្ញាណ និង គោលបំណងរបស់ពួកគេ។ ជាងនេះទៅទៀត ដោយសារពួកគេខ្វះការតាំងចិត្ត ដូច្នេះពួកគេអាចហាក់ដូចជាមិន មានការលើកទឹកចិត្ត ឬចង់ដកខ្លួន ចេញដោយមិនចង់បង្កើតអត្តសញ្ញាណ (Schmeck et al., 2013)។ ពួកគេក៏ អាចស្ទាក់ស្ទើរក្នុងការសម្រេចចិត្តដោយខ្លួនឯង ឬក្នុងការបញ្ចេញមតិណាមួយផងដែរ។ ជាឧទាហរណ៍ នៅពេលសួរ អំពីប្រភេទ តន្ត្រីដែលពួកគេចូលចិត្ត បុគ្គលដែលស្ថិតក្នុងការពង្រីកអត្តសញ្ញាណអាចឆ្លើយថា ពួកគេមិនដឹងច្រើន អំពីតន្ត្រី និងចេះតែស្តាប់អ្វីដែលកំពុងចាក់នៅលើវិទ្យុតែប៉ុណ្ណោះ។ ស្រដៀងគ្នានេះដែរ នៅពេលសួរអំពី មុខវិជ្ជាអ្វី ដែលពួកគេចូលចិត្ត ឬផ្លូវអាជីពអ្វីដែលពួកគេចាប់អារម្មណ៍ ពួកគេប្រហែលជានិយាយថា ពួកគេមិនទាន់បានគិត អំពីវានៅឡើយទេ។ ទោះបីជាការពង្រីកអត្តសញ្ញាណ ជាធម្មតាត្រូវបានគេសង្កេតឃើញ នៅពេលធំឡើង និងមិន មែនជាដំណាក់កាលពេញមួយជីវិតក៏ដោយ វាអាចបន្តធ្វើការពង្រីកអត្តសញ្ញាណ រហូតដល់ពេញវ័យចំពោះបុគ្គល មួយចំនួន។ ការបន្តការពង្រីកនេះអាចបណ្តាលមកពីបញ្ហាអារម្មណ៍ ផ្លូវចិត្តដែលបុគ្គលទាំងនេះមាន ដោយសារតែ ការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃស្ថានភាពជីវិត ដែលពួកគេមិន នឹកស្មានដល់ (Carlsson, Wangqvist & Frisen, 2016)។ ជាថ្មីម្តងទៀត ប្រសិនបើអ្នក ឬមនុស្ស ជាទីស្រលាញ់កំពុងតែមានភាពលំបាកជាមួយការពង្រីកអត្ត សញ្ញាណនេះ អ្នកប្រហែលជាគួរតែពិចារណា និយាយជាមួយអ្នកជំនាញសុខភាពផ្លូវចិត្ត ដើម្បីជួយឲ្យអារម្មណ៍ខ្លួន ឯងកាន់តែមានភាពនឹងនរ។

## សេចក្តីសន្និដ្ឋាន

នៅក្នុងការអនុវត្តជាក់ស្តែង មនុស្សត្រូវដឹងពីអត្តសញ្ញាណរបស់ពួកគេ ដើម្បីជៀសវាងការកើតមាននូវវិបត្តិអត្តសញ្ញា ណ។ ចំណេះដឹងអំពីអត្តសញ្ញាណរបស់ពួកគេមានសារៈសំខាន់ក្នុងការកំណត់អត្តសញ្ញាណរបស់ពួកគេ ដោយសារ មានកម្រិតនៃអត្តសញ្ញាណខុសៗគ្នានៅក្នុងសង្គមនីមួយៗ។ ការដឹងពីអត្តសញ្ញាណធ្វើឲ្យពួកគេចេះរៀននិងឱ្យតម្លៃ ចំពោះអត្តសញ្ញាណគ្នាទៅវិញទៅមក ហើយជាលទ្ធផល ពួក គេអាចរស់នៅជាមួយគ្នាដោយសុខដុមរមនា ព្រមទាំង អាចផ្លាស់ប្តូរខ្លួនឯងដើម្បីបំពេញតម្រូវការរបស់ពលរដ្ឋក្នុងពិភពលោក។ ម្យ៉ាងវិញទៀត ភាពចម្រុះនៃអត្តសញ្ញាណ ក៏ត្រូវបានឆ្លុះបញ្ចាំងផងដែរ ចំពោះគ្រប់ទិដ្ឋភាពទាំងអស់នៅក្នុងបញ្ហាដែលបានជួបប្រទះនឹងអំពើហិង្សា ដោយទាំង នេះត្រូវមានភាពចាំបាច់ និងចេះសម្របខ្លួនក្នុងសង្គម ព្រមទាំងដឹងពីរបៀបគោរពគ្នាទៅវិញទៅមកក្នុងសហគមន៍។

## ឯកសារយោង


- Tang, Q. (2015). *Global Citizenship Education-Topics and Learning Objectives*. France: UNESCO.
- APCEIU. (2018). *Global Citizenship Education-A Guide for Trainers*. Soul: APCEIU.
- Paul, C. & Rika, P. (2010). *Complexity, Difference and Identity*. New York: Springer.
- Alice, A. et al. (2010). *Educating for Global Citizenship Education*. Toronto: ETFO.
- Abdeljalil, A. & Kathrine, M. (2020). *Global Citizenship Education- Critical and International Perspectives.* Sweden: Springer.
- Marco, G. at el. (2009). *Global Citizenship Education- The School as a Foundation for a Fair World.* Manila: Outlook Coop.

# មេរៀនទី៥៖
# សហគមន៍មនុស្សនានា និងទំនាក់ទំនងរវាងសហគមន៍ទាំងនោះ

**DIFFERENT COMMUNITIES PEOPLE BELONG TO AND HOW THESE ARE CONNECTED**

(Mr. Dy Bonna, Ms. Nou Channy, Mr. Mao Saroeun, and Mr. Mon Munint)

វត្ថុបំណងមេរៀន
១. សេចក្តីផ្តើម
២. សហគមន៍ផ្សេងៗ និងសារៈសំខាន់នៃសហគមន៍
២.១. និយមន័យ
២.២. សារៈសំខាន់របស់សហគមន៍
៣. ការតភ្ជាប់សហគមន៍
៣.១. ទំនាក់ទំនងសង្គម និងការភ្ជាប់ទំនាក់ទំនងសង្គម
៣.២. ហេតុអ្វីបានជាទំនាក់ទំនងសង្គមមានសារៈសំខាន់?
៣.៣. ភាពខុសគ្នា និងទំនាក់ទំនងរវាងក្រុមសង្គមផ្សេងៗគ្នា
៣.៣.១. ក្រុមសង្គម
៣.៣.២ ភាពខុសគ្នានៃក្រុមសង្គម
៣.៤. ការបង្កើតទំនាក់ទំនងសហគមន៍
៣.៤.១. បណ្តាញសង្គម និងប្រព័ន្ធផ្សព្វផ្សាយសង្គម
៣.៤.២. បណ្តាញសង្គម និងប្រព័ន្ធផ្សព្វផ្សាយសង្គមផ្សេងៗគ្នា
៣.៤.៣. បញ្ហាដែលប៉ះពាល់ដល់ទំនាក់ទំនងសហគមន៍
៣.៤.៤. លក្ខណៈពិសេសនៃការភ្ជាប់ទំនាក់ទំនងសហគមន៍
៤. សន្និដ្ឋាន
គន្ថនិទ្ទេស (Bibliography)

**វត្ថុបំណងមេរៀន៖** **បន្ទាប់ពីបញ្ចប់មេរៀននេះ អ្នកសិក្សានឹងអាច៖**

| | |
|---|---|
| 1 | បង្ហាញពីភាពខុសគ្នា និងទំនាក់ទំនងរវាងក្រុមសង្គមផ្សេងៗគ្នា |
| 2 | ប្រៀបធៀប និងចែករំលែកភាពផ្ទុយគ្នា ភាពខុសគ្នានៃសង្គម វប្បធម៌ និងបទដ្ឋានច្បាប់ |

| | |
|---|---|
| 3 | បង្ហាញពីការកោតសរសើរនិងការគោរពចំពោះភាពខុសគ្នា និងភាពចម្រុះ ការបណ្តុះការយល់ចិត្ត និងសាមគ្គីភាពចំពោះបុគ្គលដទៃទៀត និងក្រុមសង្គម |
| 4 | វាយតម្លៃស៊ីជម្រៅនូវទំនាក់ទំនងរវាងក្រុម សហគមន៍ និងប្រទេសផ្សេងៗគ្នា |

## ១. សេចក្តីផ្តើម

មនុស្សជាតិមានតម្រូវការមូលដ្ឋានដូចគ្នា ប៉ុន្តែមានវិធីផ្សេងគ្នាជាច្រើនក្នុងការបំពេញតម្រូវការទាំងនោះ។ ភាពខុសគ្នានៃយេនឌ័រ វប្បធម៌ វណ្ណៈ ជាតិ សាសន៍ សាសនា ជាតិពន្ធុ ភាសា និងឋានៈ អាចមានសារៈសំខាន់ក្នុងការពន្យល់ពីការភាពខុសគ្នានានា និងការកំណត់អត្តសញ្ញាណ។ ទោះបីជាយើងទាំងអស់គ្នារស់នៅជាមួយនឹងគោលបំណងធ្វើឱ្យជីវិតមានសុភមង្គល ក៏ជីវិតរបស់យើងមិនដូចគ្នាដែរ ហើយនៅតែរស់នៅក្នុងសហគមន៍នៃពិភពលោក។ ហេតុនេះហើយ យើងត្រូវការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកតាមគោលបំណងនិងវិធីផ្សេងៗ ដូចជាការគាំទ្រពីសង្គមទាំងផ្នែកហិរញ្ញវត្ថុ និងការថែទាំសុខភាពផ្លូវចិត្ត។

បច្ចុប្បន្ន និន្នាការនៃការអប់រំពិភពលោក សង្កត់ធ្ងន់លើគោលបំណង នៃការផ្តល់ដល់អ្នកសិក្សាមិនត្រឹមតែចំណេះដឹងមូលដ្ឋានដែលផ្តោតលើបុគ្គលមានសមត្ថភាពអាន សរសេរ និងលេខនព្វន្ធ និងជំនាញ ប៉ុណ្ណោះទេ ថែមទាំងដើម្បីជួយមនុស្សឱ្យរស់នៅដោយយុត្តិធម៌ សុវត្ថិភាព អព្យាក្រឹត សន្តិភាពក្នុងជីវិតរស់ និងផ្តល់អត្ថប្រយោជន៍ដល់បរិស្ថានរបស់យើង (UNESCO, 2016)។ ការអប់រំតែងតែរួមចំណែកក្នុងការ រៀបចំយុវជនសម្រាប់សង្គម។ ការអប់រំអាចផ្លាស់ប្តូររបៀបដែលយើងគិត និងធ្វើសកម្មភាព ដើម្បីកសាង សង្គមកាន់តែយុត្តិធម៌ សន្តិភាព អធ្យាស្រ័យ ការអត់ឱន និងសង្គមបរិយាបន្ន ដើម្បីកាត់បន្ថយបញ្ហា ប្រឈមជាសកលក្នុងយុគសម័យសកលភាវូបនីយកម្ម (Wiel Veugelers, 2011)។ ដូច្នេះ ខ្លឹមសារនៃការអប់រំសម្រាប់ភាពជាពលរដ្ឋសាកលគឺជាការប្តេជ្ញាចិត្ត ក្នុងការធ្វើឱ្យអ្នកសិក្សា នាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាន ដើម្បីឱ្យមនុស្សរស់នៅចុះសម្រុងគ្នាក្នុងសហគមន៍និងមានទំនាក់ទំនងគ្នារវាងបុគ្គលក្នុងសហគមន៍ សង្គមជាតិ ក៏ដូចជាពិភពលោក។

## ២. សហគមន៍ផ្សេងៗនិងសារៈសំខាន់នៃសហគមន៍

**២.១. និយមន័យៈ** ក្នុងន័យដ៏សាមញ្ញបំផុត សហគមន៍គឺជាក្រុមមនុស្សដែលមានអ្វីមួយរួមដូចគ្នា។ ក្នុងបរិបទខ្លះ សហគមន៍ត្រូវបានកំណត់ដោយផ្អែកលើទស្សនៈរបស់មនុស្សដែលគេចាត់ទុកថាជាអត្ថប្រយោជន៍ ឬមានសារៈសំខាន់សម្រាប់ពួកគេ ហើយពួកគេចង់ក្លាយជាសមាជិកនៃសហគមន៍ ឬក្រុមនោះ (Queen, 1923)។ សហគមន៍អាចកើតមាន ឬត្រូវបានបង្កើតឡើងដោយរួមទាំងទីតាំងរួម គ្រួសារ ភូមិសាស្ត្រ ជំនឿ ពូជសាសន៍ ចំណង់ចំណូល

ចិត្ត បទពិសោធន៍ជីវិត និងប្រវត្តិរស់នៅ ឬបុព្វរួមណាមួយ។ វាក៏អាចជាការផ្តល់អត្ថប្រយោជន៍ សេចក្តីត្រូវការ ឬវិជ្ជាជីវៈបន្ថែមទៀតផងដែរ (Macqueen, K, M,. et all, 2002)។ ឧទាហរណ៍ មានប្រភេទក្រុមផ្សេងៗគ្នាជាច្រើនដែលគេហៅថា "សហគមន៍" ដែលបង្កើតឡើងដោយអត្ថប្រយោជន៍ និងគោលបំណងជាក់លាក់របស់ខ្លួន ដូចលោកស្រី Irina Sergeeva បានលើកឡើងពីប្រភេទសហគមន៍ចំនួន៨ ដូចជា៖

- អ្នកជិតខាង (**Neighbors**)៖ សំដៅលើក្រុមមនុស្សរស់នៅក្បែរគ្នានៅក្នុងភូមិ
- ក្រុមសាសនា(ជំនឿ) (**Faith-based organizations**)៖ ក្រុមបុគ្គលដែលរួបរួមដោយជំនឿសាសនា ឬជំនឿខាងវិញ្ញាណ (ជាសហគមន៍ដែលមានអាយុកាលយូរយារណាស់មកហើយ)
- ក្រុមចំណង់ចំណូលចិត្តដូចគ្នា (ក្លឹប)(**Hobby-focused clubs**)៖ សំដៅទៅលើក្រុមមនុស្ស ដែលផ្តោតលើចំណាប់អារម្មណ៍រួមគ្នាដូចជាការចម្អិនអាហារ ការអាន ការរត់ ឬក្លឹបតន្ត្រី។ ប្រភេទ នៃសហគមន៍នេះមិនកំណត់ចំនួនសមាជិកទេគឺតាមលទ្ធភាពសម្រាប់ក្រុម។
- ក្រុមអ្នកស្ម័គ្រចិត្ត (**Volunteer groups**)៖ ពាក់ព័ន្ធនឹងការចូលរួមក្នុងសកម្មភាពស្ម័គ្រចិត្តជា ក្រុម មិនថាជាមួយមិត្តភក្តិ ក្រុមគ្រួសារ មិត្តរួមការងារ ឬអ្នកស្គាល់គ្នានោះទេ។
- សហគមន៍ អតីតនិស្សិត (**Alumni networks**)៖ ជាបណ្តាញក្នុងបរិបទនៃស្ថាប័នអប់រំ ដែល រួមបញ្ចូលមានបទពិសោធន៍នៅក្នុងក្រុម។
- កន្លែងធ្វើការរួមគ្នា (**Coworking spaces**)៖ រួមមានទាំងកន្លែងធ្វើការប្រកបដោយបរិយាបន្ន និងសហគមន៍ឌីជីថល ដែលបញ្ជាក់ពីសារៈសំខាន់នៃការបង្កើតសហគមន៍នៅកន្លែងធ្វើការ
- ក្រុមអភិវឌ្ឍន៍វិជ្ជាជីវៈឬសហគមន៍សិក្សាវិជ្ជាជីវៈ (**Professional development groups/ professional learning community**)៖ បណ្តាញអាជីពដែលមានស្ទើរតែគ្រប់ប្រភេទនៃការ ងារ ឬជំនាញ ហើយអាចជាធនធានដ៏អស្ចារ្យក្នុងជីវិតអាជីពរបស់បុគ្គលម្នាក់ៗ។
- **ក្រុមធនធានបុគ្គលិក (Employee resource groups:)៖ ជាក្រុមដែលដឹកនាំដោយនិយោ ជិតដែលជំរុញឱ្យមានការចូលរួមប្រកបដោយបរិយាបន្ន និងកសាងសហគមន៍** (Sergeeva, 2022)។

អ្នកសិក្សាស្រាវជ្រាវសង្គមវិទ្យាបានបង្ហាញថា ការធ្វើចាត់ប្រភេទនៃសហគមន៍ផ្សេងគ្នាជាច្រើនអា ស្រ័យលើចរិកលក្ខណៈសមាជិកភាពរួមមានសកម្មភាព មុខងារ និងចង្វាក់នៃជីវិតនៅក្នុងភូមិ ទីប្រជុំជនតូចៗ និងសហគមន៍ជនបទ។ ភាពកក់ក្តៅ និងទំនាក់ទំនងសង្គមដែលគាំទ្រត្រូវបានពិពណ៌នាថា ជាស្នូលនៃជីវិតសហគមន៍តូចៗ ប៉ុន្តែការសិក្សាក៏បានកំណត់អត្តសញ្ញាណភាពខុសគ្នានៃការបែងចែកជម្លោះ និងការបែងចែកសង្គមនៅក្នុងសហគមន៍ដែលនៅលើផ្ទៃដីមានភាពស្អិតរម្មួត។ ប្រភេទនីមួយៗ មានលក្ខណៈខុសៗគ្នា គោលបំណង តម្រូវការសមាជិកភាព និង

ប្រពៃណីនៃអន្តរកម្ម។ ស្ថាប័នសហគមន៍ នីមួយៗបានទទួលយកការរៀបចំនៃការចូលរួមជាមួយសមាជិកផ្សេងទៀត និងបង្កើតទម្រង់ទំនាក់ទំនង តាមប្រពៃណី និងកំណត់អនុសញ្ញាពិសេសសម្រាប់អន្តរកម្ម និងវិធីនៃការរក្សាទំនាក់ទំនង (Douglas, 2010)។

**នៅក្នុងមេរៀននេះ សហគមន៍ត្រូវបានបែងចែកជាពីរកម្រិត (Douglas, 2010)៖** សហគមន៍មូលដ្ឋាន (ក្នុងតំបន់) គឺជាក្រុមមនុស្សរស់នៅជិតគ្នា ចែករំលែកផលប្រយោជន៍រួម និងជួបគ្នាជាទៀងទាត់សម្រាប់គោលបំណងទាំងនោះ។ ឧទាហរណ៍ សហគមន៍មូលដ្ឋាន គឺជាក្រុមមនុស្សនៅក្នុងរស់នៅក្បែរគ្នា ហើយជួបគ្នាដើម្បីពិភាក្សា និងដោះស្រាយបញ្ហាមួយចំនួននៅក្នុងមូលដ្ឋានរួមគ្នា។

សហគមន៍សកល គឺជាពាក្យដែលប្រើដើម្បីពិពណ៌នាអំពីសហគមន៍ណាមួយដែលមានអន្តរកម្ម ជាមួយគ្នាជុំវិញពិភពលោក និងការផ្លាស់ប្តូរវប្បធម៌។ សហគមន៍នេះមិនផ្តោតតែលើទីក្រុង ឬប្រទេស ជាក់លាក់ណាមួយទេ ប៉ុន្តែមានវិសាលភាពជុំវិញពិភពលោក ហើយគ្រប់ដណ្តប់លើមនុស្សមកពីមជ្ឈដ្ឋានផ្សេងៗគ្នា សម្រាប់បុព្វហេតុជាក់លាក់ណាមួយ។ សហគមន៍សកលខុសពីសហគមន៍មូលដ្ឋាន ត្រង់មិនមានកំណត់ទីតាំងភូមិ សាស្ត្រដែលពួកគេជួបគ្នានោះទេ។ បច្ចុប្បន្ននេះ ពាក្យថា "សហគមន៍ សកល" ច្រើនតែសំដៅលើបណ្តាញ មនុស្សដែលរស់នៅជុំវិញពិភពលោក ហើយចែករំលែកនូវជំនឿ បញ្ហា និងអត្ថប្រយោជន៍ស្រដៀងគ្នា។ សហគមន៍សកល គ្របដណ្តប់លើរបៀបដែលមនុស្សជុំវិញពិភពលោកធ្វើអន្តរកម្មជាមួយគ្នាតាមរយៈពាណិជ្ជកម្ម ការចែករំលែកព័ត៌មាន និងសហគមន៍ អនឡាញ ជាដើម។

ទោះបីជាយ៉ាងណាក៏ដោយ សហគមន៍សកលនិងសហគមន៍មូលដ្ឋាន មានភាពស្រដៀងគ្នា (អ៊ីនធឺណិត និងប្រព័ន្ធផ្សព្វផ្សាយសង្គម បញ្ហាសកល រចនាសម្ព័ន្ធ ទំហំ និងមនុស្ស) និងភាពខុសគ្នា (អន្តរកម្មសង្គម គម្លាតចម្ងាយ ការចែករំលែកបទពិសោធន៍ អារម្មណ៍ និងសំឡេង)។ ដូច្នេះ សហគមន៍គ្រប់ប្រភេទផ្តល់អត្ថប្រយោជន៍ដល់សមាជិករបស់គេ តាមរយៈការចែករំលែកអ្វីមួយនៅក្នុងទំនាក់ទំនងសង្គម។ ប៉ុន្តែសម្រាប់ក្រុមមនុស្ស ដើម្បីបង្កើតទម្រង់សហគមន៍មួយដែលបង្កើនគុណភាពនៃជីវិតរបស់សមាជិករបស់ខ្លួន បុគ្គលដែលពាក់ព័ន្ធម្នាក់ៗក៏ត្រូវតែមានអារម្មណ៍ក្នុងការចែករំលែកនូវការជឿទុកចិត្ត ការភ្ជាប់ទំនាក់ទំនង និងការយកចិត្តទុកដាក់ចំពោះគ្នាទៅវិញទៅមក។

**២.២. សារៈសំខាន់របស់សហគមន៍៖** សម្រាប់មនុស្សជាច្រើន ការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ តាមរយៈវេទិកាអនឡាញ ប្រព័ន្ធទំនាក់ទំនងសង្គមឬដោយផ្ទាល់ អាចជួយឱ្យពួកគេមានការគិតប្រកបដោយសុខមា

លភាព បង្កើនតម្លៃលើខ្លួនឯងនិងរីករាយក្នុងជីវិតកាន់តែច្រើន (DepartmentofHealthandAgedCare, 2022)។ តើអ្នកនឹងទទួលបានអ្វីពីការផ្តល់ការយកចិត្តទុកដាក់និងពេលវេលារបស់អ្នកចំពោះសហគមន៍នោះហើយតើអ្នកចង់ផ្តល់អ្វីខ្លះឱ្យដល់សហគមន៍វិញក្នុងកម្រិតណា?

ដូចដែលលោកស្រី Rosemary King (2020) បានគូសបញ្ជាក់ដែរថា បច្ចុប្បន្ននេះពិភពលោកទាំងមូលកំពុងស្វែងយល់ពីសារៈសំខាន់នៃទំនាក់ទំនងរបស់មនុស្ស ហើយមនុស្សកំពុងភ្ជាប់ទំនាក់ទំនងយ៉ាងសកម្មជាមួយមនុស្សដែលពួកគេបានស្គាល់ និងមនុស្សដែលពួកគេចង់ស្គាល់ តាមរបៀបនិងការ ច្នៃប្រតិដ្ឋបែបថ្មី។ សំណួរសំខាន់បំផុតដែលយើងទាំងអស់គ្នាត្រូវសួរខ្លួនឯងនៅថ្ងៃនេះ ហើយនឹងបន្តសួរទៅថ្ងៃមុខគឺ "តើសហគមន៍បែបណាដែលខ្ញុំចង់ចូលរួមជាមួយ?" នៅពេលដែលអ្នកបានបង្កើតទស្សនវិស័យសម្រាប់ខ្លួនអ្នក នោះអ្នកត្រូវសួរបញ្ជាក់ខ្លួនឯងថា "ហេតុអ្វីបានជាខ្ញុំចង់ក្លាយជាផ្នែកមួយរបស់សហគមន៍នោះ?"។

យោងទៅតាមសម្ព័ន្ធភាពសម្រាប់សុខភាពសហគមន៍របស់ Ontario (AHC) បានរកឃើញថាលើសពីការផ្តល់ការគាំទ្រ ការយកចិត្តទុកដាក់ថៃទាំសហគមន៍មានឥទ្ធិពលជាវិជ្ជមានទៅលើសុខមាលភាពទូទៅរបស់បុគ្គលម្នាក់ៗតាមរយៈការផ្តល់នូវពេលវេលាល្អៗ និងបំពេញនូវភាពខ្វះខាត មិនថាសហគមន៍ជាអ្នករស់នៅជិតគ្នា សហគមន៍វប្បធម៌ ឬជំនឿ ឬលំនៅដ្ឋានចូលនិវត្តន៍នោះទេ។ សហគមន៍ដែលខ្លាំង ជាសហគមន៍ដែលមានការគាំទ្រដ៏ខ្លាំងក្លា ពីអ្នកចូលរួម និងជួយគ្នាទៅវិញទៅមកទាំងផ្នែកការអនុវត្ត អារម្មណ៍ និងសង្គម ហើយក៏អាចជួយឱ្យបុគ្គលដែលងាយរងគ្រោះនិងសហគមន៍ទាំងមូលឆ្លើយតបបានកាន់តែប្រសើរឡើង សម្របខ្លួន និងធ្វើឱ្យប្រសើរឡើងវិញពីព្រឹត្តិការ ណ៍មិនល្អ ដូចជាជំងឺរាតត្បាត COVID-19 ជាដើម។ សហគមន៍អាចផ្តល់អត្ថប្រយោជន៍ដល់សមាជិក ដូចជា៖

- បណ្តាញគាំទ្រ (A support networks)
- ការអភិវឌ្ឍន៍វិជ្ជាជីវៈ (Professional development)
- មានគោលបំណងច្បាស់លាស់ (Sense of purpose)
- ការបន្ធូរភាពតានតឹង (Alleviate stress)
- ការបំផុសគំនិតថ្មីៗ (New inspiration and ideas)
- ការផ្តល់អំណាចដល់ការសម្រេចចិត្ត (Empowered decision-making)
- ការបង្កើតជំនាញទំនាក់ទំនងកាន់តែប្រសើរ (Better communication skills)
- ការពង្រឹងភាពធន់កាន់តែខ្លាំង (Greater resilience)។

ឧទាហរណ៍៖ សហគមន៍មួយដែលត្រូវបានបង្កើតឡើងសម្រាប់ក្រុមមនុស្សចូលនិវត្តន៍ដែលហៅថា សហគមន៍ចូលនិវត្តន៍។ សហគមន៍នេះ អាចជួយពួកគេឱ្យមានភាពធន់ និងទប់ទល់នឹងបញ្ហាប្រឈម នានាតាមរបៀបវិជ្ជមាន មានប្រសិទ្ធភាព និងមានសុខភាពល្អ។ ការរស់នៅពេលចូលនិវត្តន៍មានភាពឯកោ សហគមន៍អ្នកចូលនិវត្តន៍អនុញ្ញាតឱ្យមនុស្សវ័យចំណាស់រក្សាទំនាក់ទំនងសង្គម រីករាយជាមួយអាហារដែលមានតុល្យភាពល្អ មានជីវជាតិ និងទទួលបានអត្ថប្រយោជន៍ពីការថែទាំ ផ្ទាល់ខ្លួនដោយយកចិត្តទុកដាក់ និងប្រកបដោយក្ដីមេត្តាដើម្បីបំពេញតម្រូវការសុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់ពួកគេប្រកបដោយ សុវត្ថិភាព។ តើសហគមន៍ផ្សេងគ្នា តភ្ជាប់ឬមានទំនាក់ទំ នងគ្នាទៅវិញទៅមកដោយរបៀបណា?

## ៣. ការតភ្ជាប់សហគមន៍

តាំងពីសម័យបុរេប្រវត្តិមក មនុស្សបានរស់នៅជាមួយគ្នាជាក្រុមដែលពួកគាត់បានរកឃើញចំណុចសំខាន់រួមដូចជាការការពារ ជំនួយ ការគាំទ្រ អត្តសញ្ញាណរួម និងការចែករំលែកចំណេះដឹង។ តាមរយៈប្រវត្តិសាស្ត្រ គ្រួសាររស់នៅក្រោមដំបូលផ្ទះតែមួយដែលទារកនិងមនុស្សចាស់ត្រូវបានគេថែទាំដោយសារមិនអាចចិញ្ចឹមជីវិតខ្លួនឯងបាន។ អារម្មណ៍ជាសហគមន៍កើតឡើងនៅពេលដែលមនុស្សមករួមគ្នា ដើម្បីប្រយោជន៍ទាំងអស់គ្នា។ មនុស្សមានអារម្មណ៍ថាពួកគេជាកម្មសិទ្ធិរបស់សហគមន៍នៅពេលដែលមានគំរូនៃការជឿទុកចិត្ត កិច្ចសហប្រតិបត្តិការ និងការរៀបចំដែលផ្តល់អត្ថប្រយោជន៍ដល់មនុស្សគ្រប់គ្នា។ សហគមន៍រឹងមាំគឺសំខាន់ណាស់ ព្រោះវាជាប្រភពសំខាន់នៃទំនាក់ទំនងសង្គមនិងអារម្មណ៍នៃភាពជាកម្មសិទ្ធិ។ ការចូលរួមនៅក្នុងសហគមន៍ដែលភ្ជាប់ដោយអាកប្បកិរិយា គុណតម្លៃ និងគោលដៅគឺជាធាតុផ្សំដ៏សំខាន់ដើម្បីរីករាយ នឹងការបំពេញឱ្យជីវិតរស់នៅ។

សហគមន៍អាចត្រូវបានគ្រប់គ្រង និងកំណត់ទម្រង់តាមរបៀបផ្សេងៗ។ សហគមន៍អាចជាសហគមន៍និម្មិត (virtual) ឬសហគមន៍ពិសេសក្នុងគោលបំណងជាក់លាក់ណាមួយ (ad hoc) ដោយយោងលើស្ថានភាពសមស្រប ដែលដឹកនាំដោយបុគ្គលម្នាក់ឬគណៈកម្មការរួមមួយ ដោយមិនមានច្បាប់ណាមួយដាច់ណាត់នោះទេ (King, 2020)។ ដូច្នេះនៅពេលដែលអ្នកស្វែងរកបង្កើតទំនាក់ទំនងនៅក្នុងជីវិតរបស់អ្នក និងស្វែងរកសហគមន៍ដែលត្រឹមត្រូវសម្រាប់អ្នក វាជាការល្អបំផុតក្នុងការត្រឡប់ទៅសំណួរដ៏ល្អមួយ ក្នុងការគ្រប់គ្រងផលិតផលគឺ "តើបញ្ហាអ្វីដែលយើងកំពុងព្យាយាមដោះស្រាយ?"។

ការតភ្ជាប់សហគមន៍ផ្តល់នូវការគាំទ្ររបៀបរស់នៅផ្ទាល់ខ្លួន ការជួយដល់បុគ្គលដែលមានពិការភាព និងក្រុមគ្រួសាររបស់ពួកគេ ដែលអ្នកអាចមានជម្រើសអំពីរបៀបដែលអ្នកចង់រស់នៅក្នុងសហគមន៍របស់អ្នក។ នៅពេលដែលអ្នក

ស្រាវជ្រាវសំដៅទៅលើបញ្ញត្តិនៃទំនាក់ទំនងសង្គម គេផ្តោតលើអារម្មណ៍ដែលអ្នកមានជាមួយក្រុម ហើយជាទូទៅជាអារម្មណ៍ជិតស្និទ្ធនឹងមនុស្សផ្សេងទៀត។ ភស្តុតាងវិទ្យាសាស្ត្រ បង្ហាញយ៉ាងមុតមាំថានេះគឺជាតម្រូវការស្នូលផ្នែកផ្លូវចិត្តដែលចាំបាច់សម្រាប់ភាពពេញចិត្តនៅក្នុងជីវិតរបស់អ្នក។ មានវិធីសំខាន់ៗមួយចំនួនដែលមនុស្សមានទំនាក់ទំនងគ្នា ដែលអាចនាំឱ្យសហគមន៍កាន់តែយល់ចិត្តគ្នា និងមានភាពជាកម្មសិទ្ធិដូចជា មិត្តភាព ស្គាល់គ្នា សមាជិកភាព រក្សាទំនាក់ទំនង ជាផ្នែកមួយនៃ គ្រួសារ មានដៃគូ ធ្វើជាអ្នកជិតខាង ស្គាល់គ្នាឬត្រូវបានគេស្គាល់។

**៣.១. ទំនាក់ទំនងសង្គម និង ការភ្ជាប់ទំនាក់ទំនងសង្គម៖** ជាទូទៅ ទំនាក់ទំនងសង្គមសំដៅលើទំនាក់ទំនងរបស់យើងជាមួយមនុស្សនៅក្នុងបណ្តាញរបស់យើង។ ទំនាក់ទំនងសង្គមគឺពិតជាទាក់ទងនឹងការភ្ជាប់ទំនាក់ទំនងដែល វិសាលភាពរបស់វាពាក់ព័ន្ធ នឹងមុនស្សសំខាន់ៗ និងអ្នកដែលផ្តល់ការគាំទ្រក្នុងជីវិតរបស់យើង តាមរបៀបនៃការពង្រឹងភាពជាកម្មសិទ្ធិ និងសុខមាលភាពរបស់យើង។ ការសម្រេចចិត្តគឺចាប់ពីការជ្រើសរើសសហគមន៍មួយណាដែលអ្នកចង់ចូលរួមជាមួយ អ្វីដែលមានឥទ្ធិពលដល់សង្គម ដែលផ្ទុយគ្នាទៅលើទស្សនៈវិស័យរបស់ពួកគេ។ មានភាពខុសប្លែកគ្នាមួយចំនួនរវាងក្រុមសង្គមដូចជា ភាពអត់ការងារធ្វើ ការនិយាយពីភាសា ការថែទាំមនុស្សចាស់ដែលរកឃើញដោយអ្នកស្រាវជ្រាវ (Chartwell, 2022)។ ការស្រាវជ្រាវបង្ហាញ ថាទំនាក់ទំនងសង្គមអាចធ្វើអោយសុខភាពផ្លូវចិត្ត និងរាងកាយប្រសើរឡើងយ៉ាងខ្លាំង។ មនុស្សជាតិត្រូវ បានភ្ជាប់ទំនាក់ទំនងសង្គមជាមួយអ្នកដទៃ ហើយភស្តុតាងវិទ្យាសាស្ត្របង្ហាញថា វាជាតម្រូវការស្នូល សម្រាប់អារម្មណ៍ពេញចិត្តនឹងជីវិតរបស់អ្នក និងរក្សាសុខភាពផ្លូវចិត្តបានជាវិជ្ជមាន។ នៅពេលដែលអ្នក មានទំនាក់ទំនងសង្គម អ្នកហាក់ដូចជាមានអារម្មណ៍ថាអ្នកជាកម្មសិទ្ធិ និងជិតស្និទ្ធនឹងមនុស្សផ្សេងទៀត ។ កង្វះទំនាក់ទំនងសង្គម ឬគុណភាពនៃទំនាក់ទំនងសង្គមខ្សោយអាចត្រូវបានពិពណ៌នាថាជាភាពឯកោ ឬការនៅដាច់ពីគេក្នុងសង្គមដែលមិនល្អសម្រាប់សុខភាពផ្លូវកាយ ឬផ្លូវចិត្តរបស់យើងទេ (Allina, 2020) ។

**៣.២. ហេតុអ្វីបានជាទំនាក់ទំនងសង្គមមានសារៈសំខាន់**? ការភ្ជាប់ទំនាក់ទំនងសង្គមគឺជាអារម្មណ៍នៃភាពជាកម្មសិទ្ធិចំពោះក្រុមគ្រួសារ ឬសហគមន៍។ វាផ្តោតលើទំនាក់ទំនងដែលមនុស្សមានជាមួយគ្នាទៅវិញទៅមក និងការចូលរួមពាក់ព័ន្ធរបស់ពួកគេជាមួយសហគមន៍បានទូលំទូលាយ។ ទំនាក់ទំនងសហគមន៍អាចត្រូវបានផ្លាស់ប្តូរដោយយោងទៅតាមផលជះនៃបាតុភូតរបស់មនុស្សដែលផ្ទុយទៅនឹងទស្សនៈវិស័យរបស់ក្រុម។ **អត្ថប្រយោជន៍នៃការភ្ជាប់ទំនាក់ទំនងសង្គមមានដូចខាងក្រោម៖**

- មានភាពប្រាកដនិយមក្នុងការគ្រប់គ្រងលើជម្រើសរបស់មនុស្សម្នាក់ៗ (Having a realistic sense of control over one's choices)

- ការយល់ដឹងអំពីដែនកំណត់នៃការគ្រប់គ្រងនេះ (Understanding the limitations over such control)
- មើលឃើញការផ្លាស់ប្តូរជាឱកាសឬបញ្ហាប្រឈម (ជាជាងការបង្អាក់ដំណើរការ) (Seeing change as an opportunity or challenge (rather than a setback))
- ជានានូវឯកសារភ្ជាប់ជាមួយអ្នកដទៃ និងសមត្ថភាពក្នុងការចូលរួមគាំទ្ររបស់ពួកគេ (Secure attachments with others and the ability to engage their support)
- គោលដៅផ្ទាល់ខ្លួន (Personal goals)
- អារម្មណ៍កំប្លែងខ្លាំង (Strong sense of humor)
- អត់ធ្មត់ (Patience)
- ការអធ្យាស្រ័យកម្រិតខ្ពស់នៃផលប៉ះពាល់អវិជ្ជមាន (High tolerance of negative affect)

ទោះជាយ៉ាងណាក៏ដោយអាកប្បកិរិយាដ៏គួរឱ្យស្រឡាញ់របស់យើងបានផ្លាស់ប្តូរជាមួយនឹងការអភិវឌ្ឍន៍នៃមជ្ឈមណ្ឌលទីក្រុងធំៗ ការផ្លាស់ប្តូរការងារញឹកញាប់ ការបែកបាក់គ្រួសារ ឬការឃ្លាតឆ្ងាយពីគ្នា ការរីកចម្រើននៃបច្ចេកវិទ្យា របៀបរស់នៅដ៏កកកុញ និងកាលវិភាគការងារមមាញឹកខ្លាំង។

## ៣.៣. ភាពខុសគ្នា និងទំនាក់ទំនងរវាងក្រុមសង្គមផ្សេងៗគ្នា

**៣.៣.១. ក្រុមសង្គម** (social groups)៖ ក្រុមសង្គមមួយមានមនុស្សពីរនាក់ ឬច្រើននាក់ដែលប្រាស្រ័យទាក់ទងគ្នាជាទៀងទាត់ដោយផ្អែក លើការរំពឹងទុកពីគ្នាទៅវិញទៅមក និងអ្នកដែលចែករំលែកអត្តសញ្ញាណរួម។ តាមរយៈនិយមន័យនេះ យើងឃើញថា យើងទាំងអស់គ្នាជាកម្មសិទ្ធិរបស់ក្រុមសង្គមជាច្រើនប្រភេទ៖ គ្រួសាររបស់យើង ក្រុមមិត្ត ភាពផ្សេងៗ ថ្នាក់សង្គមនិងវគ្គសិក្សាផ្សេងទៀតដែលយើងចូលរួមកន្លែងធ្វើការរបស់យើង ក្លឹបនិងអង្គភាពដែលយើងចូលរួម ជាដើម។ លើកលែងតែករណីដ៏កម្រមួយចំនួនដែលយើងពិបាកស្រមៃដែលអាចមាន គ្មានយើងណាម្នាក់រស់នៅតែម្នាក់ឯង។ សូម្បីតែមនុស្សដែលអាចរស់នៅបានដោយខ្លួនឯង ក៏នៅតែប្រាស្រ័យទាក់ទងជាមួយសមាជិកគ្រួសារ មិត្តរួមការងារ និងមិត្តភក្តិ ហើយដែលនៅតែមានសមាជិកភាពជា មួយក្រុមជាច្រើន។

**៣.៣.២. ភាពខុសគ្នានៃក្រុមសង្គម** (differences of social groups)៖ សង្គមវិទូបានកំណត់ភាពខុសគ្នារវាងក្រុមសង្គម និងប្រភេទសង្គម។ ប្រភេទសង្គមគឺជាបណ្តុំនៃបុគ្គលដែលមានលក្ខណៈដូចគ្នាយ៉ាងហោចមួយ ប៉ុន្តែមិនចាំបាច់មានអន្តរកម្មទេជាមួយគ្នាទេ។ ស្ត្រីគឺជា ឧទាហរណ៍នៃប្រភេទសង្គម។ ស្ត្រីទាំងអស់យ៉ាងហោចណាស់មានរឿងមួយដូចគ្នា គឺលក្ខណៈភេទតាមបែបជីវសាស្ត្ររបស់ពួកគេ ទោះ បីជាពួកគេមិនមានអន្តរកម្មជាមួយគ្នាក៏ដោយ។ ជនជាតិអាមេរិកដើម កំណើតអាស៊ី គឺជាឧទាហរណ៍មួយផ្សេងទៀតនៃប្រភេទសង្គម ដោយសារអាមេរិកដើមកំណើត អាស៊ី ទាំងអស់មានរឿងពីរដូចគ្នា គឺប្រវត្តិជនជាតិ និងទីលំនៅរបស់ពួកគេនៅក្នុងសហរដ្ឋអាមេរិក ទោះបីជាពួក គេមិនមានទំនាក់ទំនង ឬចែករំលែកភាពស្រដៀងគ្នាផ្សេងទៀតក៏ដោយ។ ដូចដែលឧទាហរណ៍ ទាំងនេះ បានបង្ហាញ យេនឌ័រ ពូជសាសន៍ និងជាតិពន្ធុគឺជាមូលដ្ឋានសម្រាប់ប្រភេទសង្គម។ ប្រភេទសង្គមទូទៅ ផ្សេងទៀតគឺផ្អែកលើជំនឿសាសនា ទីលំនៅភូមិសាស្ត្រ និងថ្នាក់សង្គម។ ជាមួយនឹងភាពខុសគ្នាទាំងនេះ សូមមើលប្រភេទផ្សេងគ្នានៃក្រុមដែលសង្គមវិទូបានកំណត់៖

- **ក្រុមបឋម** (*Primary groups*)៖ ជាគ្រួសារ និងមិត្តភក្តិរបស់អ្នក។ គ្រួសារជាអ្នកកំណត់ តម្លៃជា មូលដ្ឋាននៃជីវិតរបស់អ្នក។ អ្នកមានអារម្មណ៍ថាជាកម្មសិទ្ធិរបស់គ្រួសារអ្នក។ នៅពេលអ្នកធំឡើង អ្នកមានអារម្មណ៍ថាមានទំនាក់ទំនងជាមួយមិត្តភក្តិ។ ក្រុមបឋមផ្តល់ឱ្យអ្នកនូវអត្តសញ្ញាណ និង ចាប់អារម្មណ៍ខ្លាំងលើខ្លួនឯង (អារម្មណ៍ដែលកំណត់ថាអ្នកជានរណា) ដោយផ្តល់នូវទំនាក់ ទំនង ជិតស្និទ្ធ និងដោយផ្ទាល់ជាងមុន។ ក្រុមទាំងនេះជាធម្មតាតូច ហើយត្រូវបានកំណត់លក្ខណៈ ដោយការប្រាស្រ័យទាក់ទងយ៉ាងទូលំទូលាយ និងទំនាក់ទំនងផ្លូវចិត្តរឹងមាំ ហើយបន្តដំណើរការ តាមពេលវេលាយូរអង្វែអ។ សមាជិកនៃក្រុមនេះ យកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះគ្នាទៅវិញទៅ មក ហើយកំណត់អត្តសញ្ញាណច្រើនជាមួយក្រុម។
- **ក្រុមបន្ទាប់បន្សំ** (*Secondary groups*)៖ ក្រុមនេះមានទំហំធំជាង មានភាពអនាមិកច្រើន បើធៀបនឹងក្រុមបឋម។ ក្រុមនេះក៏មានទំនោរទៅរកទំនាក់ទំនងរយៈពេលខ្លីជាង។ ក្រុមបែបនេះ ច្រើនតែផ្អែកលើការចែករំលែកអត្ថប្រយោជន៍ ចំណូលចិត្ត ឬសកម្មភាពរួមគ្នា។ សមាជិកក្រុម បន្ទាប់បន្សំធ្វើអន្តរកម្មដោយផ្អែកលើស្ថានភាពសង្គម។ សមាជិកក្រុមបន្ទាប់បន្សំមានអារម្មណ៍ថា មិនសូវមានទំនាក់ទំនងនឹងគ្នាដូចសមាជិកក្រុមបឋមទេ ហើយក៏មិនកំណត់អត្តសញ្ញាណច្រើន ជាមួយក្រុមរបស់ពួកគេ និងមិនសូវមិនមានអារម្មណ៍ស្មោះត្រង់ចំពោះគ្នាខ្លាំងដែរ (Christine McCown, et all., 2016)។




រូបភាព១៖ ក្រុមបឋម និងក្រុមបន្ទាប់បន្សំ

ក្នុងចំណោមក្រុមនានា ទំនាក់ទំនងរបស់យើងចាប់ផ្ដើមពីវប្បធម៌សង្គម និងបទដ្ឋានច្បាប់របស់យើងដែលមានឥទ្ធិពលលើបុគ្គលនិងសហគមន៍ទាំងមូល។ ទំនាក់ទំនងនេះហាក់ដូចជាប្រែប្រួលចុះឡើង ពេញមួយជីវិតរបស់យើង។ នៅពេលដែលយើងមើលថែទាំកុមារឬក្មេង យើងដូចជាមានអារម្មណ៍ថា និងមានទំនាក់ទំនងល្អ និងមានសុខភាពល្អ នៅពេលយើងចាស់ទៅ (King, 2020)។ ក្រុមគឺជាបណ្ដុំដ៏សំខាន់នៃជីវិតសង្គម ប៉ុន្តែក៏អាចមានផលវិបាកអវិជ្ជមានផងដែរ។ សមាជិកនៃក្រុមបឋម និងក្រុមបន្ទាប់បន្សំមួយចំនួនមានអារម្មណ៍ស្មោះត្រង់ចំពោះក្រុមទាំងនោះ ហើយមានមោទនភាពក្នុងការធ្វើជាកម្មសិទ្ធិរបស់ក្រុមទាំងនោះ។




រូបភាព២៖ ការផ្លាស់ប្ដូរទំនាក់ទំនងក្នុងសហគមន៍

## ៣.៤. ការបង្កើតទំនាក់ទំនងសហគមន៍ ( Making Community Connections )

នាពេលបច្ចុប្បន្ននេះ ការអប់រំភាពជាពលរដ្ឋសកល មានគោលបំណងរៀបចំមនុស្សជុំវិញ ពិភព លោកឱ្យរស់នៅជាមួយគ្នា ក្នុងសង្គមពហុវប្បធម៌ដោយសុខសន្តិភាពជាមួយនឹងការយល់ដឹងពីអន្តរជាតិ។

APCEIU បានលើកឡើងថា "ពលរដ្ឋសកលគឺជាអ្នកដែលរួមចំណែកដល់សហគមន៍ពិភពលោកកាន់តែទូលំទូលាយ។ ពលរដ្ឋសកលមិនត្រឹមតែធ្វើកិច្ចការក្នុងចំណោមហ្វូងមនុស្សនោះទេ ពួកគេក៏ជាម្ចាស់វាសនារបស់ខ្លួន ហើយពួកគេចង់បង្កើតអ្វីប្លែកៗថ្មីៗ ប៉ុន្តែពួកគេដឹងថាមិនអាចធ្វើវាដោយខ្លួនឯងបានទេ"។

នៅក្នុងសង្គមដ៏ទូលំទូ លាយនិងការរៀបចំសហគមន៍ គឺមានទំនាក់ទំនងរវាងគ្នាទៅវិញទៅមកដែលមិនអាចខ្វះបាននូវឆន្ទៈក្នុងការចូលរួមបានទេ។ ប៉ុន្តែឆន្ទៈទាំងនោះត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិ របស់រដ្ឋដែលពាក់ព័ន្ធរៀងៗខ្លួនដែលពិពណ៌នាពីគោលការណ៍ឬវិន័យនៃឥរិយាបទរបស់ពលរដ្ឋក្នុងការទំនាក់ទំនងក្នុងសង្គម ហើយតាមរយៈបទប្បញ្ញត្តិទាំងនេះនឹងបំ ពេញតម្រូវការបុគ្គល និងតម្រូវការទំនាក់ទំនងពីគ្នាទៅវិញទៅមក។ ជាផ្នែកមួយនៃសហគមន៍អាចមានឥទ្ធិពលវិជ្ជមានទៅលើសុខភាពផ្លូវចិត្ត និងសុខុមាលភាពផ្នែកអារម្មណ៍។

ការចូលរួមរបស់សហគមន៍ផ្តល់នូវអារម្មណ៍នៃភាពជាកម្មសិទ្ធិ និងភ្ជាប់ទំនាក់ទំនងសង្គម។ វា ក៏អាចផ្តល់នូវអត្ថន័យ និងគោលបំណងបន្ថែមដល់ជីវិតប្រចាំថ្ងៃផងដែរ។ ដូច្នេះតើ សហគមន៍ មូលដ្ឋាន និងសហគមន៍សកលមានទំនាក់ទំនងគ្នាយ៉ាងដូចម្តេច?

### ៣.៤.១. បណ្តាញសង្គម និងប្រព័ន្ធផ្សព្វផ្សាយសង្គម ( social networks and social media )

**តើបណ្តាញសង្គមជាអ្វី?** បណ្តាញសង្គមសំដៅលើទំនាក់ទំនងសង្គមដែលភ្ជាប់យើងជាមួយមនុស្សផ្សេងទៀត។ ទំនាក់ទំនងទាំងនេះរួមមានគ្រួសារ មិត្តភ័ក្តិ អ្នកស្គាល់គ្នា មិត្តរួមថ្នាក់ មិត្តរួមការងារ អ្នកជិតខាង។ល។ បណ្តាញសង្គមត្រូវបានកំណត់ថាជាការបង្កើតទំនាក់ទំនងផ្ទាល់ខ្លួន និងអង្គភាពនៅក្នុងបរិយាកាសអន្តរកម្ម ដោយមានគោលបំណងបង្កើតបណ្តាញ (Avada, 2022)។




Source: https://blog.avada.io/resources/social-networking-vs-social-media.html

**រូបភាព៣៖ បណ្តាញសង្គម**

សព្វថ្ងៃនេះនៅក្នុងពិភពការងារ យើងតែងតែឮអំពី "បណ្តាញ" ឬទាញយកអត្ថប្រយោជន៍ពីការទំនាក់ទំនងរបស់អ្នកជាមួយមនុស្សដែលមានទំនាក់ទំនងជាមួយមនុស្សផ្សេងទៀតដែលអាចជួយអ្នកឱ្យធ្វើការងារ។ ជីវិតសម័យទំនើបត្រូវបានកំណត់លក្ខណៈកាន់តែខ្លាំងឡើងដោយបណ្តាញសង្គមបែបនេះឬទំនាក់ទំនងទាំងមូល ដែល ភ្ជាប់យើងទៅមនុស្សផ្សេងទៀតនិងក្រុមនិងតាមរយៈពួកគេទៅកាន់មនុស្ស និងក្រុមផ្សេងទៀត។ ក្នុងចំណោមទំនាក់ទំនងទាំងនេះមួយចំនួនពាក់ព័ន្ធនឹងចំណងដ៏រឹងមាំ ខណៈដែលទំនាក់ទំនងផ្សេងទៀតពាក់ព័ន្ធនឹងចំណងខ្សោយ។ Face book និងគេហទំព័រផ្សេងទៀត បានបង្កើតបណ្តាញដែលមានទំហំមិនអាចនឹកស្មានដល់កាលពី មួយទសវត្សរ៍មុន។

បណ្តាញសង្គមមានសារៈសំខាន់សម្រាប់រឿងជាច្រើន រួមទាំងការទទួលបានដំបូន្មាន ការខ្ចីប្រាក់ តិចតួច និងការស្វែងរកការងារធ្វើ។ តំណភ្ជាប់ដោយប្រយោលដែលអ្នកមានទៅកាន់មនុស្ស តាមរយៈបណ្តាញសង្គមរបស់អ្នក អាចជួយអ្នកក្នុងការស្វែងរកការងារធ្វើ ឬទទួលបានការថែទាំសុខភាព កាន់តែប្រសើរឡើង។ ឧទាហរណ៍ប្រសិនបើអ្នកមានជម្ងឺធ្ងន់ធ្ងរ ដូចជាមហារីក អ្នកប្រហែលជាត្រូវពិភាក្សាជាមួយគ្រូពេទ្យបឋមរបស់អ្នកជាមុនសិន ហើយពួកគាត់នឹងបញ្ជូនអ្នកទៅកាន់អ្នកឯកទេសម្នាក់ឬច្រើននាក់ដែលអ្នកមិនស្គាល់និងអ្នកដែលមិនមានទំនាក់ទំនងជាមួយអ្នកតាមរយៈមនុស្សផ្សេងទៀតដែលអ្នកបានស្គាល់។

**ប្រព័ន្ធផ្សព្វផ្សាយសង្គម៖** ប្រព័ន្ធផ្សព្វផ្សាយសង្គមត្រូវបានគេស្គាល់ថាជាការប្រើប្រាស់បច្ចេកវិទ្យា ដែលមានមូលដ្ឋានលើបណ្តាញជាមធ្យោបាយអន្តរកម្ម ដែលសម្របសម្រួលការចែករំលែក និងប្រើប្រាស់ នូវគំនិត យោបល់ និង

ព័ត៌មានតាមរយៈការកសាងបណ្តាញ និងសហគមន៍និម្មិត។ ខ្លឹមសារដែល អ្នកប្រើ ប្រាស់ចែករំលែកនៅលើវេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គម រួមមានព័ត៌មានផ្ទាល់ខ្លួន រូបថត វីដេអូ និងឯកសារ ផ្សេងៗ។

អ្នកប្រើប្រាស់ចូលប្រើប្រព័ន្ធផ្សព្វផ្សាយសង្គមតាមរយៈកុំព្យូទ័រ ថេបប្លេត ទូរស័ព្ទចល័ត នៅលើ កម្មវិធីបណ្តាញ ឬកម្មវិធីគេហទំព័រ។ ការលេចឡើងនៃប្រព័ន្ធផ្សព្វផ្សាយសង្គមបានផ្លាស់ប្តូរទាំងស្រុងនូវទី លានប្រកួតប្រជែកសម្រាប់អាជីវកម្មជាច្រើន។ វាបានជំរុញការប្រាស្រ័យទាក់ទងជាមួយអតិថិជនកសាង ទំនាក់ទំនងជាមួយអតិថិជន និងប្រមូលព័ត៌មានសម្រាប់កិច្ចខិតខំប្រឹងប្រែងរកទីផ្សារ និងការស្រាវជ្រាវ ទីផ្សារ។






Source: https://blog.avada.io/resources/social-networking-vs-social-media.html and Christine McCown, et all. (2016)

**រូបភាព៨៖ បណ្តាញទំនាក់ទំនងសង្គម**

### ៣.៤.២. បណ្តាញសង្គម និងប្រព័ន្ធផ្សព្វផ្សាយសង្គមផ្សេងៗគ្នា (different social networks and social media)

ដូចដែលបានរៀបរាប់ ទោះបីជាមនុស្សជាច្រើនប្រើពាក្យទាំងនេះជំនួសគ្នាក៏ដោយក៏វាមិនដូចគ្នាដែរ។ តាមការពិតបណ្តាញសង្គម (social networking) ត្រូវបានគេចាត់ទុកថាជាប្រភេទបន្ទាប់បន្សំនៃប្រព័ន្ធផ្សព្វផ្សាយសង្គម។ ប៉ុន្តែវាអាចជាវិធីសាមញ្ញមួយដើម្បីយល់ពីភាពខុសគ្នារវាងបណ្តាញសង្គម និងប្រព័ន្ធផ្សព្វផ្សាយសង្គម គឺដោយមើលពាក្យទាំងនេះដាច់ដោយឡែកពីគ្នា។ បណ្តាញទាក់ទង នឹងទស្សនិកជន និងទំនាក់ទំនងរួមទាំងគ្រួសារ មិត្តភក្តិ មិត្តរួមការងារ អតិថិជន និងសូម្បីតែមនុស្សចម្លែក។ ចំណែកឯប្រព័ន្ធផ្សព្វផ្សាយពាក់ព័ន្ធនឹងព័ត៌មាន និងខ្លឹមសារដែល

អ្នកកំពុងចែករំលែកជាក់ស្តែង ដូចជាអត្ថបទ រូបភាព វីដេអូ ឯកសារ PDF ឬការធ្វើបច្ចុប្បន្នភាពស្ថានភាព ជាដើម។ នេះគឺជាតារាងសង្ខេបនៃភាពខុសគ្នារវាងបណ្តាញសង្គម និងប្រព័ន្ធផ្សព្វផ្សាយសង្គម។

| | **បណ្តាញសង្គម** | **ប្រព័ន្ធផ្សព្វផ្សាយសង្គម** |
|---|---|---|
| និយមន័យ By Definition | ទាក់ទងទៅនឹងការកំណត់ថាតើអតិថិជន របស់ជានរណា និងទំនាក់ទំនងរបស់ អ្នកជាមួយពួកគេ | ពាក់ព័ន្ធនឹងព័ត៌មាននិងខ្លឹមសារដែលអ្នកបានចែករំលែក |
| គោលដៅចម្បង The main goal | កិច្ចពិភាក្សានិងការកសាងទំនាក់ទំនង | ម៉ាឃីតជីង |
| ស្តាយក្នុងការទំនាក់ទំនង Communication Style | ពាក់ព័ន្ធនឹងការទំនាក់ទំនងទៅវិញទៅមក | ការផ្ញើសារទៅអតិថិជនដែលមានចំនួនច្រើន |
| អតិថិជន គោលដៅ Target audiences | អតិថិជនជាក់លាក់ឬចំនួនប្រជាជន នៅក្នុងក្រុម | អាចមិនមានអតិថិជនគោលដៅជាក់លាក់ទេ |
| ពេលវេលាឆ្លើយតប Timely responses | ពង្រឹងការឆ្លើយតបទាន់ពេលវេលាតាមរយៈការទំនាក់ទំនងដោយផ្ទាល់ | អាចមិនឆ្លើយតបទាន់ពេលវេលា ព្រោះមិនបានធ្វើអន្តរកម្មបានពេញ |

Source: https://www.google.com/search

**តារាង១៖ ភាពខុសគ្នារវាងបណ្តាញសង្គម និងប្រព័ន្ធផ្សព្វផ្សាយសង្គម**

ដូច្នេះបណ្តាញសង្គមមានសារៈសំខាន់កាន់តែខ្លាំងឡើងនៅក្នុងជីវិតសម័យទំនើប ហើយការចូលរួមនៅក្នុងបណ្តាញបែបនេះអាចមានលទ្ធផលអំណោយផលសម្រាប់ទិដ្ឋភាពជាច្រើននៃជីវិតរបស់មនុស្ស។មនុស្សប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមក្នុងការបង្កើតទំនាក់ទំនងក្នុងសហគមន៍ និងពិភពលោកខាងក្រៅជាមួយនឹងបណ្តាញ។

**៣.៤.៣ បញ្ហាដែលប៉ះពាល់ដល់ទំនាក់ទំនងសហគមន៍** ( Issues affecting community connection )
ការភ្ជាប់ទំនាក់ទំនង គឺជាការចាំបាច់សម្រាប់ពិភពការងារនាពេលបច្ចុប្បន្ននេះ។ យើងបង្កើតទំនាក់ទំនងក្នុងគោលបំណង និងទម្រង់ផ្សេងៗគ្នា ដូចជាសង្គម វប្បធម៌ផ្សេងៗ និងបទដ្ឋានច្បាប់។ ជាទូទៅបទដ្ឋាន (Norm) ត្រូវបានកំណត់ថាជាច្បាប់ ស្តង់ដា ឬគំរូសម្រាប់អនុវត្តសកម្មភាព។ ឧទាហរណ៍ បទដ្ឋានសង្គមគឺជាច្បាប់សម្រាប់ការប្រព្រឹត្ត។ ដើម្បីភ្ជាប់ទំនាក់ទំនងក្នុងសហគមន៍មូលដ្ឋានឬអន្តរជាតិ ប្រជាពលរដ្ឋត្រូវតែដឹងពីបទដ្ឋានទាំងផ្លូវការ និងក្រៅផ្លូវការ។ ក្នុងដំណើរការនៃការភ្ជាប់ទំនាក់ទំនង ទាំងសហគមន៍មូលដ្ឋានក្នុងស្រុក និងពិភពលោក អាចមានបញ្ហា ឬការប្រឈមមួយចំនួនដូចជាសង្គម វប្បធម៌ ផ្សេងគ្នា និងបទដ្ឋានជាដើម។

បទដ្ឋានក្នុងន័យនេះមិនមែនជាស្ថិតិជាមធ្យមនៃអាកប្បកិរិយាជាក់ស្តែងទេ ប៉ុន្តែជានិយមន័យនៃការចែករំលែកវប្បធម៌នៃអាកប្បកិរិយាដែលចង់បាន។ បទដ្ឋានគឺស្តង់ដាដោយយោងទៅលើអាកប្បកិរិយា ដែលត្រូវបានវិនិច្ឆ័យ និងអនុម័ត ឬមិនយល់ព្រម។ ទោះយ៉ាងណាក៏ដោយបទដ្ឋានអាចបែងចែកជាបីក្រុម៖

**ច្បាប់ធម្មជាតិ** (Natural Laws)៖ ច្បាប់ធម្មជាតិ គឺជាប្រព័ន្ធនៃច្បាប់ដែលផ្អែកលើការសង្កេត យ៉ាងជិតដល់អំពីធម្មជាតិរបស់មនុស្ស ហើយផ្អែកលើគុណតម្លៃដែលមាននៅក្នុងធម្មជាតិរបស់មនុស្ស ដែលអាចកាត់ចេញ និងអនុវត្តដោយឯករាជ្យនៃច្បាប់វិជ្ជមាន (Wikipedia)។ ច្បាប់ធម្មជាតិ សំដៅលើច្បាប់សីលធម៌ដែលអាចរកឃើញតាមរយៈហេតុផលរបស់មនុស្ស។ ទស្សនវិទូខាងសីលធម៌បានណែនាំថា ច្បាប់បែបនេះបង្កើតឡើងដោយមនុស្សមុនគេ និងឯករាជ្យនៃច្បាប់វិជ្ជមាន។ ច្បាប់នេះមិនដូចច្បាប់ ដែលត្រូវបានអនុម័តដោយរដ្ឋាភិបាលដើម្បីដោះស្រាយតម្រូវការ ឬអាកប្បកិរិយាជាក់លាក់នោះទេ ច្បាប់ធម្មជាតិមានលក្ខណៈជាសកល ដែលអនុវត្តចំពោះមនុស្សគ្រប់រូប គ្រប់ទីកន្លែង តាមរបៀបដូចគ្នា។ ច្បាប់ធម្មជាតិមិនត្រូវបានបង្កើតឡើង ហើយមិនធ្វើតាមរបៀបដែលជាតម្រូវការកម្មវត្ថុរបស់ច្បាប់ចង់បាននោះទេ ប៉ុន្តែពួកគេប្រព្រឹត្តផ្ទុយនឹងឆន្ទៈរបស់កម្មវត្ថុ ក្នុងបរិបទនេះ យើងអាចនិយាយបានថា៖ ការស្លាប់ ទឹកជំនន់ ផ្គរ រញ្ជួយដី សីតុណ្ហភាពខ្ពស់ និងទាប ពោលគឺជាធម្មជាតិដំណើរការនៅខាងក្រៅ បទដ្ឋានដែលរៀបចំដោយសង្គម។ ឧទាហរណ៍ ច្បាប់ធម្មជាតិសន្មតថាមនុស្សគ្រប់គ្នាជឿថាការសម្លាប់អ្នកដទៃគឺខុស ហើយការដាក់ទោសចំពោះការសម្លាប់ជីវិតអ្នកដទៃគឺត្រឹមត្រូវ (Mineshema-Lowe, 2022)។

**បទដ្ឋានបច្ចេកទេស** (Technical norms)៖ បទដ្ឋានបច្ចេកទេស និងច្បាប់គ្រប់គ្រង ទំនាក់ទំនងរវាងមនុស្ស និងពិភពខាងក្រៅ។ ឧទាហរណ៍៖ អន្តរកម្មរបស់មនុស្ស និងម៉ាស៊ីន ឧបករណ៍ តំណភ្ជាប់ផលិតកម្ម។ល។ បច្ចុប្បន្ន

បទដ្ឋានបច្ចេកទេសមានសារៈសំខាន់ពិសេសក្នុងការជំរុញ និងអភិវឌ្ឍសង្គមទូទៅ។

**បទដ្ឋានសង្គម** (Social norms)៖ បទដ្ឋានសង្គមគឺជាបទដ្ឋានដែលកំណត់ ពីអាកប្បកិរិយា របស់មនុស្សនៅក្នុងសង្គម។ ដូច្នេះ គេក៏អាចហៅថាជាការបញ្ជាផងដែរ ដោយមានទំនោរសង្គម។ នៅក្នុងបទដ្ឋានទាំងនេះ បញ្ហាគឺស្មុគស្មាញជាងបើប្រៀបធៀបទៅនឹងបទដ្ឋាន ច្បាប់ធម្មជាតិ និងបទដ្ឋានបច្ចេកទេស។ ជាធម្មតាបទដ្ឋានសង្គមត្រូវបានកំណត់ថាជា "ច្បាប់ និងស្តង់ដាដែលត្រូវបានយល់ដោយសមាជិកនៃក្រុម ហើយដែលណែនាំ ឬរារាំងអាកប្បកិរិយាសង្គមដោយបង្ខិតបង្ខំដោយច្បាប់ទេ"។

**បទដ្ឋានវប្បធម៌** (Cultural norms)៖ ច្បាប់សង្គម តម្លៃ ឬស្តង់ដាដែលកំណត់អាកប្បកិរិយា ដែលទទួលយកបាន និងសមរម្យនៅក្នុងវប្បធម៌មួយ។ បទដ្ឋានសង្គម និងវប្បធម៌ គឺជាច្បាប់ ឬការរំពឹងទុកនៃអាកប្បកិរិយា និងគំនិតដែលផ្អែកលើជំនឿរួមគ្នានៅក្នុងក្រុមវប្បធម៌ ឬសង្គមជាក់លាក់មួយ។

បទដ្ឋានសង្គម និងវប្បធម៌គឺមានឥទ្ធិពលយ៉ាងខ្លាំងលើអាកប្បកិរិយាបុគ្គលក្នុងបរិបទដ៏ធំទូលាយ រួមទាំងអំពើហិង្សា និងការទប់ស្កាត់ ពីព្រោះបទដ្ឋានអាចបង្កើតបរិយាកាសដែលអាចជំរុញ ឬកាត់បន្ថយអំពើហិង្សា និងផលប៉ះពាល់ដ៏អាក្រក់របស់វា (Matoshi, S., & Berisha, F., 2020)។ បទដ្ឋានសង្គម និងវប្បធម៌ផ្សេងៗគ្នាមានឥទ្ធិពលលើរបៀបដែលបុគ្គល មានប្រតិកម្មចំពោះអំពើ ហិង្សា។ អ្នកស្រាវជ្រាវបានសន្មត់សម្មតិកម្មថា បទដ្ឋានសង្គម និងវប្បធម៌ដែលនាំទៅដល់ការអត់ឱន ចំពោះអំពើហឹង្សាត្រូវបានរៀនក្នុងវ័យកុមារភាព ដែលក្នុងនោះកុមារជួបប្រទះនឹងការដាក់ទណ្ឌកម្មលើរាងកាយ ឬជាសាក្សីអំពើហិង្សាក្នុងគ្រួ សារ នៅក្នុងប្រព័ន្ធផ្សព្វផ្សាយ ឬនៅក្នុងកន្លែងផ្សេងទៀត(Abrahams and Jewkes, 2005; Brookmeyer et al., 2005; Lansford and Dodge, 2008; WHO, 2009) ។ បណ្ឌិតសភាជាតិនៃវិទ្យាសាស្ត្រ វិស្វកម្ម និងវេជ្ជសាស្ត្រ ឆ្នាំ2018 បានលើកឡើងពីបទដ្ឋានសង្គម និងវប្បធម៌ដែលបញ្ជាក់ពីការទទួលយកអំពើហិង្សា៖ ដំណើរការសិក្ខាសាលាដោយសង្ខេប (Patrick, 2018)។

**ឥទ្ធិពលធម្មតា** (Normative influence)៖ ដំណើរការផ្ទាល់ខ្លួន និងអន្តរបុគ្គល ដែលបណ្តាលឱ្យបុគ្គលមានអារម្មណ៍ គិត និងធ្វើសកម្មភាពដែលស្របតាមបទដ្ឋានសង្គម ស្តង់ដា និងអនុសញ្ញា។

ឥទ្ធិពលបទដ្ឋានគឺមានលក្ខណៈផ្ទាល់ខ្លួនមួយផ្នែក ពីព្រោះបុគ្គលទាំងឡាយណាដែលបានកំណត់បទដ្ឋាននៃក្រុមរបស់ពួកគេនឹងខិតខំធ្វើសកម្មភាពតាមរបៀបដែលស្របនឹងបទដ្ឋានទាំងនោះ។ វាក៏ជាអន្តរបុគ្គលផងដែរ ពីព្រោះ

ក្រុមដាក់សម្ពាធដោយផ្ទាល់ និងដោយប្រយោលលើសមាជិក ឱ្យគោរពតាមបទដ្ឋានរបស់ពួកគេ។ អ្នកដែលបំពានលើបទដ្ឋានក្រុមជាប្រចាំ តែងតែទទួលរងនូវផលវិបាក អវិជ្ជមាន នៃទំនាក់ទំនងបុគ្គល (ឧ. ភាពវង្វេងស្មារតី ការសើចចំអក ការដាក់ទណ្ឌកម្ម) ចំណែកអ្នកដែលអនុលោមតាមធម្មតាទទួលបានរង្វាន់។ **ប្រៀបធៀបឥទ្ធិពលអន្តរបុគ្គលនិង ឥទ្ធិពលបទដ្ឋាន៖**

- ដំណើរការអន្តរបុគ្គលទាំងនោះដែលប្រឈមនឹងភាពត្រឹមត្រូវនៃជំនឿរបស់បុគ្គលម្នាក់ ឬភាពសមស្របនៃអាកប្បកិរិយារបស់គាត់ ដោយហេតុនេះជំរុញការផ្លាស់ប្តូរ។ ឥទ្ធិពលបែបនេះ អាចកើតឡើងដោយផ្ទាល់ ដែលជាលទ្ធផលនៃការប្រាស្រ័យទាក់ទង និងការបញ្ចុះបញ្ចូល ឬដោយប្រយោល តាមរយៈការបង្ហាញព័ត៌មាន និងការប្រៀបធៀបខ្លួនឯងជាមួយអ្នកដទៃ (សូមមើលទ្រឹស្តីប្រៀបធៀបសង្គម) ឬក៏អាចហៅថាផងដែរថាឥទ្ធិពលសង្គមព័ត៌មាន។
- កម្រិតនៃការវិនិច្ឆ័យ ឬមតិរបស់បុគ្គលម្នាក់អំពីស្ថានភាពមិនច្បាស់លាស់ត្រូវបានទទួលយក ដោយអ្នកដទៃថាជារឿងត្រឹមត្រូវ។

តាមរយៈសិក្ខាសាលាដែលធ្វើឡើងដោយបណ្ឌិតសភាវិទ្យាសាស្ត្រ វិស្វកម្ម និងវេជ្ជសាស្ត្រជាតិ។ នៅឆ្នាំ 2018 ក៏ដោះស្រាយបញ្ហាមួយចំនួនទាក់ទងនឹងបទដ្ឋានសង្គម និងវប្បធម៌ផងដែរ។ ក្តីបារម្ភមួយ ដែលបានលើកឡើងដោយអ្នកស្រាវជ្រាវ របៀបដែលបទដ្ឋានសង្គមកំពុងផ្លាស់ប្តូរនៅពេលដែលពិភពលោក ក្លាយជាសកលភាវូបនីយកម្មកាន់តែខ្លាំងឡើង និងអំពីសមត្ថភាពក្នុងការពង្រីកអន្តរាគមន៍ដល់កម្រិតជាតិ ឬពិភពលោក ដូចជាអំពើហិង្សា ប្រឆាំងនឹងស្ត្រី ការប្រសព្វនៃបទដ្ឋាន និងបច្ចេកវិទ្យា ទំនាក់ទំនង និងប្រព័ន្ធផ្សព្វផ្សាយជាដើម។ បទដ្ឋានទាំងនោះមាននៅគ្រប់កម្រិតនៃការតភ្ជាប់ ដោយរួមមានកម្រិតបុគ្គល សហគមន៍គ្រួសារ សង្គម/ជាតិសកល។ **មានបញ្ហាទូទៅដែលប៉ះពាល់ដល់សហគមន៍មូលដ្ឋាន (បរិស្ថាន នយោបាយ សង្គម សេដ្ឋកិច្ច ឬ បញ្ហាផ្សេងទៀត) មានដូចខាងក្រោម៖**

- បញ្ហាស្រដៀងគ្នា ឬខុសគ្នាដែលជួបប្រទះនៅក្នុងសហគមន៍ផ្សេងទៀតក្នុងប្រទេសតែមួយ និងក្នុងប្រទេសផ្សេងទៀត។
- ផលប៉ះពាល់នៃបញ្ហាសកលសម្រាប់ជីវិតរបស់បុគ្គល និងសហគមន៍
- របៀបដែលបុគ្គល និងសហគមន៍ប៉ះពាល់ដល់សហគមន៍ពិភពលោក
- ចែករំលែកកង្វល់ក្នុងស្រុក ជាតិ និងសកលលោក និងមូលហេតុមូលដ្ឋានរបស់វា។
- ការផ្លាស់ប្តូរកម្លាំង និងគំរូសកល និងឥទ្ធិពលរបស់វាទៅលើជីវិតប្រចាំថ្ងៃរបស់មនុស្ស
- របៀបដែលប្រវត្តិសាស្ត្រ ភូមិសាស្ត្រ នយោបាយ សេដ្ឋកិច្ច សាសនា បច្ចេកវិទ្យា ប្រព័ន្ធ ផ្សព្វ ផ្សាយ ឬកត្តាផ្សេងទៀតមានឥទ្ធិពលលើបញ្ហាសកលបច្ចុប្បន្ន (សេរីភាពនៃការបញ្ចេញមតិ ស្ថានភាពរបស់ស្ត្រី

ជនភៀសខ្លួន ជនចំណាកស្រុក កេរ្តិ៍ដំណែលនៃអាណានិគមនិយម ទាសភាព ជនជាតិភាគតិច សាសនា និងការវិបរិលបរិស្ថាន)

- របៀបដែលការសម្រេចចិត្តដែលបានធ្វើឡើងជាសកល ឬនៅក្នុងផ្នែកមួយនៃពិភពលោក អាច ប៉ះពាល់ ដល់សុខុមាលភាពបច្ចុប្បន្ន និងអនាគតរបស់មនុស្ស និងបរិស្ថាននៅកន្លែងផ្សេងទៀត

អង្គការ UNESCO បានគូសបញ្ជាក់នៅក្នុងគំនិតផ្តួចផ្តើមដំបូងនៃការអប់រំសកល (GEFI) ដែលបានបើកដំណើរការក្នុងឆ្នាំ2012 ដោយរៀបចំការអប់រំនៅក្នុងទស្សនវិស័យជាសកល ហើយមានគោលបំណងធ្វើឱ្យអ្នកសិក្សាយល់ពីបញ្ហាសកល និងផ្តល់សិទ្ធិអំណាចឱ្យពួកគេធ្វើសកម្មភាព។ "ការអង្កេតលើទំនាក់ទំនងរវាងបញ្ហា និងការអភិវឌ្ឍន៍កម្រិតមីក្រូ និងម៉ាក្រូ គឺជាធាតុផ្សំដ៏សំខាន់ក្នុងការបណ្តុះបណ្តាល អ្នកសិក្សាដើម្បីបំពេញសក្តានុពលរបស់ពួកគេនៅក្នុងពិភពលោកដែលមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនិងអាស្រ័យគ្នាទៅវិញទៅមក" (UNESCO 2014a, p. 15)។ ទោះបីជាអង្គការ UNESCO បានព្យាយាមនាពេលថ្មីៗ ក្នុងការបង្កើតគំនិតទាំងសកល និងមូលដ្ឋាន (UNESCO 2018b) ក៏ដោយ ក៏សំឡេងនៃភាគីពាក់ព័ន្ធទាំងអស់នៅជុំវិញពិភពលោកមិនត្រូវបានគេយកមកពិចារណាស្មើភាពគ្នានៅក្នុងការជជែកពិភាក្សា GCE នោះទេ។ ដូចដែលបានចង្អុលបង្ហាញនៅក្នុងវេទិកា និងសិក្ខាសាលាអន្តរជាតិជាច្រើនស្តីពី GCE ការលំបាកគឺស្ថិតនៅក្នុងការខ្វះការយល់ដឹង ជាអន្តរជាតិ អំពីគោលគំនិត។

ដើម្បីក្លាយជាពលរដ្ឋសកលលោក ត្រូវធ្វើការសិក្សាស្វែងយល់លើប្រភេទទំនាក់ទំនង យ៉ាងហោចណាស់5ប្រភេទ៖

- ✓ មនុស្សជាតិទូទៅរបស់យើង (Our common humanity)៖ ទំនាក់ទំនងដែលយើង មានជា មួយមនុស្សផ្សេងទៀតទាំងអស់ទាក់ទងនឹងភាពស្រដៀងគ្នា និងតម្រូវការរួមរបស់យើង។
- ✓ អន្តរទំនាក់ទំនងជាសកលរបស់យើង (Our global interconnectedness)៖ ជាតំណភ្ជាប់ ទៅ កាន់មនុស្ស និងទីកន្លែងផ្សេងៗតាមរយៈពាណិជ្ជកម្ម បច្ចេកវិទ្យា ការធ្វើចំណាក ស្រុក ប្រព័ន្ធ នយោបាយ បរិយាកាសរួមរបស់យើងជាដើម។
- ✓ ទំនាក់ទំនងរវាងបញ្ហា(Links between issues)៖ ឧទាហរណ៍ ភាពក្រីក្រ និងការប្រែប្រួលអាកាសធាតុ
- ✓ ភាពស្របគ្នានៃបញ្ហាសកលជាច្រើនដែលមានបញ្ហានៅក្នុងបរិយាកាសរបស់យើង ដូចជាការ ចែករំលែកធនធាន ឬជម្លោះនៅក្នុងថ្នាក់រៀន។
- ✓ តំណភ្ជាប់រវាងការសិក្សាបច្ចុប្បន្ននិងពីមុន ព្រមទាំងការរៀននៅក្នុងផ្នែកកម្មវិធីសិក្សាផ្សេងទៀត។

### ៣.៤.៤. លក្ខណៈពិសេសនៃការភ្ជាប់ទំនាក់ទំនងសហគមន៍ (Characteristics of a Community Connector)

**គុណភាពនៃការទំនាក់ទំនងសហគមន៍អាស្រ័យលើរបៀបនៃការភ្ជាប់ទំនាក់ទំនងដូចខាងក្រោម៖**

- មានភាពជឿជាក់លើការយល់ដឹងអំពីជនមានពិការភាព
- ជឿទុកចិត្តលើសមាជិកសហគមន៍
- អ្នកដែលមានការរំពឹងទុកខ្ពស់
- អ្នកដែលអាចជឿជាក់លើអ្នកដទៃ ដើម្បីដោះស្រាយបញ្ហាដោយខ្លួនឯង និងក្នុងពេលណាមួយ
- មានសន្តានចិត្តក្នុងការជួយទុក្ខធុរៈនៅពេលគេមានបញ្ហា ឬការលំបាក
- មិនមានការស្ទាក់ស្ទើរក្នុងការអំពាវនាវ និងស្នើសុំជំនួយរបស់អ្នកដទៃឡើយ
- ងាយឱ្យអ្នកដទៃទំនាក់ទំនង និងយល់ពីតម្លៃនៃការទំនាក់ទំនងសហគមន៍
- ផ្តោតទៅលើទេពកោសល្យ និងសមត្ថភាពរបស់ជនមានពិការភាព
- ជឿថាសហគមន៍ត្រូវមានបដិសណ្ឋារកិច្ចចំពោះមនុស្សគ្រប់គ្នា
- ជាបុគ្គលដែលមានទំនុកចិត្តលើសមត្ថភាពរបស់មនុស្ស ដើម្បីធ្វើកិច្ចការដែលត្រឹមត្រូវ ដោយដឹងថាពួកគេមានគំនិតច្នៃប្រតិដ្ឋ
- ជាអ្នកដែលចេះអត់ឱនឱ្យអ្នកដទៃកែកំហុស
- មានភាពបត់បែន មានភាពចាស់ទុំ និងត្រៀមទទួលយកនៅពេលមានរឿងខុសប្រក្រតី កើតឡើងដោយរីករាយ (Davies, P. & Bolton, C., 2022)

ក្រៅពីនេះ ទំនាក់ទំនងក្នុងសហគមន៍មូលដ្ឋាន និងពិភពលោក គួរតែត្រូវបានកោតសរសើរ និងគោរពចំពោះភាពខុសគ្នានិងភាពចម្រុះ បណ្តុះចិត្តមេត្តានិងសាមគ្គីភាព ចំពោះបុគ្គលនិងក្រុមសង្គមផ្សេងទៀត ដោយការសម្របខ្លួនទៅនឹងបរិបទ។

## ៤. សន្និដ្ឋាន (Conclusion)

ការបង្កើតសហគមន៍ពិតជាមានសារៈសំខាន់ក្នុងការរស់នៅរបស់មនុស្ស។ មធ្យោបាយនៃការទំនាក់ទំនងរវាងសហគមន៍មួយទៅសហគមន៍មួយធ្វើឡើងតាមទម្លាប់ផង (ការប្រាស្រ័យទាក់ទងផ្ទាល់ដោយការផ្ញើសារលិខិតឆ្លងឆ្លើយ) និងតាមបែបបច្ចេកវិទ្យាទំនើបផង។ ទំនាក់ទំនងសហគមន៍អាចត្រូវបានផ្លាស់ប្តូរដោយយោងទៅតាមផលជះនៃបាតុភូតរបស់មនុស្ស ដែលផ្ទុយទៅនឹងទស្សនៈវិស័យរបស់ក្រុម។ ការស្វែងយល់ និងការឱ្យតម្លៃនូវភាពផ្ទុយគ្នានៃ

ការគិត ទស្សនៈឬមតិយោបល់ ភាពខុសគ្នានៃសង្គមវប្បធម៌ និងបទដ្ឋានច្បាប់ចាប់ពីកម្រិតបុគ្គល ក្រុម សហគមន៍ ប្រទេស និងសកល នាំមកនូវការគោរពបុគ្គលភាពនិងភាពចម្រុះនៃវប្បធម៌ ក្នុងទំនាក់ទំនងរវាងសង្គមមូលដ្ឋាននិងសាកល។

ការអប់រំភាពជាពលរដ្ឋសកល បានបើកចំហព្រំដែននៃទំនាក់ទំនងដែលធ្វើឱ្យប្រជាជាតិទាំងមូលទទួលស្គាល់ ថាពិភពលោកកាន់តែតូចទៅៗ តាមរយៈការប្រើប្រាស់មធ្យោបាយទំនាក់ទំនងកាន់តែឆាប់រហ័យ ងាយស្រួល និងមានប្រសិទ្ធភាពខ្ពស់។ ភាពអាស្រ័យគ្នាទៅវិញទៅមករវាងផ្នែកខ្លះនៃសហគមន៍ មូលដ្ឋាន និងសហគមន៍សកលក៏ផ្តល់លទ្ធភាពកាន់តែច្រើនសម្រាប់ភាពចម្រុះវប្បធម៌ផងដែរ។ ដូច្នេះទំនាក់ទំនងរបស់សហគមន៍ក្នុងភាពជាពលរដ្ឋសកលដែលប្រកបដោយសីលធម៌ សមធម៌ សមភាព មនុស្សធម៌ ដោយឈរលើគោលការណ៍សិទ្ធិមនុស្សជាសកល បង្ហាញនូវការទទួលស្គាល់ និងការទទួលខុសត្រូវសម្រាប់សកលលោកទាំងមូល។

**សំណួរ៖**

១. ចូររៀបរាប់ឧបសគ្គនិងអត្ថប្រយោជន៍នៅក្នុងទំនាក់ទំនងរវាងបុគ្គល ក្រុម សហគមន៍ ប្រទេស និងសកល។

២. ក្នុងបរិបទនៃការអប់រំភាពជាពលរដ្ឋសកល តើមានយន្តការដូចម្តេចខ្លះដែលអាចជួយគាំទ្រ ដល់ការពង្រឹងការរស់នៅជាមួយគ្នា ការទំនាក់ទំនងក្នុងសហគមន៍ និងការដោះស្រាយបញ្ហា នានាដែលបានកើតឡើង?

៣. ចូរបង្ហាញអំពីការគោរពនិងឱ្យតម្លៃចំពោះភាពខុសគ្នា ភាពចម្រុះ និងស្មារតីសាមគ្គីភាពចំពោះបុគ្គល ក្រុម សហគមន៍ និងប្រទេសដទៃ។

## គន្ថនិទ្ទេស ( Bibliography )

David M. Chavis & Kein Lee. ( 2015, May 12 ). *https://ssir.org/articles/entry/what_is_community_anyway.* Retrieved from https:// ssir. org/ articles /entry/what_is_community_anyway

Laurent Licata & Oliver Klein. ( 2021 ). Explaining differences between social groups: the influence of group membership and identication on attribution. *Swiss Journal of Psychology*, 244-252.

Allen M. Peter; Strathetn Mark; & Varga Liz. ( 2010 ). Cmomplexity: the Evolution of Identity and Diversity. In C. P. Rika, *Complexity, Differences and Identify* ( p. 41 ). London New York: Spinger.

Allina, H. ( 2020, September 24 ). *https://hello4health.org/why-is-social-connectedness-important/.* Retrieved from https://hello4health.org: https://hello4health.org

Avada. ( 2022, March 14 ). *https://blog.avada.io/resources/social-networking-vs-social-media.html*. Retrieved from https://blog.avada.io/resources/social-networking-vs-social-media.html: https://blog.avada. io/resources/social-networking-vs-social-media.html

BC, H. ( 2022, September 24 ). *https://www.healthlinkbc.ca/health-topics/abl0295*. Retrieved from https://amintro.com/life/6-benefits-of-community-and-connection-in-challenging-times/: https://amintro.com/life/6-benefits-of-community-and-connection-in-challenging-times/

Brian, P. ( 2014 ). Connecting to community themes, changing Community Value. In D. Mazany Terry & Pery C., *Here for Good: Community goundation and challenges of 21st century* ( pp. 171-185 ). New York: M.E.Sharpe. Inc.

Canter Lee & Canter Marlene. ( 1993 ). *Assertive Discipline.* Santa Monica : CA: Canter Association.

Chartwell. ( 2022, september 24 ). *https://chartwell.com/en/blog/2020/06/6-benefits-of-community-and-connection-in-challenging-times*. Retrieved from http://www. community healthand wellbeing. org/resources/belonging_guide:http://www.communityhealthandwellbeing.org/resources/belonging _guide

Christine McCown, et all. ( 2016 ). Groups and Organizations. In N/A, *Sociology: Understanding and Changing the Social World* ( pp. 166-173 ). Minneapolis: University of Minnesota Libraries Publishing.

Davies, P. & Bolton, C. ( 2022, September 10 ). *https://allenshea.com/2017/02/21/a-guide-to-developing-community-connections/.* Retrieved from https://allenshea.com/: https:// allenshea. com /2017/ 02/21/a-guide-to-developing-community-connections/

DepartmentofHealthandAgedCare. ( 2022, September 20 ). *https://www. headto health .gov.au/ meaningful-life/connectedness/community*. Retrieved from https://www. health.gov.au/: https://www .headtohealth.gov.au/meaningful-life/connectedness/ community

Douglas, H. ( 2010 ). TYPES OF COMMUNITY. *Springer*, 539-544.

Huang, H. H. (2010). Examining issues affecting African American participation in research studies. *Journal of Black Studies*, 619-636.

King, R. (2020, April 02). *https://www.mindtheproduct.com/the-importance-of-connection-and-community/.* Retrieved from https://www.mindtheproduct.com: https://www. mindthe product.com/the-importance -of-connection-and-community/

Macqueen, K, M,. et all. (2002). What is Community? An Evidence-Based Definition for Paticipatory Public Health. *American Journal of Public Health*, 1926-1943.

Matoshi, S., & Berisha, F. (2020). Social Norms and Legal Culture. Available at SSRN 3526973. *ResearchGate*.

Mineshema-Lowe, D. (2022, september 25). *https://www.mtsu.edu/first-amendment/ article /788/natural-law*. Retrieved from https://www.mtsu.edu/first-amendment/ article/ 788/ natural-law: https:// www.mtsu.edu/first-amendment/article/788/natural-law

Natioal Academicof Science. (2018). Addressing the Social and Cultural Norms That Underlie the Acceptance of Violence. *Natioal Academic press* (pp. 2-9). Wasinton DC.: Natioal Academic presshttps://doi.org/10.17226/25075.

Oxfam. (2016). *Global citizenship in the classroom.* England: Oxfam GB, Oxfam International. Inhouse 6669.

Patrick, K. (2018, September 24). *Addressing the Social and Cultural Norms That Underlie the Acceptance of Violence: Proceedings of a Workshop—in Brief.* Retrieved from https://doi.org/10.17226/25075: https://doi.org/10.17226/25075

Queen, S. A. (1923). What is a Community? *Oxford Journals,* , 375- 382.

Sergeeva, I. (2022, September 25). *https://www.betterup.com/blog/importance-of-community*. Retrieved from https://www.betterup.com: https://www.betterup. com/blog/importance-of-community

Tolan P. H. & Leventhal N. L. . (2013). *Disruptive Behavior Disorder.* New York: Springer.

UNESCO. (2016). *Schools in Action Global Citizens for Sustainable Development.* Paris: UNESCO.

Wiel Veugelers. (2011). The moral and the political in global citizenship: appreciating differences in education, Globalisation, societies, and Education. *Routledge Taylor & Francis Groups*, 473- 485.

# មេរៀនទី៦៖
# ការគោរពចំពោះភាពចម្រុះ និងភាពខុសគ្នា (...ពូជសាសន៍ វប្បធម៌ បរិយាបន្ន)

**DIFFERENCE AND RESPECT FOR DIVERSITY**

(Dr. Neau Vira, Mr. Po Bunthan, Dr. Um Chan Chamnan, and Mr. Chan Rada)





**ខ្លឹមសារនៃមេរៀន**

**សំណួរបំផុស**

**១.	សេចក្តីផ្តើម**

**២.	និយមន័យ**

**ក. ភាពចម្រុះ និងភាពខុសគ្នា**

**ខ. ភាពចម្រុះនៃវប្បធម៌**

**គ. សមាសភាគផ្សេងៗនៃភាពចម្រុះនៃវប្បធម៌**

**៣.	ភាពដូចគ្នា និងភាពខុសគ្នារបស់មនុស្ស**

**ក. ភាពដូចគ្នារបស់មនុស្ស**

**ខ. ភាពខុសគ្នារបស់មនុស្ស**

**គ. សារប្រយោជន៍នៃវប្បធម៌សម្រាប់ការរស់នៅរបស់មនុស្ស**

**៤.	សារៈសំខាន់នៃសន្និសិទទូទៅរបស់អង្គការយូណេស្កូចំពោះវប្បធម៌ចម្រុះ**

**៥.	ការចូលរួមគាំទ្រភាពចម្រុះនៃវប្បធម៌**

**៦.	សេចក្តីសន្និដ្ឋាន**

**ឯកសារយោង**

**ខ្លឹមសារនៃមេរៀន៖** នៅពេលសិក្សាមេរៀននេះចប់ អ្នកសិក្សានឹងអាចទទួលបាននូវកញ្ចប់សមត្ថភាពដូចខាងក្រោម៖

| | |
|---|---|
| ១. វិជ្ជាសម្បទា | មានការយល់ដឹងកាន់តែស៊ីជម្រៅទៅលើអត្ថន័យ និងខ្លឹមសារនៃមេរៀនដូចជាការគោរពចំពោះភាពចម្រុះនិងភាពខុសគ្នា ភាពចម្រុះនៃវប្បធម៌ សមាសភាគផ្សេងៗនៃភាពចម្រុះ ភាពដូចគ្នានិងភាពខុសគ្នារបស់មនុស្ស សារប្រយោជន៍នៃវប្បធម៌សម្រាប់ការរស់នៅរបស់មនុស្ស សារៈសំខាន់នៃសន្និសិទទូទៅរបស់អង្គការយូណេស្កូ និងការចូលរួមគាំទ្រភាពចម្រុះនៃវប្បធម៌។ |

| | |
|---|---|
| **២. បំណិនសម្បទា** | អាចធ្វើការវិភាគ ពន្យល់ និងបកស្រាយបានកាន់តែស៊ីជម្រៅទៅលើអត្ថន័យនិងខ្លឹមសារនៃមេរៀនដូចជាការគោរពចំពោះភាពចម្រុះនិងភាពខុសគ្នា ភាពចម្រុះនៃវប្បធម៌ សមាសភាគផ្សេងៗនៃភាពចម្រុះ ភាពដូចគ្នានិងភាពខុសគ្នារបស់មនុស្ស សារប្រយោជន៍នៃវប្បធម៌សម្រាប់ការរស់នៅរបស់មនុស្ស សារៈសំខាន់នៃសន្និសិទទូទៅរបស់អង្គការយូណេស្កូ និងការចូលរួមគាំទ្រភាពចម្រុះនៃវប្បធម៌។ |
| **៣. ចរិយាសម្បទា** | លើកទឹកចិត្ត និងជំរុញស្មារតី ឱ្យមានការចូលរួមយ៉ាងសកម្ម ក្នុងការគាំទ្រភាពចម្រុះនៃវប្បធម៌ តាមរយៈការធ្វើសកម្មភាពផ្សេងៗដើម្បីជាប្រយោជន៍ដល់មនុស្សជាតិដែលកំពុងរស់នៅលើភពផែនដីដ៏ស្រស់ស្អាតរបស់យើងនេះ។ |

## សំណួរបំផុស

1. តើអ្វីទៅជាភាពខុសគ្នា និងភាពស្រដៀងគ្នា (ភាពដូចគ្នា) របស់មនុស្ស?
2. តើភាពចម្រុះនៃវប្បធម៌គឺជាអ្វី? តើភាពចម្រុះនៃវប្បធម៌មានន័យដូចម្តេច?
3. ហេតុអ្វីបានជាភាពចម្រុះនៃវប្បធម៌មានសារៈសំខាន់ ទាំងនៅកន្លែងធ្វើការ និងទាំងក្នុងការអប់រំ?
4. តើយើងអាចគាំទ្រភាពចម្រុះនៃវប្បធម៌បានដោយរបៀបណា?

## ១. សេចក្តីផ្តើម



អង្គការ UNESCO បានលើកឡើងនៅក្នុងសន្និសិទ
ទៅរបស់ខ្លួនថាភាពចម្រុះនៃវប្បធម៌ គឺជាមរតក
របស់មនុស្សជាតិហើយភាពចម្រុះនៃវប្បធម៌ គឺជាគ
នៃការ អភិវឌ្ឍន៍មនុស្សប្រកបដោយនិរន្តរភាព។ តា
យៈសមាហរណកម្មទាំងក្នុងតំបន់ និងសកលលោក
បន្តបន្ទាប់ប្រជាជនអាចធ្វើដំណើរ និងមានទំនាក់ទំន
គ្នាកាន់តែច្រើនឡើងនៅក្នុងវិស័យផ្សេងៗ។

ការប្រាស្រ័យទាក់ទង និងការបម្លាស់ទីកាន់តែច្រើនឡើង ក៏ដូចជាការដោះដូរទំនិញ និងគំនិត យោបល់

ផ្សេងៗ បង្កើតបានជាសក្តានុពលក្នុងការបង្កើនទាំងវិបុលភាព និងសន្តិភាពឱ្យកាន់តែល្អប្រសើរឡើងជាមុន ហើយក៏វាបានជួយលើកកម្ពស់ភាពចម្រុះនៃវប្បធម៌ផងដែរ។ (ដកស្រង់ និងសង្ខេបចេញពីគម្រោងគ្រប់ជ្រុងជ្រោយ ដែលបានរៀបចំឡើងចាប់ពីឆ្នាំ២០១៣ដល់ឆ្នាំ២០១៩ ដោយអង្គការ UNESCO និងទទួលបានការឧបត្ថម្ភគាំទ្រហិរញ្ញប្បទានពីសំណាក់សាធារណរដ្ឋកូរ៉េ)។

## ២. និយមន័យ

តាមរយៈការលើកកម្ពស់ការយល់ដឹងអំពីការផ្សារភ្ជាប់ទំនាក់ទំនងជាសកល និងការប្រាស្រ័យទាក់ទងជាលក្ខណៈបុគ្គល យើងអាចរៀនសូត្រអំពីការអត់ឱន ការអធ្យាស្រ័យយោគយល់គ្នា និងការទទួលយកទស្សនៈវិស័យចម្រុះនាពេលបច្ចុប្បន្ន។

### ក. ភាពចម្រុះ និងភាពខុសគ្នា

ពាក្យថា ភាពចម្រុះ និងភាពខុសគ្នា គឺជាពាក្យដែលជារឿយៗ ត្រូវបានគេលឺ និងប្រើប្រាស់ច្រើន នៅក្នុងការងារទំនាក់ទំនងប្រចាំថ្ងៃ។ ប៉ុន្តែថាតើវាពិតជាមានន័យយ៉ាងដូចម្តេចនោះ យើងត្រូវសិក្សា និងពិនិត្យមើលឱ្យបានស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ។ យោងតាមគេហទំព័រ Wikipedia និងប្រភពផ្សេងៗ ភាពចម្រុះគឺជា "ភាពខុសគ្នានៃគុណតម្លៃ ទស្សនៈ វប្បធម៌ ជំនឿ សាសនា ជនជាតិដើម ផ្លូវភេទ ជំនាញ ចំណេះដឹង និងបទពិសោធន៍ជីវិត របស់បុគ្គលម្នាក់ៗនៅក្នុងក្រុមណាមួយ"។ មនុស្សផ្សេងៗគ្នា មាន ការដឹកនាំជីវិត ចំណង់ចំណូលចិត្ត ការគិត ក្តីសង្ឃឹម ជំនឿ ការរំពឹងទុក និងទំនួលខុសត្រូវខុសគ្នា។ ហេតុដូច្នេះហើយ ការគោរពចំពោះភាពចម្រុះ និងភាពខុសគ្នា កំពុងក្លាយជាប្រធានបទដ៏សំខាន់ដែលទាក់ទាញការយកចិត្តទុក ដាក់ពីគ្រប់មជ្ឈដ្ឋាន និងគ្រប់ភាគីពាក់ព័ន្ធ។

យោងតាមវិទ្យាស្ថានធាតទើរ Charter Institute ផ្នែកអភិវឌ្ឍន៍បុគ្គលិក ភាពចម្រុះគ្នា និងភាពខុសគ្នាទទួលស្គាល់ថាប្រជាជនមកពីសាវតារផ្សេងៗគ្នា អាចនាំមកនូវគំនិត និងការយល់ឃើញថ្មីៗ ដែលអាចធ្វើឱ្យការបំពេញការងារនិងការងារទំនាក់ទំនងកាន់តែមានប្រសិទ្ធភាព ហើយផលិតផលនិងសេវាកម្ម កាន់តែល្អប្រសើរ"។ រួមសេចក្តីមក ភាពចម្រុះ និងភាពខុសគ្នា ផ្តល់ឱ្យយើងរាល់គ្នានូវឱកាសដ៏សម្បូរបែបដើម្បី

ឈានទៅរកភាពល្អប្រសើរបំផុត ដោយមិនគិតពីពូជសាសន៍ ពណ៌សម្បុរ អាយុ ពិការភាព ឬនិន្នា ការភេទ។ ភាពចម្រុះ គឺជាអ្វីដែលធ្វើឱ្យពិភពលោកក្លាយជាកន្លែងដ៏ស្រស់ស្អាត។

## ខ. ភាពចម្រុះនៃវប្បធម៌

ភាពចម្រុះនៃវប្បធម៌ គឺជាគុណភាពនៃវប្បធម៌ចម្រុះឬខុសគ្នា ផ្ទុយពីវប្បធម៌ឯកត្តជន វប្បធម៌ ឯកសកល ឬវប្បធម៌ដូចគ្នា។ ពាក្យថាភាពចម្រុះនៃវប្បធម៌ ក៏អាចសំដៅទៅលើការមានវប្បធម៌ផ្សេងៗ គ្នា និងការគោរពភាពខុសគ្នា។ ជាងនេះទៅទៀត វាត្រូវបានគេប្រើជាញឹកញាប់ដើម្បីនិយាយអំពីភាព ខុសគ្នានៃសង្គមមនុស្ស ឬវប្បធម៌នៅក្នុងតំបន់ជាក់លាក់មួយ ឬនៅក្នុងពិភពលោកទាំងមូល។ វាសំដៅទៅលើការដាក់បញ្ចូលនូវទស្សនៈ និងវប្បធម៌ផ្សេងៗ គ្នានៅក្នុងអង្គការ ឬសង្គម។




វប្បធម៌ចម្រុះ គឺជាទស្សនៈមួយ ដែលគេប្រើសំដៅទៅភាពខុសប្លែកគ្នានៃវប្បធម៌។ សង្គមវិទូ បណ្ឌិតខាលិប រ៉ូសាដូ (Dr. Caleb Rosado) ដែលជាអ្នកជំនាញខាងភាពខុសប្លែកគ្នា និងវប្បធម៌ចម្រុះ បានពណ៌នាអត្ថន័យនៃវប្បធម៌ចម្រុះតាមលក្ខណៈ៧ចំណុចដូចខាងក្រោម៖

- កត់សម្គាល់នូវភាពខុសប្លែកគ្នាដ៏ទូលំទូលាយនៃវប្បធម៌នីមួយៗ
- ការគោរពចំពោះភាពខុសប្លែកគ្នា
- ការទទួលស្គាល់នូវការបង្ហាញចេញមក និងការចូលរួមចំណែកពីវប្បធម៌ខុសៗគ្នា

- ឱ្យតម្លៃដល់អ្វីដែលវប្បធម៌ដទៃមាន
- លើកទឹកចិត្តឱ្យមានការចូលរួមចំណែកពីក្រុមផ្សេងៗគ្នា
- ជួយមនុស្សឱ្យពង្រឹងខ្លួនឯង និងអ្នកដទៃដើម្បីឈានទៅដល់សក្តានុពលពេញលេញ តាមរយៈការត្រិះរិះឱ្យបានសព្វគ្រប់ជ្រុងជ្រោយ ពីភាពលម្អៀងទៅតាមគំនិតផ្ទាល់ខ្លួន
- ជាជាងទ្រាំអត់សង្កត់ចិត្ត យើងគួរអបអរចំពោះភាពខុសប្លែកគ្នាទាំងនោះ ដើម្បីនាំចេញមកនូវសាមគ្គីភាពក្នុងចំណោមលក្ខណៈពិសេសខុសៗគ្នា។

**ឧទាហរណ៍ខ្លះៗនៃភាពចម្រុះនៃវប្បធម៌គឺ៖**

- **នៅកន្លែងធ្វើការមានដូចជា៖** ក្រុមមនុស្សដែលនិយាយច្រើនភាសា មនុស្សដែលមានអាយុ ខុសគ្នាតែកំពុងធ្វើការជាមួយគ្នា និងមាន គោលនយោបាយច្បាស់លាស់ប្រឆាំងនឹងការរើស អើង។ល។
- **នៅក្នុងទីតាំងសាលាមានដូចជា៖** សិស្សមកពីជុំវិញពិភពលោកទទួលយកទាំងអស់គ្នា ជំនឿសាសនាទំនៀមទំលាប់ប្រពៃណី និងគាំទ្រ សិស្សានុសិស្សក្នុងការចែករំលែកវប្បធម៌របស់ពួក គេជាមួយគ្នា។ល។

## គ. សមាសភាគផ្សេងៗនៃភាពចម្រុះនៃវប្បធម៌

ពិភពលោកយើងនេះ ពោរពេញទៅដោយមនុស្សដែលមានជំនឿ សាសនា ប្រពៃណី និងរបៀបរស់នៅខុសៗគ្នា ហើយនៅក្នុងភាពខុសគ្នារបស់យើងនេះហើយ ដែលយើងរកឃើញនូវភាពស្រស់ស្អាត។ នៅក្នុងការអប់រំ និងវិជ្ជាជីវៈ ភាពចម្រុះនៃវប្បធម៌ផ្តល់អត្ថប្រយោជន៍ដល់មនុស្សគ្រប់គ្នា។ វាត្រួសត្រាយផ្លូវ សម្រាប់ដោះស្រាយបញ្ហាកាន់តែប្រសើរ ការយល់ចិត្ត និងការអាណិតអាសូរកាន់តែច្រើន ការរៀនសូត្រ កាន់តែស៊ីជម្រៅ និងការចូលទៅកាន់ពិភពលោកពីទស្សនៈផ្សេងគ្នា។

ភាពចម្រុះនៃវប្បធម៌ មានសមាសភាគផ្សេងៗដូចជា ពូជសាសន៍ ជនជាតិភាគតិច ការតម្រង់ ទិសផ្លូវភេទ សាសនា ភាសា ភេទ អាយុ ឋានៈក្នុងសង្គម ការអប់រំ បុគ្គលិកលក្ខណៈភាព និងពិការភាព ជាដើម។ល។

## ៣. ភាពដូចគ្នា និងភាពខុសគ្នារបស់មនុស្ស

មនុស្សលោកទូទៅដែលកំពុងរស់នៅលើពិភពលោកយើងនេះ មានជាតិសាសន៍ ពណ៌សម្បុរ ទំនៀមទំលាប់ ប្រពៃណី សាសនា ជំនឿ វប្បធម៌ និងភាសា ផ្សេងៗគ្នាក៏ពិតមែន ប៉ុន្តែពួកគេមានបំណងដូចគ្នាតែមួយគត់ គឺការរស់នៅដោយមានអាហារបរិភោគគ្រប់គ្រាន់ ខោអាវស្លៀកពាក់ ជម្រកស្នាក់នៅ និងឧបករណ៍ប្រើប្រាស់រួមទាំងភារៈទ្រទ្រង់ជីវិតសមរម្យ ដើម្បីមានកម្លាំង មានសេរីភាព និងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការរស់នៅ។

មនុស្សប្រភេទល្អ តែងតែទាក់ទាញរកមនុស្សប្រភេទល្អដូចគ្នា។ ជាក់ស្តែងយើងតែងឆ្ងល់ថា ហេតុអ្វីមនុស្សកោងកាចតែងមានក្រុមមិត្តភក្តិបនក្បៀនជាមនុស្សកោងកាចដូចគ្នា? ការពិតទៅសារជាតិ មនុស្សប្រភេទណា ទាញរកមនុស្សប្រភេទដូចគ្នាឱ្យមករកគ្នា។ ដូច្នេះ ប្រសិនបើអ្នកមានមនុស្សម្នាក់ដែលស្មោះត្រង់ និងល្អចំពោះអ្នកហើយ អ្នកមិនត្រូវកុហកមនុស្សទាំងនោះទេ ព្រោះការកុហកនេះអាចនឹងធ្វើឱ្យអ្នកដែលស្មោះត្រង់ នឹងអ្នកបាត់បង់ជំនឿ និងទំនុកចិត្តចំពោះរូបអ្នក។

### ក. ភាពដូចគ្នារបស់មនុស្ស

មានបំណងដូចគ្នាតែមួយគត់ គឺរស់នៅដោយ...

- មានអាហារបរិភោគ
- មានខោអាវស្លៀកពាក់
- មានជម្រកស្នាក់នៅ
- មានឧបករណ៍ប្រើប្រាស់ រួមទាំងភារៈទ្រទ្រង់ជីវិតសមរម្យ ដើម្បីមានកម្លាំង មានសេរីភាព និងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការរស់នៅ។

### ខ. ភាពខុសគ្នារបស់មនុស្ស

- ជាតិសាសន៍
- ពណ៌សម្បុរ

- ទំនៀមទំលាប់
- ប្រពៃណី
- ជំនឿ
- សាសនា
- វប្បធម៌ និង
- ភាសា។

## គ. សារប្រយោជន៍នៃវប្បធម៌ និងភាពចម្រុះនៃវប្បធម៌សម្រាប់ការរស់នៅរបស់យើង

វប្បធម៌ គឺជាអ្វីដែលកំណត់ពីឥរិយាបថ អត្តសញ្ញាណ និងរបៀបរស់នៅរបស់យើង ហើយវាសំដៅទៅលើភាសា ជំនឿ គុណតម្លៃ ទំនៀមទម្លាប់ និងអ្វីៗគ្រប់យ៉ាង ដែលត្រូវបានផ្ទេរបន្តពីមួយជំនាន់ទៅមួយជំនាន់ទៀត។ សូម្បីតែគំនិត ឬទស្សនៈយល់ឃើញរបស់យើងចំពោះអ្វីមួយក៏ទទួលរងឥទ្ធិពលយ៉ាងខ្លាំងពីវប្បធម៌ដែរ។ ហេតុនេះហើយការមាន គំនិតខុសគ្នារវាងមនុស្សម្នាក់ និងមនុស្សម្នាក់ទៀត ក្រុមមួយនិង ក្រុមមួយទៀតរហូតដល់ជាតិ សាសន៍មួយនិងជាតិ សាសន៍មួយទៀត ក្លាយជារឿងដែលចាំបាច់បំផុតដែល ត្រូវយកមកពិចារណា បើមិនដូច្នោះទេ វានឹងក្លាយទៅជាបញ្ហាធំដែលនាំឱ្យកើតទៅជាទំនាស់ទាស់ទែងខ្វែងគំនិតគ្នា យកតែត្រូវរៀងខ្លួនមិនខាន។

នៅក្នុងយុគសម័យសកលភាវូបនីយកម្ម មនុស្សគ្រប់រូបមានទំនាក់ទំនងគ្នាយ៉ាងទូលំទូលាយ ដោយមិនប្រកាន់ជាតិសាសាន៍ ពណ៌សម្បុរ និងវប្បធម៌ ដែលជាហេតុនាំឱ្យវប្បធម៌ចម្រុះកាន់តែមានសារៈសំខាន់ទ្វេដងថែមទៀត។ តាមរយៈនេះ យើងអាចរៀនពីគ្នាទៅវិញទៅមកបានកាន់តែច្រើន ប៉ុន្តែដំបូងបង្អស់យើងត្រូវតែយល់ដឹងពីគ្នាឱ្យបានច្បាស់លាស់សិន។



ការយល់ដឹងពីវប្បធម៌របស់អ្នកដទៃ ជួយយើងឱ្យយល់ពីទស្សនៈខុសៗគ្នារបស់មនុស្សនៅក្នុងពិភពលោកដែលយើងកំពុងតែរស់នៅជាមួយនេះ។ ការយល់ដឹងពីវប្បធម៌ជួយយើងឱ្យកំចាត់ចោលនូវផ្នត់គំនិតអវិជ្ជមាន និងការប្រកាន់យកតែគំនិតផ្ទាល់ខ្លួនក្នុងការវាយតម្លៃទៅលើនរណាម្នាក់ឬក្រុមមនុស្សណាមួយដែល

ខុសពីខ្លួន។ លើសពីនេះទៀត វប្បធម៌ចម្រុះជួយយើងឱ្យទទួលស្គាល់ និងគោរពរបៀបរស់នៅដែលមានលក្ខណៈពិសេសដាច់ដោយ ឡែកពីគ្នា។ ដូច្នេះហើយ នៅពេលយើងទំនាក់ទំនងជាមួយអ្នកដទៃ យើងអាចកសាងស្ពានឆ្ពោះទៅរកការជឿទុកចិត្ត គោរពឱ្យតម្លៃ និងស្វែងយល់ដោយមិនគិតពីភាពខុសគ្នានៃវប្បធម៌។ ភាពខុសប្លែកគ្នានេះ ក៏នឹងធ្វើឱ្យប្រ ទេសរបស់យើង ក្លាយទៅជាកន្លែងដែលកាន់តែគួរឱ្យចាប់អារម្មណ៍ក្នុងការរស់នៅដោយសារមានមនុស្សដែលមានវប្បធម៌ខុសៗគ្នាចូលរួមចែករំលែកនូវចំណេះ ដឹង ភាសា ជំនាញ របៀបគិតថ្មីៗ និងបទពិសោធន៍ប្លែកៗគ្នា។

ភាពចម្រុះនៃវប្បធម៌គឺមានសារៈសំខាន់នៅក្នុងគ្រប់ស្ថានភាពនៃជីវិត ជាពិសេសនៅក្នុងការងារអប់រំ ហើយវាមាន អត្ថប្រយោជន៍ជាច្រើននៅពេលដែលស្ថាប័នជឿជាក់លើអំណាចនៃភាពចម្រុះ។ ភាពចម្រុះនៃវប្បធម៌ក្នុងការអប់រំ អាចជួយគាំទ្រដល់៖

**១. ភាពយោគយល់គ្នា៖** ការប្រាស្រ័យទាក់ទងជាមួយបុគ្គលដែលមានវប្បធម៌ផ្សេងៗ ជំរុញឱ្យមានការយល់ចិត្ត និងបទពិសោធន៍ជីវិត។ ខណៈពេលដែលអ្នកមិនអាចយល់ច្បាស់ពីជីវិតរបស់នរណាម្នាក់ អ្នកនឹងដាក់ខ្លួនអ្នកនៅក្នុងទីតាំងមួយដែលនឹង អនុញ្ញាតឱ្យមានការរៀនសូត្រ ការស្តាប់ និងការយល់ដឹង។

**២. ទំនុកចិត្ត និងការរីកចម្រើន៖** នៅពេលដែលសិស្សចូលរួមជាមួយមនុស្សមកពីវប្បធម៌ផ្សេងៗគ្នា វាផ្តល់ឱ្យពួកគេនូវទំនុកចិត្តកាន់តែច្រើន នៅ ពេលទំនាក់ទំនងជាមួយអ្វី ដែលហាក់ដូចជានៅខាងក្រៅតំបន់ផាសុកភាពរបស់ពួកគេ។ វាបង្កើតភាពរឹងមាំ និងខ្លឹមសារនៃចរិត លក្ខណៈមោទនភាព និងទំនុកចិត្តរបស់ពួកគេ។

**៣. ការសិក្សាស៊ីជម្រៅ៖** ការរៀនសូត្រកើតឡើងក្នុងនិងក្រៅកម្មវិធីសិក្សា។ ជាមួយនឹងស្ថាប័នសិស្សដែលមានលក្ខ ណៈចម្រុះ សិស្សមានឯកសិទ្ធិក្នុងការស្វែងយល់បន្ថែមអំពីមនុស្ស និងប្រវត្តិមកពីជុំវិញពិភពលោក។ វាក៏រួមចំ ណែកដល់ភាពចម្រុះ នៃការគិត និងទស្សនវិស័យ ដែលធ្វើឱ្យការរៀនសូត្រកាន់តែគួរឱ្យចាប់អារម្មណ៍ និងមានភាពស្វាហាប់។

**៤. រៀបចំសម្រាប់អនាគត៖** ចូលរៀននៅគ្រឹះស្ថានអប់រំដែលមានធន្ទៈពហុវប្បធម៌រៀបចំសិស្ស សម្រាប់អនាគតនៅកន្លែងធ្វើការរបស់ពួកគេ។

**អត្ថប្រយោជន៍ផ្សេងៗទៀតនៃភាពចម្រុះនៃវប្បធម៌ មានដូចជា៖**

- **ការអាណិត៖** នៅពេលអ្នកប្រាស្រ័យទាក់ទងគ្នានិងយល់ពីភាពខុសគ្នា វានឹងបង្កើនការអាណិតអាសូរ មិនមែនការវិនិច្ឆ័យទេ។
- **ការច្នៃប្រឌិត៖** ទស្សនៈ និងការយល់ឃើញផ្សេងៗគ្នាលើពិភពលោក ជួយសម្រួលដល់ការគិតប្រកបដោយភាពច្នៃប្រឌិត។
- **ផលិតភាព៖** មនុស្សដែលសម្រេចចិត្តមករួមគ្នា ហើយមានស្ទីលការងារផ្ទាល់ខ្លួន មានទំនោរគាំទ្រក្រុមដែលមានផលិតភាពជាង។
- **ឱកាសថ្មី៖** ភាពចម្រុះបើកទ្វារទៅរកឱកាសថ្មីៗជាច្រើន។
- **ដោះស្រាយបញ្ហា៖** បញ្ហាប្រឈមត្រូវបានមនុស្សមកពីមជ្ឈដ្ឋានផ្សេងៗគ្នា រួមគ្នាដោះស្រាយបានកាន់តែប្រសើរឡើង ជា មួយនឹងមតិជាច្រើន។

## ៤. សារៈសំខាន់នៃសន្ធិសិទធនៅរបស់អង្គការយូណេស្កូចំពោះវប្បធម៌ចម្រុះ

អង្គការ UNESCO បានប្រកាសគោលការណ៍ដែលមានខ្លឹមសារសង្ខេបថា ការការពារភាពចម្រុះនៃវប្បធម៌ គឺជាការចាំបាច់ខាងសីលធម៌ដែលមិនអាចបំបែកចេញពីការគោរពសេចក្តីថ្លៃថ្នូររបស់មនុស្ស។ វាបង្កប់ន័យការប្តេជ្ញាចិត្ត ចំពោះសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ជាពិសេសសិទ្ធិរបស់បុគ្គលដែលជាកម្មសិទ្ធិរបស់ជនជាតិភាគតិច និងជនជាតិដើមភាគតិច។ គ្មាននរណាម្នាក់អាចអំពាវនាវឱ្យមានភាព ចម្រុះវប្បធម៌ដើម្បីរំលោភលើសិទ្ធិមនុស្សដែលធានាដោយច្បាប់អន្តរជាតិ ឬកំណត់វិសាលភាពរបស់ពួកគេឡើយ (ប្រការ៤-សិទ្ធិមនុស្សជាការធានាអំពីភាពចម្រុះវប្បធម៌)។ ប្រការ៣បានលើកឡើងថា ភាពចម្រុះនៃវប្បធម៌គឺជាឫសគល់មួយនៃការអភិវឌ្ឍន៍ ព្រមទាំងពង្រីកជម្រើស និងបើកចំហានូវឱកាសសម្រាប់មនុស្សគ្រប់គ្នា។

សិទ្ធិវប្បធម៌ គឺជាផ្នែកមួយដ៏សំខាន់នៃសិទ្ធិមនុស្ស ដែលមានលក្ខណៈជាសកលមិនអាចបំបែកបាន និងអាស្រ័យគ្នាទៅវិញទៅមក។ ការរីកដុះដាលនៃភាពចម្រុះប្រកបដោយការច្នៃប្រឌិត ទាមទារឱ្យ មានការអនុវត្តពេញលេញនៃសិទ្ធិវប្បធម៌ដូចដែលបានកំណត់ក្នុងមាត្រា27 នៃសេចក្តីប្រកាសជាសកល ស្តីពីសិទ្ធិមនុស្ស និងក្នុងមាត្រា13 និង15 នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌។ ដូច្នេះមនុស្សទាំងអស់គួរតែអាចបង្ហាញខ្លួនឯង បង្កើត និងផ្សព្វផ្សាយការងាររបស់ពួកគេ ជាភាសានៃជម្រើសរបស់ពួកគេ និងជាពិសេសនៅក្នុងភាសាកំណើតរបស់ពួកគេ។ មនុស្សគ្រប់រូបគួរតែមានសិទ្ធិ ទទួលបានការអប់រំ និងការបណ្តុះបណ្តាលប្រកបដោយគុណភាព ដែលគោរពយ៉ាងពេញលេញនូវអត្ត សញ្ញាណវប្បធម៌របស់ពួកគេ។ ហើយមនុស្សទាំងអស់ មានសិទ្ធិចូលរួមក្នុងជីវិតវប្បធម៌តាមជម្រើសរបស់ពួកគេ និងអនុវត្តវប្បធម៌ផ្ទាល់ខ្លួនរបស់ពួកគេ ដោយគោរពសិទ្ធិមនុស្ស និងសេរីភាព ជាមូលដ្ឋាន (មាត្រា ៥ - សិទ្ធិវប្បធម៌ជាបរិយាកាសអំណោយផលសម្រាប់ភាពចម្រុះនៃវប្បធម៌)។ នៅក្នុងសង្គមចម្រុះនៃវប្ប ធម៌ វាចាំបាច់ណាស់ក្នុងការធានាឱ្យមានអន្តរកម្មប្រកបដោយសុខដុមរមនាក្នុងចំណោម មនុស្សដែលមានពហុវប្បធម៌ក្នុងការរស់នៅជាមួយគ្នា (ប្រការ២-ពីភាពចម្រុះនៃវប្បធម៌ទៅជាពហុនិយមវប្បធម៌)។



Photo by geralt is licensed under the Pixabay License

ខណៈពេលដែលធានាឱ្យមានលំហូរដោយសេរីនៃគំនិត ដោយពាក្យសម្តីនិងរូបភាព ការយកចិត្តទុកដាក់គួរតែត្រូវ បានអនុវត្តដើម្បីឱ្យវប្បធម៌ទាំងអស់អាចបង្ហាញពីខ្លួនឯងនិងធ្វើឱ្យគេស្គាល់។ សេរីភាព នៃការបញ្ចេញមតិ ពហុនិយម ប្រព័ន្ធផ្សព្វផ្សាយ ពហុភាសា ការចូលដំណើរការស្មើៗគ្នាក្នុងសិល្បៈ និងចំណេះដឹង ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា រួមទាំងទម្រង់ឌីជីថល ហើយលទ្ធភាពសម្រាប់វប្បធម៌ ទាំងអស់មានលទ្ធភាពប្រើប្រាស់មធ្យោបាយនៃការបញ្ចេញមតិ និងការផ្សព្វផ្សាយគឺជាការធានានៃភាពចម្រុះ វប្បធម៌។ (ប្រការ៦-ឆ្ពោះទៅរកការទទួល បាន សម្រាប់ទាំងអស់គ្នា ចំពោះភាពចម្រុះនៃវប្បធម៌)

បេតិកភណ្ឌគ្រប់ទម្រង់ទាំងអស់ ត្រូវតែរក្សាទុក ពង្រឹង និងប្រគល់ឱ្យមនុស្សជំនាន់ក្រោយជាកំ ណត់ត្រានៃបទពិសោធន៍ និងសេចក្តីប្រាថ្នារបស់មនុស្ស ដើម្បីជំរុញភាពច្នៃប្រឌិត ក្នុងភាពចម្រុះទាំងអស់ និងបំផុសឱ្យមានការ សន្ទនាគ្នាយ៉ាងពិតប្រាកដក្នុងចំណោមវប្បធម៌ -មាត្រា៧)បេតិកភណ្ឌវប្បធម៌ ជាប្រភពនៃគំនិតច្នៃប្រឌិត។(សរុបសេចក្តីមក ខ្លឹមសាររួមនៃសន្និសិទរបស់ UNESCO គឺផ្តោតលើចំណុចទាំងឡាយដូចខាងក្រោម៖

- ជាជាងវាយតម្លៃវប្បធម៌ដទៃផ្អែកតាមគំនិតលម្អៀងរបស់យើង យើងត្រូវរៀនឱ្យតម្លៃវប្បធម៌ និងទស្សនៈ យល់ឃើញរបស់អ្នកដទៃ។ ដូច្នេះហើយ វាសំខាន់ណាស់ដែលមិនវាយតម្លៃវប្បធម៌អ្នកដទៃ ផ្ទុយទៅវិញ ត្រូវព្យាយាមស្វែងយល់ពីទស្សនៈយល់ឃើញរបស់អ្នកដទៃ។ ឧទាហរណ៍ ពេលទំនាក់ទំនងជាមួយអ្នក មិនជំនាញខាងភាសាអង់គ្លេស យើងត្រូវដឹងថាកម្រិតនៃចំណេះ ដឹងផ្នែកភាសាអង់គ្លេសរបស់គេ គ្មាន អ្វីទាក់ទងនឹងកម្រិតនៃភាពឈ្លាសវៃរបស់ពួកគេឡើយ។
- ចៀសវាងប្រកាន់ខ្ជាប់នូវផ្នត់គំនិតណាមួយមិនថាវិជ្ជមាន ឬអវិជ្ជមាន។ គំនិតដែលថា "ជនជាតិស្បែកស គឺពូកែ" ឬ "ជនជាតិអាស៊ីពូកែគិតលេខ" ទាំងនេះសុទ្ធតែមិនពិត សម្រាប់មនុស្សគ្រប់ គ្នានោះទេ។ ទោះជនជាតិណាក៏ដោយគឺសុទ្ធតែមានមនុស្សពូកែនេះ ឬពូកែនោះសុទ្ធតែមាន ប្រភេទនេះ ឬប្រភេទនោះ ហេតុនេះកុំប្រើប្រាស់ផ្នត់គំនិតផ្ទាល់ខ្លួនទៅវាយតម្លៃ។
- ត្រូវចេះកត់សម្គាល់ និងស្វែងយល់ថា ការយល់ឃើញនៅក្នុងក្រុមតូចៗដូចជា គ្រួសារ ភេទ ជំនឿ និងក្រុមដែលមាននិន្នាការដូចគ្នាផ្សេងទៀតគឺសុទ្ធតែ បង្កើតទៅជាវប្បធម៌ខុសៗគ្នា ហើយជះឥទ្ធិពលយ៉ាងខ្លាំងទៅលើឥរិយាបថរបស់មនុស្ស។ ដូច្នេះហើយ នៅពេលប្រឈមជាមួយអ្នក ដែលបង្ហាញ

ឥរិយាបថ ដែលមានលក្ខណៈអាត្មានិយម លម្អៀង ឬរើសអើងណាមួយនោះ អ្នកត្រូវតែប្រយ័ត្នប្រយែងជាមួយនឹង អាកប្បកិរិយារបស់អ្នកឱ្យមែនទែន។

## ៥. ការចូលរួមគាំទ្រភាពចម្រុះនៃវប្បធម៌




Photo by geralt is licensed under the Pixabay License

យើងម្នាក់ៗ អាចចូលរួមគាំទ្រ និងបណ្តុះនូវឧត្តមគតិនៃវប្បធម៌ចម្រុះនេះបានទូលំទូលាយឡើងនៅក្នុងសង្គមរស់នៅរបស់យើង។ ប្រសិនបើអ្នកមិនច្បាស់ពីរបៀបធ្វើសកម្មភាព ដើម្បីចូលរួមគាំទ្រភាពចម្រុះនៃវប្បធម៌ សូមអ្នកសាកល្បងពិចារណានូវគំនិតទាំងនេះ៖

- បើកចិត្តឱ្យទូលាយ ស្តាប់ ពិចារណា និងស្វែងយល់ឱ្យបានទូលំទូលាយ
- បង្កើនការស្វែងយល់ពីវប្បធម៌របស់ខ្លួនផ្ទាល់គឺជាជំហានដំបូង ដើម្បីឈានទៅស្វែងយល់ពីគុណតម្លៃ និងជំនឿរបស់អ្នកដទៃដែលនឹងនាំយើងយល់ពីគេដូចដែលយើងជឿលើវប្បធម៌របស់យើងដែរ
- ប្រាស្រ័យទាក់ទងជាមួយមនុស្សដែលមានវប្បធម៌ផ្សេងពីវប្បធម៌របស់អ្នក

- បង្កើនការយល់ដឹងអំពីវប្បធម៌ដទៃ តាមរយៈការអាន និងការធ្វើទំនាក់ទំនងជាមួយមនុស្ស ដែលមានវប្បធម៌ខុសៗគ្នាដោយមិនរើសអើង។ ការចូលរួមក្នុងកម្មវិធីវប្បធម៌ផ្សេងៗ ក៏ជាឱកាសជួយយើងឱ្យបង្កើនចំណេះដឹង និងទទួលស្គាល់វប្បធម៌ដទៃដែរ
- ត្រូវទទួលស្គាល់ថាភាពខុសគ្នា គឺមានប្រយោជន៍ជាជាងការបង្កគ្រោះថ្នាក់
- ត្រូវចេះសហការ និងចេះធ្វើការជាមួយមនុស្សដែលមានវប្បធម៌ខុសពីអ្នក
- ធ្វើដំណើរជុំវិញពិភពលោកឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដោយចូលរួមជាមួយសង្គមមនុស្សដែលមានវប្បធម៌ចម្រុះ និងស្វែងយល់អំពីសារៈសំខាន់នៃវប្បធម៌ចម្រុះទាំងនោះ
- ចំណាយពេលអានអក្សរសិល្ប៍ឱ្យបានច្រើន និងរៀនពីវប្បធម៌ចម្រុះ
- តាមដាន ស្តាប់ និងស្វែងយល់ពីទំនៀមទំលាប់ ប្រពៃណី សាសនា ការរស់នៅ និងសិល្បៈនានា តាមប្រព័ន្ធផ្សព្វផ្សាយ ទាំងក្នុងស្រុក និងក្រៅស្រុក
- ការរៀនភាសាបរទេសណាមួយ ក៏អាចជួយឱ្យអ្នកយល់បានច្រើនពីភាពចម្រុះនៃវប្បធម៌ និងមានទំនាក់ទំនងបានទូលំទូលាយជាមួយពិភពលោក
- ត្រូវសកម្មក្នុងការស្តាប់ ទទួលយក និងស្វាគមន៍រាល់មនុស្ស និងគំនិតទាំងឡាយដែលខុសពីគំនិត របស់អ្នកផ្ទាល់ដោយមិនរើសអើង។

## ៦. សេចក្តីសន្និដ្ឋាន

សរុបមក ការយល់ដឹងពីវប្បធម៌ចម្រុះគឺសំខាន់ណាស់ ដើម្បីឈានទៅរកការរួមនៅជាមួយគ្នាយ៉ាងសុខដុមរមនា។ វាប្រៀបដូចជាសម្លដ៏ឈ្ងុយឆ្ងាញ់មួយចានដែលកើតចេញពីការផ្សំគ្រឿងជាច្រើនមុខដូច្នោះដែរ។ ដូចពាក្យមួយឃ្លាថា "ភាពខុសប្លែកគ្នាគឺជាអ្វីដែលយើងមានដូចៗគ្នា។ សូមរីករាយជាមួយលក្ខណៈពិសេសនេះជារៀងរាល់ថ្ងៃ។"

# ឯកសារយោង

## REFERENCES

Chandler, D. and Overton, L. (2019). Cambodia – Cultural life. [online] Encyclopedia Britannica.

Available at: https://www.britannica.com/place/Cambodia/Cultural-life#ref259379

Chapter 8: Respect for Diversity in the "Introduction to Community Psychology" explains cultural humility as an approach to diversity, the dimensions of diversity, the complexity of identity, and important cultural considerations.

Dmitriev G.D. ការអប់រំពហុវប្បធម៌ - អិម: ការអប់រំជាតិ ឆ្នាំ ១៩៩៩-២០០៨។

Dzhurinsky A.N. ការអប់រំពហុវប្បធម៌៖ ខ្លឹមសារ និងទស្សនវិស័យអភិវឌ្ឍន៍។ គរុកោសល្យឆ្នាំ២០០២ លេខ១០

Syrodeeva A.A. ការអប់រំពហុវប្បធម៌៖ សៀវភៅណែនាំអប់រំ និងវិធីសាស្ត្រ។ - M., 2001។

សូចនាករ និងនិន្នាការក្នុងការអភិវឌ្ឍន៍ភាពចម្រុះនៃវប្បធម៌ (ពហុវប្បធម៌) សម្ភារៈនៃរបាយការណ៍ "ពហុនិយមវប្ប

ធម៌ក្នុងបរិបទសកលភាវូបនីយកម្មរបស់អ្នកជំនាញនៃក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមនៃ Belgorod International Model UN - ECOSOC Usmanova DI (2011).

ការអប់រំនៅពីលើអ្វីៗទាំងអស់ (ឆ្នាំ២០១២)និង ការអប់រំភាពជាពលរដ្ឋសកល។

អង្គការយូនីស្កូ ការអប់រំភាពជាព» (បោះពុម្ពឆ្នាំ២០១៤)លរដ្ឋសាកល៖ ការរៀបចំអ្នកសិក្សាសម្រាប់បញ្ហាប្រឈមនៅក្នុងសតវត្សរ៍ទី២១។«

# មេរៀនទី៧៖
# សកម្មភាពដែលអាចធ្វើជាបុគ្គល និងសមូហភាព

**ACTIONS THAT CAN BE TAKEN INDIVIDUALLY AND COLLECTIVELY**

( Dr. Neau Vira, Mr. Po Bunthan, Dr. Um Chan Chamnan, and Mr. Chan Rada )





## ខ្លឹមបំណងនៃមេរៀន

## សំណួរបំផុស

១. សេចក្តីផ្តើម

២. និយមន័យ

ក. បុគ្គលភាព

ខ. សមូហភាព

គ. សកម្មភាពបុគ្គល និងសកម្មភាពសមូហភាព

ឃ. ការងារបុគ្គល និងការងារក្រុម

៣. គុណសម្បត្តិ និងគុណវិបត្តិនៃការរៀនម្នាក់ឯង និងការរៀនជាក្រុម

ក. គុណសម្បត្តិនៃការសិក្សាតែម្នាក់ឯង ឬជាបុគ្គល

ខ. គុណវិបត្តិនៃការសិក្សាតែម្នាក់ឯង ឬជាបុគ្គល

**គ. គុណសម្បត្តិនៃការសិក្សាជាក្រុម ឬជាសមូហភាព**

**ឃ. គុណវិបត្តិនៃការសិក្សាជាក្រុម ឬជាសមូហភាព**

**៤. លក្ខណៈខុសគ្នាចំពោះការធ្វើការតែម្នាក់-ជាបុគ្គល និងជាក្រុម-ជាសមូហភាព**

**៥. ការបញ្ជ្រាបសកម្មភាពបុគ្គល និងសមូហភាពនៅក្នុងមេរៀន និងក្នុងសង្គម**

**៦. សេចក្តីសន្និដ្ឋាន**

**ឯកសារយោង**

**ចំណុចបំណងនៃមេរៀន៖** នៅពេលសិក្សាមេរៀននេះចប់ អ្នកសិក្សានឹងអាចទទួលបាននូវកញ្ចប់សមត្ថភាពដូចខាងក្រោម៖

| | |
|---|---|
| **១. វិជ្ជាសម្បទា** | មានការយល់ដឹងកាន់តែស៊ីជម្រៅទៅលើអត្ថន័យ និងខ្លឹមសារនៃមេរៀន ដូចជាភាពខុសគ្នារវាងសកម្មភាពបុគ្គល សកម្មភាពសមូហភាព និងសកម្មភាពដែលអាចធ្វើជាលក្ខណៈបុគ្គល និងលក្ខណៈសមូហភាពបាន។ |
| **២. បំណិនសម្បទា** | អាចធ្វើការវិភាគ ពន្យល់ និងបកស្រាយបានកាន់តែស៊ីជម្រៅទៅលើអត្ថន័យ និងខ្លឹមសារនៃមេរៀនដូចជាភាពខុសគ្នារវាងសកម្មភាពបុគ្គល សកម្មភាពសមូហភាព និងសកម្មភាពដែលអាចធ្វើជាលក្ខណៈបុគ្គល និងជាលក្ខណៈសមូហភាពបាន។ |
| **៣. ចរិយាសម្បទា** | លើកទឹកចិត្តនិងជំរុញស្មារតីឱ្យមានការចូលរួមយ៉ាងសកម្មក្នុងការធ្វើសកម្មភាពជាលក្ខ ណៈ បុគ្គល និងសមូហភាព។ |

**សំណួរបំផុស៖**

១. តើសកម្មភាពបុគ្គលគឺជាអ្វី? ចូរលើកឡើងពីគុណសម្បត្តិ និងគុណវិត្តិនៃសកម្មភាពបុគ្គល។
២. តើសកម្មភាពសមូហភាពគឺជាអ្វី? ចូរលើកឡើងពីគុណសម្បត្តិ និងគុណវិត្តិនៃសកម្មភាពសមូហភាព។
៣. ចូរលើកឡើងពីសារៈសំខាន់នៃសកម្មភាពបុគ្គល និងសកម្មភាពសមូហភាពចំពោះការសិក្សា។
៤. តើយើងត្រូវធ្វើដូចម្តេចដើម្បីបញ្ជ្រាបសកម្មភាពបុគ្គល និងសកម្មភាពសមូហភាពទៅក្នុងមេរៀន និងទៅក្នុងសង្គម?

## ១. សេចក្តីផ្តើម

នៅក្នុងសង្គមជាតិនីមួយៗ គេតែងតែសង្កេតឃើញថាពលរដ្ឋប្រៀបបានដូចជាកោសិកាមួយយ៉ាងសំខាន់ក្នុងការបំពេញនូវលក្ខណៈសម្បត្តិសម្រាប់ប្រទេសជាតិ ហើយវាក៏ជាផ្នែកមួយដែលធ្វើឱ្យមានការរីកចម្រើន ការអភិវឌ្ឍ និងភាពសុខដុមរមនាផងដែរ។ ពាក្យថាពលរដ្ឋមានន័យថា គឺជាប្រជាជនទាំងប្រុសទាំងស្រី ដែលទុកជាកម្លាំងស្នូលរបស់ប្រទេសជាតិ ហើយពលរដ្ឋម្នាក់ៗមានភារកិច្ច និងកាតព្វកិច្ច ដូចគ្នា និងស្មើគ្នាក្នុងការចូលរួមគ្រប់សកម្មភាពនិងគ្រប់រូបភាព។ ការបញ្ជ្រាបនូវចំណេះដឹងភាពជាពលរដ្ឋសកលGCED ទាក់ទងនឹងសកម្មភាពបុគ្គលនិងសមូហភាពនេះ អាចញុំាងឱ្យសិស្សានុសិស្សមានស្មារតីចូលរួមគិត និងធ្វើកិច្ចការគាំពារ ការពារ និងថែរក្សាវឌ្ឍភាព និងភាពសុខសាន្តនៃសង្គមយើងទាំងមូល។ ចំណេះដឹងទាំងនោះក៏មានសារៈសំខាន់ក្នុងការបណ្តុះស្មារតីបុគ្គលគ្រប់វ័យនៃជាតិសាសន៍នោះឱ្យស្គាល់នូវតម្លៃ និងភារកិច្ចខ្លួនក្នុងកិច្ចការសង្គម ដែលជាទុនដ៏ចាំបាច់សម្រាប់ការអភិវឌ្ឍនៃសង្គមដ៏មាន និរន្តភាព និងចរិភាព។



Photo by geralt is licensed under the Pixabay License

ចំពោះការសិក្សាវិញ មនុស្សយើងមានវិធីសាស្រ្តខុសៗពីគ្នាក្នុងការរៀនសូត្រដោយអ្នកខ្លះចូលចិត្តរៀនតែម្នាក់ឯង ចំណែកអ្នកខ្លះទៀតចូលចិត្តរៀនជាក្រុម។ ទោះជាយ៉ាងណាក៏ដោយ មិនថាអ្នកជ្រើសរើស ឬចូលចិត្តរៀនតាមរយៈវិធីសាស្រ្តណាក៏ដោយសុទ្ធតែមានគុណសម្បត្តិ និងគុណវិបត្តិដូចគ្នាទាំងអស់។ នៅក្នុងមេរៀននេះ យើងនឹងសិក្សា ពីសកម្មភាពពីរប្រភេទសំខាន់ៗគឺសកម្មភាពបុគ្គល និងសកម្មភាពសមូហភាព។ ការអភិវឌ្ឍសង្គមផ្តើមចេញពីការប្រមូលផ្តុំទាំងសកម្មភាពបុគ្គល និងសកម្មភាពសមូហភាព។ បើគ្មានសកម្មភាពបុគ្គល និងសមូហភាពទេ ក៏មិនមានចលនាសង្គមដែរ។ (Cases-Cortes et al., 2008)

## ២. និយមន័យ

### ក. បុគ្គលភាព

ពាក្យថាបុគ្គលភាពត្រូវបានគេកំណត់និយមន័យឱ្យថាវាគឺជាឯកត្តជនដែលបែងចែកពីវណ្ណៈសង្គម ពីក្រុម ឬពីសមូ ហភាព។ បុគ្គលភាពគឺជាមនុស្សដែលមានលក្ខណៈខុសពីអ្នកដទៃ និងជាអ្នកដែលមានគោលដៅ ឬតម្រូវការផ្ទាល់ ខ្លួន និងជាអ្នកដែលមានសិទ្ធិ និងទំនួលខុសត្រូវដោយឡែកពីមនុស្សដទៃពីក្រុម ឬពីសមូហភាព។



Photo by JESHOOTS.COM is licensed under the Unsplash License

## ខ. សមូហភាព

សមូហភាពគឺជាក្រុមមួយនៃអង្គភាពដែលត្រូវសហការ និងធ្វើការរួមគ្នាដើម្បីសម្រេចបាននូវវត្ថុបំណងរួម។ ពាក្យ សមូហភាពនេះជួនកាលត្រូវបានគេប្រើ ដើម្បីពិពណ៌នាចំពោះក្រុមទាំងមូល ឧទាហរណ៍ការប្រមូលផ្តុំមនុស្ស។ សម្រាប់គោលបំណងផ្នែកនយោបាយវិញ ពាក្យថាសមូហភាពត្រូវបានគេកំណត់ និយមន័យថាវា គឺជាការសម្រេច ជាលក្ខណៈវិមជ្ឈការ ឬជាការសម្រេចដោយសម្លេងច្រើន។



Photo by geralt is licensed under the Pixabay License

## គ. សកម្មភាពបុគ្គល និងសកម្មភាពសមូហភាព

សកម្មភាពបុគ្គលសំដៅលើសកម្មភាពទាំងឡាយណាដែលរៀបចំ ឬធ្វើឡើងដោយបុគ្គលណាម្នាក់ ហើយការធ្វើ សកម្មភាពនោះផ្អែកលើការសម្រេចចិត្តរបស់បុគ្គលលនោះឯងផ្ទាល់។ ចំណែកឯសកម្មភាពសមូហភាព សំដៅ លើសកម្មភាពទាំងឡាយណាដែលរៀបចំ ឬធ្វើឡើងដោយសមូហភាព ឬក្រុមណាមួយ ហើយការធ្វើសកម្មភាព នោះផ្អែកលើការសម្រេចចិត្តរបស់សមូហភាព ឧទាហរណ៍ បើអ្នកជ្រើសរើសការធ្វើដំណើរដោយដើរជាងការជិះរថ យន្ត នោះមានន័យថាអ្នកសម្រេចធ្វើសកម្មភាពជាលក្ខណៈបុគ្គល។ ប៉ុន្តែ បើអ្នកចូលរួមជាមួយអ្នកជិតខាងក្នុងការ ជ្រើសរើសធ្វើការលើកចិញ្ចើមផ្លូវដើម្បីជួយដល់មនុស្សទូទៅ ដើរឱ្យបានកាន់តែច្រើនគ្នានោះមានន័យថាអ្នកសម្រេច ធ្វើសកម្មភាពជាលក្ខណៈសមូហភាព។

សកម្មភាពសមូហភាព ជារឿយៗមានការជាប់ពាក់ព័ន្ធការធ្វើសកម្មភាពជាទ្រង់ទ្រាយធំ ព្រោះថាសកម្មភាពនេះមានការចូលរួមពីមនុស្សច្រើន។ ទោះបីជាយ៉ាងណាក៏ដោយ ក៏គេអាច ប្រើប្រាស់សកម្មភាពបុគ្គលដើម្បីធ្វើកិច្ច ការជាទ្រង់ទ្រាយធំបានដែរ ដូចជាការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ នាំឆ្ពោះ ទៅកាត់បន្ថយការប្រែប្រួលអាកាសធាតុជាសកល។

## ឃ. ការងារបុគ្គល និងការងារក្រុម

ការងារក្រុមគឺជាការងារដែលបុគ្គលពីនាក់ឬច្រើននាក់ សហការគ្នាធ្វើដើម្បីឱ្យបានសម្រេចតាមគោលដៅដែលចង់បាន។ ជារឿយៗបុគ្គលម្នាក់ៗទទួលបានតួនាទីផ្សេងៗគ្នា នៅក្នុងក្រុមដើម្បីផ្តល់ការទទួលខុសត្រូវក្នុងចំណោមសមាជិករបស់ខ្លួន។ នៅក្នុងវិស័យមួយចំនួន ការច្នៃប្រឌិតរីកចម្រើននៅពេលដែលមនុស្សចែករំលែកគំនិតដោយសេរី និងអាចទទួលបានអត្ថប្រយោជន៍ពីការបញ្ចូលរបស់អ្នកដទៃ។ នៅពេលប្រមូលផ្តុំគ្នាដោយគិតគូរ ក្រុមនិយោជិត អាចបង្កើតការងារប្រកបដោយគុណភាពជាមួយនឹងការសហការ និងការលើកទឹកចិត្តជាវិជ្ជមាន។

## ៣. គុណសម្បត្តិ និងគុណវិបត្តិនៃការរៀនម្នាក់ឯង និងការរៀនជាក្រុម

នៅក្នុងការរៀនសូត្រទាំងអស់រមែងតែជួបការសិក្សាទ្រឹស្តី និងការអនុវត្តន៍ការងារជាក់ស្តែងដែលគ្រូបានដាក់អោយធ្វើ ហើយការងារទាំងអស់នោះអាចធ្វើជាលក្ខណៈបុគ្គលម្នាក់ៗរីករណីខ្លះអាចធ្វើដោយពិភាក្សាជាលក្ខណៈក្រុមផងដែរ។ ជាការពិតណាស់ក្នុងការងារជាបុគ្គលនិងក្រុម ត្រូវបានបង្កើនឡើងក្នុងគោលបំណងពង្រឹងសមត្ថភាព ប្រសិទ្ធភាពនិងទំនួលខុសត្រូវ គ្រប់គ្រងខ្លួនឯងព្រមទាំងអភិវឌ្ឍន៍ឱ្យមានការគិតពិចារណា និងមានលក្ខណៈស៊ីជម្រៅ។ ការធ្វើការងារជាក្រុមតម្រូវអោយមានការចូលរួមពីគ្រប់សមាជិកទាំងអស់នៅក្នុងក្រុមដើម្បីពិភាក្សា ផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមក ក្នុងគោលបំណងសម្រេចបាននូវផលប្រយោជន៍រួមក្នុងក្រុម ដែលក្នុងនោះសមាជិកទាំងអស់ត្រូវដឹងពីភារកិច្ចដែលខ្លួនទទួលខុសត្រូវ ហើយដើម្បីអោយការងារនេះបានជោគជ័យ យើងត្រូវបែងចែកការងារ និងតួនាទីដល់ក្រុមដូចជាប្រធានក្រុម អ្នកសម្របសម្រួល និងសមាជិកក្នុងក្រុម។

## ក. គុណសម្បត្តិនៃការសិក្សាតែម្នាក់ឯង ឬជាបុគ្គល

ភាគច្រើន មនុស្សដែលជ្រើសរើសរៀនសូត្រតែម្នាក់ឯង ជាប្រភេទមនុស្សដែលពុំសូវចូលចិត្តភាពរញ៉េរញ៉ៃ និងចូលចិត្តនៅស្ងប់ស្ងាត់ ម្យ៉ាងវិញទៀតពួកគេ មិនអាចផ្តោតអារម្មណ៍រៀនឱ្យបានល្អនោះទេ នៅពេលរៀនគ្នាច្រើន ក៏ប៉ុន្តែពួកគេទទួលបានសារៈប្រយោជន៍យ៉ាងច្រើនពី ទង្វើនេះ៖



- **មានភាពឯករាជ្យ៖** អ្នកមានម្ចាស់ការលើខ្លួនឯង មិនចាំបាច់ពឹងពាក់អ្នកដទៃ ជាពិសេសចង់រៀនពេលណាក៏បាន ដោយមិនចាំបាច់បារម្ភច្រើន
- **មិនខាតពេលវេលា៖** នៅពេលរៀនជាក្រុម មានគំនិតច្រើន មុននឹងសម្រេចចិត្តអ្វីមួយ ត្រូវការជជែកគ្នាដែលចំណាយ រយៈពេលយូរ ព្រោះមនុស្សម្នាក់ៗតែងមានគំនិតផ្សេងៗពីគ្នា
- **អាចផ្តោតអារម្មណ៍បានល្អ៖** នៅពេលដែលស្ងប់ស្ងាត់មិនមានសម្លេងរំខាន អារម្មណ៍យើងមូលផាប់ចាំមេរៀន ហើយធ្វើលំហាត់ ឆាប់ចេះ
- មានទំនុកចិត្តលើខ្លួនឯង ឬជាការបញ្ចេញនូវសមត្ថភាពផ្ទាល់ខ្លួន
- មានការបង្កើតនូវស្នាដៃរបស់ខ្លួន ឬជាចំណេះដឹងដែលមាន
- អាចទទួលបាននូវចំណេះដឹង និងបទពិសោធន៍ថ្មីៗពីការស្រាវជ្រាវ
- មានភាពងាយស្រួលក្នុងការសម្រេច ឬវិនិច្ឆ័យធ្វើអ្វីមួយ
- អាចធ្វើការគិតពិចារណាលើកិច្ចការអ្វីមួយបានដោយមិនមានការកំណត់ពេលវេលា។

## ខ. គុណវិបត្តិនៃការសិក្សាតែម្នាក់ឯង ឬជាបុគ្គល

ការធ្វើការងារជាលក្ខណៈបុគ្គល គឺជាការទទួលបាននូវឱកាសក្នុងការបង្ហាញចេញនូវបទពិសោធន៍ ចរិក លក្ខណៈ ការវិនិច្ឆ័យ និងការធ្វើសេចក្តីអនុម័តលើកិច្ចការអ្វីមួយ ដែលបុគ្គលនោះមាន ក៏ដូចជាការស្តែងចេញនូវតម្រូវការផ្ទាល់ខ្លួនរបស់គេដែរ ដែលការងារនេះ អាចធ្វើឡើងដោយមិនបាច់ពឹងផ្អែកលើអ្នកដទៃដែលអាចជាហេតុនាំអោយមានការបញ្ច្រាស ខ្វែងយោបល់គ្នាឡើយ។ ប៉ុន្តែទោះជាការសិក្សាតែម្នាក់ឯងមានអត្ថប្រយោជន៍ យ៉ាងណាក៏ ដោយ វានៅតែមានចំណុចអវិជ្ជមានមួយចំនួន ដែលមិនអាច ជៀសវាងបានទេ។



- **គ្មានអ្នកពិភាក្សា៖** ជាធម្មតាខួរក្បាលច្រើនមានគំនិតច្រើនផ្សេងៗពីគ្នា ប្រសិនបើយើងមិនចេះត្រង់ចំណុចណាមួយ យើងក៏អាចពិភាក្សាគ្នាបាន ក៏ប៉ុន្តែនៅពេលដែលយើងរៀនតែម្នាក់ឯង ពេលដែលមានចម្ងល់ត្រង់ ចំណុចណាមួយ ពុំមានអ្នកណាអាចឱ្យយើងសួរបាននោះទេ។
- **មិនអាចអភិវឌ្ឍសមត្ថភាពបានលឿន៖** ភ្នំមួយខ្ពស់ក៏នៅទាបជាងស្មៅ យើងមិនអាចនិយាយថា យើងចេះគ្រប់យ៉ាងបានទេ។ នៅពេល ដែលយើងរៀនមានដៃគូ ឬជាក្រុម យើងក៏អាចប្រណាំងប្រជែងគ្នាជជែកគ្នាចុះឡើងដើម្បីស្វែង រកដំណោះស្រាយ ជាហេតុធ្វើឱ្យការអភិវឌ្ឍសមត្ថភាព ឆាប់រហ័សជាងការរៀនតែឯកឯង។
- **ស្ត្រេស៖** នៅពេលយើងរៀនមានគ្នា យើងមិនមែនសុទ្ធតែរៀនមួយមុខទេ ក៏ប៉ុន្តែមានទាំងការចំអន់គ្នាចុះឡើង ឬការនិយាយកំប្លែងជាដើម ជាហេតុធ្វើឱ្យស្ថានភាពនៃការសិក្សាគ្មានភាពតាន តឹង។ ផ្ទុយទៅវិញបើយើងរៀនម្នាក់ឯង យើងអាចនឹងអផ្សុកឬធុញទ្រាន់ជាដើម ពេលខ្លះអាចងងុយគេង លែងមានអារម្មណ៍ចង់រៀនទៀត។
- មិនមានការកែតម្រូវលើចំណុចដែលខ្វះខាត
- មានការចំណាយពេលវេលាច្រើនក្នុងការសិក្សាស្រាវជ្រាវ
- អាចមានការយឺតយ៉ាវក្នុងការសម្រេចការងាររបស់ខ្លួន
- ផលដែលទទួលបានមិនសូវមានលក្ខណះគ្រប់គ្រាន់
- អាចមានភាពស្រ្តេស តានតឹងក្នុងអារម្មណ៍
- មានភាពនឿយហត់ច្រើនក្នុងការធ្វើកិច្ចការមួយ
- មានការចំណាយថវិកាច្រើនក្នុងការធ្វើជាឯកសារ
- មិនមានគំនិតទូលំទូលាយក្នុងការបំពេញកិច្ចការ។

## គ. គុណសម្បត្តិនៃការសិក្សាជាក្រុម ឬជាសមូហភាព




- ធ្វើឱ្យសមាជិកក្នុងក្រុមមានឱកាសក្នុងការផ្លាស់ប្តូរបទពិសោធន៍ និងសហការណ៍គ្នា
- ធ្វើអោយសមាជិកក្នុងក្រុមទាំងអស់ មានភាពស្និទស្នាលនឹងគ្នា
- ធ្វើឱ្យសមាជិកនៅក្នុងក្រុមមានការចូលរួមយ៉ាងសកម្ម ជំរុញឱ្យអ្នកអសកម្មចូលរួមពិភាក្សាដោះស្រាយ និងធ្វើឱ្យពួកគេទទួលបាននូវចំណេះដឹងផ្សេងៗ
- មានការចែករំលែកគំនិត និងចំណេះដឹងដែលទាក់ទងនឹងជំនាញផ្សេងៗ ហើយការរៀនជាក្រុមបែបនេះ ជួយឱ្យអ្នកមានការអភិវឌ្ឍសមត្ថភាពខ្លាំង
- ប្រសិនបើយើងរៀនមិនសូវចេះ យើងអាចបង្កើតជាក្រុមដើម្បីឱ្យសិស្សដែលពូកែនៅក្នុងថ្នាក់ជួយបង្រៀន យើងព្រោះការធ្វើបែបនេះអាចជួយឱ្យអ្នករៀនបានច្រើនជាងមុន
- លើសពីនេះទៅទៀត យើងមានឱកាសសួរសំណួរយ៉ាងច្រើនទៅកាន់មិត្តភក្តិរបស់យើងដោយហេតុ ថាពេលខ្លះយើងអាចនឹងមិនសូវហ៊ានសួរទៅកាន់លោកគ្រូរបស់យើង និង
- មានការចំណាយថវិកាតិច ដោយមានការចូលរួមចែករំលែក។

## ឃ. គុណវិបត្តិនៃការសិក្សាជាក្រុម ឬជាសមូហភាព

- ត្រូវការកំណត់ និងជ្រើសរើសទីតាំងដើម្បីជួបជុំគ្នា
- ត្រូវការពេលវេលាច្រើនដើម្បីធ្វើការពិភាក្សា

- សមាជិកក្រុមខ្លះមិនសូវចូលរួមសហការណ៍ក្នុងពេលពិភាក្សា
- ការសិក្សាជាក្រុមអាចធ្វើឱ្យសមាជិកក្នុងក្រុមមួយចំនួនមានភាពខ្ជិលច្រអូស។ ឧទាហរណ៍បើរៀន ជាមួយគ្នារាល់ថ្ងៃពួកអ្នកដែលខ្សោយ មិនព្យាយាមធ្វើលំហាត់ដោយខ្លួនឯងនៅផ្ទះនោះទេ ប៉ុន្តែចាំមកដល់ ពេលរៀនវិញទើបសួរចម្លើយពីអ្នកដទៃ
- លើសពីនេះទៀតការសិក្សាជាក្រុមអាចខ្ជះខ្ជាយពេលវេលាព្រោះភាគច្រើនមានការនិយាយលេងដោយឥត ប្រយោជន៍ច្រើនក្នុងពេលកំពុងសិក្សា
- អាចមានភាពខ្វែងគំនិតគ្នាក្នុងពេលពិភាក្សា
- សមាជិកដែលមានយោបល់ច្រើនអាចគ្របដណ្តប់លើក្រុមទាំងមូល និង
- ការមិនព្រមទទួលយកនូវទស្សនៈយោបល់ដែលសមាជិកផ្សេងៗលើកឡើង។

## ៤. លក្ខណៈខុសគ្នាចំពោះការធ្វើការតែម្នាក់-ជាបុគ្គល និងជាក្រុម-ជាសមូហភាព

មុននឹងសម្រេចថាការងារប្រភេទនេះ ធ្វើតែម្នាក់ល្អជាង ឬធ្វើជាក្រុមល្អជាង យើងអាចមើលទៅបរិបទការងារឱ្យគ្រប់ផ្នែកជាមុនសិន ព្រោះការងារមួយចំនួនសមស្របជាមួយវិធីខ្លះ ដោយគ្រាន់តែជ្រើសរើសឱ្យត្រូវប៉ុណ្ណោះ។ ការបំ ពេញការងារដោយរលូន នឹងទទួលលទ្ធផលតាមគោលដៅយ៉ាងពិតប្រាកដ។

| **ក. ភាពឆាប់រហ័សនៃការងារ** | |
|---|---|
| ធ្វើការតែម្នាក់ឯង | ធ្វើការជាក្រុម |
|  ការធ្វើការងារគ្រប់យ៉ាង អាស្រ័យលើតែម្នាក់គឺមិនអាចសម្រេចបានឆាប់រហ័សដូចយើងគិតទេ ហៅ |  ការងារណាមួយដែលមិនធ្លាប់ធ្វើមកពីមុន អាចឱ្យអ្នកមានជំនាញជាងធ្វើជំនួសបាន។ ការងារបែប |

| | |
|---|---|
| ថាការងារសម្រេចលឿន ប៉ុន្តែនឿយហត់ព្រោះការងារនីមួយៗត្រូវអាស្រ័យលើជំនាញខុសៗគ្នា។ បើយើងត្រូវធ្វើការដែលមិនធ្លាប់ធ្វើពីមុនមក យើងនឹងមានអារម្មណ៍ថាការងារនោះមិនរលូននិងខ្វះខាត។ | បញ្ជូនតគ្នា គឺជួយឱ្យការងារនោះឆាប់រហ័សដោយគ្រាន់តែធ្វើការរបស់យើងឱ្យល្អបំផុត ខណៈមិត្តរួមការងារផ្សេងទៀតធ្វើការរបស់គេបន្ត ហើយការងារនឹងសម្រេចឆាប់ រហ័សស្មើៗគ្នា។ |
| **ខ. សហការសម្រេចចិត្ត** | |
|  |  |
| ការធ្វើការតែម្នាក់ឯង ធ្វើឱ្យយើងអាចសម្រេចចិត្តយ៉ាងឆាប់រហ័សព្រោះមិនចាំបាច់រង់ចាំការសម្រេចចិត្តពីអ្នកដទៃគ្រាន់តែយើងមានទំនុកចិត្តលើសមត្ថភាពរបស់ខ្លួន ហើយដឹងថាការសម្រេចចិត្តនោះនឹងប៉ះពាល់ដល់ការងារដែរឬទេ។ | អាចនឹងខាតពេលវេលាក្នុងការរង់ចាំគំនិតពីអ្នកដទៃ ប៉ុន្តែគ្រប់គ្នានៅក្នុងក្រុមមានចំណែករួមដើម្បីបង្កើតទំនុកចិត្តថាបានធ្វើតាមគំនិតរួម មិនមែនជាគំនិតរបស់បុគ្គលណាម្នាក់។ក្នុងករណីមានកំហុសឆ្គងកើតឡើង យើងក៏មិនចាំបាច់មកបន្ទោសថាជាកំហុសរបស់អ្នកណាម្នាក់ ព្រោះគ្រប់គ្នាត្រូវទទួលខុសត្រូវរួមដែលធ្វើឱ្យកាន់តែមានការពាក់ព័ន្ធក្នុងក្រុម។ |
| **គ. ការបង្កើតគំនិត** | |



ការធ្វើការជាបុគ្គល មិនអាចបង្កើតគំនិតច្រើនទេ ឬ បើគិតឱ្យបានច្រើន យើងក៏ត្រូវគិតឱ្យដូចជាមានមនុស្សច្រើនជួយគិតគ្នាគាំទ្រគ្នា ប្រើកម្លាំងធ្វើការច្រើននិងហត់នឿយលើសដើម។



ការងារជាក្រុម អាចទទួលបានគំនិតច្រើន ខណៈមានមនុស្សជាច្រើនជួយគិត អាចយកទៅអនុវត្តបានច្រើន គ្រប់គ្នាមានចំណែករួមក្នុងការងារ និងបញ្ចេញគំនិតស្វែងរកចំណុចល្អបំផុត ។

**ឃ. ការបង្កើតសម្ព័ន្ធភាព**



ការធ្វើការតែម្នាក់ឯង យើងស្ទើរតែគ្មានឱកាសបានចង សម្ព័ន្ធភាព ឬជជែកជាមួយអ្នកដទៃ ដើម្បីប្តូរមតិ យោបល់។ បើយើងកំពុងរកចម្លើយតបដល់ការងារដែលកំពុងធ្វើ យើងនឹងគិតតែម្នាក់ឯង គ្មានអ្នកផ្តល់ប្រឹក្សា ហើយអាចកើតស្ត្រេសបាន។



ការងារជាក្រុម អាចមានខុសចិត្តគ្នាឬជម្លោះខ្លះ ប៉ុន្តែចុងក្រោយយើងនឹងត្រឡប់មកជជែកគ្នាល្អៗ ព្រោះសម្ព័ន្ធភាពមកពីការងារជាក្រុម នឹងជួយឱ្យយើងមិនខឹងគ្នាយូរ ដោយសារមានការទទួលខុសត្រូវចំណែករួមគ្នា។

**ង. ការងារស្របនឹងសមត្ថភាព**

| | |
|---|---|
| ពេលធ្វើការតែម្នាក់ យើងត្រូវជាបុគ្គលដែលមានសមត្ថភាពគ្រប់ផ្នែកគ្មានសិទ្ធិរើសថា នឹងធ្វើការងារនេះឬការងារនោះទេព្រោះ នៅក្រុមមានតែយើងម្នាក់មិនអាចផ្ទេរឱ្យអ្នកដទៃធ្វើបាន ហៅថាមនុស្សតែម្នាក់ត្រូវបំពេញ ការងារសព្វគ្រប់។ | យើងអាចរើសបានថា នឹងធ្វើការងារអ្វីព្រោះគ្រប់គ្នាត្រូវបែងចែកតួនាទីឱ្យច្បាស់លាស់។ បើមិនស្ទាត់ធ្វើការអ្វីម្យ៉ាង យើងអាចជ្រើសយកធ្វើការងារផ្សេងទៀតគ្រាន់តែប្រាប់ពីភាពចាំបាច់ និងដែនកំណត់ការងារឱ្យក្រុមដឹងជាមុន។ ការបំពេញការងារទៅតាមសមត្ថភាព នឹងជួយឱ្យលទ្ធផលចេញមកល្អ។ |

## ៥. ការបញ្ជ្រាបសកម្មភាពបុគ្គល និងសមូហភាពនៅក្នុងមេរៀន និងក្នុងសង្គម

ខាងក្រោមនេះ គឺជាកិច្ចការ និងប្រធានបទដែលគ្រូអាចយកមកបញ្ជ្រាបទៅក្នុងមេរៀនដើម្បីជំរុញឱ្យមានសកម្មភាពជាបុគ្គល ឬសមូហភាពនៅតាមកម្រិតភូមិសិក្សា៖

### ក. ចំពោះថ្នាក់មត្តេយ្យសិក្សា និងថ្នាក់អប់រំកុមារតូច (K1, K2, K3)

ប្រធានបទពាក់ព័ន្ធនឹងសកម្មភាពបុគ្គល និងសមូហភាព៖

- សកម្មភាពដែលពួកគាត់អាចធ្វើបានមានដូចជាការថែរក្សា និងការកែលម្អផ្ទះសម្បែងដែលពួក គេរស់នៅនិងការសម្អាតបរិស្ថានសាលារៀនដូចជាការប្រមូលផ្ដុំគ្នាដើម្បីសម្អាតទីធ្លាសាលាការ កាត់បន្ថយការប្រើប្លាស្ទិក និងសកម្មភាពពាក់ព័ន្ធផ្សេងៗទៀត។

### ខ. ចំពោះថ្នាក់បឋមសិក្សា

ប្រធានបទពាក់ព័ន្ធនឹងសកម្មភាពបុគ្គល និងសមូហភាព៖

- ទំនាក់ទំនងរវាងបុគ្គល និងសមូហភាព
- ការចូលរួមប្រកបដោយសុខដុមរមនាក្នុងវប្បធម៌ផ្សេងៗគ្នា
- ការចូលរួមកំណត់អត្តសញ្ញាណនៃបញ្ហា ដើម្បីរកដំណោះស្រាយរួម
- ការចូលរួមក្លឹមសិក្សា សកម្មភាពសិក្សា កីឡា និងពលកម្មសាលានិងសង្គម

## គ. ចំពោះកម្រិតអនុវិទ្យាល័យ

ប្រធានបទពាក់ព័ន្ធនឹងសកម្មភាពបុគ្គល និងសមូហភាព៖

- កំណត់តួនាទី និងកាតព្វកិច្ចរបស់បុគ្គល និងក្រុម ក្នុងការធ្វើសកម្មភាព
- ការគិតទុកជាមុន និងការវិភាគលទ្ធផលនៃសកម្មភាព
- ការកំណត់អត្តសញ្ញាណសកម្មភាពដែលបានធ្វើឡើងដើម្បីកែលម្អសាលារៀន
- កំណត់អត្ថប្រយោជន៍ ឱកាស និងផលប៉ះពាល់នៃការចូលរួមរបស់ខ្លួន
- កត្តារួមចំណែកដល់ភាពជោគជ័យរបស់បុគ្គល និងសមូហភាព

## ឃ. ចំពោះមធ្យមសិក្សាទុតិយភូមិ

ប្រធានបទពាក់ព័ន្ធនឹងសកម្មភាពបុគ្គល និងសមូហភាព៖

- កត្តាដែលអាចពង្រឹង ឬកម្រិតនៃការចូលរួមធ្វើសកម្មភាពជាលក្ខណៈបុគ្គល និងសមូហភាព
- ការជ្រើសរើសមធ្យោបាយសមស្របបំផុតសម្រាប់ទទួលបានព័ត៌មាន ការបញ្ចេញមតិនិងចាត់វិធានការ លើបញ្ហាសកលសំខាន់ៗ (ប្រសិទ្ធភាព លទ្ធផល ផលប៉ះពាល់អវិជ្ជមាន ការពិចារណាខាងសីលធម៌)
- គម្រោងសហការលើបញ្ហាមូលដ្ឋាន និងការព្រួយបារម្ភជាសកល ដូចជាបរិស្ថាន ការកសាងសន្តិភាព ការប្រកាន់ពូជសាសន៍។ល។
- សកម្មភាពដែលត្រូវធ្វើការរួមគ្នាលើភាពជោគជ័យ និងបរាជ័យនៃការធ្វើសកម្មភាពជាបុគ្គល និងជាសមូហភាព

## ង. ចំពោះសង្គម

ប្រធានបទពាក់ព័ន្ធនឹងសកម្មភាពបុគ្គល និងសមូហភាព៖

- ធ្វើជាកូនល្អក្នុងសង្គមគ្រួសារ សិស្សល្អក្នុងសាលា និងពលរដ្ឋល្អក្នុងសង្គម
- ចូលរួមក្នុងសកម្មភាពសង្គម ដូចជាការងារមនុស្សធម៌ជាដើម

- ចូលរួមគោរពច្បាប់ ព្រោះថាច្បាប់ជាកត្តាសំខាន់ក្នុងការរក្សានូវសណ្តាប់ធ្នាប់ និងការគ្រប់គ្រងសង្គមមនុស្សឱ្យមានរបៀបរៀបរយ
- ធ្វើខ្លួនឱ្យទៅជាធនធានមួយល្អដើម្បីក្លាយខ្លួនទៅជាទំពាំងស្នងឫស្សីរបស់ប្រទេសជាតិខ្លួន
- លើកស្ទួយ និងលើកតម្កើងវប្បធម៌ អរិយធម៌ ទំនៀមទម្លាប់ប្រពៃណី អត្តសញ្ញាណជាតិរបស់ខ្លួនទាំងក្នុងប្រទេសទាំងលើឆាកអន្តរជាតិ ព្រោះថាអ្វីៗទាំងអស់ត្រូវចាប់ផ្តើមចេញពីខ្លួនឯងជាមុខសិន ទើបអ្នកដទៃគេលើកតម្កើង និងឱ្យតម្លៃជាក្រោយ
- មានមនសិការ និងការសាមគ្គីគ្នាជាធ្លុងមួយ ក្នុងនាមជាជាតិសាសន៍តែមួយ ដូចពាក្យស្លោក មួយលើកឡើងថាចង្កឹះមួយអាចកាច់បាក់តែចង្កឹះមួយបាច់មិនអាចកាច់បាក់ឡើយ។
- លុបបំបាត់រាល់ទម្រង់ទាំងឡាយណាដែលជាសញ្ញាណនៃការរើសអើង ការប្រកាន់វណ្ណៈ និងការប្រកាន់បក្ខពួក ព្រោះថាកត្តាទាំងនេះ ជាផ្នែកមួយធ្វើឱ្យសង្គមមិនអាចរីកចម្រើនទៅមុខបាន
- ជៀសវាងឱ្យបាននូវការប្រព្រឹត្តអំពើអបាយមុខទាំងឡាយ ដូចជាការជួញដូរនិងសេពគ្រឿងញៀន ការលួច ការឆក់ ការប្លន់ ល្បែងស៊ីសងគ្រប់ប្រភេទ ជាពិសេសការប្រព្រឹត្តអំពើល្មើសផ្សេងៗជាច្រើនទៀតដែលច្បាប់ហាម និងបានចែងជាធរមានថាអំពើនោះគឺជាបទល្មើស
- ត្រូវតែគោរពសិទ្ធិសេរីភាពចំព-ោះគ្នា និងគ្នា
- ត្រូវបដិសេធ និងមិនត្រូវចូលរួមជាដាច់ខាតនូវរាល់អំពើទាំងឡាយណា ដែលធ្វើឱ្យប៉ះពាល់ដល់ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ក្នុងចេតនាបង្កឱ្យមានវឹកវរដល់សង្គមជាតិ។




Photo by JESHOOTS.COM is licensed under the Unsplash License

## ៦. សេចក្តីសន្និដ្ឋាន

ការធ្វើខ្លួនឱ្យទៅជាពលរដ្ឋល្អ ពោលគឺជាពលរដ្ឋដែលចេះធ្វើការងារជាបុគ្គលនិងសមូហភាព គឺជារឿងមួយដ៏ប្រពៃសម្រាប់ប្រទេសជាតិ ព្រោះថាកាលណាប្រទេសជាតិមួយដែលសម្បូរទៅដោយពលរដ្ឋល្អ មានន័យថាប្រ ទេសជាតិនោះនឹងមានភាពរឹងមាំ ភាពខ្លាំងនិងការអភិវឌ្ឍលើវិស័យសេដ្ឋកិច្ច និងមានធនធានមនុស្សចម្រុះ។ ប្រទេសជាតិនានាក្នុងពិភពលោក តែងតែត្រូវការជានិច្ចនូវកោសិការមួយដែលគេហៅថាពលរដ្ឋល្អក្នុងប្រទេសរបស់ខ្លួន ព្រោះថានៅពេលណាដែលសម្បូរទៅដោយពលរដ្ឋល្អ នៅពេលនោះ អ្វីៗដែលល្អ ដែលសម្បូរបែប នឹងកើតមានឡើងក្នុងប្រទេសនោះជាក់ជាមិនខាន។

ក្រោយពីបានធ្វើការសិក្សាវែកញែកពីគុណសម្បត្តិ និងគុណវិបត្តិនៃសកម្មភាពជាក្រុម និងជាលក្ខណៈបុគ្គល យើងបានឃើញថាវិធីទាំងពីរនេះសុទ្ធតែមានប្រសិទ្ធភាពដូចៗគ្នា និងមានចំណុចវិជ្ជមាន និងអវិជ្ជមានដូចគ្នាដោយគ្រាន់តែថាក្នុងករណីខ្លះ យើងត្រូវពិនិត្យមើលលើស្ថានភាពជាក់ស្តែងនៃកិច្ចការនោះថា

តើវាមានលក្ខណៈគ្រប់គ្រាន់ក្នុងការបង្កើតក្រុមពិភាក្សាឬក៏អាចធ្វើជាលក្ខណៈបុគ្គលបាន។ សរុបសេចក្តីមក មិនថាការពិភាក្សាជាលក្ខណៈបុគ្គលឬជាក្រុម ថាមួយណាល្អប្រសើរជាងមួយណានោះទេ គឺវាតែងតែមានការប្រស្រ័យទាក់ទងគ្នាទៅវិញទៅមកដោយផ្អែកលើស្ថានភាព លក្ខណៈនៃកិច្ចការមួយនោះ។

# ឯកសារយោង

## References

Benne, Kenneth D., and Paul Sheats. "Functional Roles of Group Members." Journal of Social Issues 4.2 (Spring 1948): 41–49.

Ludwig, Kirk (2016): *From Individual to Plural Agency: Collective Action 1*. Vols. 2. Oxford: Oxford University Press.10.1093/acprof:oso/9780198755623.001.0001

Raimo Tuomela. Actions by collectives. Philosophical Perspectives, 3:471–496, 1989.

Tawil, Sobhi (2013). Education for "global citizenship". UNESCO: Paris. Available at: https://unesdoc.unesco.org/ark:/48223/pf0000223784_spa

UNESCO. 2014. How is Global Citizenship Taught? Wisdoms from the Classroom. http://www.unescobkk.org/education/news/article/how-is-global-citizenship-taught-wisdoms-fromthe-classroom/

# មេរៀនទី៨៖
# អាកប្បកិរិយាទទួលខុសត្រូវប្រកបដោយសីលធម៌

**ETHICAL RESPONSIBLE BEHAVIOUR**

( Ms. Bun Sophanny, Mr. Prak Peau, and Dr. Moeun Linna )



**ចំណុចបំណងមេរៀន**

**១. សេចក្តីផ្តើម**

**២. និយមន័យ**

**៣. ហេតុអ្វីសិស្សចាំបាច់ត្រូវធ្វើជាពលរដ្ឋមានសីលធម៌ និងមានការទទួលខុសត្រូវខាងសង្គម ?**

**៤. តើយើងត្រូវធ្វើដូចម្តេចដើម្បីឱ្យសិស្សក្លាយជាមនុស្សការទទួលខុសត្រូវប្រកបដោយសីលធម៌**

**៥. សន្និដ្ឋាន**

**គន្ធនិទ្ទេស**

**ចំណុចបំណងនៃមេរៀន៖** ក្រោយពីរៀនមេរៀននេះចេះអ្នកសិក្សាអាច៖

| | |
|---|---|
| **១. វិជ្ជាសម្បទា** | យល់ដឹងអំពីការទទួលខុសត្រូវសង្គម និងពលរដ្ឋ សិទ្ធិមនុស្ស និងចីរភាព ។ |
| **២. បំណិនសម្បទា** | វិភាគ និង វាយតម្លៃបញ្ហាប្រឈម និង ទ្វេគ្រោះនានា ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ អំពីអំពើរបស់ខ្លួនជាលក្ខណៈបុគ្គល សមូហភាព និងពិភពលោកទាំងមូល ។ |
| **៣. ចរិយាសម្បទា** | មានស្មារតីលើកកម្ពស់យុត្តធម៌សង្គម សិទ្ធិមនុស្ស ការពារសហគមន៍ និងពិភព លោក ដោយមានការទទួលខុសត្រូវប្រកបដោយសីលធម៌ ។ |

**សំណួរបំផុស**

១. តើបញ្ញត្តិអភិសមាចារ និងការទទួលខុសត្រូវមានន័យដូចម្តេច?
៣. ហេតុអ្វីសិស្សចាំបាច់ត្រូវធ្វើជាពលរដ្ឋមានសីលធម៌ និងមានការទទួលខុសត្រូវសង្គម?
៤. តើយើងត្រូវធ្វើដូចម្តេចដើម្បីឱ្យសិស្សក្លាយជាមនុស្សមានការយល់ដឹងអំពីការទទួលខុសត្រូវផ្នែកសីលធម៌ និងសង្គម?

## ១. សេចក្តីផ្តើម

គ្រូបង្រៀនត្រូវបានគេចាត់ទុកថាជាចលករដ៏សំខាន់ក្នុងការបម្រើ និងកែប្រែសង្គម។ ក្នុងនាមជាភ្នាក់ងារទទួលបន្ទុកអប់រំគ្រូបង្រៀនបានអនុវត្តស្របតាមកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីធ្វើឱ្យសម្រេចទៅតាមផែនការដែលបានដាក់ចេញ។ ដោយហេតុថាប្រទេសកម្ពុជា គឺជាសមាជិករបស់អង្គការសហប្រជាជាតិដែលត្រូវគោរពនូវគោលការណ៍ច្បាប់ទាំងឡាយរបស់អង្គការសហប្រជាជាតិ។ ជាពិសេសនៅពេលថ្មីៗនេះក្រសួងអប់រំយុវជន និងកីឡា បានចុះកិច្ចព្រមព្រៀង (MUO) ជាមួយអង្គការយូនីស្កូ ស្តីអំពីការអប់រំពលរដ្ឋសកលទៅក្នុងកម្មវិធីសិក្សារបស់ខ្លួន។ ជារួម ក្រសួងអប់រំយុវជន និងកីឡាតម្រូវឱ្យបញ្ជ្រាបខ្លឹមសារដែលមាននៅក្នុងគោលបំណងទាំង៩នៃការអប់រំពលរដ្ឋសកលទៅដល់គ្រប់ភូមិសិក្សា ដើម្បីរួមចំណែកធ្វើឱ្យពិភពលោកមានសុខសន្តិភាព និងការអភិវឌ្ឍប្រកបដោយចីរភាព។ ដោយឡែកគោលបំណងទី៨ដែលតម្រូវឱ្យអ្នកសិក្សាមានអាកប្បកិរិយាទទួលខុសត្រូវប្រកបដោយសីលធម៌ជាគោលបំណងដ៏សំខាន់មួយក្នុងគោលបំណងទាំង៩ដែលបានដាក់ចេញដោយអង្គការយូនីស្កូសម្រាប់ការអប់រំពលរដ្ឋសកល ។



ការអប់រំពលរដ្ឋសកល គ្រប់ដណ្តប់ទៅលើសច្បាប់រដ្ឋធម្មនុញ្ញ សិទ្ធិមនុស្ស យុត្តិធម៌ សមធម៌ ប្រជាធិបតេយ្យ កតព្វកិច្ច និងការទទួលខុសត្រូវក្នុងនាមជាពលរដ្ឋ ក្បួនច្បាប់វប្បធម៌ សេចក្តីរំពឹងទុករបស់សង្គម ការអភិវឌ្ឍប្រកបដោយចីរភាព ប្រវត្តិរឿងរ៉ាវអតីតកាល។ អ្នកសិក្សារៀនទទួលខុសត្រូវចំពោះគ្រួសារ សហគមន៍ និងជាតិ ព្រមទាំងតួនាទីជាប្រជាពលរដ្ឋពិភពលោកផងដែរ។ ( KENYA INSTITUTE OF CURRICULUM DEVELOPMENT,2020 )

## ២. និយមន័យ

អភិសមាចារ ( ETHICS ) ត្រូវបានកំណត់ថា ជាទស្សនវិជ្ជាសីលធម៌៖ ជាការសិក្សាអំពីធម្មជាតិ នៃសីលធម៌ ជម្រើសសីលធម៌ពិសេសដែលត្រូវបានធ្វើអំពើដោយមនុស្សម្នាក់។ (The American Heritage® Dictionary of the English Language, 4th edn. )

វចនានុក្រមសម្តេចជួន ណាត អភិសមាចារ ETHICS ( សីលធម៌ ) បានមកពាក្យបាលី ឬសំស្ក្រឹត ( សំ. ),( បា. )(អៈភិសៈម៉ា--) សមាចារដ៏ក្រៃលែង គឺមាយាទល្អក្រៃពេក ឬការប្រព្រឹត្តរៀបរយគួរឲ្យពេញចិត្ត គួរឲ្យជ្រះថ្លា។ ឧទាហរណ៍៖ *បព្វជិតត្រូវប្រកបជានិច្ចដោយអភិសមាចារ ។* ( ជួន ណាត ១៩៦៥ )

យោងតាមនិយមន័យដែលកំណត់ដោយវចនានុក្រមភាសាអង់គ្លេស សីលធម៌ត្រូវបានគេកំណត់ ថាជាទាក់ទងជាមួយនឹងការវិនិច្ឆ័យនៃភាពល្អ ឬភាពអាក្រក់នូវអំពើ ឬឥរិយាបថរបស់មនុស្ស។ វាអនុ លោមទៅតាមស្តង់ដាអ្វីដែលត្រឹមត្រូវឬវានៅក្នុងអាកប្បកិរិយា។ ក្នុងន័យមួយផ្សេងទៀត សីលធម៌ជា ការបង្រៀនឬបង្ហាញនូវភាពល្អឬភាពត្រឹមត្រូវនៃអាកប្បកិរិយានិងឥរិយាបថផងដែរ។ ( Jonathan P. Latimer, 2000 ) ដូច្នេះ ការទទួលខុសត្រូវប្រកបដោយ

សីលធម៌មានន័យថា ជាការទទួលខុសត្រូវទៅលើ អំពើ ឬអាកប្បកិរិយារបស់យើងប្រកបដោយសីលធម៌ ឬភាពត្រឹមត្រូវ។ នៅក្នុងនិយមន័យដោយឡែកមួយផ្សេងទៀតដែលបានលើកឡើងនៅក្នុងសៀវភៅសិក្សាគោលថ្នាក់ទី១២ បានឱ្យនិយមន័យថាទំនួលខុសត្រូវជាកតព្វកិច្ចដែលត្រូវធានារ៉ាប់រងរាល់អំពើទាំងឡាយ ដែលខ្លួនបានធ្វើដោយហ៊ានទទួលសារភាព និងហ៊ានទទួលផលវិបាកនៅចំពោះមុខខ្លួនឯងផង និងចំពោះមុខច្បាប់សង្គមផង។ ទំនួលខុសត្រូវមានពីរបែប គឺទំនួលខុសត្រូវផ្នែកសីលវិជ្ជា និងទំនួលខុសត្រូវផ្នែកសង្គម។ (ក្រសួងអប់រំយុវជន និងកីឡា 2017) សរុបសេចក្តីមក ការទទួលខុសត្រូវសង្គមគឺជាទ្រឹស្តីមួយដែលបុគ្គលត្រូវមានទំនួលខុសត្រូវចំពោះការបំពេញកាតព្វកិច្ចជាពលរដ្ឋ និងសកម្មភាពរបស់បុគ្គលម្នាក់ជាប្រយោជន៍របស់សង្គមទាំងមូល។ មានន័យថា រាល់អំពើរបស់ម្នាក់ៗមិនបង្កផលប៉ះពាល់ដល់អ្នកដទៃនិងពិភពលោក។ ជាក់ស្តែង បុគ្គលម្នាក់ៗត្រូវធ្វើមានតុល្យភាពរវាងកំណើនសេដ្ឋកិច្ច សុខមាលភាពសង្គម និងបរិស្ថាន។ ទោះបីជាយ៉ាងណាក៏ដោយវាមានពាក្យគន្លឹះ ឬគោលការណ៍ទូទៅឬដោយឡែកសម្រាប់ការផ្តល់និយមន័យ ឬគោលការក្នុងការណែនាំ និងវាយតម្លៃអំពើមួយរបស់បុគ្គលណាម្នាក់ថា ត្រូវធ្វើបែបណាជាការទទួលខុសត្រូវប្រកបដោយសីលធម៌ឬ មិនប្រកបដោយសីលធម៌។

**តើអ្វីខ្លះដែលទាក់ទងនឹងសីលធម៌ និង អ្វីខ្លះដែលមានមិនទាក់ទង?**

សីលធម៌ទាក់ទងជាមួយនឹង៖

- ការវាយតម្លៃតម្លៃផ្ទាល់ខ្លួន
- ចំណេះដឹងអំពីស្តង់ដារផ្ទាល់ខ្លួន សហគមន៍ និងគោលការណ៍សកល
- ជម្រើស និងផលប៉ះពាល់នៃជម្រើសទាំងនេះលើអ្នកដទៃ និងខ្លួនឯង
- ផលវិបាករយៈពេលខ្លី និងរយៈពេលវែង និងទទួលយកទំនួលខុសត្រូវចំពោះជម្រើសដែលខ្លួនធ្វើ

**សីលធម៌គឺមិនមែន៖**

- ការវិនិច្ឆ័យអ្នកដទៃ
- តម្លៃ គ្រួសារ
- ប្រាក់ចំណូល
- សិទ្ធិស្របច្បាប់ ឬអ្នកជំនាញខាងដោះស្រាយបញ្ហាផ្ទាល់ខ្លួន

ទោះបីជាយ៉ាងណាក៏ដោយខាងក្រោមនេះគន្លឹះណែនាំមួយចំនួនក្នុងការយល់ដឹងនិងការទទួលយកចំពោះវិបាកនៃការសម្រេចចិត្តត្រូវបានកំណត់អនុវត្ត៖

- អាកប្បកិរិយាយកចិត្តទុកដាក់ចំពោះខ្លួនឯង និងអ្នកដទៃ

- អារម្មណ៍នៃការគ្រប់គ្រង និងសមត្ថភាព ការទទួលស្គាល់ និងការទទួលយកនូវភាពចម្រុះនៃបុគ្គល និង វប្បធម៌
- ការទទួលស្គាល់សិទ្ធិមនុស្សជាមូលដ្ឋានរបស់ខ្លួនឯង និងអ្នកទៃ
- សមត្ថភាពក្នុងការបើកចំហគំនិតថ្មីៗ បទពិសោធន៍ និងមនុស្ស
- ការយល់ដឹងអំពីសារៈសំខាន់នៃការស្ម័គ្រចិត្តក្នុងសកម្មភាពសង្គម និងសហគមន៍
- សមត្ថភាពក្នុងការចូលរួមក្នុងការពិសោធន៍ជាមួយនឹងមនុស្សពេញវ័យផ្សេងៗទៀត
- ការអភិវឌ្ឍភាពជាអ្នកដឹកនាំ ទំនាក់ទំនង និងជំនាញសង្គម។

( Polk, R.K. *Social Responsibility*. ( Retrieved from Griffith Graduate Attributes Ethical Behavior and Social Responsibility Toolkit )

## ៣. ហេតុអ្វីសិស្សចាំបាច់ត្រូវមានការទទួលខុសត្រូវប្រកបដោយសីលធម៌ ?

នៅលើពិភពលោកយើងនេះ គ្មាននរណាម្នាក់អាចរស់នៅដោយឯកកោរតែម្នាក់ឯងឡើយ ការរស់នៅត្រូវពឹងផ្អែកគ្នាទៅវិញទៅមករវាងមនុស្សនិងមនុស្ស រវាងមនុស្សនិងបរិស្ថានជុំវិញ និងពិភពលោកទាំងមូល ដែលជាហេតុនាំឱ្យមនុស្សត្រូវតែបណ្ដុះវប្បធម៌សន្តិភាព និងការពារបរិស្ថាន។ ពិភពលោកប្រៀប ដូចជាសំណាញ់សំបុកពីងពាងដែលត្រូវបានភ្ជាប់អន្តរទំនាក់ទំនងគ្នា តាំងពីកម្រិតបុគ្គល គ្រួសារ សហគមន៍ ប្រទេស និងពិលោកទាំងមូល ។




បច្ចុប្បន្ននេះ សកលលោកកំពុងតែប្រឈមជាមួយនឹងបញ្ហាថ្មីៗ ជាច្រើនដែលកើតចេញពីការរីកចម្រើននៃបច្ចេកវិទ្យា និងសកលភាវូបនីយកម្ម។ បញ្ហាទាំងនោះរួមមានការកើនឡើងនៃភាពស្មុកស្មាញ និងភាពមិនច្បាស់ លាស់ ការកើនឡើងនៃឯកជនភាព និងភាពផ្សេងៗគ្នានៃសង្គម គម្លាតនៃឯកវប្បធម៌ តែមួយ និងសេដ្ឋកិច្ច ការធ្លាក់ចុះនៃសេវា

អេកូឡូស៊ីដែលពឹងផ្អែកលើសង្គមទាំងនោះ និងការកើនឡើងនូវភាពងាយរងគ្រោះបច្ចេកវិទ្យា និងធម្មជាតិ។ បញ្ហាទាំងនេះ បណ្តាលឱ្យមានការព្រួយបារម្ភណ៍ជាសកល ដែលយើងទាំងអស់គ្នាជាសមាជិកពិភពលោកត្រូវតែយកចិត្តទុកដាក់ចូលរួមដោះស្រាយនិងធ្វើសកម្មភាពជាបន្ទាន់ដើម្បីឱ្យពិភពលោកមានសន្តិភាព និងការអភិវឌ្ឍប្រកបដោយចីរភាព។ នៅក្នុងន័យនេះ បុគ្គលម្នាក់ៗក្នុងនាមជាសមាជិករបស់ពិភពលោកត្រូវទទួលខុសត្រូវចំពោះខ្លួនឯង ចំពោះគ្រួសារ ចំពោះសហគមន៍ដែលខ្លួនរស់នៅ និងចំពោះពិភពលោកទាំងមូល។

ដូចដែលបានលើកឡើងនៅក្នុងគោលការនៃឥរិយាបថទទួលខុសត្រូវជាសកល (CHARTER OF HUMAN RESPON - SIBILITY) បានផ្តល់និយមន័យថា៖ *ការអប់រំពលរដ្ឋសកលភ្ជាប់ដោយផ្ទាល់ទៅនឹងគោលការណ៍នៃការទទួលខុសត្រូវជាសកល ពីព្រោះវាជាឥរិយាបថទទួលខុសត្រូវដែលកំណត់ និងធ្វើឱ្យក្លាយជាពលរដ្ឋស្របច្បាប់នៃពិភពលោក។ អាស្រ័យហេតុនេះ បញ្ហានៃការទទួលខុសត្រូវរបស់គេម្នាក់ៗ គឺជាការបង្ហាញនូវសេរីភាព និងកិត្តិយសរបស់គេម្នាក់ៗក្នុងនាមជាពលរដ្ឋនៃសហគមន៍ពិភពលោក។ ការអប់រំ ពលរដ្ឋសកលបង្រៀន និងធ្វើឱ្យបុគ្គលម្នាក់ៗអាចអនុវត្តសេរីភាព និងសេចក្តីថ្លៃថ្នូររបស់គេប្រកបដោយការទទួលខុសត្រូវ។* (http://www.charter-human-responsibilities.net)

យោងតាមនិយមន័យដែលបានផ្តល់ដោយអង្គការ Oxfam បានកំណត់ភាពជាពលរដ្ឋសកលគឺជាជនទាំងឡាយណាដែលមានលក្ខណៈដូចខាងក្រោម៖

- យល់ដឹងពីពិភពលោកកាន់តែទូលំទូលាយនិងមានអារម្មណ៍ថាតួនាទីរបស់ពួកគេម្នាក់ៗគឺជាពលរដ្ឋសកល។
- គោរព និងផ្តល់តម្លៃនូវភាពចម្រុះ។
- មានការយល់ដឹងអំពីពិភពលោកធ្វើការ។
- ប្តេជ្ញាចិត្តយ៉ាងមុតមាំដើម្បីយុត្តិធម៌សង្គម។
- ចូលរួមនៅក្នុងសហគមន៍គ្រប់កម្រិតតាំងពីកម្រិតតំបន់រហូតដល់កម្រិតពិភពលោក។
- ធ្វើការជាមួយអ្នកដទៃដើម្បីធ្វើឱ្យពិភពលោកមានសមធម៌ និងជាកន្លែងដែលមានចីរភាព។
- ទទួលខុសត្រូវលើអំពើរបស់ខ្លួន។ (Oxfam GB,2015)

GCED ផ្តល់តម្លៃដល់ពលរដ្ឋពលគ្រប់រូបឱ្យទទួលបានតម្លៃ និងសិទ្ធិសេរីភាពរបស់ខ្លួន ក្នុងនាមជាពលរដ្ឋក្នុងសហគមន៍ និងពិភពលោកទាំងមូល។ ក្នុងបរិបទនេះ មនុស្សម្នាក់ៗត្រូវតែទទួលយកការទទួលខុសត្រូវរបស់ពួកគេទាំងកម្រិតបុគ្គល និងសមូហភាព ។

សមាសធាតុសំខាន់ៗដែលសត្រូវបានកំណត់ដោយ OXFAM៖

| ចំណេះដឹង និង ការយល់ដឹង | ជំនាញ | តម្លៃ និងអាកប្បកិរិយា |
|---|---|---|
| សមធម៌ និងយុត្តិធម៌សង្គម | ការត្រិះរិះពិចារណា និងការច្នៃប្រឌិត | អារម្មណ៍នៃការកំណត់អត្តសញ្ញាណ និងការគោរពខ្លួនឯង |
| អត្តសញ្ញាណ និងភាពចម្រុះ | ការយល់ចិត្ត | ការប្តេជ្ញាចិត្តចំពោះសមធម៌ និងយុត្តិធម៌សង្គម |
| ភាពឯករាជ្យ និងសកលភាវូបនីយកម្ម | ការយល់ដឹងខ្លួនឯង និងការឆ្លុះបញ្ចាំង | គោរពមនុស្សជាតិ និងសិទ្ធិមនុស្ស |
| ការអភិវឌ្ឍប្រកបដោយចីរភាព | ការទំនាក់ទំនង | ភាពចម្រុះនៃតម្លៃ |
| សន្តិភាព និងជម្លោះ | កិច្ចសហប្រតិត្តិការ និងការដោះស្រាយជម្លោះ | ក្តីបារម្ភចំពោះបរិស្ថាន និងការប្តេជ្ញាចិត្តចំពោះការអភិវឌ្ឍប្រកបដោយចីរភាព |
| សិទ្ធិមនុស្ស | សមត្ថភាពក្នុងការគ្រប់គ្រងភាពស្មុគស្មាញ និងភាពមិនច្បាស់លាស់ | ការប្តេជ្ញាចិត្តចំពោះការចូលរួម និងបរិយា បន្ន |
| អំណាច និងរដ្ឋាភិបាល | ផ្តល់ព័ត៌មាន និងសកម្មភាពឆ្លុះបញ្ចាំង | ជំនឿថា មនុស្សអាចនាំមកនូវការ ផ្លាស់ប្តូរ |

( Oxfam GB,2015 )

## ៤. តើយើងត្រូវធ្វើដូចម្តេច ដើម្បីឱ្យសិស្សក្លាយជាមនុស្សមានការទទួលខុសត្រូវប្រកបដោយសីលធម៌ ?

មានការពិភាក្សាជាច្រើនលើកឡើងអំពីអាកប្បកិរិយាសីលធម៌គឺជាឥរិយាបថផ្ទាល់ខ្លួន មិនមែន កើតចេញពីការហាត់រៀនឡើយ។ មានកត្តាជាច្រើនដែលជិះឥទ្ធិពលដល់ទស្សនៈសីលរបស់មនុស្សម្នាក់ៗដូចជាប្រវត្តិ តម្លៃ និងបទពិសោធន៍របស់ពួកគេ។ ប៉ុន្តែសិស្សអាចរៀនបានជាច្រើនទៀតអំពីអាកប្បកិរិយាសីលធម៌នៅពេលចូលរួមក្នុងការដោះស្រាយបញ្ហា (ទ្វេគ្រោះ) ដែលពួកគេជួបប្រទះនៅក្នុងថ្នាក់ ឬនៅពេលមានការដាក់កិច្ចការឱ្យ។

ផ្អែកតាមខ្លឹមសារនៃគោលបំណងខាងលើដែលតម្រូវឱ្យបញ្ជ្រាបក្នុងវិស័យទាំងបី គឺចំណេះដឹង ចិត្តសង្គម និងអាកប្បកិរិយាដែលមានន័យថាក្រោយពីរៀនចប់អ្នកសិក្សាទទួលបាន ចំណេះដឹងអំពីកម្រិតតំបន់ ជាតិ និងបញ្ហាសកលលោក ហើយពួកគេទទួលបានបទពិសោធន៍ ជាមួយនឹងអារម្មណ៍ ជាកម្មសិទ្ធិនៃមនុស្សលោក ចែករំលែកតម្លៃ និងការទទួលខុសត្រូវផ្អែកលើសិទ្ធិមនុស្ស។ បន្ទាប់មកពួកគេធ្វើសកម្ម ភាពប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវទៅតាមកម្រិតតំបន់ ថ្នាក់ជាតិ និងសកល លោកដោយសន្តិភាព និងចិរភាព។ យោងតាមប្រធានបទ និងគោលបំណងនៃការសិក្សារបស់ GCED ការបញ្ជ្រាបត្រូវបានបែងចែកជា ៤កម្រិត៖

| | |
|---|---|
| **ក. បឋមកម្រិតទាបៈ** | ពិភាក្សាអំពីជម្រើសនិងសកម្មភាពរបស់យើងដែលប៉ះពាល់ដល់មនុស្សផ្សេងទៀតនិងភពផែនដី ហើយទទួលយកអាកប្បកិរិយាប្រកបដោយទទួលខុសត្រូវ។ |
| **ខ. បឋមកម្រិតខ្ពស់ៈ** | ស្វែងយល់ពីគោលគំនិតយុត្តិធម៌សង្គមនិងទទួលខុសត្រូវសីលធម៌រៀនអំពីរបៀបអនុវត្តវានៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ |
| **គ. មធ្យមសិក្សាបឋមភូមិៈ** | វិភាគបញ្ហាប្រឈមនិងបញ្ហាដែលទាក់ទងនឹងយុត្តិធម៌សង្គម និងទំនួលខុសត្រូវសីលធម៌ ហើយពិចារណាពីផលប៉ះពាល់សម្រាប់បុគ្គល និងសកម្មភាពរួម។ |
| **ឃ. មធ្យមសិក្សាទុតិយភូមិៈ** | វាយតម្លៃបញ្ហានៃយុត្តិធម៌សង្គម និងចាត់វិធានការ ដើម្បីប្រឈម នឹងវិសមភាព និងការរើសអើង ។ ( UNESCO, 2015 ) |

ការបង្រៀនក្នុងសតវត្សទី២១នេះ ក៏ដូចជាខ្លឹមសារនៃការអប់រំពលរដ្ឋសកល គឺមានគោលបំណងធ្វើឱ្យមានការប្រែប្រួលក្នុងសហគមន៍ជាវិជ្ជមាន។ ដូចមាននៅក្នុងគោលបំណងរបស់ GCEDខាងលើ យើងមិនត្រឹមតែរៀនដើម្បីតែទទួលបានពុទ្ធិប៉ុណ្ណោះទេ ប៉ុន្តែវាត្រូវធ្វើឱ្យមានការប្រែប្រួលវិជ្ជមានខាងអារម្មណ៍ និងក្លាយជាទម្លាប់នៃឥរិយាបថល្អក្នុងនាមជាពលរដ្ឋពិភពលោក។ ហេតុនេះ ការបង្រៀន ទាមទារឱ្យគ្រូចេះប្រើប្រាស់វិធីសាស្ត្រផ្សេងៗក្នុងការបញ្ជ្រាបអោយខ្លឹមសារមេរៀន ដែលទាក់ទងទៅនឹង GCED ក្លាយជាឥរិយាបថឬលទ្ធផលប្រែប្រួលវិជ្ជមានជាក់ស្តែងនៅក្នុងសហគមន៍របស់ពួកគេ។ តើយើងធ្វើដូចម្តេចដើម្បីភ្ជាប់ទំនាក់ទំនងជាមួយពិភពពលោក ? បញ្ហាទាំងអស់នេះត្រូវការគ្រូបង្រៀនដែលសកម្មយ៉ាងខ្លាំងដើម្បីប្រែក្លាយចំណេះដឹងទាំងអស់នេះទៅជាអារម្មណ៍សង្គម និងឥរិយាបថ ។

**តើគ្រូបង្រៀនមានតួនាទីអ្វីខ្លះក្នុងការធ្វើឱ្យសម្រេចបាននូវគោលបំណងខាងលើ ?**

នៅក្នុងបរិស្ថានថ្នាក់រៀនដែលមានការចូលរួម គ្រូមានតួនាទីជាអ្នកសម្របសម្រួល គាំទ្រសិស្សនៅពេលពួកគេរៀន វាយតម្លៃកស្តុតាង ចរចារ ធ្វើការសម្រេចចិត្ត ផ្តល់ព័ត៌មាន ដោះស្រាយបញ្ហា ព្រមទាំងធ្វើការដោយឯករាជ្យ និងជាក្រុម។ នៅក្នុងបរិស្ថានថ្នាក់រៀនសកម្ម តួនាទីរបស់គ្រូ និងបរិស្ថាននៃការបង្រៀនត្រូវបានផ្លាស់ប្តូរដូចខាងក្រោមៈ

| ពី | ទៅ |
|---|---|
| ថ្នាក់រៀនផ្តោតលើគ្រូ ( គ្រូមជ្ឈមណ្ឌល ) | ថ្នាក់រៀនផ្តោតលើអ្នកសិក្សា( សិស្សមជ្ឈមណ្ឌល ) |
| ការរៀនផ្តោតលើផលិតផល | ការរៀនដែលផ្តោតទៅលើដំណើរការ |
| គ្រូជាអ្នកបញ្ជូនចំណេះដឹង | គ្រូជាអ្នករៀបចំចំណេះដឹង |
| គ្រូជាអ្នកធ្វើសម្រាប់អ្នកសិក្សា | គ្រូជាអ្នកបើក ( ធ្វើឱ្យអាច ) |
| ការផ្តោតទៅលើប្រធានបទជាក់លាក់ | ការផ្តោតសំខាន់ទៅលើការរៀន |

(A PMB, *2007)*




នៅក្នុងបរិបទនៃការរៀននិងការបង្រៀននេះដែរ ដើម្បីទទួលជោគជ័យ សិស្សក៏ត្រូវបានគេកំណត់ថាត្រូវតែជាអ្នកចូលរួមក្នុងសកម្ម ភាពសិក្សាសកម្មផងដែរ។ ខាងក្រោមនេះ ជាការផ្លាស់ប្តូររបស់សិស្សក្នុងបរិស្ថានថ្នាក់រៀនដែលមានការចូលរួមៈ

| ពី | ទៅ |
|---|---|
| អ្នកសិក្សាទទួលចំណេះដឹងអកម្ម | អ្នកសិក្សាសកម្ម និងចូលរួម |
| ការឆ្លើយសំណួរ | ការសួរសំណួរ (ឆ្ងល់) |
| ត្រូវបានគេបញ្ជាក | ទទួលខុសត្រូវលើការរៀនសូត្ររបស់ពួកគេ |
| ប្រគួតប្រជែងគ្នាទៅវិញទៅមក | សហការលើការរៀនសូត្ររបស់ពួកគេ |
| ចង់និយាយដោយគំនិតរបស់ពួកគេផ្ទាល់ | ស្តាប់យោបល់របស់អ្នកដទៃយ៉ាងសកម្ម |
| ការរៀនប្រធានបទលក្ខណៈបុគ្គល | ភ្ជាប់ទំនាក់ទំនងការសិក្សារបស់ពួកគេ |

(A PMB, *2007)*

ដើម្បីក្លាយខ្លួនជាពលរដ្ឋសកលដែលមានប្រសិទ្ធភាព អ្នកសិក្សាត្រូវមានភាពបត់បែន ការបង្កើតថ្មី និងសកម្ម។ ពួកគេត្រូវការសមត្ថភាពដែលអាចដោះស្រាយបញ្ហា សម្រេចចិត្ត គិតស៊ីជម្រៅ គំនិត ទំនាក់ ទំនងដែលមានប្រសិទ្ធភាព និងធ្វើការបានល្អជាមួយក្រុមតូច និងក្រុមធំបាន។ ជំនាញ និងឥរិយាបទទាំងនេះ ត្រូវបានស្គាល់យ៉ាងលឿននៅក្នុងការអប់រំនៅសតវត្សទី២១នេះ។ GCED នាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាន ដែលនៅក្នុងនោះអ្នកសិក្សាទទួលបានចំណេះដឹងដែលជាព័ត៌មានជម្រើស បន្ទាប់មកពួកគេចង់មានការផ្លាស់ប្តូរអ្វីៗឱ្យវិជ្ជមានដើម្បីផ្តល់សន្តិភាព និងចីរភាពសម្រាប់ពិភពលោក ដែលចាប់ផ្តើមពីខ្លួនគេផ្ទាល់ ។ GCED ផ្តល់ដល់អ្នកសិក្សានូវបំណិនដើម្បីបម្រើឱ្យបំណងទាំងនេះ។

ទោះបីជាយ៉ាងណាក៏ដោយ ការអនុវត្តការអប់រំពលរដ្ឋសកល ត្រូវបានសង្ខេបដោយប្រើពាក្យថា គោលការណ៍បីគឺ រៀន គិត ធ្វើ។ វាមានន័យថា ការជួយក្មេងៗរៀនអំពីបញ្ហា និងគិតស៊ីជម្រៅ និងរកមធ្យោបាយដើម្បីប្រើប្រាស់ការរៀនរបស់ពួកគេដោយខ្លួនឯងក្នុងអត្ថន័យ និងមធ្យោបាយត្រឹមត្រូវ។

**រៀន**

មានន័យថា ជានាឱ្យបានថាក្មេងៗ ត្រូវបាន ណែនាំអំពីបញ្ហាសកល ដើម្បីឱ្យពួកគេ អាច ទទួលបានចំណេះដឹង និងការយល់ដឹង ទូលំ ទូលាយអំពីអ្វីដែលកំពុងកើតឡើងនៅក្នុងពិភពលោក និងហេតុអ្វីវាសំខាន់។

**ធ្វើ**

មានន័យថា អនុញ្ញាតឱ្យសិស្ស យកការរៀន របស់គេឆ្ពោះទៅមុខនៅក្នុងរបៀបដែលមានប្រយោជន៍ និងមានអត្ថន័យចំពោះពួកគេ។ វាគួររាប់បញ្ចូលទាំងទំនាក់ទំនងចំណេះដឹងរបស់ពួកគេ ចំពោះអ្នកទៃ ប៉ុន្តែត្រូវគិតអំពី រឿងធ្វើសកម្មភាពដែលពួកគេ និងអ្នកដទៃ អាចទទួលយកដើម្បីជួយសម្រាលស្ថានភាពអយុត្តិធម៌សង្គម និងដើរតួយ៉ាង សកម្ម ដើម្បី ធ្វើវាទៅមុខជាបុគ្គលឬជាមួយអ្នកដទៃ។

**គិត**

មានន័យថា ត្រូវជួយក្មេងៗទទួលយកការរៀនដែលលើសពីសើៗ និងត្រូវការការគិតស៊ីជម្រៅ រកមូលហេតុឬសគល់នៃបញ្ហា ធ្វើការប្រៀបធៀបពីប្រវត្តិ និងតំបន់ គិតអំពី សង្គម ភាពសម្បៀង និងគិតផងដែរ អំពីតើ ដំណោះស្រាយណាមួយដែលអាចកើត មានឡើង។

( Schools for future youth, 2014)

ឧទាហរណ៍ខាងក្រោមបង្ហាញអំពីការបង្រៀនអំពីទឹក

**វាយតម្លៃការរៀន**

កំណត់ហេតុនៃការរៀនប្រចាំថ្ងៃត្រូវបានរក្សាទុកដោយសិស្ស ពេញមេរៀនទាំងមូលជួយពួកគេដើម្បីវាយតម្លៃការសិក្សារបស់គេផ្ទាល់ និងឥទ្ធិពលរបស់វាទៅលើឥរិយាបថចំពោះការប្រើប្រាស់ទឹក។

**សួរសំណួរ**

ប្រើរូបភាព ឬវត្ថុជម្រុញផ្សេងទៀត ដើម្បីលើកឡើងសំណួរ។ ឧ៖ តើយើងប្រើប្រាស់ទឹកសម្រាប់ធ្វើអ្វីខ្លះ? តើវាមករកយើងដោយរបៀបណា? តើមានអ្វីកើតឡើងចំពោះទឹកដែលយើងប្រើប្រាស់? តើនរណាជាម្ចាស់ទឹក? ហេតុអ្វីបានជាមនុស្សខ្វះទឹកស្អាតប្រើប្រាស់? តើទឹកកខ្វក់មានផលវិបាកអ្វីខ្លះ ?

**ការឆ្លើយតបជាពលរដ្ឋសកលសកម្ម**

- ចងចាំតម្រូវការដើម្បីសន្សំទឹកជាធនធានមួយមានតម្លៃ
- អនុវត្តការត្រួតពិនិត្យទឹកនៅផ្ទះនិងនៅសាលា
- គិតទៅដល់អ្វីដែលត្រូវធ្វើដើម្បីប្រើប្រាស់ទឹកប្រកបដោយសមធម៌ និងចិរភាព
- បញ្ចុះបញ្ចូលអ្នកនយោបាយជុំវិញតម្រូវការកាត់ បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ និងជម្រុញសហគន៍ និងប្រទេសដែលងាយរងគ្រោះសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ។
- ចាប់ផ្តើមកាត់បន្ថយការបញ្ចេញចោលទាំងនៅសាលា និងនៅផ្ទះ។

**ទឹក**

**ធ្វើឱ្យមានការជាប់ទាក់ទង**

- គ្រប់គ្នាមានសិទ្ធិសម្អាតទឹក
- ទឹកធម្មតាត្រូវការប្រើប្រាស់ជុំវិញពិភពលោក
- វដ្តរបស់ទឹកជាឧទាហរណ៍មួយនៃការអាស្រ័យគ្នា ទៅវិញទៅមកនៃពិភពលោក
- គ្រោះរាំងស្ងួត និងជំនន់៖ មូលហេតុ និងឥទ្ធិពល របស់វានៅក្នុងផ្នែកផ្សេងៗនៃពិភពលោក។ តើ ពួក វាអាចមានទំនាក់ទំនងទៅនឹងអ្វីដែលកើតឡើងដ៏វែងឆ្ងាយយ៉ាងដូចម្តេច? (ឧទាហរណ៍៖ តាមរយៈ ការ ប្រែប្រួល អាកាសធាតុ)
- ទំនាក់ទំនងរវាងទឹក សុខភាព និងភាពក្រីក្រ

**ការរុករកទស្សនៈ និងតម្លៃ**

- របៀបដែលមនុស្សទទួលបានតម្រូវការទឹកជាមូលដ្ឋានផ្សេងៗគ្នា
- ទស្សនៈផ្សេងៗអំពីតម្រូវការនៅក្នុងប្រទេស និងប្រទេសដទៃទៀត
- តួនាទីរបស់ទឹកនៅក្នុងជីវិតរបស់បុរស និងស្ត្រី ក្មេងប្រុស និងក្មេងស្រី និង របៀបលក្ខណៈពិសេសរបស់វាក្នុងទំនាក់មិនស្មើភាពរវាងភេទ
- វប្បធម៌ និងសាសនាចំពោះឥរិយាបថនៃការប្រើប្រាស់ទឹក
- ទស្សនៈផ្សេងៗចំពោះការកាន់កាប់ទឹក (ឧ៖ ថាប្រទេស Wales

(Oxfam GB, 2015)

## ៥. សន្និដ្ឋាន

ការអប់រំពលរដ្ឋសកលជាប្រធានបទដ៏សំខាន់មួយដែលគ្រប់ថ្នាក់ដឹកនាំនយោបាយ និងប្រតិបត្តិករ ត្រូវតែចូលរួមធ្វើ ដើម្បីឱ្យពិភពលោកមានសន្តិភាព និងការអភិវឌ្ឍប្រកបដោយចីរភាព។ ពីព្រោះយើងរស់នៅលើផែនដីនេះ ត្រូវមានការទទួលខុសត្រូវទាំងសង្គម សេដ្ឋកិច្ច និងបរិស្ថាន ដើម្បីជាប្រយោជន៍សម្រាប់ជំនាន់ក្រោយ។ នៅក្នុងបរិបទនេះ គ្រូបង្រៀនមានភារកិច្ចសំខាន់ជាងគេក្នុងការបញ្ជ្រាបការអប់រំពលរដ្ឋសកលដល់សិស្សានុសិស្សរបស់ខ្លួន។ គ្រូបង្រៀនត្រូវមានការប៉ិនប្រសព្វក្នុងការប្រែក្លាយចំណេះដឹងដែលមានការត្រិះរិះពិចារណាអំពីបញ្ហាតាំងពីថ្នាក់មូលដ្ឋាន ជាតិ តំបន់ និងសកលលោកឱ្យក្លាយជាចិត្តសង្គមដែលអ្នកសិក្សាជិតជាប់ជាមួយនឹងអារម្មណ៍ថាខ្លួនជាផ្នែក១នៃមនុស្សទូទៅ ដោយចែករំលែកនូវតម្លៃការទទួលខុសត្រូវ សេចក្តីអាណិតអាសូរ សាមគ្គីភាព និងអាចប្រែក្លាយអាកប្បកិរិយាដោយធ្វើសកម្មភាពប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវ ចាប់ពីថ្នាក់មូលដ្ឋានរហូតដល់កម្រិតពិភពលោក ។

សរុបសេចក្តីមក គ្រូបង្រៀនត្រូវធ្វើឱ្យមានការប្រែប្រួលជាវិជ្ជមានអំពីចំណេះដឹងអំពីពិភពលោក អារម្មណ៍នៃការស្រឡាញ់មនុស្សជាតិ មានស្មារតីការពារថែរក្សាពិភពលោក គោរពសិទ្ធិអ្នកដទៃ ការពារ យុត្តិធម៌ មានការទទួលខុសត្រូវប្រកបដោយសីលធម៌។ ជាពិសេស អ្នកសិក្សាត្រូវបានគេមើលឃើញថា មានប្រែប្រួលជាវិជ្ជមាននៅក្នុងសង្គមជាក់ស្តែងដែលកើតចេញពីរបៀបបញ្ជ្រាបរបស់គ្រូក្នុងសតវត្សទី២១នេះ។ ជាពិសេស គ្រូមិនត្រឹមតែផ្តល់ចំណេះដឹងដល់សិស្សប៉ុណ្ណោះទេ គ្រូត្រូវធ្វើឱ្យអ្នកសិក្សាគិតឱ្យកាន់តែស៊ីជម្រៅស្វែងរកហេតុផល គុណសម្បត្តិ និងគុណវិបត្តិរបស់អំពីអំពើរបស់ខ្លួនក្នុង ការទំនាក់ទំនងជាមួយអ្នកទៃនិងពិភពលោក និងធ្វើរឿងដែលមានប្រយោជន៍ចំពោះខ្លួនឯង អ្នកដទៃ និងពិភពលោកទាំងមូលដូចជាហ៊ានជួយការពារយុត្តិធម៌សង្គម ការពារសិទ្ធិពីការរំលោភបំពានជាដើម (រៀន គិត ធ្វើ)។

# គន្ធនិទ្ទេស


## ក. ឯកសារជាភាសាខ្មែរ

- ជួន ណាត. (១៩៦៧). *វចនានុក្រមខ្មែរ ភាគ១ ភាគ២, ភ្នំពេញ៖ ការផ្សាយរបស់*វិទ្យាស្ថានពុទ្ធ សាសនបណ្ឌិត, បោះពុម្ពលើកទី៥.
- ក្រសួងអប់រំ យុវជន និងកីឡា. (២០១៧). សៀវភៅសិក្សាគោល សីលធម៌ពលរដ្ឋវិជ្ជាថ្នាក់ទី១២. ភ្នំពេញ

## ខ. ឯកសារជាភាសាអង់គ្លេស

- DocJonathan P. Latimer (2000). The American Heritage® Dictionary of the English Language, 3th edit. USA.
- Oxfam GB (2015). **Education for Global Citizenship**: A guide for schools.
- UNESCO (2015). **Global Citizenship Education: Topics and Learning Objectives.**
- Schools for future youth (2014). **Global Citizenship Education Framework.**
- Oxfam GB (2015). **Global Citizenship in the classroom: A guide for teachers.**
- A PMB (2007). **Active Learning and Teaching Methods for Key Stage 3.**
- Crebert, G., Patrick, C.-J., Cragnolini, V., Smith, C., Worsfold, K., & Webb, F. (2011). **Ethical Behavior and Social Responsibility Toolkit.** $2^{nd}$ Edition. Griffith University. (Retrieved from the World Wide Web 4th April, 2011). - http://www.griffith.edu.au/gihe/resources-support/graduate-attributes.

# មេរៀនទី៩៖
# ប្រសិទ្ធភាពនៃការធ្វើការងារជាក្រុម

**GETTING ENGAGED AND TAKING ACTION**

( Ms. Bun Sophanny, Mr. Prak Peau, and Dr. Moeun Linna )

## ១. តើអ្វីជាប្រសិទ្ធភាពនៃការធ្វើការជាក្រុម?

ប្រសិទ្ធភាពការងារជាក្រុម គឺជាកិច្ចការដែលត្រូវធ្វើដោយក្រុមឱ្យទទួលបានភាពជោគជ័យ និងសេចក្តីសម្រេចតាមគោលបំណងនីមួយៗ។ ទន្ទឹមនឹងនេះដែរ ការងារជាក្រុម គឺជាវិធីសាស្ត្រមួយដ៏មានប្រសិទ្ធភាពក្នុងការជំរុញសកម្មភាពសិក្សា លើកទឹកចិត្ត អភិវឌ្ឍការគិតតាមបែបស៊ីជម្រៅការប្រាស្រ័យទាក់ទង និងហ៊ានក្នុងការធ្វើការសម្រេចចិត្តរបស់សិស្សានុសិស្សថែមទៀតផង។ ម្យ៉ាងទៀត ចំពោះកិច្ចការដែលត្រូវធ្វើជាក្រុមគឺទាមទារឱ្យសមាជិកក្នុងក្រុមទាំងឡាយចូលរួមសហការ ព្រមទាំងមានការយោគយល់រវាងគ្នានិងគ្នា ពោលគឺពីសមាជិកម្នាក់ទៅម្នាក់ទៀត។ លើសពីនេះទៀត វាក៏តម្រូវជាចាំបាច់ឱ្យមានការគ្រប់គ្រងក្រុមប្រកដោយភាពទំនួលខុសត្រូវខ្ពស់ផងដែរ។

អាល់បឺត អាញស្តាញទទួលបានកិត្តិយយ៉ាងខ្លាំងដោយការរកឃើញ**រីឡាទីវិតេ** ប៉ុន្តែតាមជាតុពិតនោះ ចំពោះរបកគំហើញគាត់ ពោលគឺបានពឹងផ្អែកលើការពិភាក្សាជាមួយនឹងមិត្តកិត្តិគាត់ ព្រមទាំងសហេសេវិតា (គឺជាមនុស្សដែលធ្វើការជាមួយគ្នាឬក្រុមជាមួយគ្នា យើងអាចហៅម្យ៉ាងទៀតថាសហការីក៏បាន) របស់គាត់ផងដែរ។ បន្ទាប់ពីគាត់បានទទួលការកែលម្អពីប្រភពផ្សេង គាត់បានដាំស្លនូវបញ្ញត្តិ គាត់ឱ្យបានកាន់តែប្រសើរឡើងថែមទៀត ។ ទន្ទឹមនឹងនេះដែរ លោកមួហ្វីបាននិយាយថានៅពីក្រោយភាពជោគជ័យទាំងអស់គឺជាក្រុមមួយ។ ម្យ៉ាងទៀត នៅពេលដែលមនុស្សមានជំនាញ ទេពកោសល្យ និងចំណេះដឹងដោយឡែកៗពីគ្នាធ្វើការជាក្រុមមួយ ពួកគេអាចបង្កើតដំណោះស្រាយដែលមានប្រយោជន៍ និងជាក់ស្តែងទៀតផង។ ក្រៅពីនេះ ប្រសិនបើយោងទៅលើលោក ហ្វ្រាន់ ចូហាន់សុន ដែលជាអ្នកនិពន្ធអំពី Medicine Effect បានផងដែរនិយាយថាគំនិតនវានុវត្តច្រើនបំផុតកើតឡើងនៅឯចំណុចប្រសព្វ ពោលគឺជាចំណុចដែលគំនិតមកពីមនុស្សផ្សេងៗប្រទេះគ្នាទៅវិញទៅមក។

ដូច្នេះ ការធ្វើការងារជាក្រុម គឺវិធីសាស្ត្រដ៏មានប្រសិទ្ធភាពបំផុតមួយក្នុងចំណោមវិធីសាស្ត្រទាំងឡាយ ដែលផ្តល់សារៈសំខាន់ និងផលប្រយោជន៍ជាច្រើនដល់សិស្សានុសិស្សក្នុងការយកទៅអនុវត្តក្នុងថ្នាក់រៀនដើម្បីជួយពួកគាត់ឱ្យកាន់តែមានសមត្ថភាព ភាពប៉ិនប្រសព្វ និងមានទំនុកចិត្តលើខ្លួន។ លើសពីនេះទៀត ពួកគេអាចទទួលបាននិង

មានបញ្ញត្តិមូលដ្ឋាន អំពីរបៀបក្នុងការសេម្រប និងរស់នៅក្នុងសហគមន៍និងផ្សេងៗទៀតផង។ សរុបមក នេះគឺជាវិធីសាស្ត្រតម្រង់ទិសសិស្សានុសិស្សឱ្យទទួលបានភាពជោគជ័យនាថ្ងៃអនាគតទាំងក្នុងសាលានិងសង្គម។

## ២. និយមន័យនៃពាក្យគន្លឹះ

**ប្រសិទ្ធភាព** គឺជាពាក្យដែលផ្សំមកពី "ប្រសិទ្ធ" និង "ភាព" ដែលប្រសិទ្ធមានន័យថាធ្វើឲ្យសម្រេច, ធ្វើឲ្យ ពូកែ; ធ្វើឲ្យមានស្រីសួស្តីជោគជ័យ រីឯ ភាព មានន័យថា ភាវៈ; បែប, បែបបទ; លំនាំ, លំនាំសមសា, ឫកពា; ទម្រង់, សណ្ឋាន, ទ្រង់ទ្រាយ។[26] ដូចនេះ ប្រសិទ្ធភាពមានន័យថា បែបបទឬក៏លំនាំនៃការធ្វើឱ្យអ្វី មួយឱ្យបានសម្រេច។ ឧទាហរណ៍ *កសិករងាកមកប្រើប្រាស់ជាជម្មជាតិសម្រាប់ដំណាំ ព្រោះវាទទួលបាន ប្រសិទ្ធភាពខ្ពស់ និងមិនធ្វើឱ្យប៉ះដល់សុខភាពអ្នកបរិភោគ។* **ការងារ** មានន័យថាគឺជាកិច្ចដែលត្រូវធ្វើទៅតាមមុខងាររៀងខ្លួន តាមការចាត់តាំង និងប្រគល់ជូន[27]។ ឧទាហរណ៍ *កម្មកររោងចក្រប្រឹងប្រែងធ្វើការងារថែមម៉ោងដើម្បីទទួលបានប្រាក់បន្ថែម។* **ក្រុម** គឺសំដៅដល់លំដាប់; ប៉ែកដោយតំណែង, ដោយមុខ, ដោយសង្កាត់, ដោយពួក[28]។ ឧទាហរណ៍ *សិស្សចែកក្រុមពិភាក្សាកិច្ចការសាលា។*

ដូច្នេះ បើយោងទៅលើនិយមន័យនៃពាក្យនីមួយៗខាងលើ យើងអាចសន្និដ្ឋានបានថា ប្រសិទ្ធភាពការងារជាក្រុមគឺជាលំនាំ ឬបែបបទនៃការធ្វើការងារអ្វីមួយឱ្យបានជោគជ័យដោយក្រុម ឬពួក។

## ៣. ការអនុវត្តការងារជាក្រុមនៅក្នុងថ្នាក់រៀន

**៣.១. ដំណើរការនៃរៀបចំក្រុមនីមួយៗ៖** ដំណើរការនៃការរៀបចំក្រុមគឺជាដំណើរការដំបូងនៃចាប់ផ្តើមការងារជាក្រុម។ ហេតុដូចនេះ ចូរអ្នកព្យាយាមគិតឱ្យបានច្បាស់លះអំពីរបៀបដែលសិស្សនឹងត្រូវបានរៀបចំទៅក្នុងក្រុមនីមួយៗ។ ម្យ៉ាងទៀត តើវាមានភាពងាយស្រួលសម្រាប់ក្រុមដែលបានបង្កើតឡើងនិងសម្រាប់សិស្សទាំងអស់ដើម្បីឱ្យពួកគេទទួលអារម្មណ៍ល្អក្នុងក្រុមឬទេ?លើស ពីនេះទៀត អ្នកក៏ត្រូវតែគិតអំពីប្លង់ថ្នាក់រៀនរបស់អ្នកថាតើនឹងមានផលប៉ះពាល់ដល់ចំនួនក្រុមឬទេ។ យើងត្រូវគិតផងដែរ ថាតើសិស្សម្នាក់អាចស្តាប់ឮសិស្សម្នាក់ទៀតបានច្បាស់ទេ?ទន្ទឹមនឹងនេះដែរ តើអ្នកអាចគ្រប់គ្រងសកម្មភានៃក្រុមនីមួយៗដោយរបៀបណាដើម្បីរក្សាកម្រិតសំឡេងពួកគេនោះ?

---

[26] វចនានុក្រមភាសាខ្មែរ បោះពុម្ពគ្រាទី៥ ឆ្នាំ១៩៦៧

[27] វចនានុក្រមភាសាខ្មែរ បោះពុម្ពគ្រាទី៥ ឆ្នាំ១៩៦៧

[28] វចនានុក្រមភាសាខ្មែរ បោះពុម្ពគ្រាទី៥ ឆ្នាំ១៩៦៧

យើងត្រូវយកចិត្តទុកដាក់ទៅលើជំនាញ និងភាពដោយឡែកៗរវាងគ្នា និងគ្នា នៅក្នុងចំណោមសិស្សទាំងឡាយ ព្រោះជាការផ្តល់តម្លៃនិងគោរពដល់ពួកគេ ព្រមទាំងបង្កើតបានបរិយាកាសបរិយាបន្ននៅក្នុងក្រុមទៀតផង។ មួយយ៉ាងវិញទៀតយើងសាកសួរសិស្សអំពីបទពិសោធកិច្ចការជាក្រុមដែលពួកគេធ្លាប់ឆ្លងកាត់ ហើយណែនាំឱ្យពួកគេបង្កើតវិន័យមូលដ្ឋានសម្រាប់ក្រុមដើម្បីឱ្យក្រុមពួកគេទទួលបាននូវភាពជោគជ័យនៅពេលដំណើរការក្រុម។

**៣.២. ការរៀបចំសកម្មភាពក្រុមនីមួយៗ៖** ជាដំបូងគឺត្រូវកំណត់នូវគោលបំណងសម្រាប់ការអប់រំ ពោលគឺត្រូវកំណត់ថាតើអ្វីដែលយើងចង់ឱ្យបានសម្រេចតាមរយៈសកម្មភាពក្រុមនីមួយៗ រួមទាំងការសិក្សា (ឧ៖ ចំណេះដឹងអំប្រធានបទដែលពួកគេត្រូវជ្រើសរើសសម្រាប់ក្រុម? និងសង្គម (ឧ៖ គឺសមត្ថភាពស្តាប់របស់ពួកគេ)។ ចំពោះសម្មភាពគួរតែទាក់ទងទៅនឹងគោលបំណងនិងខ្លឹមសារមេរៀន ហើយត្រូវរៀចំដើម្បីជួយសិស្សឱ្យបានរៀនសូត្រផងដែរ ពោលគឺមិនមែនរៀបចំដើម្បីតែបង្គ្រប់កិច្ចនៃពេលវេលានោះទេ។ នៅក្នុងន័យនេះ រ៉ូប៊ីសុននិងហ្វ្រាន់ឈីនី (២០១៤) បានលើកឡើងថា សម្រាប់រៀនជាក្រុមគឺមានប្រសិទ្ធភាពណាស់ ហើយសិស្សត្រូវយល់ឱ្យបានច្បាស់ថាតើកិច្ចការឬការងារជាក្រុមគឺសំដៅទៅលើគោលដៅនៃការសិក្សានិងទិសគំនិតប្រកដដោយសុភវិនិច្ឆ័យ។ នៅពេលដែលយើងយល់ថា យើងគួរតែប្រើប្រាស់ការងារជាក្រុមសម្រាប់កិច្ចការ ពោលគឺយើងគួរតែពិចារណារាល់សំណួរទាំងឡាយនេះសិន៖

១. តើគោលបំណងនៃ សកម្មភាពគឺជាអ្វី?
២. តើគោលបំណងនោះនឹងត្រូវបន្តដោយឱ្យសិស្សធ្វើការងារជាក្រុមដោយរបៀបណា?
៣. តើការងារពិតជាពិបាកដែលតម្រូវឱ្យសិស្សធ្វើការងារជាក្រុមឬទេ?
៤. តើខ្លឹមសារមេរៀនេះ ទាមទារឱ្យធ្វើការងារជាក្រុមមែនឬទេ?
៥. តើអ្នកមានហេតុផលបែបណាខ្លះ ដែលកិច្ចកាមិនត្រូវធ្វើការ ងារជាក្រុមនោះ?

ផ្សេងពីនេះទៀត ប្រសិនបើកិច្ចការមានភាពប្រឈមខ្លាំង យើងគួរតែដាក់កិច្ចការស្រួលមុនដើម្បីឱ្យសិស្សមានការចាប់អារម្មណ៍នៅក្នុងការធ្វើការងារជាក្រុម ពោលគឺក្នុងន័យព្យាយាមលើកទឹកចិត្តដល់ដំណើរការក្រុមរបស់ពួកគេ។ ចំពោះការងារជាក្រុមគួរតែបំផុសនិងជំរុញ ព្រមទាំងឱ្យមានសកម្មភាពប្រកួត ប្រជែងគ្នាក្នុងក្រុមនិងជាមួយនឹងក្រុមដទៃផងដែរ។ លើសពីនេះទៀត ការប្រមូលគំនិត យើងប្រាកដណាស់នឹងទទួលបានមតិយោបល់ផ្សេងៗគ្នា។ ដូច្នេះនេះសបញ្ជាក់ថា សិស្សានុសិស្សបានបង្កើតគំនិតល្អៗជាងអ្វីដែលពួកគេបំពេញកិច្ចការម្នាក់ឯង។

ចំពោះការរៀនចំកិច្ចការជាក្រុមនេះទៀតសោធគឺត្រូវតែឱ្យមានធាតុចូលដូចជាការលើកទឹកចិត្ត ការសហការ ភាពឯករាជ្យ ហើយការបែងចែកកិច្ចការក៏គួរតែឱ្យមានលក្ខណៈសមធម៌ផងដែរ។ រាល់សមាជិកក្រុមទាំងអស់ត្រូវតែមានការទទួលខុសខ្ពស់សម្រាប់ឱ្យក្រុមពួកគេទទួលបានជោគជ័យ ដោយត្រូវមានគំនិតថាភាពជោគជ័យរបស់គេម្នាក់ៗគឺអាស្រ័យលើក្រុមទាំងមូល។ម្យ៉ាងទៀត នៅពេលដែលអ្នកកំពុង និងទទួលអារម្មណ៍ថាមិត្តភក្តិអ្នកពឹងផ្អែកលើកអ្នកពោលគឺកុំមានការអន់ចិត្ត ពីព្រោះនេះគឺជាការលើកទឹកចិត្តដ៏មានប្រសិទ្ធភាពបំផុតចំពោះការងារជាក្រុម។ ចំណែកឯការសម្រេចចិត្តទៅលើទំហំនៃក្រុមគឺជាគោលការណ៍ដ៏សំខាន់ណាស់។ ហេតុដូចនេះ ទំហំក្រុមដែលអ្នកបានរើសគឺអាស្រ័យចំនួនសិស្សនៅក្នុងថ្នាក់ ហើយការធ្វើការសម្រេចចិត្ត ពីរបៀបដែល អ្នកបែងចែកសិស្សទៅតាមក្រុមនីមួយៗគឺធ្វើឡើយដោយការតម្រូវនិងការស្ម័គ្រចិត្តរបស់សិស្សផងដែរ។

យើងត្រូវផ្តល់ពេលវេលាឱ្យបានគ្រប់គ្រាន់សម្រាប់ការងារជាក្រុម ពីព្រោះមិនអាចក្តោបខ្លឹមសារមេរៀនតាមតែអ្នកចង់បាននោះទេ ប្រសិនបើអ្នកបង្រៀនពេញមួយម៉ោងនោះ។ (ឧ.មួយមេរៀន អ្នកត្រូវបង្រៀនមួយម៉ោង។) ដូច្នេះ អ្នកគួរតែកាត់បន្ថយម៉ោងបង្រៀនអ្នកខ្លះ ដើម្បីឱ្យផ្តល់វេលាសម្រាប់សិស្សធ្វើការងារជាក្រុម។ ទន្ទឹមនឹងនេះដែរអ្នកក៏គួរតែព្យាករណ៍ពីពេលវេលាថាតើប្រធានបទនៃក្រុមនីមួយៗត្រូវការពេលវេលាប៉ុន្មានសម្រាប់បញ្ចប់កិច្ចការ ។ លើសពីនេះទៀត យើងក៏គួរតែទុកពេលវេលា សម្រាប់ក្រុមនីមួយធ្វើបទបង្ហាញចំពោះលទ្ធផលពួកគេផងដែរ។

**៣.៣. ការណែនាំពីសកម្មភាពក្រុម៖** ជាដំបូងអ្នកត្រូវប្រាប់ពីមូលហេតុនៃការធ្វើការងារជាក្រុម (ចំពោះលោកគ្រូ អ្នកគ្រូ)។ ចូរកុំគិតថា សិស្សដឹងថាអ្វីគឺជាគោលបំណងនៃវិធីសាស្ត្របង្រៀន។ ដូច្នេះ ចូរភ្ជាប់សកម្មភាពទាំងនេះទៅខ្លឹមសារនៃមេរៀនសម្រាប់ថ្នាក់និងលទ្ធផលនៃការសិក្សារបស់សិស្ស។ សិស្សត្រូវតែយល់ឱ្យបានច្បាស់ពីគោលបណងនិងសារប្រយោជន៍ក្នុងការរៀនធ្វើការជាក្រុម។

សូមឱ្យសិស្សបង្កើតជាក្រុមការងារឱ្យបានមុនពេលលោកគ្រូ អ្នកគ្រូផ្តល់ការណែនាំដល់ពួកគេ។ ប្រសិនបើជាអ្នកព្យាយាមផ្តល់ការណែនាំដល់ពួកគេជាមុន សិស្សឬសមាជិក្រុមនីមួយៗ មិនសូវស្តាប់ការ ណែនាំរបស់អ្នកនោះទេ ព្រោះពួកគេរវល់តែជាមួយនឹងការជ្រើសរើសសមាជិកក្រុមរបស់ពួកគេ។ ក្នុងករណីដែលអ្នកលោកគ្រូ អ្នកគ្រូយល់ថាទម្រង់ក្រុមពួកគេមានបញ្ហាប្រឈម លោកគ្រូអ្នកគ្រូត្រូវតែសម្រប សម្រួលដល់ទម្រង់ក្រុមដែលសិស្សានុ សិស្សបានជ្រើសរើស ពីព្រោះពួកគេនឹងសម្រេចការងារជាមួយគ្នាបានល្អប្រសិន បើពួកគេស្គាល់ឬជឿជាក់គ្នាទៅវិញទៅមកនោះ។ បន្ទាប់មកទៀត ចំពោះសកម្មភាពជាក្រុម មុនដំបូងនេះគឺត្រូវឱ្យសិស្សណែនាំខ្លួនពួកគេទៅក្នុងក្រុមពួកគេ

និងផ្សេងៗ។ ម្យ៉ាងទៀត ប្រសិនបើការងារជាក្រុមមានរយៈពេលយូរគួរសម អ្នកអាចឱ្យពួកធ្វើសកម្មភាព និងបែងចែកក្រុមធំជាក្រុមតូចៗ តទៀត ដើម្បីកសាងនូវខ្លឹមសារនៃប្រធានឱ្យបានកាន់តែល្អ។

ក្រោយពីសម្មភាពខាងលើសមស្រប និងមានលក្ខណៈសមធម៌ហើយសូមពន្យល់រាល់កិច្ចការឱ្យបានច្បាស់លាស់ទៅកាន់ក្រុមនៅនីមួយៗ។ ចំពោះសេចក្តីពន្យល់គឺត្រូវពន្យល់ពីលទ្ធផលចុងដែលយើងបាន ព្រោះវាមានសារៈសំខាន់ខ្លាំងបំផុត។ វិធីសាស្រ្តពន្យល់ណែនាំគឺអ្នកអាចធ្វើបានតាមរយៈការសរសេរអក្សរនៅលើក្តារខៀន និងរូបភាព។

ចំពោះសកម្មភាពបន្ទាប់មកទៀត អ្នកអាចបង្កើតវិន័យសម្រាប់ក្រុមនីមួយៗ ព្រមទាំងវិសាលភាព ពេលវេលារបស់ក្រុមផងដែរ ពោលគឺក្នុងន័យដើម្បីបង្កើតពីរបៀបដែលសមាជិកក្រុមធ្វើការជាមួយគ្នា ប្រកបដោយសេចក្តីគោរព និងការផ្តល់តម្លៃចំពោះសមាជិកក្រុម។

ជាចុងក្រោយ សូមអនុញ្ញាតិឱ្យសិស្សសួរសំណួរ។ ទោះបីជាអ្នកជឿជាក់លើការណែនាំរបស់ថាបានល្អយ៉ាងណាក៏ដោយក៏សិស្សគួរតែមានសំណួរអំពីសកម្មភាពផងដែរ។ ដូច្នេះ យើងអាចផ្តល់ពេលវេលាដល់ពួកគេដើម្បីសួរសំណួរមុនពេលចាប់ផ្តើមកិច្ចការ។

**៣.៤. តួនាទីក្នុងការត្រួតពិនិត្យក្រុម៖** ចំពោះការជ្រើសរើសប្រធានក្រុមគឺជាការគ្រប់គ្រងលើក្រុម ពោលគឺមិនមែនជាដាក់សម្ពាធពីលើនោះទេ។ នៅពេលដែលសិស្សកំពុងធ្វើការងារពួកគេ សូមចែកពួកគេជាក្រុម ហើយឆ្លើយនឹងសំណួរដែលមាន។ លើសពីនេះទៀត យើងក៏ត្រូវស្តាប់ពីនិន្នាការពីការពិភាក្សាគ្នារបស់សិស្សានុសិស្សផងដែរ។ ហេតុអីចាំបាច់ធ្វើដូច្នេះ? ពីព្រោះក្នុងគោលបំណងដើម្បីជួយតម្រង់ទិសពួកគេទៅលើទៅប្រធានដែលបាន និងកំពុងពិភាក្សា។ អ្នកត្រូវជៀសវាងការជ្រៀតជ្រែតក្នុងការការងារក្រុមពួកគេ ពោលគឺត្រូវទុកពេលសម្រាប់ពួកគេដោយខ្លួនពួកគេនៅពេលដែលជួបបញ្ហា។ ជាការល្អប្រសិនបើ អ្នកអាចចាក ចេញពីថ្នាក់រយៈពេលខ្លីនោះ ពីព្រោះវត្តមានអ្នកនឹងអាចធ្វើឱ្យអ្នកសិស្សមិនសូវនឹងហ៊ានបញ្ចេញយោបល់ពួកគេ។

ចូររំពឹងពីសិស្សរបស់អ្នកឱ្យបានច្រើន ដើម្បីឱ្យពួកគេមានភាពក្លាហានថែមទៀត។ ទន្ទឹមនឹងនេះដែរ សូមបង្ហាញសេចក្តីជឿជាក់ទៅលើពួកគេថាពួកគេធ្វើបាន និងមានធ្វើដោយទំនួលខុសត្រូវខ្ពស់បំផុត។ ក្រៅពីនេះ សូមកុំបង្ហាញអ្វីដែលអ្នកដឹងដល់ពួកគេលឿនពេក នៅក្នុងករណីដែលអ្នកមកត្រួតពិនិត្យក្រុមនីមួយៗកំពុងពិភាក្សា ហើយទទួល

អារម្មណ៍ថា ពួកគេកំពុងជួបប្រទះ នឹងភាពមិនច្បាស់លាស់ ឬការខ្វែងគំនិតគ្នា ពេលគឺត្រូវជៀវាងទំនោរនៃការផ្តល់ចម្លើយឬដោះស្រាយការខ្វែងគំនិតគ្នាជាដាច់ខាត។

ជាចុងក្រោយ សូមបញ្ជាក់តួនាទីរបស់អ្នកដល់សិស្សានុសិស្ស ពេលគឺយើងត្រឹមតែជាអ្នកសម្របសម្រួលប៉ុណ្ណោះ។ ប្រសិនបើសិស្សរិះគន់អ្នកថា មិនបានជួយអ្វីទាល់តែសោះ ចំពោះកិច្ចការពួកគេ ពេលគឺអ្នកត្រូវតែពន្យល់ដល់ពួកគេថា អ្នកគ្រាន់តែជាអ្នកឃ្លាំមើលពួកគេនោះទេ ដោយគ្មានសិទ្ធិក្នុងការផ្តល់ចម្លើយឡើយ។

**៣.៥. ចុងបញ្ចប់នៃក្រុមកិច្ចការៈ** មុនដំបូង ត្រូវផ្តល់ដំណឹងដល់ក្រុមនូវពេលវេលាក្នុងការបញ្ចប់សកម្មភាពពិភាក្សាក្រុមឱ្យទាន់ពេលវេលាដែលបានកំណត់។ ហេតុអ្វីបានជាយើងចាំបាច់ធ្វើដូច្នេះ? ក៏ព្រោះសិស្សក៏ចង់ឃើញពីលទ្ធផលនៃក្រុមពួកគេនិងក្រុមផ្សេងៗផងដែរ។ បន្ទាប់មកអ្នកអាចបញ្ចប់ដោយឱ្យក្រុមឡើងធ្វើរាយការណ៍ក្នុងមួយក្រុម។ ចំពោះការរាយការណ៍របស់ក្រុមនីមួយៗ គឺអាចធ្វើបានតាមរយៈការរាយការណ៍ដោយផ្ទាល់ឬក៏សំណេរជាលាយល័ក្ខអក្សរ។ បន្ទាប់មកទៀត លោកគ្រូ អ្នកគ្រូត្រូវកំណត់ពីគំរូ ដែលចង់ឱ្យសិស្សចូលរួម ព្រោះនៅពេលដែលសិស្សឆ្លើយសំណួរ គឺត្រូវសិស្សត្រូវប្រកាន់ខ្ជាប់នូវ ក្រមសីលធម៌ដែលគ្រូ ចង់បានសម្រាប់មិត្តរួមថ្នាក់ពួកគេ។ ម្យ៉ាងទៀត យើងក៏ត្រូវត្រៀមខ្លួនចម្លើយ និងទទួលយកគំនិតផ្សេងៗគ្នារបស់សិស្សផងដែរ។ តែយ៉ាងណាក៏ដោយសូមកុំឱ្យខ្លឹមសារជៀសឆ្ងាយពីគ្គីរំពឹងទុក ព្រោះយើងត្រូវភ្ជាប់គំនិតយោបល់ទៅនឹងខ្លឹមសារនិងគោលបំណងនៃប្រធាននីមួយៗ។ ប្រសិនបើគំនិតដែលទទួលបានពីសិស្សប្រាកដជាខុសគ្នា អ្នកត្រូវតែក្តោបឱ្យបានថាតើចម្លើយណាត្រូវនិងខុស ហើយធាប់កែតម្រូវ តាមតែធ្វើទៅបាន។ ទន្ទឹមនឹងដែរ ទោះបីជាការពិភាក្សាក្រុមត្រូវបានបញ្ចប់ដោយការពិភាក្សាក៏ដោយក៏ត្រូវទុកសំណួរដែលមិនមានចម្លើយដើម្បីស្រាវជ្រាវបន្ថែមទៀតឬសម្រាប់ថ្នាក់បន្ទាប់។ ចំពោះអ្វីដែលជា ជំហ៊ានបន្ទាប់គឺត្រូវឱ្យសិស្សគិតពីដំណើរការងារជាក្រុមឡើងវិញ។ មូលហេតុអ្វីបានជាចាំបាច់ត្រូវធ្វើដូច្នេះ? ពីព្រោះការធ្វើដូច្នេះគឺដើម្បីជួយពួកគេនូវអ្វីដែលពួកគេបានរៀន និងរបៀបនៃដំណើរការជាក្រុម លើកក្រោយៗទៀត។

## ៤. សារៈសំខាន់នៃប្រសិទ្ធភាពការងារជាក្រុម

ចំពោះការចូលរួមសកម្មភាពជាក្រុម គឺអាចជួយសិស្សនៅក្នុងការអភិវឌ្ឍសមត្ថភាពទំនាក់ទំនង និងការសហការពេលគឺក្នុងន័យដើម្បីជួយពួកគេឱ្យទទួលបានភាពជោគជ័យទាំងក្នុងថ្នាក់និងសង្គម។ នៅទីនេះ យើងនឹងចែករំលែកពីសារៈសំខាន់នៃការធ្វើការងារជាក្រុមមួយចំនួន ព្រមទាំងបង្ហាញអ្នកពីរបៀបដែលលោកគ្រូ អ្នកគ្រូអាចបង្រៀនសិស្សរបស់អ្នកពីរបៀបនៃការធ្វើការងារជាក្រុមឱ្យមានប្រសិទ្ធភាពផងដែរ។ (សូមបញ្ជាក់ ចំពោះសារៈ

សំខាន់នៃការធ្វើការងារជាក្រុមគឺមានច្រើនទៅតាមបរិការនីមួយៗ ប៉ុន្តែយើងសូមលើកតែខ្លះៗ ពោលគឺខ្លះទៀតទុកលទ្ធភាពសម្រាប់សិស្សស្វ័យសិក្សា។) សម្រាប់សារៈសំខាន់នៃការធ្វើការងារជាក្រុមមួយចំនួនសម្រាប់ជួយអភិវឌ្ឍសិស្សឱ្យបានជោគជ័យ នឹងបង្ហាញជូនខាងក្រោមនេះ។

**៤.១. ការរៀនពីជំនាញសង្គមសំខាន់ៗ៖** ការធ្វើការងារជាក្រុមគឺជាការបង្រៀនពីជំនាញទំនាក់និងសង្គមសំខាន់ៗដូចជា ការធ្វើឱ្យមានប្រសើរឡើងនៃសមត្ថភាពស្តាប់ និងប្រសិទ្ធភាពនៃការនិយាយស្តី។ ម្យ៉ាងវិញទៀត នៅពេលដែលសិស្សធ្វើការងារជាក្រុមគឺសិស្សនឹងរៀនពីរបៀបនៃការស្តាប់អ្នកដឹកនាំក្រុមពួកគេនិងគ្រូបង្រៀនដើម្បីអនុវត្តតួនាទីរៀងៗខ្លួនក្នុងក្រុម ជាពិសេសពួកគេមានបទសោធទៅលើការរស់នៅក្នុងសង្គម។ លើសពីនេះទៀត សិស្សក៏រៀនបន្ថែមទៀតពីរបៀបនៃការស្តាប់យោបល់របស់សមាជិកម្នាក់ទៅម្នាក់ទៀតដើម្បីឱ្យដំណើរការងារសម្រេចបានប្រកបដោយប្រសិទ្ធភាពខ្ពស់។

ការងារជាក្រុមក៏នឹងបង្រៀនសិស្សឱ្យដឹងពីរបៀបនៃការផ្តល់តម្លៃ និងជឿជាក់លើសមត្ថភាពនិងយោបល់ពួកគេទៅក្នុងក្រុម។ ដូច្នេះវាគឺមានសារៈសំខាននិងប្រយោជន៍ណាស់ក្នុងការទទួលបានគំនិតមកពីមនុស្សផ្សេងៗគ្នា ពោលគឺនិយាយពីរបៀបក្នុងទាក់ទាញអ្នកស្តាប់ឱ្យចូលចិត្តស្តាប់ជាពិសេសគឺរបៀបទំនាក់ទំនងជាមួយនឹងមនុស្សជុំវិញខ្លួន។

**៤.២. ការកសាងទំនុកចិត្តលើខ្លួនឯង៖** ចំពោះការធ្វើការជាក្រុម គឺបង្រៀនសិស្សឱ្យដឹងថាយោបល់ និងគំនិតរបស់ពួកគេត្រូវបានគោរព និងផ្តល់តម្លៃ។ ជាមួយគ្នានេះដែរ សិស្សនឹងកាន់តែសប្បាយនៅពេលដែលដឹងថាយើងជួយកសាងទំនុកចិត្តពួកគេ ព្រមទាំងនាំឱ្យការជួយជំរុញសកម្មភាពការងារជាក្រុមថ្ងៃក្រោយទៀតផងដែរ។ ដូច្នេះនេះគឺនឹងក្លាយជាគន្លឹះកសាងទំនុកចិត្តដោយខ្លួនឯង ព្រោះការរួមសកម្មភាពការងារជាក្រុមជួយបង្ហាត់បង្រៀនសិស្សឱ្យមានជំនាញទំនាក់ទំនងកាន់តែប្រសើរ។ លើសពីនេះទៀត សូម្បីសមាកជិកក្រុមក៏ទទួលអារម្មណ៍កកក្តៅ ហើយក៏អាចក្លាយជាអ្នកចូលរួមយ៉ាងសកម្មនិងរៀនពីរបៀបសប្បាយចិត្តចំពោះការងារជាក្រុម។

**៤.៣. កាត់បន្ថែមភាពអត្មានិយម៖** ចំពោះសារៈប្រយោជន៍នៃការធ្វើការងារជាក្រុមមួយទៀតគឺជាសក្តានុភាពរបស់វាក្នុងការកាត់បន្ថែមភាពអត្មានិយមចំពោះការសិក្សាទៅលើសិស្សដទៃទៀត។ នៅពេលដែលសិស្សដឹងថានាងឬគាត់ទទួលបានការគោរពនិងឱ្យតម្លៃពីសំណាក់សិស្សផ្សេងទៀត នាងឬគាត់នឹងមានភាពក្លាហានប្រឈមជាមួយនឹងការប្រមាថនិងមាក់ ងាយផងដែរ។ ម្យ៉ាងទៀត បើសិននាងឬគាត់ក្លាយជាផ្នែកមួយនៃក្រុមដែល ត្រូវបានយកចិត្តទុកដាក់ពីសំណាក់សមាជិកក្រុម ពោលគឺជាកត្តាមួយដ៏សំខាន់ក្នុងការជួយប្រព័ន្ធគាំទ្រដ៏ រឹងមាំថែមទៀត។

ជាចុងក្រោយ សមាជិកក្រុមនឹងមានទំនោរគំនិតជាមួយគ្នា ព្រមទាំងអាចសហការគ្នា យ៉ាងមានប្រសិទ្ធភាព។ បន្ថែមលើសពីនេះទៀត ទំនុកចិត្តលើខ្លួនឯងពីសកម្មភាពជាក្រុមអាចផ្តល់អំណាចដល់សិស្សឱ្យក្រោកឈរឡើងសម្រាប់ជនរងគ្រោះផ្សេងទៀតនៃការសម្លុត ដែលប្រហែលជាមិនមាន ប្រព័ន្ធគាំទ្រស្រដៀងគ្នា។

**៤.៤. ជួយសិស្សឱ្យជោគជ័យនៅថ្ងៃអនាគត៖** សារៈសំខាន់ និងសារប្រយោជន៍នៃការធ្វើការងារជាក្រុមស្ទើរតែអាចបកប្រែទៅជាភាពជោគជ័យនៅក្នុងសង្គមក៏ថាបាន។ ជាហេតុផលមួយដ៏សមរម្យ យើងសង្កេតឃើញថាមានផ្លូវអាជីពតិចតួចណាស់ដែលសម្រេចភាគជោគជ័យដោយខ្លួនឯងបាននោះ។ ម្យ៉ាងទៀត ប្រសិនបើជាយើងនិយាយពីបុគ្គលិកក្រុមហ៊ុនមួយ ពោលគឺការងារដំណើរទៅបានអាស្រ័យលើមនុស្សក្នុងក្រុមហ៊ុនសហការគ្នាទៅវិញទៅមកដើម្បីបំពេញភារកិច្ច។ ដូច្នេះ ការណែនាំសិស្សពីរបៀបធ្វើការងារជាក្រុម គឺជាការផ្តល់ឱកាសឱ្យពួកគេកាន់តែមានសមត្ថភាពនិងភាពរីករាយនៅពេលដែលបំពេញការងារជាក្រុមទៀតផង។ សរុបមក ចំពោះការពេញចិត្តគឺត្រូវបានឆ្លុះបញ្ចាំងតាមរយៈកិច្ចការពួកគេ ពោលគឺការទទួលលើកភារកិច្ចរបស់ខ្លួនដើម្បីនាំទៅរកក្រុមមួយដ៏ជោគជ័យបានក៏ដូចជាភាពជោគជ័យសម្រាប់ខ្លួនឯងដែរ។

UNESCO

United Nations
Educational, Scientific and
Cultural Organization

국제연합
교육과학문화기구

APCEIU

Asia-Pacific Centre of
Education for International Understanding
under the auspices of UNESCO

유네스코 아시아태평양 국제이해교육원